ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

# របាយការណ៍វិភាគស្ថានភាពស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា

## សម្រាប់ការរៀបចំផែនការសកម្មភាពជាតិស្តីពីរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា

ខែ តុលា ឆ្នាំ ២០២៥

UN WOMEN

# មាតិកា


**បុព្វកថា** ៥

**អក្សរកាត់ និងពាក្យបំព្រួញ** ៦

**សន្ទានុក្រម** ១១

**សេចក្តីសង្ខេប** ១៤

**ទិដ្ឋភាពទូទៅ** ២៧

គោលបំណងនៃរបាយការណ៍ ២៧

រចនាសម្ព័ន្ធនៃរបាយការណ៍ ២៨

**ផ្នែកទី ១ ៖ សេចក្តីផ្តើម និងសាវតារ** ២៩

**១. សេចក្តីផ្តើម** ៣០

១.១. សាវតារ ៣០

១.១.១ ក្របខណ្ឌអន្តរជាតិ ៣០

១.១.២ ក្របខណ្ឌអាស៊ាន និងប្រទេសកម្ពុជា ៣២

១.២. វិធីសាស្ត្រ ៣៥

**ផ្នែកទី ២ ៖ស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា** ៣៦

**២. ទិដ្ឋភាពទូទៅនៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ASEAN RPA-WPS)** ៣៧

**៣. បញ្ហាស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា** ៣៩

៣.១. ស្ត្រី និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងជម្លោះ និងវិបត្តិមនុស្សធម៌ ៣៩

៣.១.១ បរិបទនៃស្ត្រី និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងស្ថានភាពជម្លោះ ៣៩

៣.១.២ ស្ត្រីក្នុងស្ថានភាពក្រោយជម្លោះ និងការកសាងសន្តិភាពនៅកម្ពុជា ៤០

៣.១.៣ គោលនយោបាយ ផែនការ និងយន្តការជាតិ ៤២

៣.២. ស្ត្រី និងការជួញដូរ និងបទល្មើសឆ្លងដែន ៤៤

៣.២.១ បរិបទនៃស្ត្រី និងការជួញដូរ និងបទល្មើសឆ្លងដែន ៤៤

៣.២.២ គោលនយោបាយ ផែនការ និងយន្តការជាតិ ៤៦

៣.៣. ស្ត្រី សន្តិភាព និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត ៤៧

៣.៣.១ បរិបទនៃយេនឌ័រ សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងពិភពឌីជីថល ៤៧

៣.៣.២ គោលនយោបាយ ផែនការ និងយន្តការជាតិ ៥០

៣.៤. ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី ៥១
៣.៤.១ បរិបទនៃការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី ៥១
៣.៤.២ គោលនយោបាយ ផែនការ និងយន្តការថ្នាក់ជាតិ ៥៣
៣.៥. ស្ត្រីក្នុងវិស័យសន្តិសុខ ការទូតអន្តរជាតិ និងកងកម្លាំងរក្សាសន្តិភាព ៥៤
៣.៥.១ ស្ត្រីក្នុងវិស័យអនុវត្តន៍ច្បាប់នៅកម្ពុជា ៥៤
៣.៥.២ បរិបទរបស់ស្ត្រីក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការកសាងសន្តិភាព ៥៥
៣.៥.៣ គោលនយោបាយ ផែនការ និងយន្តការជាតិ ៥៨
៣.៦. ស្ត្រី និងអាកាសធាតុ សន្តិភាព និងសន្តិសុខ ៥៩
៣.៦.១ ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ ៥៩
៣.៦.២ គោលនយោបាយ ផែនការ និងយន្តការជាតិ ៦១
៣.៧. របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងលទ្ធភាពទទួលបានសន្តិសុខសេដ្ឋកិច្ច ឱកាសរបរចិញ្ចឹមជីវិត ធនធានធម្មជាតិ និងសន្តិសុខមនុស្ស ៦៣
៣.៧.១ បញ្ហាសន្តិសុខសំខាន់ៗពាក់ព័ន្ធនឹងការចូលរួមផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ៦៣
៣.៧.២ ដីធ្លី ធនធានធម្មជាតិ និងរបរចិញ្ចឹមជីវិត ៦៤
៣.៧.៣ គោលនយោបាយ ផែនការ និងយន្តការជាតិ ៦៦
៣.៨. ស្ត្រី និងសិទ្ធិពលសង្គម ៦៨
៣.៨.១ ស្ត្រី និងបរិបទសង្គម-វប្បធម៌ ៦៨
**៤. ការវិភាគការគូសផែនទីអ្នកពាក់ព័ន្ធ** ៧១
៤.១. ក្រសួង/ស្ថាប័ន និងយន្តការរដ្ឋាភិបាល ៧១
៤.២. សង្គមស៊ីវិល ៧៥
៤.៣. ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ៧៨

---

**ផ្នែកទី ៣ ៖ កាលានុវត្តភាព បញ្ហាប្រឈម និងមេរៀនដែលទទួលបាន** ៨០
**៥. ឧត្តមានុវត្តន៍ កាលានុវត្តភាព និងបញ្ហាប្រឈម** ៨១
៥.១. កាលានុវត្តភាព ៨១
៥.២. បញ្ហាប្រឈម ៨៣
**៦. មេរៀនដែលបានទទួលពីបទពិសោធន៍របស់ប្រទេសផ្សេងទៀតលើផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS)** ៨៥
៦.១. បទពិសោធន៍សកលនៃការរៀបចំ និងការអនុវត្តផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS) ៨៥
៦.២. គំរូផែនការសកម្មភាពជាតិ ៦៩

**ផ្នែកទី ៤៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ៩២

**៧. ឧត្តមានុវត្តន៍ ភាពលានុវត្តភាព និងបញ្ហាប្រឈម** ៩៣

**៨. អនុសាសន៍ឆ្ពោះទៅរកការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា** ៩៧

៨.១. អាទិភាពសំខាន់ៗនៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ សម្រាប់ការពិចារណាដែលស្របតាមផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ៩៧

៨.១.១ សសរស្តម្ភនៃការការពារ ៩៨

៨.១.២ សសរស្តម្ភនៃការចូលរួម ៩៩

៨.១.៣ សសរស្តម្ភនៃការទប់ស្កាត់ ១០០

៨.១.៤ សសរស្តម្ភនៃការសង្គ្រោះ និងស្តារឡើងវិញ ១០២

៨.២. យន្តការសម្របសម្រួលដែលអាចមាន ១០៣

៨.៣. ជំហានបន្ទាប់ដែលបានលើកឡើងពីការសិក្សានេះ ១០៤

**៩. ឧបសម្ព័ន្ធ** ១០៥

៩.១. តារាងសង្ខេបបញ្ហាស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គោលនយោបាយ វិធានការ និងគម្លាត ១០៥

៩.២. បញ្ជីឯកសារដែលបានពិនិត្យ ១១២

៩.៣. បញ្ជីអ្នកពាក់ព័ន្ធដែលបានពិគ្រោះយោបល់ ១១៧

៩.៤. សេចក្តីសង្ខេបនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ស្តីពី ស្ត្រីសន្តិភាព និងសន្តិសុខ អនុសាសន៍ទូទៅលេខ ៣០ និង ៣៧ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងផែនការសកម្មភាពទីក្រុងប៉េកាំង ១២១

៩.៥. សេចក្តីសង្ខេបនៃតារាងម៉ាទ្រិកផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ១២៣

# បុព្វកថា

កម្ពុជាជឿថា សន្តិភាព និងវិបុលភាពយូរអង្វែងអាចសម្រេចបានពេញលេញ លុះត្រាតែមានការចូលរួមពីពលរដ្ឋទាំងអស់នៅក្នុងសង្គម។ របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS) លើកឡើងពីវិសមភាពយេនឌ័រក្នុងសន្តិភាព និងសន្តិសុខ និងផ្តល់ឱកាស ដើម្បីជំរុញការរួមចំណែករបស់ស្ត្រី បង្កើនការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅថ្នាក់ជាតិថ្នាក់តំបន់ និងថ្នាក់សកល ព្រមទាំងពង្រឹងតួនាទីរបស់ស្ត្រីក្នុងសសរស្តម្ភទាំងបួននៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គឺការទប់ស្កាត់ការចូលរួម ការការពារ និងការសង្គ្រោះ និងស្តារឡើងវិញ។

កម្ពុជាគឺជាប្រទេសសមាជិកឈានមុខគេមួយនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលហៅកាត់ថា "អាស៊ាន" ដែលបានជំរុញការរៀបចំ និងការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន។ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ASEAN RPA-WPS) ដែលត្រូវបានអនុម័តនៅឆ្នាំ ២០២២ និងកញ្ចប់ឧបករណ៍ស្តីពីការធ្វើមូលដ្ឋានីយកម្ម និងគោលការណ៍ណែនាំសម្រាប់ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលបានដាក់ចេញនៅឆ្នាំ២០២៣ តំណាងឱ្យសមិទ្ធផលសំខាន់ៗរបស់អាស៊ាន ជាពិសេសគណៈកម្មាធិការអាស៊ានស្តីពីស្ត្រី (ACW) ក្នុងការជំរុញរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

កម្ពុជាប្តេជ្ញាជំរុញរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នៅថ្នាក់សកល ថ្នាក់តំបន់ និងថ្នាក់ជាតិ។ ផ្អែកតាមផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងកញ្ចប់ឧបករណ៍ស្តីពីការធ្វើមូលដ្ឋានីយកម្មផែនការសកម្មភាពនេះ ការវិភាគស្ថានភាពយ៉ាងគ្រប់ជ្រុងជ្រោយលើបញ្ហាពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខក្នុងបរិបទកម្ពុជាត្រូវបានធ្វើឡើងចាប់ពីខែសីហា ដល់ខែធ្នូ ឆ្នាំ២០២៤។ ដំណើរការនេះគឺជាជំហានដ៏សំខាន់មួយ ដើម្បីផ្តល់មូលដ្ឋានព័ត៌មានសម្រាប់ការរៀបចំផែនការសកម្មភាពជាតិដំបូងបង្អស់របស់កម្ពុជាស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS)។ សម្រាប់ទិសដៅអនាគត ជំហានបន្ទាប់រួមមានការពិនិត្យ និងការកំណត់អាទិភាពបន្ថែមទៀតលើបញ្ហា WPS សំខាន់ៗសម្រាប់កម្ពុជាក្នុងការបង្កើតយន្តការសម្របសម្រួលបែបពហុភាគី ដោយមានជំនាញបច្ចេកទេស ក៏ដូចជាការគាំទ្រ និងការដឹកនាំនយោបាយនៅកម្រិតខ្ពស់ ការធានាថាសកម្មភាពដែលបានស្នើឡើងបន្សីគ្នា និងលើកឡើងពីគម្លាតក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិដែលមានស្រាប់ និងពង្រឹងកិច្ចសហការជាមួយស្ថាប័នរាជរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ជាច្រើន ដើម្បីជំរុញរបៀបវារៈ WPS បន្ថែមទៀត។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមថ្លែងអរគុណចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រីដែលបានរួមចំណែក និងគាំទ្រដល់ការរៀបចំការវិភាគស្ថានភាពស្តីពីបញ្ហា WPS នៅកម្ពុជានេះ។ ដំណើរការនេះមានកិច្ចប្រជុំ សិក្ខាសាលា បទសម្ភាសន៍ និងវគ្គបណ្តុះបណ្តាលជាមួយក្រសួង-ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ មន្ត្រីស្ថានទូត ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការសង្គមស៊ីវិល រួមទាំងអង្គការស្ត្រី និងបណ្តាញយុវជន ព្រមទាំងស្ត្រី និងយុវជនដែលរស់នៅជនបទក្នុងខេត្តចំនួន ៣ រួមទាំងសហគមន៍ជនជាតិភាគតិចផងដែរ។ ការចូលរួមរបស់ពួកគេគឺមានសារៈសំខាន់ណាស់ និងមានតម្លៃបំផុត។

ខណៈដែលយើងកំពុងបន្តទៅដំណាក់កាលបន្ទាប់នៃការរៀបចំ និងអនុវត្តផែនការសកម្មភាពជាតិដំបូងបង្អស់របស់កម្ពុជាស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS) យើងរំពឹងថានឹងបន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ក៏ដូចជាបន្តការគាំទ្រ ការចូលរួម និងការដឹកនាំពីអ្នកទាំងអស់គ្នាក្នុងការជំរុញរបៀបវារៈ WPS នៅកម្ពុជាក្នុងពេលបច្ចុប្បន្ន និងក្នុងរយៈពេលប៉ុន្មានឆ្នាំទៅមុខទៀត។

លោកជំទាវ គង់ សូរីតា



រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី

# អក្សរកាត់ និងពាក្យពេញ

| | | |
|---|---|---|
| AAC | Action Aid Cambodia | អង្គការអាក់សិនអេតកម្ពុជា |
| ACWC | ASEAN Commission on the Promotion and Protection of the Rights of Women and Children | គណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិស្ត្រី និងកុមារ |
| ADD | Action on Disability and Development | អង្គការសកម្មភាពលើពិការភាព និងអភិវឌ្ឍន៍ |
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) |
| ASEAN RPA-WPS | Regional Plan of Action on Women, Peace and Security | ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ASEAN RPA-WPS) |
| BPfA | Beijing Platform for Action | ផែនការសកម្មភាពទីក្រុងប៉េកាំង |
| CEDAW | Convention on the Elimination of All forms of Discrimination against Women | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| CERD | Convention on the Elimination of Racial Discrimination | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ |
| CDPO | Cambodia Disabled People's Organisation | អង្គការជនពិការកម្ពុជា |
| CDRI | Cambodia Development Resource Institute | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CHRC | Cambodia Human Rights Committee | គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា |
| CIPA | Cambodian indigenous People's Association | សមាគមជនជាតិដើមភាគតិចកម្ពុជា |
| CMAA | Cambodian Mine Action and Victim Assistance Authority | អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន |
| CMAC | Cambodian Mine Action Centre | មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា |
| CNCW | Cambodian National Committee for Women | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| COMMIT | Coordinated Mekong Ministerial Inititative against Trafficking | គំនិតផ្តួចផ្តើមសម្របសម្រួលថ្នាក់រដ្ឋមន្ត្រីប្រឆាំងអំពើជួញដូរមនុស្សក្នុងតំបន់ទន្លេមេគង្គ |

| | | |
|---|---|---|
| CPCS | Centre for Peace and Conflict Studies | មជ្ឈមណ្ឌលសិក្សាបណ្តុះបណ្តាលកសាងសន្តិភាព និងដោះស្រាយទំនាស់ |
| CSDG | Cambodian Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា |
| CSHL /RULE | Centre for Studies on Humanitarian Law, Royal University of Law and Economics | មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវនីតិមនុស្សធម៌ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| CSO | Civil Society Organisation | អង្គការសង្គមស៊ីវិល |
| DRR | Disaster Risk Reduction | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| DV Law | Law on the Prevention of Domestic Violence and Protection of Victims | ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ |
| ECCC | Extraordinary Chambers in the Court of Cambodia | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) |
| GADC | Gender and Development Cambodia | អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា |
| GBV | Gender-Based Violence | អំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| GBViE | Gender-Based Violence in Emergencies | អំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រោះអាសន្ន |
| GEDI | Gender Equality and Disability Inclusion | សមភាពយេនឌ័រ និងបរិយាបន្នពិការភាព |
| GMAG | Gender Mainstreaming Action Group | ក្រុមសកម្មភាពបញ្ជ្រាបយេនឌ័រ |
| GMAP | Gender Mainstreaming Action Plan | ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ |
| ICT | Information, Communication and Technology | ព័ត៌មាន ទំនាក់ទំនង និងបច្ចេកវិទ្យា |
| LGBTIQ+ | Lesbian Gay Bi-sexual Transgender Intersex Questioning | ស្ត្រីស្រឡាញ់ភេទដូចគ្នា បុរសស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរភេទ អន្តរភេទ និងអ្នកមានចម្ងល់អំពីអត្តសញ្ញាណយេនឌ័រ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

| | | |
|---|---|---|
| MISP | Minimum Initial Service Package | កញ្ចប់សេវាបឋមអប្បបរមា |
| MLMUPC | Ministry of Land Management, Urban Planning and Construction | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MoND | Ministry of National Defence | ក្រសួងការពារជាតិ |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MoFAIC | Ministry of Foreign Affairs and International Cooperation | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| MoI | Ministry of Interior | ក្រសួងមហាផ្ទៃ |
| MoINF | Ministry of Information | ក្រសួងព័ត៌មាន |
| MoJ | Ministry of Justice | ក្រសួងយុត្តិធម៌ |
| MoLVT | Ministry of Labour and Vocational Training | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoPTC | Ministry of Post and Telecommunications | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| MoSVY | Ministry of Social Affairs, Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoWA | Ministry of Women's Affairs | ក្រសួងកិច្ចការនារី |
| NAADR | National Authority for Alternative Dispute Resolution | អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក) |
| NAP | National Action Plan | ផែនការសកម្មភាពជាតិ |
| NAP DRR | National Action Plan – Disaster Risk Reduction | ផែនការសកម្មភាពជាតិ - ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| NAPVAW | National Action Plan for the Prevention of Violence Against Women | ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី |
| NAP WPS | National Action Plan on Women, Peace and Security | ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ |

| | | |
|---|---|---|
| NCCT | National Committee for Counter Trafficking | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| NCDD | National Committee for Subnational Democratic Development | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NCDM | National Committee for Disaster Management | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NCSD | National Council for Sustainable Development | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| NGO | Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NPMEC | National Centre for Peacekeeping forces, Mine and ERW Clearance | មជ្ឈមណ្ឌលជាតិ គ្រប់គ្រងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| NSP-CTIP | National Strategic Plan for Counter Trafficking in Persons | ផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស |
| PKO | Peace Keeping Operations | ប្រតិបត្តិការរក្សាសន្តិភាព |
| RCAF | Royal Cambodian Armed Forces | កងយោធពលខេមរភូមិន្ទ |
| ROAP | Regional Office of Asia and the Pacific (UN Women) | ការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក (UN Women) |
| RWI | Raoul Wallenberg Institute | វិទ្យាស្ថាន Raoul Wallenberg |
| SDG | Sustainable Development Goal | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SEA | Sexual Exploitation and Abuse | ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ |
| SGBV | Sexual and Gender-Based Violence | អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ |
| TAF | The Asia Foundation | មូលនិធិអាស៊ី |
| TIC | Transparency International | អង្គការតម្លាភាពអន្តរជាតិ |
| TPO | Transcultural Psychosocial Organization Cambodia | អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា |
| TWGG-GBV | Technical Working Group on Gender-Sub-working Group on GBV | ក្រុមការងារបច្ចេកទេសស្តីពីយេនឌ័រ-អនុក្រុមការងារស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ |

| | | |
|---|---|---|
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNFPA | United Nations Population Fund | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន |
| UNODC | United Nations Office on Drugs and Crime | ការិយាល័យអង្គការសហប្រជាជាតិ ទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម |
| UNOHCHR | United Nations Office of the High Commissioner for Human Rights | ឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស |
| UNRCO | United Nations Resident Coordinators Office | ការិយាល័យអ្នកសម្របសម្រួល អង្គការសហប្រជាជាតិ |
| UNSCR | United Nations Security Council Resolution | សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ |
| UN Women | United Nations Entity for Gender Equality and the Empowerment of Women | អង្គភាពអង្គការសហប្រជាជាតិសម្រាប់ សមភាពយេនឌ័រ និងការផ្ដល់សិទ្ធិអំណាច ដល់ស្ត្រី |
| USAID | United States Agency for International Development | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍ អន្តរជាតិ |
| VAWG | Violence Against Women and Girls | អំពើហិង្សាលើស្ត្រី និងក្មេងស្រី |
| VCSP | Village Commune Safety Policy | គោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព |
| WCCC | Women and Children's Consultative Committee | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| WPS | Women, Peace and Security | ស្ត្រី សន្តិភាព និងសន្តិសុខ |

# សទ្ទានុក្រម

**សេដ្ឋកិច្ចពណ៌ខៀវ (blue economy)**

សំដៅលើការប្រើប្រាស់ធនធានសមុទ្រប្រកបដោយចីរភាពសម្រាប់កំណើនសេដ្ឋកិច្ច ជីវភាពរស់នៅប្រសើរឡើង និងការបង្កើតការងារ ហើយក្នុងពេលជាមួយគ្នានោះ រក្សាសុខុមាលភាពប្រព័ន្ធអេកូឡូស៊ីសមុទ្រ[1]។

**សេដ្ឋកិច្ចដែលគិតគូរពីសុខុមាលភាព**

សំដៅលើទាំងការងារថៃទាំមានប្រាក់ឈ្នួល និងការងារថៃទាំគ្មានប្រាក់ឈ្នួល ដែលធ្វើឡើងដោយមនុស្ស សម្រាប់ជាផ្នែកមួយនៃការរស់រាន និងសុខុមាលភាពរបស់មនុស្ស និងការធានាឱ្យមានកម្លាំងពលកម្មគ្រប់គ្រាន់[2]។

**ជនជាតិចាម ឬខ្មែរមូស្លីម ឬខ្មែរអ៊ីស្លាម**

ជាពាក្យដែលគេប្រើសម្រាប់អ្នក ដែលប្រតិបត្តិសាសនាអ៊ីស្លាមក្នុងប្រទេសកម្ពុជា។ ខ្មែរមូស្លីមត្រូវបានគេទទួលស្គាល់ជាទូទៅថា មានអនុក្រុមសំខាន់ៗ ៣ គឺចាមបានី (ជនជាតិចាមពីមុន) ចាម-ចាម(ចាមអរតូដុក) និងចាម-ជ្វា។[3]

**បទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត**

រួមបញ្ចូលបទល្មើសផ្សេងៗជាច្រើន និងចែកចេញជាពីរប្រភេទធំៗ គឺបទល្មើសដែលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងបទល្មើសដែលពឹងផ្អែកលើប្រព័ន្ធអ៊ីនធឺណិត។ បទល្មើសដែលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត រួមមានការធ្វើសកម្មភាពរបស់ឧក្រិដ្ឋជនតាមអនឡាញ ដូចជាការជួញដូរមនុស្ស ការបោកបញ្ឆោត និងការញុះញង់ឱ្យបង្កអំពើហិង្សា និងការស្អប់ខ្ពើម។ បទល្មើសដែលពឹងផ្អែកលើប្រព័ន្ធអ៊ីនធឺណិត គឺជាបទល្មើសដែលប្រព្រឹត្តឡើងតាមរយៈការប្រើប្រាស់ឧបករណ៍ព័ត៌មាន ទំនាក់ទំនង និងបច្ចេកវិទ្យា (ICT) និងរួមមានការបញ្ឆោតលួចព័ត៌មាន ការលួចព័ត៌មានអត្តសញ្ញាណ និងការបន្សាយមេរោគប្រភេទ malware និង ransomware។ ជនបង្កបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត មានចាប់ពីឧក្រិដ្ឋកម្មម្នាក់ៗ រហូតដល់បណ្ដាញឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង ដែលសុទ្ធតែកេងប្រវ័ញ្ចលើអនាមិកភាព និងការចូលប្រើប្រាស់ប្រព័ន្ធឌីជីថល[4]។

**សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត**

សំដៅលើយុទ្ធសាស្ត្រ គោលនយោបាយ នីតិវិធី ការអនុវត្ត និងវិធានការដែលត្រូវបានរៀបចំឡើងដើម្បីកំណត់រកការគំរាមកំហែង និងភាពងាយរងគ្រោះ ទប់ស្កាត់ការគំរាមកំហែងពីការកេងប្រវ័ញ្ចលើភាពងាយរងគ្រោះ សម្រាលគ្រោះថ្នាក់ដែលបង្កឡើងដោយការគំរាមកំហែងសំខាន់ៗ និងការពារសុវត្ថិភាពមនុស្ស ទ្រព្យសម្បត្តិ និងព័ត៌មាន[5]។

**សិទ្ធិឌីជីថល**

គឺជាសិទ្ធិមនុស្សក្នុងយុគសម័យអ៊ីនធឺណិត។ ដោយទាក់ទងយ៉ាងជិតស្និទ្ធនឹងសេរីភាពបញ្ចេញមតិ និងឯកជនភាព សិទ្ធិទាំងនេះរួមបញ្ចូលសិទ្ធិចូលមើល ប្រើប្រាស់ បង្កើត និងផ្សព្វផ្សាយប្រព័ន្ធឌីជីថល និងប្រើប្រាស់កុំព្យូទ័រ ឧបករណ៍អេឡិចត្រូនិក និងបណ្ដាញទំនាក់ទំនង។[6]

**ការផ្សព្វផ្សាយព័ត៌មានឯកជនក្នុងចេតនាមិនល្អ (doxing)**

ជាទម្រង់មួយនៃការគំរាមកំហែងតាមអ៊ិនធឺណិតដែលប្រើព័ត៌មាន សេចក្ដីថ្លែង ឬកំណត់ត្រារសើប ឬសម្ងាត់ ដើម្បីបៀតបៀន លាតត្រដាង បង្កគ្រោះថ្នាក់ហិរញ្ញវត្ថុ ឬបង្កការកេងប្រវ័ញ្ចផ្សេងៗទៀតលើបុគ្គលដែលជាគោលដៅ[7]។

---

[1] https://www.un.org/regularprocess/sites/www.un.org.regularprocess/files/rok_part_2.pdf
[2] https://www.unescap.org/sites/default/d8files/knowledge-products/SDD-How-Invest-Care-Economy-Primer.pdf
[3] *Voice and Visibility: A participatory exploration of Minority Women human rights in Cambodia*, Women Peace Makers, January 2024
[4] https://www.un.org/en/peace-and-security/basic-facts-about-global-cybercrime-treaty#:~:text=What%20is%20cybersecurity?,privacy%2C%20trust%2C%20and%20security.
[5] Ibid
[6] https://www.weforum.org/stories/2015/11/what-are-your-digital-rights-explainer
[7] https://www.fortinet.com/resources/cyberglossary/doxing

**សេវាសំខាន់ៗ**

សំដៅលើកញ្ចប់សេវាស្នូលដែលផ្តល់ដោយវិស័យថែទាំសុខភាព សេវាសង្គម វិស័យយុត្តិធម៌ និងនគរបាល។ យ៉ាងហោចណាស់ សេវាទាំងនេះត្រូវធានាសិទ្ធិ សុវត្ថិភាព និងសុខុមាលភាពរបស់ស្ត្រី និងក្មេងស្រីគ្រប់រូបដែលប្រឈមនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ[8]។

**អំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV)**

សំដៅលើសកម្មភាពចេតនា ឬការខកខានមិនបានធ្វើសកម្មភាព ទោះជាការគំរាមកំហែង ឬជាក់ស្តែងក៏ដោយ ប្រឆាំងនឹងបុគ្គល ឬក្រុមណាមួយដោយផ្អែកលើយេនឌ័រ ដែលបណ្តាលឱ្យមាន ការឈឺចាប់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត។ អំពើហិង្សាទាក់ទងនឹងយេនឌ័ររួមបញ្ចូលទាំងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក៏ដូចជាបុរស និងក្មេងប្រុស អ្នកស្រលាញ់ភេទដូចគ្នា (LGBTIQ+) និងអ្នកដទៃទៀតដែលមិនអនុលោមតាមបទដ្ឋានយេនឌ័រ ទូទៅ[9]។

**សន្តិសុខមនុស្ស**

ដូចការកត់សម្គាល់ក្នុងសេចក្តីសម្រេចលេខ ៦៦/៩២០ របស់មហាសន្និបាត អ.ស.ប គឺជាវិធីសាស្ត្រមួយ ដើម្បីជួយដល់រដ្ឋសមាជិកក្នុងការកំណត់រក និងដោះស្រាយបញ្ហាប្រឈមទូទៅ និងឆ្លងវិស័យ សម្រាប់ការរស់រាន របរចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពលរដ្ឋនៃរដ្ឋសមាជិកទាំងនោះ។ សេចក្តីសម្រេចនេះ អំពាវនាវឱ្យប្រើប្រាស់ "វិធីសាស្ត្រដែលផ្តោតការយកចិត្តទុកដាក់លើមនុស្ស គ្រប់ជ្រុងជ្រោយ ផ្អែកតាមបរិបទ និងផ្តោតលើការទប់ស្កាត់ ដែលពង្រឹងការការពារ និងការបង្កើនភាពអង់អាចដល់មនុស្សគ្រប់រូប"[10]។

**បរិយាបន្ន**

សង្កត់ធ្ងន់លើសារៈសំខាន់នៃការធានាភាពជាតំណាងរបស់ស្ត្រីគ្រប់រូប។

**សន្តិភាព**

មិនមែនត្រឹមតែជាការគ្មានជម្លោះហិង្សា (សន្តិភាពអវិជ្ជមាន) ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការមានយុត្តិធម៌ សមធម៌ និងការគោរពសិទ្ធិមនុស្ស និងភពផែនដី (សន្តិភាពវិជ្ជមាន) ផងដែរ[11]។

**សន្តិសុខ**

ក្នុងបរិបទនៃស្ត្រី សន្តិភាព និងសន្តិសុខ រួមបញ្ចូលការការពារសិទ្ធិ និងការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រី នៅក្នុងគ្រប់ផ្នែកទាំងអស់នៃសន្តិភាព និងសន្តិសុខ ចាប់ពីការទប់ស្កាត់ជម្លោះ រហូតដល់ការកសាងឡើងវិញក្រោយជម្លោះ។ សន្តិសុខសំដៅលើស្ថានភាពនៃការរួចផុតពីគ្រោះថ្នាក់ ឬការគំរាមកំហែង រួមទាំងការគំរាមកំហែងដល់សន្តិសុខមនុស្ស ដូចជា ការកើនឡើងនៃភាពជ្រុលនិយម និងអំពើហិង្សាជ្រុលហួសហេតុ ការជួញដូរមនុស្ស វិបត្តិអាកាសធាតុ វិបត្តិសុខភាពសកល និងវិបត្តសកលលោកធំៗផ្សេងទៀត[12]។

**ការបៀតបៀនផ្លូវភេទ**

រួមបញ្ចូលឥរិយាបថផ្លូវភេទដែលមិនត្រូវបានស្វាគមន៍ ដូចជា ការប៉ះពាល់រាងកាយ និងការរំលោភបំពាន ការលើកឡើងដែលមានលក្ខណៈផ្លូវភេទ ការបង្ហាញរូបភាពអាសអាភាស និងការទាមទារផ្លូវភេទ ទោះជាតាមរយៈពាក្យសម្តី ឬសកម្មភាពក៏ដោយ។ ការប្រព្រឹត្តបែបនេះអាចជាការបន្ទាបបន្ថោក និងអាចបង្កបញ្ហាសុខភាព និងសុវត្ថិភាព។ វាជាការរើសអើងនៅពេលដែលស្ត្រីមានមូលដ្ឋានសមហេតុផលដើម្បីជឿថា ការជំទាស់របស់នាង នឹងធ្វើឱ្យនាងខាតប្រយោជន៍ទាក់ទងនឹងការងាររបស់នាង រួមទាំងការជ្រើសរើសឱ្យចូលធ្វើការ ឬការដំឡើងឋានៈ ឬនៅពេលដែលវាបង្កើតឱ្យមានបរិយាកាសការងារប្រកបដោយអរិភាព"[13]។

[8] *Essential Services Packages for Women and Girls Subject to Violence, Core Elements and Quality Guidelines, Module 5, Chapter 1, pg. 7.*
[9] *ILO C190*, https://gbv.itcilo.org/index.php/information_sheet/show/id/1.html
[10] https://www.un.org/humansecurity/what-is-human-security/
[11] https://news.un.org/en/story/2014/09/476992; https://www.visionofhumanity.org/defining-the-concept-of-peace/
[12] https://www.unwomen.org/en/what-we-do/peace-and-security
[13] អនុសាសន៍ទូទៅលេខ ១៩ នៃអនុសញ្ញា CEDAW, អំពើហិង្សាលើស្ត្រី, កថាខណ្ឌ ១៨, វគ្គទី ១១ ឆ្នាំ ១៩៩២។

**អំពើហិង្សាផ្លូវភេទ**

សំដៅលើសកម្មភាពផ្លូវភេទណាមួយ ការប៉ុនប៉ងទទួលបានសកម្មភាពផ្លូវភេទ ឬសកម្មភាពផ្សេងទៀតរបស់បុគ្គលណាម្នាក់ប្រឆាំងនឹងផ្លូវភេទរបស់បុគ្គលណាម្នាក់ផ្សេងទៀត តាមរយៈការបង្ខិតបង្ខំ ដោយមិនគិតពីទំនាក់ទំនងរបស់ជនបង្កជាមួយជនរងគ្រោះ ឬមជ្ឈដ្ឋាន[14]។

**យុត្តិធម៌អន្តរកាល**

រួមបញ្ចូល "ដំណើរការ និងយន្តការទាំងអស់ដែលទាក់ទងនឹងការប៉ុនប៉ងរបស់សង្គមមួយក្នុងការដោះស្រាយកេរ្តិ៍ដំណែលនៃការបំពារបំពាន និងការរំលោភបំពានទ្រង់ទ្រាយធំពីអតីតកាល ដើម្បីធានាគណនេយ្យភាព ផ្តល់យុត្តិធម៌ និងសម្រេចបានការផ្សះផ្សា"[15]។

**ការចំអក ឬឌឺដង (trolling)**

ក្នុងបរិបទនៃបណ្តាញសង្គម សំដៅលើសកម្មភាពនៃការបង្ហោះ ឬការបញ្ចេញមតិតាមអ៊ិនធឺណិតដោយចេតនា ដើម្បីធ្វើឱ្យអ្នកដទៃអន់ចិត្ត ឬបង្ករឿងជាមួយអ្នកដទៃ[16]។

**អំពើហិង្សាលើស្ត្រី**

សំដៅលើ "ការប្រព្រឹត្តអំពើហិង្សាផ្អែកលើយេនឌ័រដែលបង្ក ឬនឹងបង្កជាគ្រោះថ្នាក់ ឬការឈឺចាប់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត និងផ្លូវអារម្មណ៍លើស្ត្រី ដូចជា ការគំរាមកំហែងប្រព្រឹត្ត ការបង្ខិតបង្ខំ ឬការដកហូតសេរីភាពតាមទំនើងចិត្ត មិនថាកើតមានក្នុងជីវិតសាធារណៈ ឬជីវិតឯកជនឡើយ"[17]។

**ស្ត្រី និងក្មេងស្រីគ្រប់លក្ខណៈចម្រុះ (Women in all their diversity)**

ជាពាក្យដែលអង្គការ UN Women ប្រើប្រាស់ ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តចំពោះការទទួលស្គាល់ និងការលើកឡើងពីបទពិសោធន៍ និងតម្រូវការផ្សេងៗរបស់មនុស្សគ្រប់រូបដែលត្រូវបានកំណត់អត្តសញ្ញាណជាស្ត្រី និងក្មេងស្រី រួមទាំងអ្នកដែលមានភាពងាយរងគ្រោះប្រទាក់ក្រឡាគ្នា ដូចជា ពិការភាព ពូជសាសន៍ ជាតិពន្ធុ អាយុ និន្នាការផ្លូវភេទ និងស្ថានភាពសង្គម-សេដ្ឋកិច្ច[18]។ ផែនការនារីរតនៈទី ៦ ប្រើប្រាស់ពាក្យ "បរិយាបន្ន" ដើម្បីសង្កត់ធ្ងន់លើសារៈសំខាន់នៃការធានាភាពជាតំណាងរបស់ស្ត្រីគ្រប់រូប។

**របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ**

សំដៅលើរបៀបវារៈដែលបង្កើតឡើងដោយសេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (២០០០) និងសេចក្តីសម្រេចជាបន្តបន្ទាប់ចំនួន ១០ ផ្សេងទៀត ដែលលើកកម្ពស់ការដាក់បញ្ចូលទស្សនៈយេនឌ័រទៅក្នុងសមាសភាគទាំងអស់នៃសន្តិភាព និងសន្តិសុខ។ របៀបវារៈនេះអនុវត្តទស្សនៈយេនឌ័រចំពោះសន្តិភាព និងសន្តិសុខ។[19]

[14] https://apps.who.int/violence-info/sexual-violence/
[15] ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ, S/2004/616, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៤
[16] https://www.esafety.gov.au/young-people/trolling
[17] សេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី មាត្រា ១។
[18] https://www.unwomen.org/en/about-us/about-un-women
[19] *Women, Peace and Security Handbook: Compilation and analysis of United Nations Security Council resolution language 2000-2012." New York: Women"s International League for Peace and Freedom.* សេចក្តីសម្រេចទាំង ១០ នោះគឺសេចក្តីសម្រេចលេខ ១៨២០ (២០០៨), ១៨៨៨ (២០០៨), ១៨៨៩ (២០០៩), ១៩៦០ (២០១០), ២១០៦ និង ២១២២ (២០១៣), ២២៤២ (២០១៥), ២៤៦៧ និង ២៤៩៣ (២០១៩) និង ២៥៣៨ (២០២០)។

# សេចក្តីសង្ខេប

## សាវតារ

សេចក្តីសម្រេចលេខ ១៣២៥ (ឆ្នាំ ២០០០) របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បញ្ជាក់ពីតួនាទីសំខាន់របស់ស្ត្រីក្នុងការទប់ស្កាត់ និងដោះស្រាយជម្លោះ និងក្នុងគំនិតផ្តួចផ្តើមកសាងសន្តិភាព។ របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS) ទទួលស្គាល់ថា ជាញឹកញាប់ ស្ត្រីត្រូវបានផាត់ចេញពីដំណើរការសន្តិសុខ និងលើកទឹកចិត្តឱ្យមានការដឹកនាំ និងការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីក្នុងកិច្ចខិតខំប្រឹងប្រែងសន្តិភាពនៅគ្រប់វិស័យនៃជីវិត សាធារណៈ និងជីវិតឯកជន។ ការអនុវត្តរបៀបវារៈ WPS ត្រូវបានទទួលស្គាល់ថាជាការចាំបាច់ដើម្បីសម្រេចបានសន្តិភាព និងវិបុលភាពប្រកបដោយចីរភាពក្នុងតំបន់អាស៊ាន រួមទាំងពាក់ព័ន្ធនឹងបញ្ហាសន្តិសុខទូទៅ និងបញ្ហាសន្តិសុខថ្មីៗដែលកំពុងលេចឡើង ចាប់ពីជម្លោះដល់ការប្រែប្រួលអាកាសធាតុ ការជួញដូរមនុស្ស រហូតដល់សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងបទល្មើសឆ្លងដែន។

កម្ពុជាស្ថិតនៅជួរមុខក្នុងការស្វែងរកការគាំទ្រមតិឱ្យមានការធ្វើមូលដ្ឋានីយកម្មរបៀបវារៈ WPS ក្នុងតំបន់អាស៊ាន។ នៅខែ វិច្ឆិកា ឆ្នាំ ២០២២ ថ្នាក់ដឹកនាំអាស៊ានបានអនុម័តផែនការសកម្មភាពតំបន់អាស៊ានដំបូងបង្អស់ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ASEAN RPA-WPS)។ ក្រសួងកិច្ចការនារីក្នុងនាមជាសមាជិកគណៈកម្មាធិការអាស៊ានស្តីពីស្ត្រី បានដើរតួនាទីសំខាន់ក្នុងការគាំទ្រការរៀបចំ ASEAN RPA-WPS និងកញ្ចប់ឧបករណ៍ស្តីពីការធ្វើមូលដ្ឋានីយកម្ម និងគោលការណ៍ណែនាំសម្រាប់ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលអាស៊ានបានអនុម័តនៅខែ ធ្នូ ឆ្នាំ ២០២៣ ក្រោមការគាំទ្រពី UN Women។

## ការសិក្សា

គោលបំណងនៃការវិភាគស្ថានភាពនេះ គឺដើម្បីពិនិត្យមើលបញ្ហាសន្តិសុខទូទៅ បញ្ហាសន្តិសុខថ្មីៗ និងបញ្ហាសន្តិសុខដែលកំពុងលេចឡើងក្នុងបរិបទនៃរបៀបវារៈ WPS នៅកម្ពុជា កំណត់រកគោលនយោបាយ ផែនការ និងយន្តការពាក់ព័ន្ធដែលមានស្រាប់ ទាញយកមេរៀនដែលទទួលបានពីកម្ពុជា និងបណ្តាប្រទេសផ្សេងទៀត និងផ្តល់អនុសាសន៍សម្រាប់ការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS) នៅកម្ពុជា ស្របតាមផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ASEAN RPA-WPS)។

ការសិក្សានេះបានប្រើប្រាស់អភិក្រមផ្អែកលើសិទ្ធិមនុស្ស ដោយអនុវត្តតាមគោលការណ៍នៃការចូលរួម បរិយាបន្នសមភាពយេនឌ័រ និងការយកចិត្តទុកដាក់ចំពោះយេនឌ័រ។ វិធីសាស្ត្រនេះរួមបញ្ចូលទាំងការពិនិត្យឯកសារពាក់ព័ន្ធ និងការពិគ្រោះយោបល់ជាក្រុម និងបទសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ដែលបានធ្វើឡើងក្នុងអំឡុងខែ កក្កដា និង ខែ សីហា ឆ្នាំ ២០២៤។

ការសិក្សានេះមានអ្នកចូលរួមជិត ២៥០ នាក់ (ស្ត្រី ២០៥ នាក់ និងបុរស ៤៣ នាក់) រួមទាំងអ្នកបង្កើតគោលនយោបាយ និងមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល បុគ្គលិកទីភ្នាក់ងារអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ មន្ត្រីស្ថានទូត គ្រឹះស្ថានសិក្សា និងស្រាវជ្រាវ ស្ត្រីមកពីក្រុមជួបការលំបាក និងស្ត្រីនៅជនបទ យុវជន និងយុវនារី និងស្ត្រី និងបុរសដែលជាកងកម្លាំងរក្សាសន្តិភាពអង្គការសហប្រជាជាតិ នៅក្នុងប្រទេសកម្ពុជា។

លទ្ធផលរកឃើញត្រូវបានលើកមកពិភាក្សាក្នុងកិច្ចប្រជុំជាច្រើន និងសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដែលបានរៀបចំឡើងចាប់ពីខែ តុលា ឆ្នាំ ២០២៤ ដល់ខែ មីនា ឆ្នាំ ២០២៥។ មតិយោបល់របស់អ្នកពាក់ព័ន្ធ ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ចុងក្រោយ។

### ១.ស្ត្រី និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងវិបត្តិជម្លោះ និងវិបត្តិមនុស្សធម៌

អំពើហិង្សាលើស្ត្រី និងក្មេងស្រី បណ្តាលមកពីវិសមភាពនៃទំនាក់ទំនងអំណាចយេនឌ័រ និងការរើសអើង ដែលធ្វើឱ្យកាន់តែធ្ងន់ធ្ងរដោយជម្លោះ វិបត្តិមនុស្សធម៌ ភាពក្រីក្រ បញ្ហាសេដ្ឋកិច្ច និងកត្តាផ្សេងទៀត។ ក្នុងអំឡុងគ្រោះអាសន្ន ដូចជាជម្លោះ ឬគ្រោះមហន្តរាយធម្មជាតិ មានហានិភ័យកាន់តែខ្លាំងនៃអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពានសម្រាប់ស្ត្រី និងក្មេងស្រី និងជាពិសេសស្ត្រី និងក្មេងស្រីដែលត្រូវបានតម្រូវឱ្យនៅតែផ្ទះ នៅពេលដែលការដើរហើរត្រូវបានរឹតត្បិត។

វិបត្តិកូវីដ-១៩ គឺជាឧទាហរណ៍ច្បាស់លាស់មួយ ៖ ទិន្នន័យ និងរបាយការណ៍នានាគូសបញ្ជាក់ថា គ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី បានកើតឡើងក្នុងអត្រាយ៉ាងខ្ពស់។ វិបត្តិនេះ បានរំលេចពីភាពចាំបាច់ដែលរាជរដ្ឋាភិបាលកម្ពុជាត្រូវពង្រឹងប្រព័ន្ធគាំពារសង្គមរបស់ខ្លួន ជាពិសេសសម្រាប់ស្ត្រីងាយរងគ្រោះ និងធានាថា វិធានការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការគ្រោះអាសន្ន។

កម្ពុជាមានប្រវត្តិសាស្ត្រនាពេលថ្មីៗដែលគួរឱ្យចាប់អារម្មណ៍ជុំវិញការកសាងសន្តិភាព និងការអភិវឌ្ឍ ដោយកម្ពុជាបានផ្លាស់ប្តូរពីជម្លោះប្រដាប់អាវុធតាមរយៈបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងការកសាងប្រទេសជាតិឆ្ពោះទៅសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរយៈពេលបួនទសវត្សរ៍កន្លងមក ក្រោយការដួលរលំរបបខ្មែរក្រហម។ អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ កើតឡើងយ៉ាងច្រើននៅក្នុងអំឡុងពេលមានជម្លោះ ហើយនេះក៏ជាករណីសម្រាប់កម្ពុជាផងដែរ។ ជនរងគ្រោះជាច្រើននៅតែរងទុក្ខដោយការប៉ះទង្គិចទាំងផ្លូវចិត្ត និងផ្លូវកាយ។

រាជរដ្ឋាភិបាលបានអនុវត្តជំហានជាច្រើន ដើម្បីគាំទ្រដល់ការចងចាំ ការព្យាបាលការប៉ះទង្គិចផ្លូវចិត្តពីអតីតកាល និងការទប់ស្កាត់មិនឱ្យមានអំពើព្រៃផ្សៃនាពេលអនាគត ដូចជាការកំណត់យកថ្ងៃទី២០ ខែឧសភា ជាថ្ងៃទិវាជាតិនៃការចងចាំ ការកសាងបូជនីយដ្ឋានចងចាំ ដូចជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងវាលពិឃាដ ជើងឯក និងការផលិតសម្ភារៈអប់រំស្តីពីអំពើប្រល័យពូជសាសន៍ ដែលលើកកម្ពស់ការទប់ស្កាត់ ការព្យាបាល កិច្ចសន្ទនាអន្តរជំនាន់ និងការផ្សះផ្សា តាមរយៈប្រព័ន្ធអប់រំផ្លូវការ។

បទពិសោធន៍របស់កម្ពុជា ជាមួយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) តំណាងឱ្យជំហានដ៏សំខាន់មួយឆ្ពោះទៅរកយុត្តិធម៌ និងការផ្សះផ្សា និងផ្តល់ឱកាសពិសេសមួយក្នុងការពង្រឹងបន្ថែមនូវសន្តិភាព និងការអភិវឌ្ឍនៅក្នុងប្រទេស។ អង្គការមិនមែនរដ្ឋាភិបាលក៏បានដើរតួនាទីសំខាន់ផងដែរក្នុងការផ្សះផ្សា និងការព្យាបាលជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ តាមរយៈសកម្មភាពផ្សព្វផ្សាយដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការផ្តល់លទ្ធភាពទទួលបានយុត្តិធម៌ និងការគាំទ្រផ្នែកចិត្តសង្គម និងការលើកកម្ពស់ការនិយាយការពិត កិច្ចសន្ទនាអន្តរជំនាន់ និងការកសាងសមត្ថភាពក្នុងមូលដ្ឋានសម្រាប់ការដោះស្រាយជម្លោះ។

អ្នកពាក់ព័ន្ធដែលត្រូវបានសម្ភាសន៍ក្នុងការសិក្សានេះ យល់ឃើញថា ប្រវត្តិសាស្ត្រកម្ពុជាបទពិសោធន៍នៃការប៉ះទង្គិចផ្លូវចិត្តអន្តរជំនាន់ អំពើហិង្សាលើស្ត្រី និងយុត្តិធម៌អន្តរកាលនៅតែមានភាពពាក់ព័ន្ធខ្លាំងបំផុតទៅនឹងអនាគតប្រកបដោយសន្តិភាពរបស់កម្ពុជា។ ក្រៅពីនេះ ពួកគេបានចាត់ទុកបទពិសោធន៍ដ៏លំបាករបស់កម្ពុជាជាឧទាហរណ៍ដ៏មានតម្លៃសម្រាប់បង្ហាញដល់បណ្តាប្រទេសផ្សេងទៀត ដែលខិតខំលើកកម្ពស់ការកសាងសន្តិភាព និងការដោះស្រាយជម្លោះ សម្រាប់ជាមូលដ្ឋានគ្រឹះនៃសន្តិសុខ និងស្ថិរភាពក្នុងតំបន់។

## ២.ស្ត្រី ការជួញដូរ និងបទល្មើសឆ្លងដែន

អ្នកជួញដូរមនុស្ស កេងប្រវ័ញ្ចទាំងពលរដ្ឋខ្មែរ និងជនបរទេសនៅក្នុងប្រទេសកម្ពុជា ហើយពលរដ្ឋខ្មែរក៏ត្រូវបានជួញដូរទៅក្រៅប្រទេសផងដែរ។ គោលនយោបាយការពារជាតិ ឆ្នាំ ២០២២ របស់កម្ពុជា ចាត់ទុកការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន និងសកម្មភាពឆ្លងដែនខុសច្បាប់ផ្សេងទៀត ជាបញ្ហាដែលគួរឱ្យព្រួយបារម្ភ។ អំពើជួញដូរមនុស្ស និងបទល្មើសឆ្លងដែន បង្កការគំរាមកំហែងចំពោះសន្តិភាព និងសន្តិសុខជាតិ និងអន្តរជាតិ ដោយធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពរបស់ពលរដ្ឋខ្មែរ អាចបង្កឱ្យមានការបែកខ្ញែក និងភាពតានតឹងក្នុងសង្គម នៅក្នុងព្រំដែន និងឆ្លងដែន និងបង្កើនហានិភ័យសម្រាប់ សហគមន៍ដែលងាយរងគ្រោះដោយបទល្មើសទាំងនេះ។ របាយការណ៍ឆ្នាំ ២០២៣ របស់អង្គការសហប្រជាជាតិបានបង្ហាញឱ្យដឹងថា ប្រជាជនរាប់សែននាក់កំពុងត្រូវបានបង្ខំឱ្យចូលរួមជាមួយក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំងដើម្បីធ្វើសកម្មភាពបទល្មើសតាមអនឡាញនៅតំបន់អាស៊ីអាគ្នេយ៍ ចាប់ពីការបោកប្រាស់ដែលទាក់ទាញឱ្យចូលរួមវិនិយោគ (romance-investment scam) និងគ្រីបតូ (crypto) រហូតដល់ការសម្អាតប្រាក់ និងល្បែងភ្នាល់ខុសច្បាប់[20] ហើយស្ត្រីក៏កំពុងត្រូវបានគេកេងប្រវ័ញ្ចនៅក្នុងមជ្ឈមណ្ឌលសេវាអនឡាញបោកប្រាស់ (online scams center) នៅក្នុងតំបន់នេះផងដែរ។ ជនរងគ្រោះប្រឈមនឹងទម្រង់ផ្សេងៗជាច្រើននៃការរំលោភបំពាន និងការបៀតបៀន ដូចជា ការគំរាមកំហែងដល់សុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួន។

ការរីករាលដាលនៃជំងឺកូវីដ-១៩ បានផ្លាស់ប្តូរហានិភ័យដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស ដោយស្ត្រីងាយរងគ្រោះខ្លាំងជាងបុរស។ ពលករទេសន្តរប្រវេសន៍ជាច្រើនដែលត្រឡប់មកវិញ មិនសូវមានឱកាសការងារជាប់លាប់នៅពេលត្រឡប់មកវិញ ហើយនេះធ្វើឱ្យពួកគេងាយរងគ្រោះខ្លាំងដោយការជួញដូរមនុស្ស។ ស្ត្រីងាយរងផលប៉ះពាល់ជាងបុរស។

បទសម្ភាសន៍ជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ស្ត្រី និងយុវជននៅតំបន់ជនបទ រួមទាំងក្រុមជនជាតិដើម និងជនជាតិភាគតិចបានលើកឡើងពីកង្វល់ជុំវិញការជួញដូរគ្រឿងញៀន និងសេព

[20] https://bangkok.ohchr.org/wp-content/uploads/2023/08/ONLINE-SCAM-OPERATIONS-2582023.pdf

គ្រឿងញៀនដោយយុវជន និងផលប៉ះពាល់អវិជ្ជមានរបស់វាលើសុវត្ថិភាពសហគមន៍ និងគ្រួសារ។

## ៣.ស្ត្រី សន្តិភាព និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត

សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត កាន់តែក្លាយជាចំណុចអាទិភាពនៃគោលនយោបាយសន្តិសុខជាតិ និងអន្តរជាតិ ជាពិសេសក្នុងបរិបទឌីជីថលភាវូបនីយកម្មយ៉ាងលឿនរហ័ស និងការគំរាមកំហែងដែលបង្កឡើងដោយបច្ចេកវិទ្យាទំនើប ការវាយប្រហារតាមប្រព័ន្ធបច្ចេកវិទ្យា (cyberwarfare) និងការវាយប្រហារលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ។ គោលនយោបាយការពារជាតិឆ្នាំ ២០២២ របស់កម្ពុជា ទទួលស្គាល់ថា បទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត គឺជាការគំរាមកំហែងយ៉ាងខ្លាំងដល់កម្ពុជា និងតំបន់ទាំងមូល។ ការគំរាមកំហែងតាមប្រព័ន្ធអ៊ីនធឺណិតបង្កអន្តរាយដល់សន្តិសុខជាតិ និងស្ថិរភាពសង្គម តាមរយៈការផ្តោតគោលដៅលើសេដ្ឋកិច្ច ចារកម្ម និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជា មន្ទីរពេទ្យ ទូរគមនាគមន៍ និងប្រព័ន្ធដឹកជញ្ជូនជាដើម។ ការវាយប្រហាលើប្រព័ន្ធទាំងនេះ អាចប៉ះពាល់យ៉ាងខ្លាំងដល់ស្ត្រី។

ការទទួលបាន និងសុវត្ថិភាពរបស់ស្ត្រីនៅលើវេទិកាឌីជីថល ជាកត្តាសំខាន់ក្នុងការបង្កលទ្ធភាពឱ្យមានការចូលរួមស្មើភាពគ្នាក្នុងជីវិតសាធារណៈ។ យោងតាមក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MoPTC) ប្រជាជនកម្ពុជាត្រឹមតែ ៣០ភាគរយប៉ុណ្ណោះដែលមានជំនាញឌីជីថលកម្រិតមូលដ្ឋាន។ នៅកម្ពុជា ចំនួនស្ត្រីដែលប្រើប្រាស់បណ្តាញសង្គម មានតិចជាងបុរស (៤៤,៨ ភាគរយ ទល់នឹង ៥៥,២ ភាគរយ)។ ការស្រាវជ្រាវដោយ EngageMedia រកឃើញថា ការវាយប្រហារតាមប្រព័ន្ធឌីជីថលដែលគួរឱ្យព្រួយបារម្ភសម្រាប់អ្នកឆ្លើយតបក្នុងការស្ទង់មតិនៅកម្ពុជា រួមមានការលួចយកគណនី ការក្លែងបន្លំតាមអ៊ីនធឺណិត ការតាមដាន ការបៀតបៀនតាមអ៊ីនធឺណិត និងពាក្យសម្តីស្អប់ខ្ពើម។ អ្នកឆ្លើយតបជាង ៦០ ភាគរយ លើកឡើងថា ពួកគេមានសមត្ថភាពទាបក្នុងការការពារខ្លួនពីការគំរាមកំហែងតាមប្រព័ន្ធឌីជីថលបែបនេះ។[21]

បច្ចេកវិទ្យាឌីជីថលដើរតួនាទីសំខាន់ក្នុងការងាររបស់អង្គការសង្គមស៊ីវិលរបស់ស្ត្រី និងអ្នកការពារសិទ្ធិមនុស្សរបស់ស្ត្រី។ ការគំរាមកំហែងក្នុងប្រព័ន្ធបច្ចេកវិទ្យា (cyberthreat) អាចរំខានដល់ការងាររបស់ពួកគេ បំផ្លាញកេរ្តិ៍ឈ្មោះ ហើយថែមទាំងបង្កគ្រោះថ្នាក់ផ្លូវកាយ ឬរបួសផ្លូវចិត្តទៀតផង។ ការសិក្សាឆ្នាំ ២០២៤ ដោយអង្គការ UN Women រកឃើញថា អង្គការសង្គមស៊ីវិលរបស់ស្ត្រីបានលើកឡើងពីការយល់ឃើញក្នុងកម្រិតខ្ពស់ចំពោះការគំរាមកំហែង និងការទទួលរងការគំរាមកំហែង ជាងអង្គការសង្គមស៊ីវិលដែលមិនពាក់ព័ន្ធនឹងស្ត្រី ជាពិសេសពាក់ព័ន្ធនឹងការបៀតបៀនតាមអនឡាញ (៧៣ ភាគរយ ទល់នឹង ៤៨ ភាគរយ) ការចំអក ឬការឌឺដង (trolling) (៧១ ភាគរយ ទល់នឹង ៥៥ ភាគរយ) និងការផ្សព្វផ្សាយព័ត៌មានឯកជនក្នុងចេតនាមិនល្អ (doxing) (៦១ ភាគរយ ទល់នឹង ៣២ ភាគរយ)[22]។ ខណៈដែលការប្រើពាក្យសម្តីស្អប់ខ្ពើមត្រូវបានហាមឃាត់ក្រោមមាត្រា ៤៩៤ និង ៤៩៦ នៃក្រមព្រហ្មទណ្ឌ ការពិភាក្សាជាមួយអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល និងស្ត្រីជនបទ និងយុវជន បានបញ្ជាក់ថា ស្ត្រីជារឿយៗគឺជាគោលដៅនៃអំពើគំរាមកំហែង ឬយាយីប្រើប្រាស់មធ្យោបាយអ៊ីនធឺណិត ការបៀតបៀនតាមអ៊ីនធឺណិត និងសារបែបរើសអើងពាក្យសម្តីស្អប់ខ្ពើម និងការឆបោកហិរញ្ញវត្ថុតាមអ៊ីនធឺណិត។

## ៤.ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី

រដ្ឋាភិបាលបានប្តេជ្ញាបង្កើនការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងវិស័យសាធារណៈ និងនយោបាយ។ ចំណុចដៅសម្រាប់ចំនួនស្ត្រីនៅក្នុងតួនាទីដឹកនាំ ត្រូវបានកំណត់ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDG) ៥.៥. ស្តីពីសមភាពយេនឌ័រ (៥.៥.១-៥.៥.៥) និង គោលដៅ CSDG ១៦ (ចំណុចដៅ ១៦.៧)។

គិតត្រឹម ឆ្នាំ ២០២៤ ចំនួនសមាជិកសភាជាស្ត្រី គឺ ១៤,៤ ភាគរយ ក្នុងនោះមានស្ត្រីជាប្រធានរដ្ឋសភា និងស្ត្រីចំនួន ០២ រូបទៀត ជាប្រធានគណៈកម្មាធិការជំនាញ។ ស្ត្រីជាសមាជិកព្រឹទ្ធសភាមានការកើនឡើងពី ១៤,៨ ភាគរយ ក្នុងឆ្នាំ ១៩៩៩ ដល់ ១៧,៧៤ ភាគរយ ក្នុងឆ្នាំ ២០២៤។ ស្ត្រីចំនួន ០៣ រូប ជារដ្ឋមន្ត្រី ០១ រូប ជាអគ្គសវនករ និង ០១ រូបទៀត ជាអគ្គទេសាភិបាលធនាគារជាតិ ដែលសុទ្ធតែមានឋានៈស្មើនឹងទេសរដ្ឋមន្ត្រី។ ស្ត្រីដែលមានឋានៈរដ្ឋលេខាធិការ មានប្រមាណ ១៤,៨ ភាគរយ និងឋានៈអនុរដ្ឋលេខាធិការមានប្រមាណ ១៥,៧ ភាគរយ។

ស្ត្រីក្នុងវិស័យសាធារណៈមានការកើនឡើងជាបន្តបន្ទាប់ គឺកើនពីប្រមាណ ២២ ភាគរយ ក្នុងឆ្នាំ ២០១៨ ដល់ ៤១ ភាគរយ ក្នុងឆ្នាំ ២០២៤។ ស្ត្រីជាមន្ត្រីរាជការ ដែលមាន

[21] https://engagemedia.org/projects/gif-report-digital-safety/
[22] https://asiapacific.unwomen.org/en/what-we-do/peace-and-security/cybersecurityCybersecurity Threats, Vulnerabilities and Resilience Among Women Human Rights

តួនាទីធ្វើសេចក្តីសម្រេច ចាប់ពីអនុប្រធានការិយាល័យដល់អគ្គនាយក និងឋានៈស្មើ កើនឡើងពី ២៤ ភាគរយ ក្នុងឆ្នាំ ២០១៨ ដល់ ២៧ ភាគរយ ក្នុងឆ្នាំ ២០២៣។

**នៅថ្នាក់ក្រោមជាតិ ៖**

- ស្ត្រីចំនួន ០២រូប ជាអភិបាលរាជធានី ខេត្ត (ស្មើនឹង ៨ ភាគរយ)។
- ស្ត្រីជាអភិបាលរង មានចំនួន ២៩ រូប (ស្មើនឹង ១៣ ភាគរយ)។
- ស្ត្រីជានាយកទីចាត់ការ ប្រធានអង្គភាពលទ្ធកម្មសាលារាជធានី ខេត្ត មានចំនួន ១៦ រូប (ស្មើនឹង ៩,៩ ភាគរយ)។
- ស្ត្រីជានាយករងទីចាត់ការ អនុប្រធានអង្គភាពលទ្ធកម្មសាលារាជធានី ខេត្ត មានចំនួន ៨០ រូប (ស្មើនឹង ២៥,៨០ ភាគរយ)។
- ស្ត្រីជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្តមាន ១៧,៦ ភាគរយ។

**នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ៖**

- ស្ត្រីជាអភិបាលក្រុង ស្រុក ខណ្ឌ មានចំនួន ០៧ រូប (ស្មើនឹង ៣,៤ ភាគរយ)។
- ស្ត្រីជាអភិបាលរងក្រុង ស្រុក ខណ្ឌ មានចំនួន ២៤៣ រូប (ស្មើនឹង ២១,២ ភាគរយ)។
- ស្ត្រីជានាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ មានចំនួន ២០ រូប (ស្មើនឹង ១០,៦៣ ភាគរយ)។
- ស្ត្រីជានាយករងរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ មានចំនួន ១២០ រូប (ស្មើនឹង ២៦,៧ ភាគរយ)។
- ស្ត្រីជាប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានចំនួន ៦,២ ភាគរយ និងស្ត្រីជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានចំនួន ១៩,៣ ភាគរយ។

**នៅថ្នាក់ឃុំ សង្កាត់ ៖**

- ស្ត្រីជាមេឃុំ-ចៅសង្កាត់ មានចំនួន ១៧៦ រូប (ស្មើនឹង ១០,៧ ភាគរយ)។
- ស្ត្រីជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ មានប្រមាណ ១៩,៧ ភាគរយ។
- ស្ត្រីជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ មានចំនួន ១១,៣ ភាគរយ។
- ស្ត្រីជាស្មៀនឃុំ សង្កាត់ មានចំនួន ១៨,២ ភាគរយ និងស្ត្រីជាសមាជិក មានចំនួន ២២ ភាគរយ។

ទោះជាយ៉ាងណាក៏ដោយ ស្ត្រីនៅតែមានភាពជាតំណាងតិចតួចក្នុងមុខតំណែងធ្វើសេចក្តីសម្រេច ដែលធ្វើឱ្យរឹតត្បិតដល់ការឆ្លុះបញ្ចាំងអំពីអាទិភាព និងទស្សនៈរបស់ស្ត្រីនៅក្នុងគោលនយោបាយ និងអភិបាលកិច្ច។ ទោះបីជាបច្ចុប្បន្ន ស្ត្រីមានចំនួន ១៤,៤ ភាគរយ នៅរដ្ឋសភា និងចំនួន ១៧,៧ ភាគរយនៅក្នុងព្រឹទ្ធសភា (២០២៤) ក៏ដោយ ក៏ភាពជាតំណាងរបស់ស្ត្រីនៅកម្រិតក្រុមប្រឹក្សាឃុំ/សង្កាត់នៅមានកម្រិតទាប (ទោះបីជាបានកើនឡើងដល់ ២២ ភាគរយ នៅឆ្នាំ ២០២២ ក្តី)។ មេឃុំជាស្ត្រីមានតែ ១០,៧ ភាគរយប៉ុណ្ណោះ។

ការសិក្សាថ្មីមួយដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) រកឃើញថា សមាជិកក្រុមប្រឹក្សាជាស្ត្រី (៣៧ ភាគរយ) ច្រើនជាងបុរស (១៣%) បានរាយការណ៍ថា គ្រួសារដើរតួនាទីធំបំផុតក្នុងការលើកទឹកចិត្តពួកគាត់ឱ្យឈរឈ្មោះ[23]។

ទោះបីជាគ្រួសារផ្តល់ការលើកទឹកចិត្តក៏ដោយ ក៏នៅតែមានឥរិយាបថរើសអើងជាទូទៅចំពោះស្ត្រីនៅក្នុងមុខតំណែងដឹកនាំ៖ ៤៦ ភាគរយនៃសមាជិកក្រុមប្រឹក្សាជាបុរស ធៀបនឹង ២១ ភាគរយនៃសមាជិកក្រុមប្រឹក្សាជាស្ត្រី បានលើកឡើងថា បុរសធ្វើជាអ្នកដឹកនាំនយោបាយបានល្អជាងស្ត្រី។ ថ្នាក់ដឹកនាំជាន់ខ្ពស់ជាស្ត្រីក្នុងរដ្ឋាភិបាលបានសង្កត់ធ្ងន់លើការគាំទ្រពីថ្នាក់ដឹកនាំជាន់ខ្ពស់ជាបុរស និងសហការី ក្នុងការបង្កើតបរិយាកាសការងារសមប្រកប និងការពង្រីកឱកាសសម្រាប់ឱ្យស្ត្រីបោះជំហានក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត។

ក្នុងតំបន់អាស៊ីអាគ្នេយ៍ ក៏មានការព្រួយបារម្ភចំពោះភាពជាតំណាងដ៏សំខាន់ផងដែរ នៅពេលដែលអ្នកដឹកនាំជាស្ត្រីមិនមានទំនាក់ទំនងជិតស្និទ្ធជាមួយអង្គការស្ត្រី ឬមិនឆ្លុះបញ្ចាំងពីបទពិសោធន៍របស់ក្រុមស្ត្រីផ្សេងៗ ជាពិសេសស្ត្រីជួបការលំបាក។ ការសិក្សាថ្មីមួយស្តីពីសិទ្ធិស្ត្រីជនជាតិភាគតិចនៅកម្ពុជាបង្ហាញថា អ្នកឆ្លើយតបចំនួន ៦១ ភាគរយ បានលើកឡើងថា ស្ត្រីមិនដែល ឬកម្រចូលរួមក្នុងសហគមន៍របស់ពួកគេដើម្បីដោះស្រាយបញ្ហា ឬអាទិភាពអភិវឌ្ឍន៍ក្នុងសហគមន៍ណាស់។

បន្ទុកនៃការថែទាំ និងការងារផ្ទះដោយមិនទទួលបានប្រាក់ឈ្នួល នៅតែជាឧបសគ្គធំបំផុតមួយចំពោះសមភាពយេនឌ័រនៅកម្ពុជា ប៉ុន្តែកម្រត្រូវបានដោះស្រាយដោយគោលនយោបាយសាធារណៈ ឬកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍។ ការងារថែទាំគ្មានប្រាក់ឈ្នួល ដែលមានលក្ខណៈផ្អែកតាមយេនឌ័រខ្លាំង មានតម្លៃទាប និងគ្មានការគាំទ្រ រឹតត្បិតការចូលរួមប្រកបដោយអត្ថន័យរបស់

[23] *The Status of Women in Commune/Sangkat Government, CDRI, June 2024*

ស្ត្រីក្នុងកិច្ចខិតខំប្រឹងប្រែងពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ រួមទាំងការទប់ស្កាត់ជម្លោះ ការឆ្លើយតប ការកសាងសន្តិភាព និងកិច្ចខិតខំប្រឹងប្រែងសង្គ្រោះ និងស្តារឡើងវិញ។ គ្រួសារបន្តអនុវត្ត និងពង្រឹងការបែងចែកការងារផ្អែកតាមយេនឌ័រ ដោយបណ្តាលឱ្យស្ត្រី និងក្មេងស្រីទទួលខុសត្រូវលើការងារថែទាំ។ នៅជនបទ មានស្ត្រី (២៥,៧ ភាគរយ) ច្រើនជាងបុរស (១១,៥ ភាគរយ) ដែលប្រឡូកក្នុងការងារគ្រួសារដែលគ្មានប្រាក់ឈ្នួល។ ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ បានដាក់បន្ទុកបន្ថែមទៀតដល់ការងារថែទាំគ្មានប្រាក់ឈ្នួលរបស់ស្ត្រីនៅក្នុងតំបន់រងផលប៉ះពាល់។

## ៥.ស្ត្រីក្នុងវិស័យសន្តិសុខ ការទូតអន្តរជាតិ និងកងកម្លាំងរក្សាសន្តិភាព

ស្ត្រីនៅក្នុងវិស័យសន្តិសុខ ដើរតួនាទីសំខាន់ក្នុងការកែលម្អប្រសិទ្ធភាពប្រតិបត្តិការនៃការអនុវត្តច្បាប់។ ភាគរយស្ត្រីជាភ្នាក់ងារអនុវត្តច្បាប់នៅតែមានកម្រិតទាបក្នុងតំបន់អាស៊ាន ដែលមានចាប់ពី ៦ ភាគរយ នៅប្រទេសឥណ្ឌូណេស៊ី ដល់ ២០ ភាគរយ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ហើយកម្ពុជាមានប្រមាណ ១១ ភាគរយ។ មានគម្លាតយេនឌ័រកាន់តែធំនៅក្នុងមុខតំណែងដែលមានឋានៈកាន់តែខ្ពស់។ ភាពខុសគ្នានេះធ្វើឱ្យប៉ះពាល់ដល់ការឆ្លើយតបសំខាន់ៗដែលយកចិត្តទុកដាក់នឹងយេនឌ័រ ជាពិសេសក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ និងបទល្មើសផ្សេងទៀត។ មន្ត្រីនគរបាលជាស្ត្រីដែលបានសម្ភាសន៍ ចង់ឃើញមានមន្ត្រីនគរបាលជាស្ត្រីកាន់តែច្រើននៅក្នុងមុខតំណែង ដឹកនាំជាពិសេសក្នុងការិយាល័យរដ្ឋបាលនៅសហគមន៍ ដោយគូសបញ្ជាក់ថា មន្ត្រីនគរបាលជាស្ត្រីបានបង្ហាញពីសមត្ថភាពរបស់ពួកគេ ក្នុងការដោះស្រាយស្ថានភាពជម្លោះដែលអាចកើតមានឡើង ដោយសន្តិវិធី និងផ្តល់ជូនសេវាដល់ស្ត្រី និងគ្រួសារនៅក្នុងសហគមន៍បានកាន់តែមានប្រសិទ្ធភាព។

កិច្ចសហប្រតិបត្តិការអន្តរជាតិគឺជាអាទិភាពសំខាន់មួយ ដូចដែលបានគូសបញ្ជាក់ក្នុងគោលនយោបាយការពារជាតិឆ្នាំ ២០២២ របស់កម្ពុជា។ គិតត្រឹមខែ ធ្នូ ឆ្នាំ ២០២៤ កម្ពុជាស្ថិតក្នុងចំណោមរដ្ឋសមាជិកអាស៊ានឈានមុខគេដែលបានបញ្ជូនកងកម្លាំងជាស្ត្រីទៅប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ (UN PKO) ដោយបានបញ្ជូនកងកម្លាំងរក្សាសន្តិភាពជាស្ត្រីចំនួន ២១,៤ ភាគរយនៃចំនួនកងកម្លាំងរក្សាសន្តិភាពសរុបរបស់ខ្លួន។ ការសិក្សាថ្មីមួយរកឃើញថា មិនមានការរឹតត្បិតជាផ្លូវការមិនឱ្យស្ត្រីបម្រើការក្នុង UN PKOs នោះទេ[24]។ បុរស និងស្ត្រីបម្រើការដោយស្មើភាពគ្នាក្នុងតួនាទីដឹកនាំ តួនាទីប្រយុទ្ធ និងតួនាទីប្រតិបត្តិការ ក្នុងពេលបំពេញបេសកកម្ម ប៉ុន្តែមានស្ត្រី (២៤ ភាគរយ) ច្រើនជាងបុរស (៨ ភាគរយ) ដែលបានលើកឡើងថា ពួកគេប្រឈមនឹងការមាក់ងាយពីសង្គម នៅពេលពួកគេត្រូវបានបញ្ជូនទៅប្រតិបត្តិការនេះ ដោយការមាក់ងាយភាគច្រើនគឺមកពីសមាជិកគ្រួសារ។

ការបណ្តុះបណ្តាលមុនពេលបញ្ជូនគឺជាលក្ខខណ្ឌតម្រូវមួយ ហើយស្ត្រី និងបុរស ៩៣ ភាគរយ បាននិយាយថាពួកគេបានចូលរួមក្នុងការបណ្តុះបណ្តាលនោះ។ ទោះយ៉ាងណា ការបណ្តុះបណ្តាលផ្អែកយេនឌ័រមិនមែនជាលក្ខខណ្ឌចាំបាច់សម្រាប់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ (RCAF) ឡើយ។ មានបុរស (៤៣ ភាគរយ) តិចជាងស្ត្រី (៥៧ ភាគរយ) ដែលបានចូលរួមការបណ្តុះបណ្តាលផ្អែកយេនឌ័រ។ នេះបញ្ជាក់ពីលទ្ធផលរកឃើញក្នុងការសិក្សាផ្សេងទៀតដែលបង្ហាញថា បុរសកម្រចូលរួមនៅក្នុងការបណ្តុះបណ្តាលណាស់ នៅពេលដែលការបណ្តុះបណ្តាលផ្អែកយេនឌ័រក្នុងពេលបម្រើការងារនោះ មិនមែនជាកាតព្វកិច្ច។

RCAF មានក្របខណ្ឌច្បាប់សម្រាប់ទប់ស្កាត់ និងដោះស្រាយការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (SEA) និងការបណ្តុះបណ្តាលមុនពេលបញ្ជូន។ ទោះជាយ៉ាងណា ការសិក្សាថ្មីមួយស្តីពី UN PKO បានបង្ហាញពីកម្រិតទាបនៃការបៀតបៀនដែលបានរាយការណ៍ (៤ភាគរយ-៩ភាគរយ) ប៉ុន្តែក្នុងចំណោមកងកម្លាំងដែលបានស្ទង់មតិ មានកងកម្លាំងតែ ៥៨ ភាគរយប៉ុណ្ណោះ ដែលបានដឹងអំពីគោលនយោបាយបៀតបៀនផ្លូវភេទណាមួយ។ បច្ចុប្បន្ន មិនមានយន្តការបណ្តឹងផ្ទៃក្នុងនោះទេ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MoFAIC) ទទួលស្គាល់តួនាទីសំខាន់របស់ស្ត្រីក្នុងការរួមចំណែកដល់ស្ថិរភាពនយោបាយ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម និងសន្តិភាព និងដើរតួនាទីសំខាន់ក្នុងការការពារពលរដ្ឋកម្ពុជានៅបរទេស ជាពិសេសស្ត្រី។ ការចូលរួមរបស់ស្ត្រីកម្ពុជាក្នុងកិច្ចការការទូតបច្ចុប្បន្នគឺ ១៦ ភាគរយ ដែលលើសបន្តិចពីមធ្យមភាគសកល (១៥ ភាគរយ)។ ទោះជាយ៉ាងណា ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីពន្លឿនការដំឡើងឋានៈស្ត្រីក្នុងមុខតំណែងដឹកនាំក្នុងវេទិកាអន្តរជាតិ ដើម្បីឱ្យសម្រេចបានចំនួនអប្បបរមា ៣០ ភាគរយ សម្រាប់

[24] https://asiapacific.unwomen.org/en/digital-library/publications/2024/07/mowip-2023-assessment#

តំណាងស្មើភាពគ្នា ក្រោមអនុសាសន៍លេខ ១៩៩០/១៥ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃ អ.ស.ប (ECOSOC)។

## ៦.ស្ត្រី និងអាកាសធាតុ សន្តិភាព និងសន្តិសុខ

សន្តិសុខអាកាសធាតុ សំដៅលើការទទួលស្គាល់ថាការប្រែប្រួលអាកាសធាតុដែលបង្កឱ្យមានការគំរាមកំហែងយ៉ាងខ្លាំងដល់សន្តិសុខជាតិ និងពិភពលោក ហើយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុអាចបង្កឱ្យមានអស្ថិរភាពសង្គមនយោបាយ និងសេដ្ឋកិច្ច។ កម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលងាយរងគ្រោះបំផុតដោយការប្រែប្រួលអាកាសធាតុ។ សន្ទស្សន៍ភាពធន់របស់ស្ត្រីកម្ពុជារកឃើញថា ស្ត្រីមិនសូវធន់នឹងគ្រោះមហន្តរាយ ដូចបុរស ដោយសារកត្តាត្រួតគ្នាជាច្រើន ដូចជា ប្រភពចំណូលមិនឋិតថេរ និងមិនជាប់លាប់ លទ្ធភាពទាបក្នុងការទទួលបានការការពារផ្នែករចនាសម្ព័ន្ធពីមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ កង្វះជម្រកសុវត្ថិភាព និងប្រព័ន្ធជូនដំណឹងជាមុន លំនៅឋានទ្រុឌទ្រោម និងសំណាញ់សុវត្ថិភាព និងបណ្ដាញសង្គមទន់ខ្សោយ។

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការរិចរឹលបរិស្ថាន និងការខ្សត់ធនធានធម្មជាតិ កំពុងរួមចំណែកដល់អសន្តិសុខ និងអស្ថិរភាពទូទាំងពិភពលោក រួមទាំងកម្ពុជា។ បញ្ហាប្រឈមទាំងនេះធ្វើឱ្យប៉ះពាល់ដល់សន្តិសុខតាមរបៀបផ្សេងគ្នា ដូចជា ការប្រែប្រួលគំរូចល័តភាព និងការផ្លាស់ទីលំនៅ ភាពស្រួចស្រាវនៃការប្រជែងដណ្ដើមដីធ្លី ទឹក និងធនធានផ្សេងទៀត ការថយចុះសន្តិសុខស្បៀង និងជីវភាពរស់នៅ ហានិភ័យសុខភាពសាធារណៈ ការប្រែប្រួលឌីណាមិកក្នុងសេដ្ឋកិច្ចពណ៌ខៀវ និងការផ្លាស់ប្ដូរលំនាំនៃបទល្មើសដែលមានអង្គការចាត់តាំង (រួមទាំងបទល្មើសបរិស្ថាន)។ បទសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធ បានបញ្ជាក់ពីផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុលើសន្តិសុខសេដ្ឋកិច្ចរបស់ស្ត្រី។

ក្នុងករណីខ្លះ បញ្ហានេះបានបង្កភាពតានតឹងកាន់តែខ្លាំងលើលទ្ធភាពទទួលបានធនធានទឹកដែលកំពុងខ្សត់ សម្រាប់កសិកម្ម និងសិទ្ធិដីធ្លី។ ការបង្កើនភាពអង់អាចដល់ស្ត្រីតាមរយៈការអប់រំ ឱកាសសេដ្ឋកិច្ច និងតួនាទីដឹកនាំ បង្កផលប៉ះពាល់ចម្រុះ និងជ្រាលជ្រៅលើការពង្រឹងភាពធន់របស់សហគមន៍ទៅនឹងផលប៉ះពាល់នៃអាកាសធាតុ និងការគាំទ្រដល់ការទប់ស្កាត់ជម្លោះ និងសន្តិភាពប្រកបដោយចីរភាព។ លើសពីនេះទៀត អ្នកដឹកនាំជាស្ត្រីច្រើនតែផ្ដោតអាទិភាពលើសុខុមាលភាពសហគមន៍ និងការអភិវឌ្ឍប្រកបដោយចីរភាព ដែលនាំទៅរកយុទ្ធសាស្ត្របង្កើនភាពធន់នឹងអាកាសធាតុដែលមានបរិយាបន្ន និងប្រសិទ្ធភាព។

## ៧. របៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS) និងលទ្ធភាពទទួលបានសន្តិសុខសេដ្ឋកិច្ច ឱកាសប្រកបរបរចិញ្ចឹមជីវិត ធនធានធម្មជាតិ និងសន្តិសុខមនុស្ស

ស្ត្រីដើរតួនាទីសំខាន់ក្នុងសន្តិភាព និងសន្តិសុខ រួមទាំងការពន្លឿនការស្ដារសេដ្ឋកិច្ចឡើងវិញក្រោយជម្លោះ និងការរួមចំណែកដល់សន្តិភាពប្រកបដោយចីរភាព។ នៅកម្ពុជា វិស័យកសិកម្មដើរតួនាទីសំខាន់ក្នុងការទ្រទ្រង់កំណើន សេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ ការចូលរួមរបស់ស្ត្រីក្នុងកម្លាំងពលកម្មប្រមាណ ៧៨,៩ ភាគរយ គឺស្ថិតក្នុងចំណោមប្រទេសដែលមានអត្រាខ្ពស់បំផុតក្នុងតំបន់។ ទោះជាយ៉ាងណា បទសម្ភាសន៍ជាមួយស្ត្រី និងយុវជននៅជនបទ បានបង្ហាញពីឱកាសសេដ្ឋកិច្ចតិចតួច និងការលំបាកក្នុងការរកបានការងារសមរម្យតាមរដូវកាលនៅជិតៗផ្ទះ។ ស្ថានភាពទាំងនេះបានជំរុញឱ្យមានភាពអសន្តិសុខស្បៀង និងជីវភាពរស់នៅ ហើយជារឿយៗបានបង្ខំពួកគេឱ្យធ្វើចំណាកស្រុកដើម្បីស្វែងរកការងារ។ ទេសន្តរប្រវេសន៍ ដើរតួនាទីជាជីវិតសេដ្ឋកិច្ចសំខាន់ និងជាកត្តាជំរុញចល័តភាពសង្គមសម្រាប់គ្រួសារកម្ពុជា។

តាមការគូសបញ្ជាក់ដោយមន្ត្រីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល នៅពេលធ្វើទេសន្តរប្រវេសន៍ក្រោមលក្ខខណ្ឌ ដែលគ្មានសុវត្ថិភាព ឬមិនស្របច្បាប់ វាអាចធ្វើឱ្យស្ត្រីជនបទប្រឈមនឹងហានិភ័យជាច្រើន រួមទាំងការគំរាមកំហែងចំពោះសុវត្ថិភាពនិងសុខុមាលភាពគ្រួសារទោះបីជាមានគោលនយោបាយដែលឆ្លើយតបនឹងយេនឌ័រក៏ដោយ។

គ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ (UXO) ត្រូវបានបន្សល់ទុកពីសង្គ្រាមរាប់ទសវត្សរ៍កន្លងមកនៅក្នុងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលបានផ្ដល់អាទិភាពដល់ការបោសសម្អាតគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ដោយបានបញ្ចូលសកម្មភាពមីនទៅក្នុងយុទ្ធសាស្ត្រជាតិ និងបានកំណត់គោលដៅនៃការប្រែក្លាយកម្ពុជាជាប្រទេសគ្មានមីននៅឆ្នាំ ២០២៥។ ស្ត្រីកម្ពុជាបានចូលរួមកាន់តែច្រើនឡើងក្នុងការងារដោះមីន និងបោសសម្អាតគ្រាប់មីន ដោយស្ត្រីមានចំនួន ៣៤ភាគរយនៃបុគ្គលិកប្រតិបត្តិការសរុប និងមានស្ត្រី ២២ ភាគរយ កាន់មុខតំណែងគ្រប់គ្រង ឬមុខតំណែងជាប្រធានត្រួតពិនិត្យក្នុងឆ្នាំ ២០២៣[25]។

[25] https://www.mineactionreview.org/assets/downloads/Cambodia_Clearing_the_Mines_2024.pdf

ផលវិបាកនៃគ្រាប់មីនមានភាពខុសគ្នាសម្រាប់ស្ត្រី ក្មេងស្រី ក្មេងប្រុស និងបុរស។ ស្ត្រីច្រើនតែជាជនរងគ្រោះដោយប្រយោល និងច្រើនតែបំពេញតួនាទីថែទាំ និងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ជនរងគ្រោះ ខណៈដែលក្មេងស្រីច្រើនតែជាអ្នក ដែលត្រូវបញ្ឈប់ពីការសិក្សា ឬបង្ខំឱ្យរៀបការនៅវ័យក្មេង នៅពេលធនធានរបស់គ្រួសារមានកម្រិត ក្រោយជួបឧប្បត្តិហេតុគ្រាប់មីន។[26] ស្ត្រី និងក្មេងស្រីក៏ប្រឈមនឹងហានិភ័យខ្ពស់នៃការរំលោភបំពានផ្លូវភេទ នៅក្នុងតំបន់គំរាមកំហែង និងគ្មានសុវត្ថិភាពផងដែរ។

នៅកម្ពុជា ស្ត្រីជនបទជាអ្នកដែលត្រូវប្រមូល និងផ្គត់ផ្គង់ធនធានធម្មជាតិ និងពឹងផ្អែកយ៉ាងខ្លាំងលើធនធានទាំងនោះ ដើម្បីទ្រទ្រង់ជីវិត និងជីវភាព។ ស្ត្រី ជាពិសេសស្ត្រីនៅជនបទ និងសហគមន៍ជនជាតិដើមភាគតិច មានបន្ទុកធ្ងន់ជាពិសេស ក្នុងការងារផ្ទះ រួមមានកសិកម្ម ការចិញ្ចឹមសត្វ ការដេរប៉ាក់ កិច្ចការផ្ទះ និងការប្រមូលអាហារពីព្រៃ ជាពិសេសនៅពេលដែលគ្មានសន្តិសុខស្បៀង។ ការស្រាវជ្រាវបង្ហាញថា សិទ្ធិ និងលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានធនធានធម្មជាតិ និងប្រភពប្រាក់ចំណូលរបស់ពួកគេ នៅតែមិនចិតថេរ[27]។ សំឡេងរបស់ស្ត្រីត្រូវបានដាត់ចេញមួយភាគធំពីដំណើរការគ្រប់គ្រង និងធ្វើសេចក្តីសម្រេចស្តីពីធនធានធម្មជាតិ ហើយស្ត្រីច្រើនតែមិនសូវមានអំណាចក្នុងការចរចា ឬផ្សះផ្សាលទ្ធផល នៅពេលមានការប្រជែងដណ្តើម ឬការហិចហោចធនធានធម្មជាតិ។ ខណៈដែលរាជរដ្ឋាភិបាលបានបោះជំហានសំខាន់ៗក្នុងការលើកកម្ពស់សមធម៌យេនឌ័រក្នុងសិទ្ធិកាន់កាប់ដីធ្លី ស្ត្រីជនបទជាច្រើននៅតែខ្វះព័ត៌មានស្តីពីសិទ្ធិដីធ្លី និងដំណើរការធ្វើប័ណ្ណកម្មសិទ្ធិដីធ្លី ហើយជាញឹកញាប់ ភាពលំអៀងយេនឌ័រ រារាំងពួកគេមិនឱ្យអនុវត្តសិទ្ធិផ្ទាល់ខ្លួន។ ហេតុនេះហើយទើបជម្លោះពាក់ព័ន្ធដីធ្លីនៅតែកើតមានជាទូទៅ។

ការស្រាវជ្រាវបង្ហាញថា ការគ្រប់គ្រងធនធានធម្មជាតិដែលកាន់តែមានបរិយាបន្ន និងល្អប្រសើរ និងឆ្លើយតបនឹងយេនឌ័រ ដោយផ្អែកលើចំណេះដឹងរបស់ស្ត្រី និងការឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី អាចជួយឱ្យសហគមន៍កាន់តែមានសន្តិភាព និងសន្តិសុខ។

អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹតលេខ នស/រកត/១១២៣/២៣៨១ នៅថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០២៣។ អាជ្ញាធរនេះបំពេញមុខងារជាស្ថាប័នថ្នាក់ជាតិ ដើម្បីបំពេញបន្ថែមលើយន្តការដោះស្រាយវិវាទដែលមានស្រាប់។ អ.ដ.ក មានកាតព្វកិច្ចដោះស្រាយជម្លោះស៊ីវិល តាមរយៈការផ្សះផ្សា និងការសម្រុះសម្រួល នៅក្រៅប្រព័ន្ធតុលាការផ្លូវការ។ អាជ្ញាធរនេះមានគោលដៅកាត់បន្ថយថិរវេលានៃវិវាទដែលមិនទាន់បានដោះស្រាយ លើកកម្ពស់វប្បធម៌សន្តិភាព និងការយោគយល់គ្នា និងពង្រឹងបរិយាកាសប្រកបដោយសន្តិសុខផ្លូវចិត្ត និងផ្លូវកាយ។ ស្ត្រីកំពុងប្រើប្រាស់សេវាទាំងនេះ ដើម្បីដោះស្រាយវិវាទជាច្រើន រួមទាំងវិវាទដែលពាក់ព័ន្ធនឹងដីធ្លី ទ្រព្យសម្បត្តិ ប្រាក់កម្ចី បញ្ហាគ្រួសារ កេរមរតក ការងារ និងការខ្វែងគំនិតគ្នាក្នុងពាណិជ្ជកម្ម។

## ៨.ស្ត្រី និងសិនិទ្ធពលសង្គម

កម្ពុជាមានក្រុមជនជាតិដើមភាគតិចប្រមាណ ២២ ក្រុម បូករួមនឹងក្រុមជនជាតិភាគតិចសំខាន់ៗផ្សេងទៀត រួមមានខ្មែរមូស្លីម (ចាម) វៀតណាម និងខ្មែរកម្ពុជាក្រោម។ ស្ត្រី និងក្មេងស្រីជនជាតិដើមភាគតិច និងជនជាតិភាគតិចផ្សេងទៀតនៅកម្ពុជា ប្រឈមនឹងទម្រង់ជាក់លាក់នៃការរើសអើង ការទទួលបានឱកាសតិចតួច និងភាពងាយរងគ្រោះពីអំពើហិង្សា។ ពួកគេជាកម្មវត្ថុនៃផ្នត់គំនិតយេនឌ័រអវិជ្ជមានពីក្នុងសហគមន៍របស់ពួកគេផ្ទាល់ ដែលអាចបន្ទុចបង្អាក់ស្ត្រីមិនឱ្យបន្តការសិក្សា ធ្វើការងារ ឬបំពេញតួនាទីដឹកនាំ និងឃាត់ឃាំងស្ត្រីពីសង្គមទាំងមូល ដែលអាចធ្វើឱ្យស្ត្រីកាន់តែឯកោរបន្ថែមទៀត។

ទោះបីជារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបញ្ជាក់ពីសិទ្ធិសេរីភាពស្មើគ្នាក្នុងការដើរហើរ ប៉ុន្តែការសិក្សាថ្មីមួយរកឃើញថា ៦៤ ភាគរយនៃអ្នកឆ្លើយតបដែលជាស្ត្រីជនជាតិភាគតិច បានរាយការណ៍ថា ពួកគេមិនសូវមានសេរីភាពដើរហើរក្រៅផ្ទះ ដូចបុរសឡើយ។ ស្ត្រីចាមដែលបានសម្ភាសន៍បានគូសបញ្ជាក់ពីកង្វះលទ្ធភាពទទួលបានព័ត៌មានការចូលរួមតិចតួចក្នុងជីវិតសហគមន៍ និងកម្សោយនៃភាពជាតំណាងនៅក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាន។ ដោយសារគ្មានតំណាង និងការចូលរួមប្រកបដោយអត្ថន័យ ទើបពួកគេប្រឈមនឹងភាពឯកោ ហើយគ្មាននរណាគិតគូរពីតម្រូវការរបស់ពួកគេឡើយ។ កាលៈទេសៈទាំងនេះអាចរួមចំណែកបង្កើនភាពតានតឹង និងអសន្តិសុខនៅក្នុង និងរវាងសហគមន៍នានា។

ស្ត្រី និងក្មេងស្រីដែលមានពិការភាព ជួបប្រទះទម្រង់ដ៏ស្មុគស្មាញ និងប្រទាក់ក្រឡាគ្នាការរើសអើង។ ការរើសអើងបែបនេះមានភាពស្រួចស្រាវបំផុតក្នុងស្ថានភាពមានជម្លោះ គ្រោះមហន្តរាយ បរិបទក្រោយជម្លោះ ឬអន្តរកាល ដែលពួកគេ

[26] https://unidir.org/wp-content/uploads/2023/11/UNIDIR_ Factsheet_Gender_and_Diversity_in_the_APMBC.pdf

[27] Gender, Peace and Natural Resource Management, Research Brief, UN Women, December 2022

មិនត្រឹមតែរងផលប៉ះពាល់ខ្លាំងប៉ុណ្ណោះទេ ប៉ុន្តែការចូលរួមរបស់ពួកគេក៏ច្រើនតែត្រូវបានគេមើលរំលង ឬចាត់ទុកថាមិនសូវសំខាន់ផងដែរ។ តាមធម្មតា ការចូលរួមរបស់ពួកគេក្នុងដំណើរការដោះស្រាយជម្លោះ ការផ្តល់សេវា និងជំនួយយន្តការយុត្តិធម៌ និងដំណើរការអភិវឌ្ឍន៍ គឺមានកម្រិត។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០១៩-២០២៣ ផ្តល់ក្របខណ្ឌសកម្មភាពរឹងមាំក្នុងក្រសួង និងទីភ្នាក់ងារនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាសមភាពយេនឌ័រ ការជំរុញភាពជាអ្នកដឹកនាំរបស់ស្ត្រី និងការធានាបរិយាបន្នពិការភាព និងសេវាដែលមានគុណភាពសម្រាប់អ្នករួចរស់ពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

## គោលនយោបាយ ផែនការ និងយន្តការថ្នាក់ជាតិ ដែលពាក់ព័ន្ធនឹងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS)

រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតអាទិភាពលើការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីតាមរយៈរបៀបវារៈគោលនយោបាយជាតិ យុទ្ធសាស្ត្រ និងផែនការរបស់ខ្លួន មានជាអាទិ៍យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ (២០២៤-២០២៨) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ ឆ្នាំ ផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី (ផែនការនារីរតនៈទី ១-៦) ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW I-IV) ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NSP-CTIP I-IV) គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព (២០១០/២០២១) ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន (២០២៣) ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥។ សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មអ៊ីនធឺណិត (cybercrime) សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខតាម អ៊ីនធឺណិត និងសេចក្តីព្រាងច្បាប់ស្តីពីការការពារទិន្នន័យផ្ទាល់ខ្លួន សុទ្ធតែត្រូវរួមបញ្ចូលទស្សនៈយេនឌ័រ។

យេនឌ័រត្រូវបានបញ្ជ្រាបទៅក្នុងផែនការ និងគោលនយោបាយតាមវិស័យទាំងអស់ដូចជា ផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (NAP-DRR) (២០២៤-២០២៨) យុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព ២០២០-២០២៤ ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ២០១៨-២០៣០ ផែនការយុទ្ធសាស្ត្រស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ២០១៣-២០២៣ ផែនការសកម្មភាពស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ២០១៩-២០២៣ គោលនយោបាយនិងក្របខណ្ឌយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម (GMPSFA) ២០២២-២០២៦ ការបញ្ជ្រាបយេនឌ័រក្នុងផែនការសកម្មភាពមីន ២០២១-២០២៥ យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ២០១៦-២០២៣ ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ ២០១៩-២០២៣ (MoPTC) និងយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន និង សារគមនាគមន៍ (ICT) ២០២០ គោលនយោបាយបញ្ជ្រាបយេនឌ័ររបស់ក្រសួងការពារជាតិ (MoND) កម្មវិធីជាតិសម្រាប់រដ្ឋបាលសាធារណៈ ២០២១-២០៣០ និងយុទ្ធសាស្ត្រឆ្នាំ ២០២៤-២០២៨ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD)។ល។

យន្តការរដ្ឋាភិបាលសំខាន់ៗ ដែលលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងពាក់ព័ន្ធនឹងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ រួមមានក្រសួងកិច្ចការនារី (MoWA) ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (CNCW) ក្រុមការងារបច្ចេកទេសស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ (TWGG-GBV) ក្រុមការងារបញ្ជ្រាបយេនឌ័រតាមវិស័យ (GMAGs) គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (WCCCs) នៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NCCT) គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD) គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការអន្តរក្រសួងសម្រាប់ការអភិវឌ្ឍប្រជាជនតំបន់ខ្ពង់រាប និងអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក) ដែលទើបបង្កើតថ្មី។ល។

ក្រសួង និងស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល អង្គការយុវជន គ្រឹះស្ថានសិក្សា និងស្រាវជ្រាវ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត រួមទាំងវិស័យឯកជន និងអ្នកដឹកនាំសាសនា សុទ្ធតែមានតួនាទីក្នុងការពន្លឿនរបៀបវារៈ WPS នៅកម្ពុជា។ វិធីសាស្ត្រដែលមានផលជះខ្ពស់ត្រូវបានបង្កើតឡើងដើម្បីណែនាំដល់ការរៀបចំ និងការអនុវត្តផែនការសកម្មភាពជាតិស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS)។ ធាតុផ្សំ និងគោលការណ៍សំខាន់ៗ រួមមាន ក) ឆន្ទៈនយោបាយ ខ) ការរចនាដែលផ្តោតលើលទ្ធផល គ) យន្តការសម្របសម្រួល ឃ) ការចូលរួម

របស់សង្គមស៊ីវិល ង) ប្រព័ន្ធតាមដាន និងវាយតម្លៃ និង ច) ធនធានដែលបានបែងចែក។

ខាងក្រោមនេះជាបញ្ជីបណ្ដោះអាសន្ននៃស្ថាប័នពាក់ព័ន្ធដែលត្រូវចូលរួមក្នុងការរៀបចំ NAP-WPS នៅកម្ពុជា និងយន្តការសម្របសម្រួលថ្នាក់ជាតិ៖ក្រសួងកិច្ចការនារី(MoWA) ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MoFAIC) ក្រសួងការពារជាតិ (MoND) ក្រសួងមហាផ្ទៃ (MoI) ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MoPTC) ក្រសួងព័ត៌មាន (MI) ក្រសួងបរិស្ថាន (MoE) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) ក្រសួងសុខាភិបាល (MoH) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម (NPMEC) និងមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC)។ គួរមានការត្រួតពិនិត្យ និងតាមដានពីរដ្ឋសភា គណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (CNCW) និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។ អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ជាពិសេសអង្គការសង្គមស៊ីវិលស្ត្រី និងអង្គការ ឬបណ្ដាញយុវជន គួរតែជាផ្នែកសំខាន់មួយនៃ NAP-WPS និងយន្តការសម្របសម្រួល ខណៈដែលដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងគ្រឹះស្ថានសិក្សា ឬស្រាវជ្រាវ អាចផ្តល់ការគាំទ្រសំខាន់ក្នុងផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងប្រឹក្សាយោបល់។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍សម្រាប់ការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS) នៅកម្ពុជា

ខាងក្រោមនេះជាប្រធានបទដែលងាយនឹងត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំ NAP-WPS ដំបូង ស្របតាមអាទិភាពរបស់រដ្ឋាភិបាលកម្ពុជា ៖

- ស្ត្រី ការជួញដូរមនុស្ស និងបទល្មើសឆ្លងដែន
- ស្ត្រី សន្តិភាព និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត
- ស្ត្រីក្នុងវិស័យសន្តិសុខ ការទូតអន្តរជាតិ និងកងកម្លាំងរក្សាសន្តិភាព និង
- ស្ត្រី និងអាកាសធាតុ សន្តិភាព និងសន្តិសុខ។

ប្រធានបទសំខាន់ផ្សេងទៀត ដែលមានលើកឡើងក្នុងរបាយការណ៍នេះ ដែលអាចបញ្ចូលទៅក្នុង NAP-WPS ឬបញ្ជ្រាបទៅក្នុងផែនការសកម្មភាពជាតិផ្សេងទៀត រួមមាន ៖

- ស្ត្រីនិងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងជម្លោះ និងវិបត្តិមនុស្សធម៌
- របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS) និងសន្តិសុខសេដ្ឋកិច្ច ឱកាសប្រកបរបរចិញ្ចឹមជីវិត ធនធានធម្មជាតិ និងសន្តិសុខមនុស្ស
- ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី និង
- ស្ត្រី និងសនិទ្ធពលសង្គម។

គួរពិនិត្យឡើងវិញលម្អិតលើផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីកំណត់រកកម្លាំងផ្គួបជាមួយផែនការ និងយុទ្ធសាស្ត្រជាតិដែលមានស្រាប់ ហើយកម្ពុជាគួរផ្តោតលើផ្នែកសំខាន់ៗមួយចំនួន ដើម្បីបង្កើនផលជះ។ ផ្នែកសំខាន់ៗទាំងនេះអាចរួមមាន ១) ការបង្កើនការចូលរួម និងភាពជាអ្នកដឹកនាំ និងការធ្វើសេចក្តីសម្រេចរបស់ស្ត្រីនៅគ្រប់វិស័យ និងគ្រប់កម្រិតនៃរដ្ឋាភិបាល និងវិស័យសាធារណៈ ជាពិសេសក្នុងវិស័យសន្តិសុខ ដូចជា ការអនុវត្តច្បាប់ កងកម្លាំងប្រដាប់អាវុធ ប្រតិបត្តិការរក្សាសន្តិភាព អ.ស.ប និងយុត្តិធម៌ ២) ការពង្រឹងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងការដោះស្រាយបទល្មើសបច្ចេកវិទ្យា ដែលកំណត់គោលដៅលើស្ត្រី និងក្មេងស្រី រួមទាំងអក្ខរកម្មឌីជីថល ៣) ការពង្រឹងភាពពាក់ព័ន្ធរវាងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខជាមួយនឹងការចូលរួមរបស់ស្ត្រីក្នុងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការគ្រប់គ្រងធនធានធម្មជាតិ និង ៤) ការដោះស្រាយអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងវិបត្តិនានា និងក្នុងស្ថានភាពគ្រោះអាសន្ន ក៏ដូចជាការផ្សះផ្សា និងដំណោះស្រាយក្រោយជម្លោះ។

កម្ពុជាមានលក្ខណៈសម្បត្តិក្នុងការអនុវត្តវិធីសាស្ត្រចម្រុះមួយសម្រាប់ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាពនិងសន្តិសុខ (NAP-WPS) ព្រោះរបៀបវារៈ WPS ពាក់ព័ន្ធនឹងអាទិភាពជាតិរបស់កម្ពុជាស្តីពីសមភាពយេនឌ័រ និងការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការលើកកម្ពស់សន្តិភាព និងស្ថិរភាពនៅកម្រិតសហគមន៍ កម្រិតជាតិ កម្រិតតំបន់ និងកម្រិតសកល។

ដោយសារតែកម្ពុជាមានយន្តការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពជាច្រើន និងផែនការសកម្មភាពជាតិស្តីពីសមភាពយេនឌ័រ និងសិទ្ធិស្ត្រី ការសំខាន់គឺត្រូវស្ថាបនាពីលើយន្តការដែលមានស្រាប់ទាំងនេះសម្រាប់ការរៀបចំ NAP-WPS។ កម្ពុជាអាចរៀបចំ NAP-WPS ដើម្បីពង្រឹងក្របខណ្ឌដែលមានស្រាប់ ហើយក្នុងពេលជាមួយគ្នានោះ លើកឡើង

ពីគម្លាត និងតម្រូវការថ្មីៗនៅក្នុងទិដ្ឋភាពគោលនយោបាយបច្ចុប្បន្នរបស់ខ្លួនស្តីពីយេនឌ័រ និងសន្តិសុខ។ កត្តាជោគជ័យដ៏សំខាន់មួយ គឺការបញ្ជាក់ច្បាស់ពីតម្លៃបន្ថែមនៃ NAP-WPS ពាក់ព័ន្ធនឹងក្របខណ្ឌបញ្ជ្រាបយេនឌ័រដែលមានស្រាប់ និងផែនការសកម្មភាពជាតិ។

សកម្មភាពអាទិភាពសំខាន់ៗសម្រាប់ NAP-WPS របស់កម្ពុជា គួរតែតម្រឹមតម្រង់តាមលទ្ធផល និងធាតុចេញយុទ្ធសាស្ត្រនៃ ASEAN RPA-WPS ក្រោមសសរស្តម្ភទាំងបួននៃរបៀបវារៈ WPS គឺការការពារ ការចូលរួម ការទប់ស្កាត់ និងការសង្គ្រោះ និងស្តារឡើងវិញ។ ខាងក្រោមនេះជាការណែនាំមួយចំនួន ដែលបន្សីគ្នានឹង ASEAN RPA-WPS។

## សសរស្តម្ភនៃការការពារ

**លទ្ធផលយុទ្ធសាស្ត្រទី ១ ៖** ការការពារសិទ្ធិស្ត្រី ស្ត្រីវ័យក្មេង និងក្មេងស្រី រួមទាំងក្រុមអ្នកទទួលបានឱកាសតិចតួច តាមរយៈគោលនយោបាយ ការអនុវត្ត និងស្ថាប័នដែលទាក់ទងនឹងសន្តិភាព និងសន្តិសុខ រួមទាំងការការពារពីគ្រប់ទម្រង់នៃអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ (SGBV) នៅក្នុងស្ថានភាពជម្លោះ ក្រោយជម្លោះ ការកសាងសន្តិភាព និងមនុស្សធម៌។

### សកម្មភាពដែលស្នើឡើង ៖

- ធានាថា ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រនៅក្នុងវិបត្តិ និងស្ថានភាពគ្រោះអាសន្ន រួមទាំងជម្លោះ និងគ្រោះមហន្តរាយពីមុន បច្ចុប្បន្ន និងអាចកើតឡើងនាពេលអនាគត អាចទទួលបានយន្តការច្បាប់ យន្តការយុត្តិធម៌ យន្តការកិច្ចគាំពារសង្គម និងយន្តការយុត្តិធម៌អន្តរកាល។
- ពង្រឹងសមត្ថភាពរបស់អ្នកឆ្លើយតបជួរមុខក្នុងវិស័យសន្តិភាព និងសន្តិសុខ ដើម្បីទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រស្របតាមអាទិភាពក្នុង NAPVAW និងយន្តការសម្របសម្រួលពហុវិស័យ។
- ពង្រីកឱកាសសម្រាប់អង្គការសង្គមស៊ីវិល និងអង្គការស្ត្រីក្នុងការសហការជាមួយអ្នកពាក់ព័ន្ធក្នុងរដ្ឋាភិបាលលើការគ្រប់គ្រង និងអនុវត្តបណ្តាញបញ្ជូនសម្រាប់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ ជាពិសេសក្នុងស្ថានភាពជម្លោះ និងគ្រោះអាសន្ន។
- លើកកម្ពស់វិធានការសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីដោះស្រាយបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត និងការគំរាមកំហែងចំពោះសុវត្ថិភាព និងសន្តិសុខរបស់ស្ត្រី ដែលសុទ្ធសឹងធ្វើឱ្យបាត់ស្ថិរភាពក្នុងសហគមន៍។
- ធានាការការពារ និងការគាំទ្រដល់ជីវភាពរបស់ស្ត្រី ជាពិសេសក្នុងពេលមានវិបត្តិ និងគ្រោះមហន្តរាយ ដូចជា តាមរយៈការដោះស្រាយតម្រូវការការងារថៃទាំដែលមិនទទួលបានប្រាក់ឈ្នួលរបស់ស្ត្រី ដែលជាឧបសគ្គរារាំងការចូលរួមក្នុងសេដ្ឋកិច្ច និងសន្តិសុខរបស់ស្ត្រី។
- វិះរកវិធីរួមបញ្ចូលរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងកម្មវិធីសិក្សាសម្រាប់ការអប់រំនិងបណ្តុះបណ្តាលដើម្បីកសាងការយល់ដឹង និងបង្កើនចំណេះដឹងស្តីពីគោលបំណងនៃសន្តិភាព និងសន្តិសុខ នៅក្នុងគ្រួសារ សហគមន៍ និងកម្មវិធីបណ្តុះបណ្តាល។
- បង្កើនការបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យអភិបាលកិច្ច និងសន្តិសុខរួមទាំងនគរបាលជាតិ វិស័យការពារជាតិ កងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងសកម្មភាពមីន និងកសាងសមត្ថភាពរបស់ GMAG ក្នុងការអនុវត្ត GMAP។
- កសាងសមត្ថភាពរបស់កងកម្លាំងនៃវិស័យសន្តិសុខ ដូចជា នគរបាលជាតិ កងកម្លាំងប្រដាប់អាវុធ និងកងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ដើម្បីការពារសិទ្ធិស្ត្រីរួមទាំងសិទ្ធិស្ត្រីមានហានិភ័យ ឬការព្រួយបារម្ភជាក់លាក់ ដូចជាស្ត្រីជនជាតិភាគតិច និងស្ត្រីជនជាតិដើមភាគតិច ស្ត្រីចំណាកស្រុក ស្ត្រីមានពិការភាព និងស្ត្រីចាស់ជរា ដើម្បីធានាសុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់ពួកគេ។

## សសរស្តម្ភនៃការចូលរួម

**លទ្ធផលយុទ្ធសាស្ត្រទី ២ ៖** ការចូលរួមពេញលេញប្រកបដោយអត្ថន័យ និងដោយស្មើភាពរបស់ស្ត្រី នៅក្នុងស្ថាប័ន អង្គការ និងដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលទាក់ទងនឹងសន្តិភាព និងសន្តិសុខ រួមទាំងនៅក្នុងតំណែងដឹកនាំ។

### សកម្មភាពដែលស្នើឡើង ៖

- បង្កើនការចូលរួម និងការរីកចម្រើនរបស់ស្ត្រីឆ្ពោះទៅរកតួនាទីដឹកនាំ ជាពិសេសក្នុងវិស័យសន្តិភាព និងសន្តិសុខតាមរយៈការបង្កើតបរិយាកាសការងារដែលអំណោយផល និងការអនុវត្តកូតាបណ្តោះអាសន្ន ដើម្បីបំពេញចំណុចដៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៥ និងទី ១៦ ស្របតាមអនុសាសន៍ ៣១ក និង ៣១ខ ឆ្នាំ ២០១៩ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ចំពោះកម្ពុជា។
- អនុវត្តវគ្គបណ្តុះបណ្តាលកាតព្វកិច្ចស្តីពីសមភាពយេនឌ័រសម្រាប់បុរស និងអ្នកដឹកនាំជាបុរសក្នុងវិស័យនានា ខណៈពេលដែលជំរុញសារៈសំខាន់នៃការគាំទ្ររបស់អ្នកដឹកនាំជាបុរសចំពោះការដឹកនាំរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត គំនិត

ផ្តួចផ្តើមកសាងសន្តិភាព និងការសម្រុះសម្រួល ការដោះស្រាយ និងការទប់ស្កាត់ជម្លោះ ។

• ពង្រឹងតួនាទី និងការចូលរួមរបស់ស្ត្រី និងស្ត្រីវ័យក្មេងនៅកម្រិតថ្នាក់ក្រោមជាតិ សហគមន៍ និងមូលដ្ឋានក្នុងការលើកកម្ពស់ សិទិទ្ធពលសង្គម ការទប់ស្កាត់ជម្លោះ ដំណោះស្រាយ និងការកសាងសន្តិភាព ក្នុង និងរវាងសហគមន៍នានា។

• គាំទ្រការចូលរួមរបស់អង្គការសង្គមស៊ីវិលស្ត្រី និងអង្គការយុវជន រួមទាំងដោយបុរស និងស្ត្រីវ័យក្មេងក្នុងការពិគ្រោះយោបល់ រៀបចំផែនការ អនុវត្ត និងវាយតម្លៃគំនិតផ្តួចផ្តើមស្តីពីសន្តិភាព សន្តិសុខ និងមនុស្សធម៌ រួមទាំងយន្តការស្ថាប័នដើម្បីឱ្យមានធាតុចូលសង្គមស៊ីវិល និងយុវជន។

• ចាប់ដៃគូសហការជាមួយប្រព័ន្ធផ្សព្វផ្សាយ ស្ថាប័នសិក្សាស្រាវជ្រាវ អង្គការជំនឿ និងវិស័យឯកជន ដើម្បីបង្កើនការចូលរួម និងការដឹកនាំរបស់ស្ត្រីក្នុងកិច្ចខិតខំប្រឹងប្រែងពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខនៅថ្នាក់ជាតិ និងបង្កើនភាពលេចធ្លោរបស់ស្ត្រីគំរូនៅក្នុងវិស័យទាំងនេះ។

• ពិចារណាពីកម្មវិធី និងគំនិតផ្តួចផ្តើម ដែលកសាងសមត្ថភាព និងបណ្តុះបណ្តាលស្ត្រីឱ្យក្លាយជាអ្នកផ្សះផ្សា និងអ្នកចរចាក្នុងផ្នែកមូលបទផ្សេងៗដែលពាក់ព័ន្ធនឹងការកសាងសន្តិភាព ការទប់ស្កាត់ជម្លោះ ដំណោះស្រាយ និងការស្តារឡើងវិញ នៅកម្រិតតំបន់ និងកម្រិតប្រទេស។

• បន្តលើកកម្ពស់ និងបង្កើនលទ្ធភាពទទួលបានការបណ្តុះបណ្តាលស្តីពីអក្ខរកម្មឌីជីថលសន្តិសុខតាមប្រព័ន្ធបច្ចេកវិទ្យា និងបច្ចេកទេសសម្រាប់អ្នកដឹកនាំជាស្ត្រី និងស្ត្រីក្នុងតួនាទីអនុវត្តច្បាប់ ដើម្បីឱ្យស្ត្រីអាចអនុវត្តជំនាញ និងទស្សនៈវិស័យរបស់ខ្លួនទៅក្នុងការកំណត់រកដំណោះស្រាយដែលមានប្រសិទ្ធភាព។

• ពង្រឹងការដឹកនាំរបស់ស្ត្រី និងការចូលរួមប្រកបដោយអត្ថន័យក្នុងច្បាប់ ឬគោលនយោបាយដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យា ការធ្វើសេចក្តីសម្រេចចិត្ត និងការពង្រឹងការអនុវត្តច្បាប់ជាពិសេសក្នុងការអភិវឌ្ឍ និងការឆ្លើយតបនឹងការគំរាមកំហែងដោយប្រព័ន្ធបច្ចេកវិទ្យា ស្របតាមគោលការណ៍ WPS។

• កំណត់រកបទដ្ឋាន និងការអនុវត្តដែលអាចផ្លាស់ប្តូរ ឬអនុវត្តបាន ដើម្បីបង្កើនភាពជាតំណាងរបស់ស្ត្រី ជាពិសេសក្នុងតួនាទីដឹកនាំ និងដើម្បីបង្កើនតុល្យភាពយេនឌ័រក្នុងវិស័យសន្តិភាព និងសន្តិសុខ និងបន្តលើកកម្ពស់បរិយាបន្នពេញលេញសម្រាប់ស្ត្រី (រួមទាំងស្ត្រីមកពីក្រុមជួបការលំបាក និងក្រុមជនជាតិភាគតិច)។

## សសរស្តម្ភនៃការទប់ស្កាត់

**លទ្ធផលយុទ្ធសាស្ត្រទី ៣ ៖** អង្គភាពតាមវិស័យស្ថាប័ន និងរដ្ឋសមាជិកអាស៊ានរួមចំណែកយ៉ាងសកម្មដល់ការទប់ស្កាត់ជម្លោះជាសកល នៅថ្នាក់តំបន់ និង ថ្នាក់ជាតិ ក៏ដូចជាការទប់ស្កាត់អំពើហិង្សា គ្រោះមហន្តរាយ និងការគំរាមកំហែងផ្សេងទៀតចំពោះសន្តិភាព និងសន្តិសុខ ដោយមានគោលការណ៍នៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ជាស្នូលនៃសកម្មភាពរបស់ពួកគេ។

**សកម្មភាពដែលស្នើឡើង ៖**

• ពង្រឹងកិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងតំបន់អាស៊ានស្តីពីការបញ្ជ្រាបយេនឌ័រ និងការចូលរួមរបស់ស្ត្រីក្នុងការកសាងសន្តិភាព និងការទប់ស្កាត់ជម្លោះ រួមទាំងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការឆ្លើយតបគ្រោះអាសន្ន ការគំរាមកំហែងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងហានិភ័យថ្មីៗផ្សេងទៀត។

• ធ្វើការស្រាវជ្រាវផ្អែកលើភស្តុតាងដើម្បីរិះរកវិធីធ្វើយ៉ាងណាឱ្យស្ត្រី បុរស និងយុវជន រួមទាំងអ្នកមកពីសហគមន៍ជួបការលំបាកបានចូលរួម ឬអាចទទួលបានកាគាំទ្រឱ្យចូលរួមក្នុងការកាត់បន្ថយអំពើហិង្សា ជម្លោះ អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ និងការគំរាមកំហែងបរិស្ថាន ដូចជាកម្សោយក្នុងការគ្រប់គ្រងធនធានធម្មជាតិ។

• កសាងភាពជាដៃគូតាមរយៈយន្តការដែលមានការសម្របសម្រួលដែលរួមបញ្ចូលស្ត្រីជាអ្នកផ្សះផ្សា និងស្ត្រីជាអ្នកកសាងសន្តិភាព អង្គការសង្គមស៊ីវិលរបស់ស្ត្រី អង្គការយុវជន និងអង្គការជំនឿ ដើម្បីធានាថា គោលនយោបាយស្តីពីការ ការទប់ស្កាត់ជម្លោះ ឆ្លុះបញ្ចាំងពីតម្រូវការ និងទស្សនៈវិស័យរបស់ស្ត្រី។

• កំណត់រក និងដោះស្រាយតម្រូវការកសាងសមត្ថភាពរបស់អ្នកឆ្លើយតបបឋម អ្នកអនុវត្តន៍ និងអ្នកបង្កើតគោលនយោបាយ ដើម្បីធានាថា ពួកគេអាចអនុវត្តអន្តរាគមន៍ដែលបន្សុីគ្នានឹង WPS ដើម្បីទប់ស្កាត់ការរីករាលដាល និងកាត់បន្ថយការបង្កគ្រោះថ្នាក់។

• ស្របតាមការប្តេជ្ញាចិត្តចំពោះអនុសញ្ញា CEDAW និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (CERD) និងដើម្បីទប់ស្កាត់ការប្រើប្រាស់ពាក្យសម្តីស្អប់ខ្ពើម ដែលអាចបង្កឱ្យមានភាពតានតឹង បន្តលើកកម្ពស់ការយល់ដឹង និងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ និងសាធារណជនស្តីពីការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និង ការរើសអើងពូជសាសន៍នៅក្នុងប្រព័ន្ធយុត្តិធម៌ រួមទាំងយន្តការបណ្តឹង។

• ធ្វើយុទ្ធនាការកសាងការយល់ដឹងជាសាធារណៈ និងអន្តរាគមន៍ចំគោលដៅ ដើម្បីទប់ស្កាត់ការគំរាមកំហែងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត

ជាពិសេសបទល្មើសដែលបង្កផលប៉ះពាល់លើស្ត្រី ក្មេងស្រី និងសហគមន៍ងាយរងគ្រោះ ហើយក្នុងពេលជាមួយគ្នានោះ បង្កើនអក្ខរកម្មឌីជីថល។

• ពង្រឹងសមត្ថភាពក្នុងការតាមដានរក និងទប់ស្កាត់ផលប៉ះពាល់ដែលពាក់ព័ន្ធនឹងយេនឌ័រ ដោយសារការគំរាមកំហែងពីសន្តិសុខក្នុងប្រព័ន្ធឌីជីថល គ្រោះថ្នាក់ និងបទល្មើសដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។

**លទ្ធផលយុទ្ធសាស្ត្រទី ៤ ៖** ស្ថាប័ន យន្តការ និងដំណើរការសន្តិភាព និងសន្តិសុខ ទទួលបានជោគជ័យក្នុងការបង្ការទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ។

**សកម្មភាពដែលស្នើឡើង ៖**

• ទាញយកប្រយោជន៍ពីមេរៀនដែលទទួលបានពីជំងឺរាតត្បាតជំងឺកូវីដ-១៩ និងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងអំពើហិង្សា ទាក់ទងនឹងយេនឌ័រ ដើម្បីធានាថា ផែនការឆ្លើយតបនឹងគ្រាអាសន្ន និងការត្រៀមបង្ការគ្រោះមហន្តរាយ រួមបញ្ចូលទាំងស្តង់ដារនៃការទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងពេលមានគ្រាអាសន្ន។

• ធានាថា យុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់វិស័យសុខាភិបាល ឆ្នាំ២០២០-២០២៤ គាំទ្រតម្រូវការរបស់ស្ត្រី និងក្មេងស្រី ដោយរួមបញ្ចូលយ៉ាងពេញលេញនូវក្រុមការងារអន្តរទីភ្នាក់ងារ (IAWG) ស្តីពីកញ្ចប់សេវាបឋមអប្បបរមា (MISP) សុខភាពបន្តពូជក្នុងគ្រាវិបត្តិ។

• ស្របតាមអនុសាសន៍ទូទៅលេខ ៣៧ (២០១៨) នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ធ្វើស្ថាប័ននូបនីយកម្មភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងការទប់ស្កាត់គ្រោះមហន្តរាយ និងការត្រៀមបង្ការ រួមទាំងការអភិវឌ្ឍ និងការផ្សព្វផ្សាយប្រព័ន្ធជូនដំណឹងជាមុន វិធានការឆ្លើយតប និងស្តារឡើងវិញ និងការកាត់បន្ថយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ ធានាថា ការប្រកាសជូនដំណឹងជាមុន ត្រូវបានផ្តល់ជូនតាមរបៀបដែល បំពេញតម្រូវការរបស់ក្រុមស្ត្រីគ្រប់លក្ខណៈចម្រុះ ហើយអ្នកឆ្លើយតបបឋមមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបាន ទិន្នន័យបែងចែកតាមភេទ និងការកសាងសមត្ថភាពដើម្បីធានាថាវិស័យសន្តិភាព និងសន្តិសុខ អនុវត្តកិច្ចអន្តរាគមន៍នានា ដើម្បីទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងពេលឆ្លើយតបនឹងគ្រោះអាសន្ន។

• ដាក់បញ្ចូលលទ្ធផលរកឃើញ និងអនុសាសន៍នៃការសិក្សាឆ្នាំ២០២៣ របស់ RCAF ស្តីពី MOWIP ទៅក្នុងសកម្មភាពអាទិភាពនៃផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខសម្រាប់ UN PKO និងផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវលទ្ធផលរកឃើញដែលអាចអនុវត្តបានចំពោះស្ត្រីនៅក្នុងការអនុវត្តច្បាប់។

## សសរស្តម្ភនៃការសង្គ្រោះ និងស្តារឡើងវិញ

**លទ្ធផលយុទ្ធសាស្ត្រទី ៥ ៖** តម្រូវការរបស់ស្ត្រី និងក្មេងស្រី ត្រូវបានបំពេញនៅក្នុងដំណើរការសង្គ្រោះ និងស្តារឡើងវិញនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ហើយស្ត្រីមានការចូលរួមដោយស្មើភាព និងប្រកបដោយអត្ថន័យនៅក្នុងដំណើរការទាំងនេះ រួមទាំងនៅក្នុងតំណែងធ្វើសេចក្តីសម្រេចចិត្ត និងភាពជាអ្នកដឹកនាំ។

**សកម្មភាពដែលស្នើឡើង ៖**

• ធានាថា គោលនយោបាយ និងវិធានការអនុវត្តមានលក្ខណៈឆ្លើយតបនឹងយេនឌ័រដោយផ្អែកតាមអាទិភាពរបស់ស្ត្រីនៅដំណាក់កាលសង្គ្រោះ និងស្តារឡើងវិញ រួមទាំងតាមរយៈការពិគ្រោះយោបល់ជាមួយស្ត្រីក្នុងសហគមន៍ដែលមានតម្រូវការ និងសមត្ថភាពផ្សេងៗ។ ប្រមូល និងវិភាគទិន្នន័យបែងចែកតាមភេទដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់គោលនយោបាយ និង អន្តរាគមន៍ផ្អែកលើភស្តុតាង។

• ពង្រឹងការចូលរួម និងការដឹកនាំរបស់ស្ត្រីក្នុងយន្តការសម្របសម្រួលពហុវិស័យ បណ្តាញ និងភាពជាដៃគូនៅកម្រិតអន្តរជាតិ និងកម្រិតតំបន់ ដើម្បីធានាថារបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានដាក់បញ្ចូលក្នុងកិច្ចខិតខំប្រឹងប្រែងសង្គ្រោះ និងស្តារឡើងវិញ ដើម្បីលើកកម្ពស់សិនិទ្ធភាពសង្គម និងការចូលរួមរបស់អ្នកពាក់ព័ន្ធប្រកបដោយបរិយាបន្ន។

• លើកកម្ពស់ និងអនុវត្តកម្មវិធីដែលលើកឡើងពីសិទ្ធិសេដ្ឋកិច្ច និងតម្រូវការរបស់ស្ត្រី រួមទាំងស្ត្រីនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីបង្កើនសន្តិសុខ និងសុវត្ថិភាពរបស់ស្ត្រី គ្រួសារ និងជីវភាពរបស់ពួកគាត់ ជាពិសេសពាក់ព័ន្ធនឹងលទ្ធភាពទទួលបានឱកាសរកប្រាក់ចំណូលក្នុងពេលសង្គ្រោះ និងស្តារឡើងវិញ។

• ស្របតាមអនុសាសន៍១៣កឆ្នាំ២០១៩នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទចំពោះកម្ពុជា បន្តកសាងលើសមិទ្ធផលរបស់កម្ពុជា តាមរយៈអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីជំរុញដំណើរការយុត្តិធម៌ និងការផ្សះផ្សាដែលពាក់ព័ន្ធនឹងជម្លោះនាពេលកន្លងមក រួមទាំងយន្តការគាំទ្រជនរងគ្រោះក្នុងការខិតខំដោះស្រាយផលប៉ះពាល់នៃអំពើប្រល័យពូជសាសន៍ អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ និងការប៉ះទង្គិចផ្លូវចិត្តអន្តរជំនាន់ដែលបង្កផលប៉ះពាល់លើស្ត្រី គ្រួសារ និងសហគមន៍។ នេះរួមបញ្ចូលទាំងគំនិតផ្តួចផ្តើមក្នុងមូលដ្ឋាន ដូចជា កិច្ចសន្ទនាសហគមន៍ស្តីពីការកសាងសន្តិភាព និងការផ្លាស់ប្តូរជម្លោះ

កិច្ចសន្ទនាអន្តរជំនាន់រវាងអ្នករស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ និងកម្មវិធីអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងកាន់តែស៊ីជម្រៅអំពីជម្លោះនាពេលកន្លងមក សម្រាប់ជាមូលដ្ឋាននៃការទប់ស្កាត់ជម្លោះនាពេលអនាគត។

- បង្កើតកម្មវិធីដែលឆ្លើយតបនឹងយេនឌ័រ ដើម្បីផ្តល់ការគាំទ្រសមស្របផ្នែកចិត្តសង្គមដល់ជនរងគ្រោះនៃជម្លោះ និងអំពើហិង្សា ដើម្បីដោះស្រាយការប៉ះទង្គិចផ្លូវចិត្ត រួមទាំងផលប៉ះពាល់អន្តរជំនាន់នៃអំពើហិង្សាលើស្ត្រី និងគ្រួសារ តាមរយៈវិធីសាស្ត្រដោះស្រាយជម្លោះ និងកសាងសន្តិភាព។

## ជំហានបន្ទាប់

- បង្កើតយន្តការសម្របសម្រួលនៅពេលចាប់ផ្តើមដំណើរការរៀបចំ និងព្រាងផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីធានាភាពម្ចាស់ការរឹងមាំ និងការប្តេជ្ញាចិត្តផ្នែកនយោបាយក្នុងការអនុវត្ត។ លក្ខខណ្ឌយោងសម្រាប់យន្តការសម្របសម្រួល គួរបញ្ជាក់ច្បាស់អំពីក្រសួង/ស្ថាប័នដឹកនាំ និងក្រសួង/ស្ថាប័នពាក់ព័ន្ធដែលចូលរួម នៅកម្ពុជា។
- ស្របតាមឧត្តមានុវត្តជាសកល យន្តការសម្របសម្រួលសម្រាប់ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា គួរតែដំណើរការទាំងនៅកម្រិតនយោបាយ (ជាន់ខ្ពស់) និងកម្រិតបច្ចេកទេស ក្រោមការត្រួតពិនិត្យពីកម្រិតខ្ពស់។ យន្តការនេះគួរប្រើប្រាស់ក្រុមការងារបញ្ជ្រាបយេនឌ័រតាមក្រសួងស្ថាប័ន (GMAGs) និងក្រុមការងារបច្ចេកទេសយេនឌ័រ ដែលចូលរួមដោយអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល និងវិស័យឯកជន។
- អនុវត្តការលើកកម្ពស់ការយល់ដឹងអំពីរបៀបវារៈ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ រួមទាំងផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងភាពពាក់ព័ន្ធរបស់វាទៅនឹងបរិបទកម្ពុជា ជាមួយស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ស្ថាប័នសិក្សាធិការ និងស្រាវជ្រាវ ប្រព័ន្ធផ្សព្វផ្សាយ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ក៏ដូចជា សង្កត់ធ្ងន់លើបញ្ហាសន្តិសុខក្រៅពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- រៀបចំក្របខណ្ឌពេលវេលាសម្រាប់ការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា ស្របតាមកញ្ចប់ឧបករណ៍ស្តីពីការធ្វើមូលដ្ឋានីយកម្មផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ នេះគួររួមបញ្ចូលយន្តការសម្របសម្រួល លក្ខខណ្ឌយោង និងការចូលរួមរបស់ភាគីពាក់ព័ន្ធ និងដំណើរការប្រកបដោយបរិយាបន្ន។

# ទិដ្ឋភាពទូទៅ

ចាប់តាំងពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ ១៩៩១ មក រាជរដ្ឋាភិបាលកម្ពុជាបានគ្រប់គ្រងដំណាក់កាលក្រោយជម្លោះបានយ៉ាងជោគជ័យ បន្ទាប់ពីរយៈពេលជាច្រើនឆ្នាំនៃជម្លោះ និងការបំផ្លិចបំផ្លាញក្រោមរបបខ្មែរក្រហម តាមរយៈការផ្តោតអាទិភាពលើការផ្សះផ្សាជាតិ ការកសាងសន្តិភាព និងការកសាងឡើងវិញ។

កម្ពុជាមានកំណើនសេដ្ឋកិច្ចរឹងមាំក្នុងរយៈពេលពីរទសវត្សរ៍មុនពេលមានការផ្ទុះឡើងនៃជំងឺកូវីដ-១៩ នៅឆ្នាំ២០២០។ កំណើនសេដ្ឋកិច្ចកម្ពុជា បានកើនឡើងក្នុងអត្រាមធ្យមប្រចាំឆ្នាំ ៧,៦ ភាគរយ រវាងឆ្នាំ ១៩៩៥ និង ២០១៩ ហើយអត្រាភាពក្រីក្រ បានធ្លាក់មកត្រឹម ១៧,៨ ភាគរយ នៅឆ្នាំ ២០១៩ ដែលធ្វើឱ្យប្រទេសកម្ពុជាស្ថិតក្នុងស្ថានភាពរឹងមាំជាងមុនបើធៀបនឹងពីរទសវត្សរ៍មុន។ បន្ទាប់ពីសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ ២០១៥ កម្ពុជាបានកំណត់គោលដៅក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។[28] ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០ មានលក្ខណៈបន្សីយ៉ាងទូលំទូលាយជាមួយនឹង "P ទាំង ៥ (5 P's")" នៃរបៀបវារៈឆ្នាំ២០៣០ តាមរយៈការសម្រេចបាននូវសន្តិភាព វិបុលភាព ភពផែនដី និងភាពជាដៃគូ ក៏ដូចជាការប្រកាន់ខ្ជាប់សិទ្ធិមនុស្ស សេចក្តីថ្លៃថ្នូរ និងសមភាពរបស់ប្រជាជន។[29] សមភាពយេនឌ័រ គឺជាអាទិភាពសំខាន់មួយនៃអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចមានចែងក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការជាតិរបស់ខ្លួន។

កម្ពុជាបានក្លាយជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) នៅឆ្នាំ ១៩៩៩ ដែលបង្ហាញពីការប្តេជ្ញាចិត្តរបស់ព្រះរាជាណាចក្រកម្ពុជាចំពោះកិច្ចសហប្រតិបត្តិក្នុងតំបន់លើផ្នែកពាណិជ្ជកម្ម ចល័តភាពនៃកម្លាំងពលកម្ម សន្តិភាព និងសន្តិសុខ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ កម្ពុជាបានដើរតួនាទីនាំមុខក្នុងការជំរុញរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ (WPS) នៅក្នុងអាស៊ាន និងបានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះរបៀបវារៈនេះ ទាំងនៅនៅថ្នាក់តំបន់ និងអន្តរជាតិ រួមទាំងតាមរយៈការបង្កើនការបញ្ជូនកងកម្លាំងស្ត្រីទៅក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។ កម្ពុជាក៏បានធ្វើការប្តេជ្ញាចិត្ត និងខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការជំរុញសមភាពយេនឌ័រនៅក្នុងប្រទេសផងដែរ។ បច្ចុប្បន្ន ការបញ្ជ្រាបយេនឌ័រត្រូវបានដាក់បញ្ចូលទៅក្នុងស្ទើរតែគ្រប់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការជាតិ។ សកម្មភាពរបស់រដ្ឋាភិបាលក៏បានផ្តោតអាទិភាពផងដែរលើការបង្កើនការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុង វិស័យនានា និងការលុបបំបាត់អំពើហិង្សាលើស្ត្រី។

ក្នុងបរិបទនេះ ការរៀបចំផែនការសកម្មភាពជាតិស្តីពីរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS) ដែលស្របទៅនឹងផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ASEAN RPA-WPS) គឺជាឱកាសសម្រាប់កម្ពុជាក្នុងការពង្រឹងការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងប្រទេស និងដើម្បីពង្រឹងបន្ថែមនូវការចូលរួមចំណែករបស់ខ្លួនដល់សន្តិភាព និងសន្តិសុខនៅកម្រិតជាតិ តំបន់ និងអន្តរជាតិ។

# គោលបំណងនៃរបាយការណ៍

គោលបំណងចម្បងនៃរបាយការណ៍វិភាគស្ថានភាពនេះរួមមាន ៖

- ពិនិត្យមើលបញ្ហាសន្តិសុខប្រពៃណី និងមិនមែនប្រពៃណី ព្រមទាំងបញ្ហាសន្តិសុខដែលកំពុងលេចឡើងថ្មីនៅកម្ពុជាក្នុងបរិបទនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ
- ពិនិត្យមើលបញ្ហាសន្តិសុខប្រពៃណី និងមិនមែនប្រពៃណី ព្រមទាំងបញ្ហាសន្តិសុខដែលកំពុងលេចឡើងថ្មីនៅកម្ពុជាក្នុងបរិបទនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ
- រំលេចមេរៀន និងការអនុវត្តល្អៗពីកម្ពុជា និងប្រទេសផ្សេងទៀតក្នុងវិស័យសន្តិភាព និងសន្តិសុខ និង
- ផ្តល់នូវការណែនាំសម្រាប់ជំហានបន្ទាប់ក្នុងការរៀបចំផែនការសកម្មភាពជាតិស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS) នៅកម្ពុជា ដែលស្របទៅនឹងផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

[28] https://www.worldbank.org/en/country/cambodia
[29] រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១ (២០២៤-២០២៨) សម្រាប់កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព៖ ការកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅរកការសម្រេចបាននូវចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ រាជធានីភ្នំពេញ ខែសីហា ឆ្នាំ២០២៣

របាយការណ៍នេះ មានគោលបំណងផ្តល់នូវភស្តុតាងជាក់លាក់ និងបង្ហាញពីតម្លៃបន្ថែមនៃរបៀបវារៈ ស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា។ របាយការណ៍នេះអាចប្រើប្រាស់ជាការស្វែងរកការគាំទ្រមតិ និងជាឯកសារយោង សម្រាប់ក្រសួងកិច្ចការនារី (MoWA) ក្នុងការកៀរគរការគាំទ្រផ្នែកនយោបាយ ធានាការចូលរួម និងជំរុញភាពជាម្ចាស់ពីក្រសួង និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។ ឯកសារនេះក៏នឹងជួយបង្កើនការយល់ដឹង និងកសាងការគាំទ្រសម្រាប់របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងចំណោមទីភ្នាក់ងារអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល (NGOs) អង្គការសង្គមស៊ីវិល (CSOs) អង្គការដឹកនាំដោយស្ត្រី អង្គការ និងបណ្តាញយុវជន សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងទៀត រួមទាំងវិស័យឯកជនផងដែរ។

# រចនាសម្ព័ន្ធនៃរបាយការណ៍

## ផ្នែកទី ១៖ សេចក្តីផ្តើម និងសាវតារ

ផ្នែកនេះ ពិនិត្យមើលក្របខណ្ឌសកល និងក្របខណ្ឌតំបន់ស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ រួមទាំងតួនាទីរបស់ កម្ពុជាក្នុងការបង្កើតផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ផ្នែកនេះក៏ពិពណ៌នាអំពីអភិក្រម និងវិធីសាស្ត្រដែលគេប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍វិភាគស្ថានភាពផងដែរ។

## ផ្នែកទី ២៖ បញ្ហាស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា

ផ្នែកនេះកំណត់រកបញ្ហាសន្តិសុខប្រពៃណី និងបញ្ហាសន្តិសុខមិនមែនប្រពៃណី ព្រមទាំងបញ្ហាសន្តិសុខកំពុងលេចឡើងថ្មី ដែលប៉ះពាល់ដល់ស្ត្រីនៅកម្ពុជា។ ផ្នែកនេះក៏ពណ៌នាអំពីគោលនយោបាយ ផែនការ និងយន្តការមានស្រាប់ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា កំណត់រកអ្នកដែលអាចជាអ្នកពាក់ព័ន្ធ បង្ហាញពីការអនុវត្តល្អៗ និងមេរៀនដែលអាចជាមូលដ្ឋានសម្រាប់ការធ្វើសកម្មភាពបន្ថែមទៀតផងដែរ។

## ផ្នែកទី ៣៖ កាលានុវត្តភាព បញ្ហាប្រឈម និងមេរៀនដែលទទួលបាន

ផ្នែកនេះរៀបរាប់អំពីកាលានុវត្តភាព និងបញ្ហាប្រឈមសម្រាប់ការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា ក៏ដូចជារំលេចមេរៀនមួយចំនួនដែលទទួលបានពីបទពិសោធន៍របស់ប្រទេសផ្សេងទៀតក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាពជាតិ ជាពិសេសពាក់ព័ន្ធនឹងយន្តការសម្របសម្រួល។

## ផ្នែកទី ៤៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ផ្នែកនេះបង្ហាញពីសេចក្តីសន្និដ្ឋានពីលទ្ធផលរកឃើញសំខាន់ៗ និងផ្តល់បណ្តុំអនុសាសន៍ ដើម្បីណែនាំដល់ការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា ដែលស្របទៅនឹងផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ASEAN RPA-WPS) និងកញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំស្តីពីការធ្វើមូលដ្ឋានីយកម្មសម្រាប់ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

# ផ្នែកទី ១

# សេចក្ដីផ្ដើម និងសាវតារ



Photo: UN Women/Lim Sophorn



# ១. សេចក្តីផ្តើម

Photo: UN Women/Lim Sophorn

## ១.១. សាវតារ

### ១.១.១ ក្របខណ្ឌអន្តរជាតិ

នៅខែតុលា ឆ្នាំ២០០០ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCR) បានអនុម័តសេចក្តីសម្រេចដ៏សំខាន់លេខ ១៣២៥ **(UNSCR 1325)** ដែលបញ្ជាក់ពីតួនាទីសំខាន់របស់ស្ត្រីក្នុងការទប់ស្កាត់ និងដោះស្រាយជម្លោះ និងក្នុងគំនិតផ្តួចផ្តើមកសាងសន្តិភាព។ របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS) ផ្អែកលើសសរស្តម្ភបួន ៖ ការទប់ស្កាត់ ការចូលរួម ការការពារ និងការសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញ[30]។ ចាប់តាំងពីពេលនោះមក ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចបន្ថែមចំនួន ១០ ទៀត ដើម្បីផ្តល់ការណែនាំលម្អិតជាក់លាក់បន្ថែមទៀតអំពីទិដ្ឋភាពជាក់លាក់នៃជម្លោះ និងផលប៉ះពាល់ដែលកើតមានលើស្ត្រី។

**អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW)** គឺជាលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិជាមូលដ្ឋានមួយ ដែលផ្តោតលើសិទ្ធិស្ត្រី។ អនុសាសន៍ទូទៅលេខ ៣០ (២០១៣) ស្តីពីស្ត្រីក្នុងការទប់ស្កាត់ជម្លោះ ក្នុងស្ថានភាពជម្លោះ និងស្ថានភាពក្រោយជម្លោះ បានបញ្ជាក់អំពីការអនុវត្តអនុសញ្ញានេះចំពោះបរិបទជាច្រើន ដែលរងផលប៉ះពាល់ដោយជម្លោះ និងវិបត្តិនយោបាយ។ អនុសាសន៍ខាងលើក៏បានគូសបញ្ជាក់ពីទំនាក់ទំនងរបស់អនុសញ្ញានេះជាមួយនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដែលទាក់ទងនឹងស្ត្រី សន្តិភាព និងសន្តិសុខផងដែរ។[31]

ក្រៅពីនេះ អនុសាសន៍ទូទៅលេខ ៣៧ (២០១៨) ស្តីពីទិដ្ឋភាពយេនឌ័រនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ[32] និងសេចក្តីព្រាងអនុសាសន៍ទូទៅលេខ ៤០ (២០២៤) ស្តីពីតំណាងស្មើភាព និងបរិយាបន្នរបស់ស្ត្រីក្នុងប្រព័ន្ធធ្វើសេចក្តីសម្រេចចិត្ត[33] ក៏ពាក់ព័ន្ធខ្លាំងនឹងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខផងដែរ។ ជារួមអនុសញ្ញា CEDAW និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ បង្កើតបានជាក្របខណ្ឌជាក់ស្តែងមួយសម្រាប់ការដាក់បញ្ចូលសមភាពយេនឌ័រទៅក្នុងការទប់ស្កាត់ជម្លោះ ការកសាងសន្តិភាព ការកសាងឡើងវិញក្រោយជម្លោះ និងគណនេយ្យភាព។

---

[30] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣២៥ អាចរកបាននៅ៖ http://unscr.com/en/resolutions/doc/1325
[31] https://www.unwomen.org/en/digital-library/publications/2015/8/guidebook-cedawgeneralrecommendation30-womenpeacesecurity
[32] https://www.ohchr.org/en/documents/general-comments-and-recommendations/general-recommendation-no37-2018-gender-related
[33] https://www.ohchr.org/en/documents/general-comments-and-recommendations/draft-general-recommendation-no-40-equal-and

កម្ពុជាគឺជាហត្ថលេខីនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗទាំងអស់រួមទាំងអនុសញ្ញា CEDAW និងសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់នារយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី តាមរយៈច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការជាតិ។ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា CEDAW នៅឆ្នាំ ១៩៩២ និងពិធីសារបន្ថែមនៃអនុសញ្ញា CEDAW នៅឆ្នាំ ២០១០។ សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការ CEDAW នៃអង្គការសហប្រជាជាតិស្តីពីរបាយការណ៍លើកទី ៦ របស់កម្ពុជា ដែលចេញផ្សាយនៅខែ វិច្ឆិកា ឆ្នាំ ២០១៩ រួមមានអនុសាសន៍ ដើម្បីអនុម័តផែនការសកម្មភាពជាតិគ្រប់ជ្រុងជ្រោយមួយសម្រាប់ការអនុវត្តសេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងសេចក្តីសម្រេចបន្តបន្ទាប់ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។[34] វដ្តនៃការរាយការណ៍របស់គណៈកម្មាធិការ CEDAW បានផ្តល់ក្របខណ្ឌសំខាន់មួយសម្រាប់ការជំរុញរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងការពង្រឹងការពាក់ព័ន្ធនឹងរបៀបសមភាពយេនឌ័រទូលំទូលាយរបស់កម្ពុជា។

**សេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងប៉េកាំង (BPfA)** ដែលត្រូវបានអនុម័តដោយឯកច្ឆន្ទនៅសន្និសីទពិភពលោកលើកទី ៤ (១៩៩៥) របស់អង្គការសហប្រជាជាតិស្តីពីស្ត្រី គឺជាផែនការគោលសម្រាប់ការជំរុញសិទ្ធិស្ត្រី និងធានាឱ្យស្ត្រីចូលរួមយ៉ាងពេញលេញ និងស្មើភាពក្នុងការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ និងនយោបាយ។ ក្នុងចំណោមវិស័យអាទិភាពចំនួន ១២ វិស័យមួយស្តីពីស្ត្រី និងជម្លោះប្រដាប់អាវុធ លើកឡើងពីផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធ និងប្រភេទជម្លោះផ្សេងទៀតមកលើស្ត្រី រួមទាំងស្ត្រីដែលរស់នៅក្រោមការកាន់កាប់របស់បរទេស។ ឯកសារនេះរៀបរាប់ពីគោលបំណងយុទ្ធសាស្ត្រចំនួន ៦ និងសកម្មភាពពាក់ព័ន្ធ ដែលត្រូវអនុវត្តដោយរដ្ឋាភិបាល ស្ថាប័នអន្តររដ្ឋាភិបាល ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល។[35] ផែនការសកម្មភាពទីក្រុងប៉េកាំង បានជំរុញកិច្ចខិតខំប្រឹងប្រែងជាសកលលើរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ចាប់តាំងពីពេលដែលត្រូវបានអនុម័តនៅឆ្នាំ ១៩៩៥។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)** ដែលត្រូវបានអនុម័តនៅឆ្នាំ ២០១៥ បំពេញបន្ថែមលើរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងឆ្លុះបញ្ចាំងពីគោលបំណងនៃផែនការសកម្មភាពទីក្រុងប៉េកាំង និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ១៣២៥ និងសេចក្តីសម្រេចបន្តបន្ទាប់។ កិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តការប្តេជ្ញាចិត្តទាំងនេះនឹងរួមចំណែកដល់ការសម្រេចបាន ៖

- គោលដៅ SDG ទី ៥ សមភាពយេនឌ័រ
  - ចំណុចដៅ ៥.១ ៖ ការបញ្ឈប់អំពើហិង្សាលើស្ត្រី
  - ចំណុចដៅ ៥.២ ៖ ការបញ្ឈប់ការរើសអើងស្ត្រី
  - ចំណុចដៅ ៥.៥ ៖ ការបង្កើនតួនាទីរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត
- គោលដៅ SDG ទី ១៣ ៖ សកម្មភាពអាកាសធាតុ
- គោលដៅ SDG ទី ១៦ ៖ សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ
  - ចំណុចដៅ ១៦.៧ ៖ ការធានាការធ្វើសេចក្តីសម្រេចចិត្តដែលមានលក្ខណៈឆ្លើយតប បរិយាបន្ន មានការចូលរួម និងភាពជាតំណាង នៅគ្រប់កម្រិត។

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពមានគោលបំណងកាត់បន្ថយអំពើហិង្សាគ្រប់ទម្រង់ និងអំពាវនាវឱ្យមានដំណោះស្រាយយូរអង្វែងចំពោះជម្លោះ និងភាពអសន្តិសុខ រួមទាំងការពង្រឹងនីតិរដ្ឋ ការកាត់បន្ថយការរីកសាយអាវុធ និងការរួមបញ្ចូលប្រទេសកំពុងអភិវឌ្ឍន៍កាន់តែច្រើនទៅក្នុងអភិបាលកិច្ចកម្រិតសកល។ កម្ពុជាប្តេជ្ញាចិត្តសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបានធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍន៍ទាំងនេះទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាចំនួន ១៨ (CSDGs) ដោយបន្ថែមគោលដៅទី ១៨ ៖ បញ្ចប់ផលប៉ះពាល់អវិជ្ជមាននៃមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងលើកកម្ពស់ជំនួយដល់ជនរងគ្រោះ។[36]

---

[34] CEDAW/C/KHM/CO/6
[35] https://www.icsspe.org/system/files/Beijing%20Declaration%20and%20Platform%20for%20Action.pdf
[36] គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ ខែកក្កដា ឆ្នាំ២០២២

### ១.១.២ ក្របខណ្ឌអាស៊ាន និងកម្ពុជា

ការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានទទួលស្គាល់ថាមានសារៈសំខាន់សម្រាប់ការសម្រេចបានសន្តិភាព និងវិបុលភាពប្រកបដោយចីរភាពនៅក្នុងតំបន់អាស៊ាន។ ប្រទេសសមាជិកអាស៊ានទាំងអស់បានអនុម័ត ឬគាំទ្រការប្តេជ្ញាចិត្តថ្នាក់តំបន់ស្តីពីសមភាពយេនឌ័រ និងការការពារសិទ្ធិស្ត្រី។ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ASEAN RPA-WPS) ត្រូវបានបង្កើតឡើងដោយផ្អែកលើការចូលរួមផ្នែកនយោបាយអស់រយៈពេលជាច្រើនទសវត្សរ៍នៅក្នុងតំបន់អាស៊ាន លើបញ្ហានានាពាក់ព័ន្ធនឹងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

ថ្នាក់ដឹកនាំអាស៊ានបានអនុម័តសេចក្តីថ្លែងការណ៍រួមស្តីពីការលើកកម្ពស់ស្ត្រីសន្តិភាពនិងសន្តិសុខនៅក្នុងអាស៊ាននៅខែវិច្ឆិកា ឆ្នាំ ២០១៧ ដើម្បីបញ្ជាក់ជាថ្មីអំពីការប្តេជ្ញាចិត្តនេះ[37]។ ក្របខណ្ឌយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រ អាស៊ាន ២០២១-២០២៥ ដែលដឹកនាំដោយគណៈកម្មាធិការអាស៊ានស្តីពីស្ត្រី (ACW) និងគណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិស្ត្រី និងកុមារ (ACWC) ទទួលស្គាល់ទំនាក់ទំនងដ៏ស្មុគស្មាញនៃវិសមភាពផ្នែករចនាសម្ព័ន្ធ ឧបសគ្គផ្នែកស្ថាប័ន និងបទដ្ឋានសង្គម ដែលបន្តឱ្យមានវិសមភាពយេនឌ័រ[38] ។

ក្របខណ្ឌនេះទទួលស្គាល់ថា ការអនុវត្តរបៀបវារៈ WPS ទាមទារការចូលរួមយ៉ាងច្រើនពីស្ថាប័នតាមវិស័យផ្សេងទៀតរបស់អាស៊ាន ជាពិសេសនៅក្នុងសហគមន៍នយោបាយ-សន្តិសុខ និងសហគមន៍សេដ្ឋកិច្ច និងអំពាវនាវឱ្យមានវិធីសាស្រ្តដែលមានការសម្របសម្រួល និងជាយុទ្ធសាស្រ្ត ដើម្បីប្រើប្រាស់អាណត្តិ សមត្ថភាព និងស្ថាប័នពាក់ព័ន្ធ សំដៅគាំទ្រដល់ការបញ្ជ្រាបយេនឌ័រ[39]។

នៅថ្ងៃទី ២២-២៣ ខែសីហា ឆ្នាំ២០១៩ អាស៊ានបានរៀបចំជាលើកដំបូងនូវសន្និសីទថ្នាក់តំបន់ស្តីពីការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នាទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ សន្និសីទនេះរៀបចំឡើងដោយក្រសួងកិច្ចការនារី ក្រោមកិច្ចសហការជាមួយលេខាធិការដ្ឋានអាស៊ាន គណៈកម្មាធិការអាស៊ានស្តីពីស្ត្រី និង ACWC ដោយមានការគាំទ្រពីគម្រោង PROSPECT រវាងអាស៊ាន និង USAID និងអង្គការ UN Women។ ចាប់តាំងពីការអនុម័តសេចក្តីថ្លែងការណ៍រួមស្តីពីការលើកកម្ពស់របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន នៅខែ វិច្ឆិកា ឆ្នាំ ២០១៧ មក នេះជាកិច្ចសន្ទនាអន្តរវិស័យថ្នាក់តំបន់ជាលើកដំបូង ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់អាស៊ានក្នុងការពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ហើយនេះក៏ជាចំណុចចាប់ផ្តើមដ៏សំខាន់មួយសម្រាប់ការបង្កើតកិច្ចសហការឆ្លងវិស័យស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ រវាងសហគមន៍សង្គម-វប្បធម៌អាស៊ាន និងសហគមន៍នយោបាយ និងសន្តិសុខអាស៊ានផងដែរ។ ក្រៅពីនេះ សន្និសីទថ្នាក់តំបន់នេះបានពន្លឿនកិច្ចសន្ទនាអន្តរវិស័យស្តីពីការអនុវត្ត ASEAN Women's Peace Registry ដែលស្ថិតក្រោមវិទ្យាស្ថានអាស៊ានដើម្បីសន្តិភាព និងការផ្សះផ្សា។

លទ្ធផលសម្រេចបានដ៏សំខាន់មួយនៃសន្និសីទថ្នាក់តំបន់នេះគឺការប្តេជ្ញាចិត្តរបស់អាស៊ានក្នុងការរៀបចំការសិក្សាថ្នាក់តំបន់ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីកត់ត្រាពីវឌ្ឍនភាព វិភាគនិន្នាការនានា ត្រួតពិនិត្យបញ្ហាប្រឈមជាបន្តបន្ទាប់ និងកំពុងលេចឡើង និងចាប់យកមេរៀនដែលទទួលបាន។ អនុសាសន៍ពីការសិក្សានេះ បានត្រួសត្រាយផ្លូវសម្រាប់អាស៊ានក្នុងការរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ[40]។

កម្ពុជាគឺជាសមាជិកដំបូងមួយនៃក្រុមប្រឹក្សាពិគ្រោះយោបល់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (និងបានធ្វើជាប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់នេះក្នុងឆ្នាំ ២០២២)។ ក្រុមប្រឹក្សាពិគ្រោះយោបល់នេះ បានចាប់ផ្តើមឡើងជាក្រុមការងារបណ្តោះអាសន្នក្រៅផ្លូវការ ដែលចូលរួមដោយតំណាងមកពី ACW និង ACWC នៃរដ្ឋសមាជិកអាស៊ានចំនួន ៥ ដែលប្តេជ្ញាគាំទ្រដល់របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ នៅឆ្នាំ ២០២២ កម្ពុជាបានធ្វើជាប្រធានអាស៊ាន និងបានដឹកនាំពេញលេញក្នុងការពន្លឿនការរៀបចំផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

---

[37] ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ខែធ្នូ ឆ្នាំ២០២២
[38] ASEAN Gender Mainstreaming Framework 2021-2025, September 2021; available at: https://asean.org/book/asean-gender-mainstreaming-strategic-framework-2021-2025/
[39] ដូចខាងលើ
[40] សូមមើល ASEAN, *ASEAN Regional Study on WPS*, available at https://wps.asean.org/resources/asean-regional-study-on-women-peace-and-security/

ក្នុងអំឡុងពេលដែលកម្ពុជាធ្វើជាប្រធានអាស៊ាន ថ្នាក់ដឹកនាំអាស៊ានបានអនុម័តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខជាលើកដំបូង នៅកិច្ចប្រជុំកំពូលអាស៊ានក្នុងខែ វិច្ឆិកា ឆ្នាំ ២០២២ ដែលអមមកជាមួយនឹងការដាក់ឱ្យដំណើរការជាផ្លូវការនូវផែនការសកម្មភាពនេះ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២ នារាជធានីភ្នំពេញ។ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ រៀបរាប់ពីយុទ្ធសាស្ត្រក្នុងការអនុវត្តសសរស្តម្ភទាំងបួននៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គឺ ការការពារ ការចូលរួម ការទប់ស្កាត់ និងការសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ។ ផែនការសកម្មភាពនេះបានផ្តល់ក្របខណ្ឌទូលំទូលាយ និងបត់បែនសម្រាប់ឱ្យរដ្ឋសមាជិកអាស៊ានធ្វើមូលដ្ឋានីយកម្មរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងកំណត់អាទិភាពអាទិភាពដែលសមស្របនឹងបរិបទជាតិ និងបរិបទមូលដ្ឋាន។ ផែនការសកម្មភាពនេះក៏មានគោលបំណងពង្រឹង និងដំណើរការការប្តេជ្ញាចិត្តថ្នាក់តំបន់ចំពោះរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខផងដែរ។ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ តំណាងឱ្យជំហាន សំខាន់មួយនៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់អាស៊ានក្នុងការទទួលស្គាល់ និងប្រើប្រាស់ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងការទប់ស្កាត់អំពើហិង្សា ការដោះស្រាយជម្លោះ និងការកសាងសន្តិភាព។

អាស៊ាន និងអង្គការ UN Women បានសហការគ្នារៀបចំកញ្ចប់ឧបករណ៍ស្តីពីការធ្វើមូលដ្ឋានីយកម្ម និងគោលការណ៍ណែនាំសម្រាប់ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក្រោមការដឹកនាំរបស់កម្ពុជាក្នុងនាមជាប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងអ្នកគាំទ្រគំនិតផ្តួចផ្តើមការធ្វើមូលដ្ឋានីយកម្ម។ កញ្ចប់ឧបករណ៍នេះត្រូវបានដាក់ឱ្យដំណើរការនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ និងត្រូវបានប្រើប្រាស់ ដើម្បីកសាងការយល់ដឹងអំពីរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងចំណោមអ្នកពាក់ព័ន្ធក្នុងរដ្ឋាភិបាល។ កញ្ចប់ឧបករណ៍នេះផ្តល់ការណែនាំជាក់ស្តែងសម្រាប់ការប្រែក្លាយសកម្មភាពអាទិភាពនៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ទៅជាការអនុវត្តជាក់ស្តែងដែលមានលទ្ធផលច្បាស់លាស់ និងធានាថា មិនមាននរណាម្នាក់ត្រូវបានទុកចោល[41]។ ក្រសួងកិច្ចការនារី ក្នុងនាមជាសមាជិកនៃគណៈកម្មាធិការអាស៊ានស្តីពីស្ត្រី បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រ និងជំរុញការរៀបចំកញ្ចប់ឧបករណ៍ស្តីពីការធ្វើមូលដ្ឋានីយកម្មនេះ។

នៅក្នុងសសរស្តម្ភនយោបាយនិងសន្តិសុខអាស៊ានរដ្ឋាភិបាលកម្ពុជាបានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យរក្សាសន្តិភាព ដោយមានផែនការបង្កើនការបញ្ជូនយោធិននារីឱ្យចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិដល់ ២០ ភាគរយ ត្រឹមឆ្នាំ២០២៤[42]។ ត្រឹមខែ ឧសភា ឆ្នាំ ២០២៤ កម្ពុជាសម្រេចបានចំណុចដៅនេះ ដោយយោធិននារីមានចំនួន ២១,៤ ភាគរយនៃចំនួនកងកម្លាំងរក្សាសន្តិភាពសរុបដែលបានបញ្ជូន (គិតត្រឹមខែធ្នូ ឆ្នាំ២០២៤)[43]។ បច្ចុប្បន្ន កម្ពុជាគឺជារដ្ឋសមាជិកអាស៊ានឈានមុខគេមួយទាំងលើការជំរុញតួនាទីរបស់ស្ត្រីនៅក្នុងប្រតិបត្តិការរក្សាសន្តិភាពអង្គការសហប្រជាជាតិ (PKO) និងចំនួនយោធិននារីដែលត្រូវបានបញ្ជូនទៅបំពេញបេសកកម្មរក្សាសន្តិភាព។[44]

កម្ពុជាគឺជារដ្ឋសមាជិកអាស៊ានដំបូងគេនិងជាប្រទេសទីពីរក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិកដែលបានធ្វើការវាយតម្លៃស្តីពីការវាស់វែងឱកាសសម្រាប់ស្ត្រីនៅក្នុងប្រតិបត្តិការរក្សាសន្តិភាព (MOWIP)។ ការវាយតម្លៃនេះធ្វើឡើងក្រោមជំនួយពីមូលនិធិផ្តួចផ្តើម Elsie សម្រាប់ស្ត្រីកងកម្លាំងក្នុងប្រតិបត្តិការរក្សាសន្តិភាព។[45] នេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមុតមាំ របស់រដ្ឋាភិបាលក្នុងការកំណត់រកបញ្ហាប្រឈម និងឱកាសសម្រាប់ការពង្រឹងតួនាទីដ៏មានអត្ថន័យនៃការចូលរួមរបស់ស្ត្រីក្នុងការរក្សាសន្តិភាព។ នេះក៏ជាវេទិកាដ៏ល្អមួយសម្រាប់កម្ពុជាក្នុងការបង្ហាញពីភាពជាអ្នកដឹកនាំ និងចែករំលែកមេរៀនដែលទទួលបានជាមួយរដ្ឋជាសមាជិកអាស៊ានផ្សេងទៀតដែលផ្តោតអាទិភាពលើតួនាទីរបស់ស្ត្រីក្នុងការរក្សាសន្តិភាព។[46]

នៅកម្រិតជាតិកម្ពុជាមានបទពិសោធន៍ពិសេសមួយក្នុងការស្តារឡើងវិញក្រោយជម្លោះជាពិសេសក្នុងការទទួលស្គាល់តួនាទីសំខាន់របស់ស្ត្រីក្នុងការសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ មានសន្ទុះដែលមិនធ្លាប់មានពីមុនមកក្នុងការធ្វើមូលដ្ឋានីយកម្មរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជំរុញដោយសារកើនឡើងនៃតម្រូវការបន្ទាន់ក្នុងការដោះស្រាយបញ្ហាប្រឈមផ្នែកសន្តិសុខទូទៅនិងបញ្ហាប្រឈមផ្នែកសន្តិសុខថ្មីៗចាប់ពីជម្លោះ និងការប្រែប្រួលអាកាសធាតុ រហូតដល់ការជួញដូរមនុស្ស សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងបទល្មើសឆ្លងដែន។ ស្ត្រី និង

[41] ឧបករណ៍និងគោលការណ៍ណែនាំសម្រាប់ការធ្វើមូលដ្ឋានីយកម្មផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ទីក្រុងចាការតា លេខាធិការដ្ឋានអាស៊ាន ខែធ្នូ ឆ្នាំ២០២៣
[42] https://cambodia.un.org/en/179373-
[43] https://peacekeeping.un.org/sites/default/files/operational_effect_and_women_peacekeepers_74_may_2024.pdf
[44] https://cambodia.un.org/en/179373-
[45] https://elsiefund.org/wp-content/uploads/2024/08/240730-Press-Release-MOWIP-Launch.pdf
[46] ទស្សនទានសង្ខេបៈ ការដាក់ឱ្យប្រើប្រាស់ឧបករណ៍និងគោលការណ៍ណែនាំសម្រាប់ការធ្វើមូលដ្ឋានីយកម្មរបស់អាស៊ាន និងសិក្ខាសាលាលើកកម្ពស់ការយល់ដឹងស្តីពីការធ្វើមូលដ្ឋានីយកម្មរបស់ស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា ថ្ងៃទី១៤-១៥ ខែធ្នូ ឆ្នាំ២០២៣
[47] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា

ក្មេងស្រីរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងពាក់ព័ន្ធក្នុងបញ្ហាទាំងនេះ តាមរបៀបដែលច្រើនតែគ្មានគេយកចិត្តទុកដាក់ ឬមានការយល់ខុស។ លើសពីនេះ ស្ត្រី និងក្មេងស្រីមិនត្រូវបានរួមបញ្ចូលប្រកបដោយអត្ថន័យទៅក្នុងការរៀបចំ និងអនុវត្តដំណោះស្រាយ ឬគោលនយោបាយស្តីពីសន្តិភាព និងសន្តិសុខ និងដំណើរការធ្វើសេចក្តីសម្រេចចិត្តឡើយ។

គោលដៅរួមរបស់រាជរដ្ឋាភិបាលកម្ពុជា(RGC)ដូចមានចែងនៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ គឺការកសាងសង្គមមួយដែលមានសន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខ ដែលស្ថិតនៅលើមាគ៌ានៃការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌។[47] រដ្ឋាភិបាលក៏បានផ្តោតអាទិភាពដល់សមភាពយេនឌ័រនិងការបង្កើនភាពអង់អាចដល់ស្ត្រីតាមរយៈរបៀបវារៈគោលនយោបាយជាតិ យុទ្ធសាស្រ្តជាតិ និងផែនការជាតិរបស់ខ្លួនផងដែរ។ នេះរួមមានដំណាក់កាលជាបន្តបន្ទាប់នៃយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ១-៤ និងយុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទី ១ ឆ្នាំ ២០២៤-២០២៨ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (NSDP) រយៈពេល ៥ ឆ្នាំ ២០១៩-២០២៣ (ហើយផែនការឆ្នាំ ២០២៤-២០២៨ នឹងចេញផ្សាយឆាប់ៗនេះ) ក៏ដូចជាផែនការយុទ្ធសាស្រ្តជាតិរយៈពេល ៥ ឆ្នាំរបស់ក្រសួងកិច្ចការនារីស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី ទី ១-៦ (ផែនការចុងក្រោយបំផុតគឺ ឆ្នាំ ២០២៤-២០២៨)។

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងកិច្ចការនារី (MoWA) បានបង្ហាញការយកចិត្តទុកដាក់លើការជំរុញបន្ថែមនូវរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា ដែលស្របទៅនឹងសេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងស្ត្រីភេទ (CEDAW) និងផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ASEAN RPA-WPS) តាមរយៈការរៀបចំផែនការសកម្មភាពជាតិស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ។ កម្ពុជាមានចំណាប់អារម្មណ៍ និងការយកចិត្តទុកដាក់ជាពិសេសលើសសរស្តម្ភនៃការទប់ស្កាត់ជម្លោះ ការចូលរួម ការសង្គ្រោះបន្ទាន់ និងស្តារឡើងវិញក្នុងរបៀបវារៈ WPS ហើយកម្ពុជាមានមេរៀនដ៏មានតម្លៃពីបរិបទក្រោយជម្លោះ។ ផ្អែកលើការដឹកនាំរបស់កម្ពុជាក្នុងការជំរុញផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងចំណាប់អារម្មណ៍យ៉ាងខ្លាំងរបស់កម្ពុជាក្នុងការធ្វើមូលដ្ឋានីយកម្ម ផែនការសកម្មភាពតំបន់ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (RPA-WPS) នៅក្នុងបរិបទជាតិ ការកសាងកម្លាំងផ្ទួបរវាងកិច្ចខិតខំប្រឹងប្រែងថ្នាក់តំបន់ និងថ្នាក់ជាតិ នឹងមានសារៈសំខាន់សម្រាប់ធានាការចូលរួម និងភាពជាម្ចាស់នៅថ្នាក់ជាតិ។

ដោយទទួលស្គាល់តួនាទីសំខាន់របស់ស្ត្រី និងអង្គការសង្គមស៊ីវិល (CSO) ក្នុងការជំរុញរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ អង្គការ UN Women ក្រោមកិច្ចសហការជាមួយអង្គការសង្គមស៊ីវិលដែលដឹកនាំដោយស្ត្រីចំនួនពីរ គឺ អង្គការនារីដើម្បីសន្តិភាព (WPM) និងសម្ព័ន្ធដើម្បីការផ្លាស់ប្តូរជម្លោះ (ACT) បានរៀបចំកិច្ចសន្ទនាអន្តរកម្មជាមួយអង្គការសង្គមស៊ីវិលស្តីពីការជំរុញរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា កាលពីថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០២៣។[48] អ្នកចូលរួមបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នៅកម្ពុជា ដោយធានាបាននូវអភិក្រមប្រកបដោយបរិយាបន្ន និងអន្តរវិស័យ ដើម្បីដោះស្រាយបញ្ហាកំពុងលេចឡើងថ្មី ដូចជា សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងសន្តិសុខអាកាសធាតុ ការវិនិយោគធនធានគ្រប់គ្រាន់ និងការទទួលស្គាល់តម្រូវការក្នុងការពង្រឹងសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេលើរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

ក្រសួងកិច្ចការនារី ក្រោមកិច្ចសហការជាមួយអាស៊ាន (ជាពិសេសគណៈកម្មាធិការអាស៊ានស្តីពីស្ត្រី) និងអង្គការ UN Women បានរៀបចំសិក្ខាសាលារយៈពេលពីរថ្ងៃនៅថ្ងៃទី ១៤-១៥ ខែធ្នូ ឆ្នាំ ២០២៣ ដើម្បីដាក់ឱ្យដំណើរការកញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំស្តីពីការធ្វើមូលដ្ឋានីយកម្មសម្រាប់ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (២០២៣) និងដើម្បីបង្កើនការយល់ដឹងអំពីរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ព្រមទាំងភាពពាក់ព័ន្ធរបស់វាទៅនឹងអាទិភាព និងបរិបទជាតិរបស់កម្ពុជា។[49] លទ្ធផលសំខាន់ៗ រួមមានចំណាប់អារម្មណ៍ និងការយកចិត្តទុកដាក់លើការធ្វើមូលដ្ឋានីយកម្មផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងបរិបទកម្ពុជា ការសង្កត់ធ្ងន់លើបញ្ហាសន្តិសុខមិនមែនប្រពៃណី ដូចជា សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត សន្តិសុខអាកាសធាតុ និងការជួញដូរមនុស្ស ការគាំទ្រឱ្យក្រសួងកិច្ចការនារី

[48] ទស្សនទានសង្ខេប៖ កិច្ចសន្ទនាប្រកបដោយអន្តរកម្មជាមួយអង្គការសង្គមស៊ីវិលស្តីពីការជំរុញរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ។ អង្គការ UN Women អង្គការស្ត្រីដើម្បីសន្តិភាព និងអង្គការសកម្មភាពដើម្បីសន្តិភាព។ មនុស្ស២៥នាក់ (ស្ត្រី១៩នាក់) មកពីអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិលចំនួន១០បានចូលរួម។

[49] ទស្សនទានសង្ខេប៖ ការដាក់ឱ្យប្រើប្រាស់ឧបករណ៍និងគោលការណ៍ណែនាំសម្រាប់ការធ្វើមូលដ្ឋានីយកម្មរបស់អាស៊ាន និងសិក្ខាសាលាលើកកម្ពស់ការយល់ដឹងស្តីពីការធ្វើមូលដ្ឋានីយកម្មរបស់ស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា ថ្ងៃទី១៤-១៥ ខែធ្នូ ឆ្នាំ២០២៣។ អ្នកចូលរួម១១១នាក់បានចូលរួមនៅថ្ងៃទី១ និង៤៧នាក់ រួមទាំងមកពីក្រសួង/ស្ថាប័នផ្សេងៗចំនួន១៧បានចូលរួមនៅថ្ងៃទី២។

ដឹកនាំការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS) និងអនុសាសន៍ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួល ឬក្រុមការងារថ្នាក់ជាតិជាផ្នែកមួយនៃដំណើរការនេះ។

## ១.២. វិធីសាស្ត្រ

ការវិភាគស្ថានភាព បានប្រើប្រាស់អភិក្រមផ្អែកលើសិទ្ធិមនុស្ស ដោយអនុវត្តតាមគោលការណ៍សំខាន់ៗនៃការចូលរួម បរិយាបន្ន សមភាពយេនឌ័រ និងការយកចិត្តទុកដាក់លើយេនឌ័រ រួមទាំងកិច្ចខិតខំប្រឹងប្រែងរួមបញ្ចូលក្រុមស្ត្រី និងក្រុមយុវជនចម្រុះ ហើយទន្ទឹមនឹងនោះ ធានាការគោរពតាមគោលការណ៍សំខាន់ៗនៃការរក្សាការសម្ងាត់ ឯកជនភាព សុវត្ថិភាព និងការយល់ព្រមដោយបានទទួលព័ត៌មានគ្រប់គ្រាន់។ វិធីសាស្ត្រ រួមមានការពិនិត្យឯកសារមួយចំនួនធំ ដែលមានស្រាប់ដែលពាក់ព័ន្ធនឹងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក៏ដូចជាការពិគ្រោះយោបល់ និងការសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ រួមទាំងអ្នកបង្កើតគោលនយោបាយ និងមន្ត្រីរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល បុគ្គលិកទីភ្នាក់ងារអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ និងមន្ត្រីស្ថានទូត ស្ថាប័នសិក្សាស្រាវជ្រាវ ស្ត្រីមកពីក្រុមជួបការលំបាក និងតំបន់ជនបទ យុវជន យុវនារី និងកងកម្លាំងរក្សាសន្តិភាពអង្គការសហប្រជាជាតិ (ទាំងពីរភេទ)។

សិក្ខាសាលាពិគ្រោះយោបល់ស្តីពីរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា ត្រូវបានរៀបចំឡើងនៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០២៤ នារាជធានីភ្នំពេញ ដែលសហការរៀបចំដោយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងកិច្ចការនារី ក្រោមការគាំទ្រពីក្រុមការងារផ្ទៃក្នុងរបស់ក្រសួងកិច្ចការនារីស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ និងអង្គការ UN Women ប្រចាំនៅកម្ពុជា ព្រមទាំងមានការគាំទ្រពីការិយាល័យប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (ROAP) នៃអង្គការ UN Women ដែលមានអ្នកចូលរួមសរុបចំនួន ៥០ នាក់ (ស្រី ៣៩ នាក់ និងប្រុស ១១ នាក់) មកពីក្រសួង/ស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល និងទីភ្នាក់ងារអង្គការសហប្រជាជាតិ។ នៅអំឡុងខែ កក្កដា និងខែ សីហា ឆ្នាំ ២០២៤ មានការរៀបចំសម្ភាសន៍ និងកិច្ចពិភាក្សាក្រុមគោលដៅដោយប្រើប្រាស់កម្រងសំណួរបែបពាក់កណ្តាលរចនាសម្ព័ន្ធ ហើយមានអ្នកចូលរួមសរុបចំនួន ១៩៨ នាក់ (ស្រី ១៦៦ នាក់ និងប្រុស ៣២ នាក់) រួមទាំងអ្នកបង្កើតគោលនយោបាយ មន្ត្រីរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ស្ថាប័នសិក្សា/ស្រាវជ្រាវ ក្រុមយុវជន និងក្រុមស្ត្រីជួបការលំបាកនៅថ្នាក់ជាតិ និងនៅក្នុងខេត្តចំនួនបី គឺខេត្តមណ្ឌលគិរី ស្វាយរៀង និងកំពង់ឆ្នាំង។

មន្ត្រីវិភាគកម្មវិធីស្ត្រី សន្តិភាព និងសន្តិសុខ របស់អង្គការ UN Women ប្រចាំនៅកម្ពុជា ក្រុមទីប្រឹក្សា និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងកិច្ចការនារី បានធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នាក្នុងការធ្វើផែនការ និងការដំណើរការសិក្ខាសាលាពិគ្រោះយោបល់ កិច្ចពិភាក្សាក្រុមគោលដៅ និងការសម្ភាសន៍សម្រាប់ការវិភាគស្ថានភាពនេះ។ នេះរួមបញ្ចូលការពិនិត្យឯកសារពាក់ព័ន្ធ ការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ និងកិច្ចប្រជុំផ្តល់មតិត្រឡប់លើលទ្ធផលរកឃើញពីការងារចុះមូលដ្ឋាន និងការអនុវត្តលំហាត់កំណត់ភាគីពាក់ព័ន្ធ។ មតិយោបល់ស្តីពីលទ្ធផលរកឃើញបឋម និងរបាយការណ៍ព្រាង ត្រូវបានបញ្ចូលទៅក្នុងដំណើរការនេះ និងឆ្លុះបញ្ចាំងក្នុងរបាយការណ៍ចុងក្រោយ។ សិក្ខាសាលាពិគ្រោះយោបល់ចុងក្រោយស្តីពី ការវិភាគស្ថានភាព WPS នៅកម្ពុជា បានធ្វើឡើងនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៤ ដោយមានអ្នកចូលរួម ៧១ នាក់ (ស្រី ៦៣ នាក់) មកពីក្រសួង និងស្ថាប័នពាក់ព័ន្ធ ទីភ្នាក់ងារអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ដើម្បីពិនិត្យឡើងវិញលើលទ្ធផលរកឃើញ និងប្រមូលយោបល់ត្រឡប់។ ក្រៅពីនេះ មានការរៀបចំកិច្ចប្រជុំតាមដានបន្តជាច្រើនរវាង MoWA និងអង្គការ UN Women នៅចន្លោះខែធ្នូ ឆ្នាំ២០២៤ និង ខែមីនា ឆ្នាំ ២០២៥ ដើម្បីបញ្ចប់របាយការណ៍នេះ និងពិចារណាពីជំហានបន្ទាប់។

# ផ្នែកទី ២

# ស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា




Photo: UN Women/Lim Sophorn



# ២. ទិដ្ឋភាពទូទៅនៃផែនការសកម្មភាពតំបន់អាស៊ាន ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ASEAN RPA-WPS)

Photo: UN Women/Lim Sophorn

របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ផ្អែកលើសសរស្តម្ភដែលទាក់ទងគ្នាចំនួនបួន៖ ការទប់ស្កាត់ ការចូលរួម ការការពារ និងការសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ។

- **ការទប់ស្កាត់** សំដៅលើការធានាថា ស្ត្រីចូលរួមដោយស្មើភាព និងពេញលេញក្នុងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ជម្លោះ និងអំពើហិង្សា ហើយអន្តរាគមន៍ និងគោលនយោបាយស្តីពីសន្តិភាព និងសន្តិសុខ មានប្រសិទ្ធភាពក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ នេះរួមបញ្ចូលការទទួលស្គាល់វិធីផ្សេងៗដែលស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុស និងអ្នកមកពីក្រុមជួបការលំបាក អាចទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- **ការចូលរួម** ពាក់ព័ន្ធនឹងការបង្កើនតំណាង និងការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីនៅគ្រប់កម្រិតក្នុងគោលនយោបាយ និងកម្មវិធីស្តីពីសន្តិភាព និងសន្តិសុខ។
- **ការការពារ** មានគោលបំណងធានាថា តម្រូវការ និងសិទ្ធិជាក់លាក់របស់ស្ត្រី និងក្មេងស្រីត្រូវបានទទួលស្គាល់ និងបំពេញនៅក្នុងកិច្ចខិតខំប្រឹងប្រែងពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ។
- **ការសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ** ផ្តោតលើការធានាការទទួលបានសេវា និងការការពារសិទ្ធិសម្រាប់ស្ត្រី និងក្មេងស្រីក្នុងពេល និងក្រោយពេលជម្លោះ និងគ្រោះមហន្តរាយ។

ជំងឺរាតត្បាតកូវីដ១៩ និងបញ្ហាប្រឈមនៃសន្តិសុខផ្សេងទៀតដែលកំពុងលេចឡើង រួមទាំងបទល្មើសឆ្លងដែន ការគំរាមកំហែងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត អំពើជួញដូរមនុស្ស គ្រោះមហន្តរាយធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងលទ្ធិជ្រុលនិយមហិង្សា បាននាំឱ្យមានការពិនិត្យឡើងវិញលើអ្វីដែលបង្កើតបានជាសន្តិសុខ។ ទស្សនទាននេះគ្របដណ្តប់លើសពីជម្លោះប្រដាប់អាវុធធម្មតា និងរួមបញ្ចូលការគំរាមកំហែងដល់សន្តិសុខមនុស្ស ដែលហួសពីគំរូទូទៅនៃសន្តិសុខជាតិ។[50]

ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខគ្របដណ្តប់លើសសរស្តម្ភសំខាន់ៗទាំង ៤ នៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ នៅក្នុងតារាងសង្ខេបខាងក្រោម សសរស្តម្ភនីមួយៗមានលទ្ធផលមួយ (លើកលែងតែការទប់ស្កាត់ដែលមានលទ្ធផលពីរ) ហើយលទ្ធផលនីមួយៗអមដោយសូចនាករជាច្រើន ដើម្បីវាស់វែងវឌ្ឍនភាព។ លទ្ធផលនីមួយៗក៏មានធាតុចេញ និងសកម្មភាពអាទិភាពជាច្រើនផងដែរ។[51]

---

[50] អាស៊ាន ការសិក្សាថ្នាក់តំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ខែមីនា ឆ្នាំ២០២០ អាចរកបាននៅ https://asean.org/asean-regional-plan-of-action-on-women-peace-and-security/
[51] ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ខែធ្នូ ឆ្នាំ២០២២

*តារាងទី ១ ៖ សេចក្តីសង្ខេបលទ្ធផលចុងក្រោយនៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ*

| |
|---|
| **ការការពារ** |
| **លទ្ធផលយុទ្ធសាស្ត្រទី ១ ៖** ការការពារសិទ្ធិរបស់ស្ត្រី ស្ត្រីវ័យក្មេង និងក្មេងស្រី រួមទាំងក្រុមដែលទទួលបានឱកាសតិចតួចនៅក្នុងគោលនយោបាយ ការអនុវត្ត និងស្ថាប័នពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ រួមទាំងការការពារស្ត្រី និងក្មេងស្រីពីគ្រប់ទម្រង់នៃអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ (SGBV) នៅក្នុងបរិបទជម្លោះ ក្រោយជម្លោះ ការកសាងសន្តិភាព និងមនុស្សធម៌។ |
| **ការចូលរួម** |
| លទ្ធផលយុទ្ធសាស្ត្រទី ២ ៖ ការចូលរួមពេញលេញ ប្រកបដោយអត្ថន័យ និងដោយស្មើភាពរបស់ស្ត្រី ក្នុងស្ថាប័ន អង្គការ និងដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ រួមទាំងក្នុងតួនាទីដឹកនាំ។ |
| **ការទប់ស្កាត់** |
| **លទ្ធផលយុទ្ធសាស្ត្រទី ៣ ៖** អង្គភាព និងស្ថាប័នតាមវិស័យ និងរដ្ឋសមាជិកអាស៊ាន ដើរតួនាទីយ៉ាងសកម្មក្នុងការរួមចំណែកដល់ការទប់ស្កាត់ជម្លោះនៅថ្នាក់សកល ថ្នាក់តំបន់ និងថ្នាក់ជាតិ និងការទប់ស្កាត់អំពើហិង្សា គ្រោះមហន្តរាយ និងការគំរាមកំហែងផ្សេងទៀតដល់សន្តិភាព និងសន្តិសុខ ដោយមានគោលការណ៍នៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ជាស្នូលនៃសកម្មភាពទាំងនេះ។ |
| **លទ្ធផលយុទ្ធសាស្ត្រទី ៤ ៖** ស្ថាប័ន យន្តការ និងដំណើរការសន្តិភាព និងសន្តិសុខទទួលបានជោគជ័យក្នុងការទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ ។ |
| **ការសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ** |
| **លទ្ធផលយុទ្ធសាស្ត្រទី ៥ ៖** តម្រូវការរបស់ស្ត្រី និងក្មេងស្រីត្រូវបានបំពេញនៅក្នុងដំណើរការសង្គ្រោះបន្ទាន់ និងស្តារឡើងវិញនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ហើយស្ត្រីមានការចូលរួមដោយស្មើភាព និងប្រកបដោយអត្ថន័យនៅក្នុងដំណើរការទាំងនេះ រួមទាំងនៅក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្ត និងភាពជាអ្នកដឹកនាំ។ |

*ប្រភព៖ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ(២០២២)*




# ៣. បញ្ហាស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា

Photo: UN Women/Lim Sophorn

ការពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម នៅតែជាចំណុចសំខាន់នៃរបៀបវារៈអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។ រដ្ឋាភិបាលបានអនុវត្តវិធានការយ៉ាងទូលំទូលាយ ដើម្បីទប់ស្កាត់កុំឱ្យភាពចលាចលសង្គម ឈានទៅដល់អំពើហិង្សា។ នៅកម្ពុជា បញ្ហាសន្តិសុខដែលពាក់ព័ន្ធនឹងរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ (WPS) រួមមានអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រក្នុងបរិបទមានវិបត្តិ ក្រោយជម្លោះ ការកសាងសន្តិភាព និងមនុស្សធម៌ ការជួញដូរស្ត្រី និងក្មេងស្រី បទល្មើសឆ្លងដែន រួមទាំងគ្រឿងញៀន សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងបទល្មើសបច្ចេកវិទ្យា ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ សន្តិសុខសេដ្ឋកិច្ចរបស់ស្ត្រី និងលទ្ធភាពទទួលបានធនធានធម្មជាតិ សិនិទ្ធពលសង្គម ព្រមទាំងការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

## ៣.១. ស្ត្រី និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងជម្លោះ និងវិបត្តិមនុស្សធម៌

### ៣.១.១ បរិបទនៃស្ត្រី និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងស្ថានភាពជម្លោះ

អំពើហិង្សាលើស្ត្រី និងក្មេងស្រី បណ្តាលមកពីវិសមភាពនៃទំនាក់ទំនងអំណាចយេនឌ័រ និងការរើសអើង និងធ្វើឱ្យកាន់តែធ្ងន់ធ្ងរដោយជម្លោះ និងវិបត្តិមនុស្សធម៌ ភាពក្រីក្រ បញ្ហាសេដ្ឋកិច្ច និងពេលខ្លះ ការសេពគ្រឿងស្រវឹង និងសារធាតុញៀនផ្សេងទៀតដែលបង្កគ្រោះថ្នាក់[52]។ ក្នុងអំឡុងគ្រោះអាសន្ន ដូចជា ជម្លោះ ឬគ្រោះមហន្តរាយ ធម្មជាតិ មានកម្រិតខ្ពស់នៃហានិភ័យអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពាន។ ការផាត់ចេញពីសង្គម និងការរឹតត្បិតការដើរហើរក្នុងអំឡុងព្រឹត្តិការណ៍ទាំងនេះ បានបង្កហានិភ័យជាក់លាក់សម្រាប់ស្ត្រី និងក្មេងស្រី។

វិបត្តិកូវីដ-១៩ គឺជាឧទាហរណ៍ច្បាស់លាស់មួយដែលទិន្នន័យ និងរបាយការណ៍នានាបង្ហាញថា គ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី បានកើតឡើងក្នុងអត្រាយ៉ាងខ្ពស់[53]។ កត្តារួមចំណែកឱ្យមានស្ថានភាពនេះ រួមមានភាពតានតឹងក្នុងគ្រួសារដែលពាក់ព័ន្ធនឹងសន្តិសុខ សុខភាព និងហិរញ្ញវត្ថុ ការរស់នៅក្នុងស្ថានភាពណែនតាន់តាប់ ការដាក់ឱ្យនៅដាច់ដោយឡែកជាមួយជនរំលោភបំពាន ការរឹតត្បិតចល័តភាព និងការបិទការចេញចូល ទីសាធារណៈ។ សេវាសំខាន់ៗ ដូចជា ការថែទាំសុខភាព ការបញ្ជូន ការគាំទ្រផ្នែកចិត្តសង្គម និងច្បាប់ ជម្រកសុវត្ថិភាព និងរបរចិញ្ចឹមជីវិត គឺមិនមានផ្តល់ ឬខ្វះខាតជាខ្លាំង។

[52] https://www.unwomen.org/sites/default/files/Headquarters/Attachments/Sections/Library/Publications/2020/Issue-brief-COVID-19-and-ending-violence-against-women-and-girls-en.pdf
[53] https://www.unwomen.org/en/news/in-focus/in-focus-gender-equality-in-covid-19-response/violence-against-women-during-covid-19

ការរឹតត្បិតចល័តភាព និងការផ្អាកសកម្មភាពការងារ ការបិទសាលារៀន និងការផ្អាកសកម្មភាពក្នុងសង្គម បានរាំងស្ទះដល់សកម្មភាព និងការរៀបចំកម្មវិធីទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ[54]។

អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ ក៏កើតឡើងយ៉ាងច្រើនផងដែរ នៅក្នុងស្ថានភាពគ្រោះអាសន្ន និងវិបត្តិផ្សេងទៀត ដូចជា ស្ថានភាពក្រោយជម្លោះ និងក្នុងអំឡុង និងក្រោយគ្រោះមហន្តរាយ។ ការសិក្សាជាច្រើនបានបង្ហាញថា គ្រោះមហន្តរាយធម្មជាតិ បានបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើស្ត្រី និងក្មេងស្រី។ ពួកគេកាន់តែងាយប្រឈមនឹងអំពើហិង្សា និងការកេងប្រវ័ញ្ច ដោយសារការបាត់បង់ផ្ទះសម្បែង និងការបង្អាក់ប្រព័ន្ធគាំទ្របែបប្រពៃណី កង្វះលទ្ធភាពទទួលបានសេវា និងឧបសគ្គផ្នែករចនាសម្ព័ន្ធ និងឧបសគ្គសង្គមក្នុងការទទួលបានស្បៀងអាហារ ការសង្គ្រោះបន្ទាន់ សម្ភារផ្គត់ផ្គង់ និងសម្ភារអនាម័យ[55]។ ប្រភេទទូទៅនៃអំពើហិង្សា ដែលកើតឡើងក្នុងស្ថានភាពគ្រោះអាសន្ន មានដូចជា ការរំលោភសេពសន្ថវៈ និងទម្រង់ផ្សេងទៀតនៃការប្រទូស្តកេរខ្មាស និងការវាយប្រហារលើរូបរាងកាយ ការរំលោភបំពានផ្លូវចិត្ត និងផ្លូវអារម្មណ៍ ការកេងប្រវ័ញ្ច និងការជួញដូរផ្លូវភេទ។ លើសពីនេះ អំពើហិង្សាក៏អាចរារាំងមិនឱ្យស្ត្រី និងក្មេងស្រីទទួលបានសេវា ឬជម្រកសុវត្ថិភាព/ទីតាំងសុវត្ថិភាពក្នុងអំឡុងគ្រោះអាសន្នផងដែរ។

សន្តិភាព និងសន្តិសុខប្រកបដោយចីរភាពនៅកម្ពុជា អាចសម្រេចទៅបានតាមរយៈការជំរុញការចូលរួមទាំងបុរស និងស្ត្រី។ នេះទាមទារការបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការបញ្ឈប់វិសមភាពយេនឌ័រ និងការស្អប់ស្ត្រីដែល ពាក់ព័ន្ធបំផុតនឹងអំពើហិង្សាផ្លូវភេទ ទាំងក្នុងពេលមានជម្លោះ និងក្នុងពេលមានសន្តិភាព។ ភស្តុតាងបង្ហាញថា បទដ្ឋានសង្គមដែលមិនមានសមធម៌នៅកម្ពុជា រួមចំណែកដល់អំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមរយៈការលើកកម្ពស់ការអត់ឱនចំពោះអំពើហិង្សា និងការទម្លាក់ការស្តីបន្ទោសលើជនរងគ្រោះ។ នៅឆ្នាំ ២០២១ មានស្ត្រីត្រឹមតែ ៣១ ភាគរយប៉ុណ្ណោះ ដែលបានជួបប្រទះអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ ហើយបានស្វែងរកជំនួយ។ ស្ត្រីចំនួន ១៦ ភាគរយ មិនបានស្វែងរកជំនួយឡើយ ប៉ុន្តែបានប្រាប់នរណាម្នាក់អំពីអំពើហិង្សានោះ។[56] មូលហេតុចម្បងដែលស្ត្រីបានលើកឡើងចំពោះការមិនស្វែងរកសេវាដើម្បីទទួលបានជំនួយ រួមមានការជឿថា អំពើហិង្សាគឺជារឿងធម្មតា ឬមិនមែនជាការអាម៉ាស់ ឬការអាប់ឱនធ្ងន់ធ្ងរ និងការភ័យខ្លាចបាត់បង់កូន ឬបង្កភាពអាម៉ាស់ដល់គ្រួសារ។[57]

វិបត្តិកូវីដ-១៩ បានរំលេចភាពចាំបាច់ដែលរាជរដ្ឋាភិបាលកម្ពុជាត្រូវពង្រឹងប្រព័ន្ធគាំពារសង្គមរបស់ខ្លួន ជាពិសេសសម្រាប់ស្ត្រីងាយរងគ្រោះ និងធានាថា ការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រត្រូវបានដាក់បញ្ចូលក្នុងការរៀបចំផែនការគ្រោះអាសន្ន។ មេរៀនដែលទទួលបានពីការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ គូសបញ្ជាក់ពីសារៈសំខាន់នៃការដាក់បញ្ចូលការទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រទៅក្នុងផែនការឆ្លើយតបបន្ទាន់ និងត្រៀមបង្ការគ្រោះមហន្តរាយ ដែលបន្សីុគ្នានឹងស្តង់ដារការទប់ស្កាត់ និងការឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រាអាសន្ន (GBViE)។ នៅកម្ពុជា សេវាទាក់ទងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រមិនត្រូវបានចាត់ទុកជាអាទិភាពសំខាន់ នៅក្នុងផែនការមេសម្រាប់ការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ ឡើយ។ ការទទួលបានសេវាសំខាន់ៗសម្រាប់ស្ត្រី ដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ រងផលប៉ះពាល់ដោយសារការពន្យារពេល ឬការឆ្លើយតបយឺតយ៉ាវ។ បញ្ហានេះតម្រូវឱ្យមានការសម្របសម្រួល ដូចជា ការប្រើប្រាស់បរិក្ខារការពារខ្លួន ការបង្កើនការទំនាក់ទំនងតាមទូរស័ព្ទ និងការផ្តល់សេវាតាមអ៊ីនធឺណិតមួយចំនួន។[58]

### ៣.១.២ ស្ត្រីក្នុងស្ថានភាពក្រោយជម្លោះ និងការកសាងសន្តិភាពនៅកម្ពុជា

កម្ពុជា មានប្រវត្តិសាស្ត្រនាពេលថ្មីៗ ដែលគួរឱ្យចាប់អារម្មណ៍ជុំវិញការកសាងសន្តិភាព និងការអភិវឌ្ឍ ដោយបានផ្លាស់ប្តូរពីជម្លោះប្រដាប់អាវុធ តាមរយៈបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងការកសាងប្រទេសជាតិទៅជាការសម្រេចបានកំណើនសេដ្ឋកិច្ចជាប់លាប់ក្នុងរយៈពេលបួនទសវត្សរ៍កន្លងមក បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម។ ក្នុងរយៈពេល ២៥ ឆ្នាំកន្លងមកនេះ គោលនយោបាយ ឈ្នះ-ឈ្នះ របស់រដ្ឋាភិបាល បាននាំមកនូវសន្តិភាព ឯកភាពជាតិ និងបូរណភាពទឹកដី[59] និងទទួលស្គាល់ស្ត្រីថាជាឆ្អឹងខ្នងនៃសង្គម។ ក្រោយការបញ្ចប់ជម្លោះក្នុងស្រុក ស្ត្រីដែលមានជាង ៦០ភាគរយនៃចំនួនប្រជាជន

[54] https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2020/brief-prevention-violence-against-women-and-girls-and-covid-19-en.pdf?la=en&vs=3049
[55] https://documents1.worldbank.org/curated/en/937751468329371031/pdf/929670REVISED00ent0Brief0APRIL02015.pdf
[56] អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ ២០២១-២០២២, ទំព័រ ៣២១
[57] ក្រសួងកិច្ចការនារី ឆ្នាំ ២០១៥, ការស្ទាបស្ទង់មតិថ្នាក់ជាតិស្តីពីសុខភាពនិងបទពិសោធន៍ជីវិតរបស់ស្ត្រីក្នុងប្រទេសកម្ពុជា, របាយការណ៍សង្ខេប, ទំព័រ ២០-២១
[58] ផលប៉ះពាល់នៃជំងឺកូវីដ១៩លើការទទួលបានសេវាសំខាន់ៗសម្រាប់ជនរងគ្រោះជាស្ត្រីនៃអំពើហិង្សាផ្អែកលើយេនឌ័រ, លទ្ធផលរកឃើញក្រសួងកិច្ចការនារី, ACCESS, ខែឧសភា ឆ្នាំ ២០២២
[59] រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០២៣ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១, ២០២៤-២០២៨

ពេញវ័យ និងបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសន្តិភាព និងសន្តិសុខ តាមរយៈសកម្មភាពសេដ្ឋកិច្ច ការកសាងទំនុកចិត្តឡើងវិញ តាមរយៈសមាគម និងបណ្តាញស្ត្រី និងការចូលរួមនៅគ្រប់កម្រិតនៃរដ្ឋាភិបាល ចាប់ពីថ្នាក់ភូមិ និងថ្នាក់ឃុំ រហូតដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ខេត្ត និងថ្នាក់ជាតិ[60]។ ចក្ខុវិស័យថ្នាក់ជាតិរបស់កម្ពុជាសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព គឺចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០ បន្សុីគ្នាយ៉ាងខ្លាំងជាមួយនឹងរបៀបវារៈឆ្នាំ ២០៣០ តាមរយៈការខិតខំសម្រេចបានគោលដៅសន្តិភាព វិបុលភាព ភពផែនដី និងភាពជាដៃគូ ដោយផ្តោតសំខាន់លើសិទ្ធិមនុស្ស សេចក្តីថ្លៃថ្នូរ និងសមភាពសម្រាប់ប្រជាជនគ្រប់រូប[61]។

អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ មានការរីករាលដាលនៅក្នុងអំឡុងពេលមានជម្លោះ។ ជនរងគ្រោះនៅតែរងទុក្ខដោយការប៉ះទង្គិចទាំងផ្លូវចិត្ត និងផ្លូវកាយយូរអង្វែង បន្ទាប់ពីឧប្បត្តិហេតុដំបូង។ វប្បធម៌និទណ្ឌភាពក្នុងអំឡុងពេលសង្គ្រាម ចំណែករួមដល់ការបន្តទទួលយកអំពើហិង្សាផ្លូវភេទ ក្នុងពេលដែលមានសន្តិភាព[62]។ ក្នុងសហគមន៍ជាច្រើន ជនបង្ក និងអ្នករស់រានមានជីវិតរស់នៅជាមួយគ្នា ដោយគ្មានការដោះស្រាយការប៉ះទង្គិចផ្លូវចិត្តពីអតីតកាល។ ប្រជាជនកម្ពុជាភាគច្រើនដែលកើតក្រោយសម័យសង្គ្រាម មានការយល់ដឹងតិចតួចអំពីប្រវត្តិសាស្ត្រថ្មីៗរបស់ពួកគេ[63]។ ការទប់ស្កាត់មិនឱ្យអំពើហិង្សាកើតឡើងវិញ ទាមទារការប្តេជ្ញាឱ្យមានការផ្សះផ្សាគ្នា ដែលចូលរួមដោយសង្គមទាំងមូល រួមទាំងរដ្ឋាភិបាល គ្រឹះស្ថានសិក្សា វិស័យឯកជន សង្គមស៊ីវិល ស្ត្រី បុរស និងយុវជន។

បទពិសោធន៍របស់កម្ពុជា តាមរយៈអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បង្ហាញពីឱកាសពិសេសមួយ ក្នុងការពង្រឹងបន្ថែមនូវសន្តិភាព និងការអភិវឌ្ឍនៅក្នុងប្រទេស។[64] ដោយត្រូវបានបង្កើតឡើងនៅឆ្នាំ២០០១ អ.វ.ត.ក តំណាងឱ្យជំហានដ៏សំខាន់មួយឆ្ពោះទៅរកយុត្តិធម៌ និងការផ្សះផ្សា ក្រោយរបបខ្មែរក្រហម និងអំពើប្រល័យពូជសាសន៍។ ការវិវត្តន៍ដ៏សំខាន់មួយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺការទទួលស្គាល់កាន់តែខ្លាំងចំពោះជនរងគ្រោះនៅក្នុងដំណើរការនីតិវិធីរបស់ខ្លួន។ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនរងគ្រោះអាចដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី និងទាមទារសំណង "ផ្លូវចិត្ត និងសមូហភាព" ដើម្បីស្តារសេចក្តីថ្លៃថ្នូររបស់ពួកគេ តាមរយៈការទទួលស្គាល់ជាផ្លូវការ និងបង្កើតការរំឭកជាសមូហភាព។[65] គម្រោងសំណងរបស់ អ.វ.ត.ក ផ្តោតលើបីផ្នែកសំខាន់ៗ៖ ការអប់រំ ការចងចាំ និងការស្តារនីតិសម្បទា។ ក្នុងចំណោម ១៣ គម្រោង ដែលបានអនុវត្តដើម្បីផលប្រយោជន៍រួម (គំនិតផ្តួចផ្តើមសំណងដែលមានគោលបំណងផ្តល់អត្ថប្រយោជន៍ដល់ក្រុមជនរងគ្រោះជាច្រើន ជាជាងជនរងគ្រោះម្នាក់ៗ) គម្រោងចំនួន ៣ ត្រូវបានបង្កើតឡើងជាពិសេសសម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ៖ គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍ (ផ្តោតលើប្រជាជនចាម និងអតីតខ្មែរក្រហម) សំឡេងពីជនជាតិភាគតិច និងការអប់រំផ្នែកច្បាប់ និងពលរដ្ឋ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីជនជាតិភាគតិច។[66]

បច្ចុប្បន្ន អ.វ.ត.ក កំពុងបំពេញមុខងារនៅសេសសល់របស់ខ្លួន រួមទាំងកិច្ចការពារជនរងគ្រោះ និងសាក្សី ការត្រួតពិនិត្យការអនុវត្តសំណង ការផ្សព្វផ្សាយនូវសមិទ្ធផលរបស់ អ.វ.ត.ក ដល់សាធារណជនទូទៅ និងការថែរក្សាបណ្ណសារ។ ខណៈពេលដែល អ.វ.ត.ក កំពុងឈានទៅរកការបិទដំណើរការទាំងស្រុង មន្ត្រីកម្ពុជា និងអ្នកជំនាញអន្តរជាតិយល់ស្របថា ការគាំទ្របន្តពីអន្តរជាតិគឺជាការសំខាន់ក្នុងការលើកកម្ពស់ការផ្សះផ្សា រួមចំណែកដល់សន្តិភាព និងស្ថិរភាពក្នុងតំបន់ និងការពារសិទ្ធិរបស់អ្នករស់រានមានជីវិតពីរបបនេះ។ នេះរួមបញ្ចូលការទទួលស្គាល់ថា ស្ត្រីមិនមែនគ្រាន់តែជាជនរងគ្រោះដោយវិបត្តិ ងាយប្រឈមហានិភ័យ ឬត្រូវការការការពារប៉ុណ្ណោះទេ ប៉ុន្តែក៏ជាអ្នកចូលរួមដ៏សកម្ម អ្នកអនុវត្តន៍ដ៏ជំនាញ និងជាអ្នករួមចំណែកបែបស្ថាបនាដល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងយូរអង្វែងសម្រាប់សន្តិភាព និងសន្តិសុខ និងវឌ្ឍនភាពសង្គមជារួមផងដែរ[67]។

បន្ថែមលើតួនាទីរបស់ខ្លួននៅក្នុង អ.វ.ត.ក រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការជាច្រើន ដើម្បីគាំទ្រដល់ការរំលឹកការចងចាំ ព្យាបាលការប៉ះទង្គិចផ្លូវចិត្ត និងការទប់ស្កាត់មិនឱ្យមានអំពើព្រៃផ្សៃនាពេលអនាគត។ វិធានការមានដូចជា ការប្រកាសយកថ្ងៃទី ២០ ខែ ឧសភា ជាថ្ងៃទិវាជាតិនៃការចងចាំ ការគាំទ្រដល់ទីតាំងរំលឹក ដូចជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងវាលពិឃាដជើងឯក និងការរៀបរៀងសៀវភៅសិក្សាមួយស្តីពីអំពើប្រល័យពូជសាសន៍តាមរយៈក្រសួងអប់រំ យុវជន និងកីឡា ក្រោមកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ សៀវភៅពុម្ពនេះលើកកម្ពស់ការទប់ស្កាត់ ការព្យាបាលផ្លូវចិត្ត កិច្ចសន្ទនាអន្តរជំនាន់ និងការផ្សះផ្សា តាមរយៈការបង្រៀនប្រវត្តិសាស្ត្រនៅក្នុងប្រព័ន្ធអប់រំ[68]។

[60] https://www.peacewomen.org/assets/file/Resources/NGO/part_goodgovernancegrounduppostconflictcambodia_march2004.pdf បទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ជាមួយស្ត្រីជាមន្ត្រីរដ្ឋាភិបាល
[61] រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០២៣ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១, ២០២៤-២០២៨; UNSDCF Cambodia 2024-2028
[62] https://gbvkr.org/gender-based-violence-under-khmer-rouge/
[63] https://www.usip.org/publications/2022/10/never-again-legacy-cambodias-khmer-rouge-trials
[64] https://cambodia.un.org/en/269119-op-ed-genocide-convention-and-cambodia-lessons-past-prevention-future#:
[65] https://www.eccc.gov.kh/en/organisation/victim-and-witness-support
[66] https://www.eccc.gov.kh/en
[67] https://www.phnompenhpost.com/opinion/cambodias-take-wps-agenda-context-covid-19
[68] https://irct.org/wp-content/uploads/2022/11/Volume-21-No.-2.pdf

អង្គការមិនមែនរដ្ឋាភិបាលបានដើរតួនាទីសំខាន់ក្នុងការផ្សះផ្សា និងការសះជារបស់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ។ ឧ. គម្រោងស្ត្រី និងយុត្តិធម៌អន្តរកាល ផ្តោតលើសកម្មភាពផ្សព្វផ្សាយ និងការស្វែងរកការគាំទ្រមតិសម្រាប់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ រួមទាំងការទទួលបានយុត្តិធម៌ ការគាំទ្រផ្នែកចិត្តសង្គម ការនិយាយការពិត និងកិច្ចសន្ទនា។[69] គំនិតផ្តួចផ្តើមផ្សេងទៀតបានលើកកម្ពស់ការយោគយល់គ្នាទៅវិញទៅមក តាមរយៈកិច្ចសន្ទនាអន្តរជំនាន់ និងពិព័រណ៍ចល័ត ជាពិសេសការគាំទ្រដល់ការសះជា និងការទទួលស្គាល់សម្រាប់ជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។[70]

បទសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ បានគូសបញ្ជាក់ពីសារៈសំខាន់នៃផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) និងភាពជោគជ័យនៃវិធីសាស្ត្រសម្របសម្រួលអ្នកពាក់ព័ន្ធចម្រុះរបស់កម្ពុជា ក្នុងការដោះស្រាយ និងឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសអំពើហិង្សាក្នុងគ្រួសារ។ ទោះយ៉ាងណាក៏ដោយ អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល មន្ត្រីស្ថានទូត ដៃគូអភិវឌ្ឍន៍ និងស្ថាប័នសិក្សាបានសម្តែងក្តីកង្វល់អំពីទម្រង់ផ្សេងៗនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី រួមទាំងប្រវត្តិសាស្ត្រនៃអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ ការប៉ះទង្គិចផ្លូវចិត្តអន្តរជំនាន់ និងបទដ្ឋាន និងផ្នត់គំនិតយេនឌ័រដែលបង្កគ្រោះថ្នាក់។ ការព្រួយបារម្ភត្រួតគ្នាទាំងនេះ ត្រូវបានកំណត់ជាបញ្ហាសន្តិសុខសំខាន់ៗដែលប៉ះពាល់ដល់ស្ត្រី និងក្មេងស្រី។ ភាគីពាក់ព័ន្ធក៏បានមើលឃើញពីប្រវត្តិសាស្ត្រក្រោយជម្លោះរបស់កម្ពុជា ភាពពាក់ព័ន្ធជាបន្តបន្ទាប់នៃយុត្តិធម៌អន្តរកាល និងបទពិសោធន៍នៃការប៉ះទង្គិចផ្លូវចិត្តអន្តរជំនាន់ និងអំពើហិង្សា ថានៅតែជាមេរៀនដ៏មានតម្លៃទាំងសម្រាប់វឌ្ឍនភាពជាតិ និងជាឧទាហរណ៍សម្រាប់ប្រទេសផ្សេងទៀត។ ស្ត្រីជាអ្នកដឹកនាំជាន់ខ្ពស់នៅក្នុងរដ្ឋាភិបាលបានសង្កត់ធ្ងន់លើសារៈសំខាន់នៃបណ្តាញស្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការដោះស្រាយជម្លោះកន្លងមក និងការពន្លឿនការកសាងសន្តិភាព និងបានកត់សម្គាល់ថា ការគាំទ្រពីអ្នកដឹកនាំជាន់ខ្ពស់ជាបុរស នៅតែមានសារៈសំខាន់ក្នុងការលើកកម្ពស់តួនាទីរបស់ស្ត្រីនៅក្នុងកិច្ចខិតខំប្រឹងប្រែងសន្តិភាព។[71]

### ៣.១.៣ គោលនយោបាយ ផែនការ និងយន្តការជាតិ

ការលុបបំបាត់គ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី គឺជាអាទិភាពចម្បងក្នុងរបៀបវារៈរបស់កម្ពុជា សម្រាប់ការអភិវឌ្ឍធនធានមនុស្ស និងភាពសុខដុមនៅក្នុងគ្រួសារ និងសង្គម។[72] ក្នុងរយៈពេល ១៥ ឆ្នាំកន្លងមកនេះ ផែនការសកម្មភាពជាតិជាច្រើនត្រូវបានអនុវត្ត ដើម្បីដោះស្រាយបញ្ហានេះ រួមមាន ៖

- ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (ផែនការ NAPVAW លើកទី ១-៣) ៖ ផែនការ NAPVAW ទី ៤ (២០២៤-២០២៨) នឹងត្រូវបានដាក់ចេញនាពេលខាងមុខ
- ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NSP-CTIP) លើកទី ១-៣ និងទី ៤ (២០២៤-២០២៨)
- ផែនការសកម្មភាពស្តីពីការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ (បានពន្យាររហូតដល់ឆ្នាំ ២០២៣)
- ផែនការសកម្មភាពស្តីពីការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់ខេត្តរតនគិរីឆ្នាំ២០១៧-២០២១។

បច្ចុប្បន្ន កម្ពុជាកំពុងរៀបចំសេចក្តីព្រាងផែនការសកម្មភាពស្តីពីការទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង និងការឆាប់មានផ្ទៃពោះក្នុងចំណោមយុវជន។

[69] https://gbvkr.org/activities/
[70] https://act-kh.org/
[71] ការសម្ភាសន៍ជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់របស់រដ្ឋាភិបាល (រដ្ឋសភា និងឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ), ខែសីហា ឆ្នាំ ២០២៤
[72] ផែនការយុទ្ធសាស្ត្រនារីរតនៈ ទី ៦ ឆ្នាំ ២០២៤-២០២៨ របស់ក្រសួងកិច្ចការនារី

កម្ពុជាបានចូលរួមក្នុងការប្តេជ្ញាចិត្តថ្នាក់តំបន់តាមរយៈអាស៊ាន ដើម្បីការពារសិទ្ធិស្ត្រី រួមទាំងសេចក្តីប្រកាសរបស់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី និងអំពើហិង្សាលើកុមារ និងផែនការសកម្មភាពថ្នាក់តំបន់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី ឆ្នាំ ២០១៦-២០២៥ (ASEAN RPA on EVAW)។ ផែនការសកម្មភាពជាតិលើកទីបីស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ ២០១៩-២០២៣ (NAPVAW III) ដែលដឹកនាំរបស់ក្រសួងកិច្ចការនារី គឺជាក្របខណ្ឌគោលនយោបាយសំខាន់ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅកម្ពុជា និងស្របទៅនឹងផែនការសកម្មភាពតំបន់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី។ ផែនការ NAPVAW III បានកំណត់អាទិភាពចំនួនបី និងរៀបរាប់ពីយុទ្ធសាស្ត្រចំនួន ៤ ៖

អាទិភាពនៃ NAPVAW III រួមមាន ៖
១.អំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាលើដៃគូស្និទ្ធស្នាល
២.ការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទ និង
៣. អំពើហិង្សាលើស្ត្រីដែលមានហានិភ័យកើនឡើង ឬនៅក្នុងក្រុមងាយរងគ្រោះ។

យុទ្ធសាស្ត្រនៃ NAPVAW រួមមាន ៖
១.ការទប់ស្កាត់
២.កិច្ចការពារផ្លូវច្បាប់ និងសេវាពហុវិស័យ
៣. ច្បាប់ និងគោលនយោបាយ និង
៤.ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ (M&E)។[73]

ផែនការ NAPVAW លើកទីបួន (២០២៥-២០៣០) កំពុងស្ថិតក្នុងដំណាក់កាលរៀបចំ ប៉ុន្តែអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រនៅក្នុងបរិបទនៃការគំរាមកំហែងសន្តិសុខដែលកំពុងលេចឡើង និងស្ថានភាពជម្លោះ មិនត្រូវបានលើកឡើងឱ្យបានគ្រប់គ្រាន់នៅក្នុងផែនការមុនៗឡើយ។ ដូច្នេះ វាជាការសំខាន់ និងជាពេលវេលាដ៏សក្តិសមក្នុងការដាក់បញ្ចូលការទប់ស្កាត់ និងការឆ្លើយតបនឹងអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ ក្នុងបរិបទវិបត្តិ បរិបទជម្លោះ និងបរិបទមនុស្សធម៌ ទៅក្នុងផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា។

ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ កំណត់ និងចែងពីប្រភេទផ្សេងៗនៃការដាក់ពិន័យ និងទណ្ឌកម្មសម្រាប់បទល្មើសប្រឆាំងនឹងមនុស្សជាតិ និងអំពើហិង្សា ដូចជា ការរំលោភសេពសន្ថវៈ ទាសភាពផ្លូវភេទ ពេស្យាចារដោយបង្ខំ ការមានផ្ទៃពោះ ការធ្វើឱ្យអា (sterilization) និងទម្រង់ផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទ (ផ្នែកទី ២, មាត្រា ១៨៨) និងការប្រទូស្តកេរខ្មាស (ផ្នែកទី ៣ មាត្រា ២៣៩-២៥២)។ ក្រមនេះមាននិយមន័យដាច់ដោយឡែកមួយ និងទណ្ឌកម្មសម្រាប់ការបៀតបៀនផ្លូវភេទ ក្នុងមាត្រា ២៥០។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ (ច្បាប់អំពើហិង្សាក្នុងគ្រួសារ) បានកំណត់ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត ក្នុងការធ្វើអន្តរាគមន៍ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ។ អនុសញ្ញា CEDAW ផ្តល់អនុសាសន៍ឱ្យមានការពិនិត្យឡើងវិញយ៉ាងទូលំទូលាយលើច្បាប់អំពើហិង្សាក្នុងគ្រួសារ ដើម្បីធានាការការពារសិទ្ធិស្ត្រីយ៉ាងពេញលេញ។[74]

ក្រុមការងារបច្ចេកទេសស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ (TWGG-GBV) ដើរតួនាទីជាយន្តការថ្នាក់ជាតិសម្រាប់រដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីចូលរួមក្នុងការចែករំលែកព័ត៌មាន ការសម្របសម្រួល និងការរៀបចំផែនការសកម្មភាពរួម។ សមាជិក TWGG-GBV រួមមានក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន ១៧ ដៃគូអភិវឌ្ឍន៍ចំនួន ៤ និងអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិលជាង ៣០។ ផែនការសកម្មភាពជាតិលើកទី ៣ ស្តីពីការទប់ស្កាត់អំពើហិង្សា រួមទាំងយន្តការសម្របសម្រួលនៃក្រុមការងារបច្ចេកទេសស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងលើយេនឌ័រនៅថ្នាក់ក្រោមជាតិ និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ បានដើរតួនាទីជាមគ្គុទេសក៍សម្រាប់កិច្ចសហប្រតិបត្តិការដែលបន្តកើនឡើងក្នុងចំណោមក្រសួង ស្ថាប័ន និងមន្ទីរនានារបស់រដ្ឋាភិបាល អង្គការសង្គមស៊ីវិល/អង្គការ

[73] ក្រសួងកិច្ចការនារី, ផែនការ NAPVAW ទី ៣ ឆ្នាំ ២០១៩-២០២៣
[74] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) ឆ្នាំ ២០១៩, សេចក្តីសង្កេតសន្និដ្ឋាន, កថាខណ្ឌ២៥ខ

មិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយ យុទ្ធនាការ និងព្រឹត្តិការណ៍សាធារណៈ។[75] ក្រោមផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សា ក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី ដើរតួនាទីជាផែនទីបង្ហាញផ្លូវសម្រាប់អ្នកសារព័ត៌មានស្តីពីស្តង់ដារនៃការរាយការណ៍អំពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ដោយរៀបរាប់អំពីទណ្ឌកម្ម និងអំពាវនាវឱ្យពង្រឹងការងារតាមដានដើម្បីធានាអនុលោមភាព[76]។

គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាពរបស់កម្ពុជា (២០០១) ដែលត្រូវបានកែប្រែវិសាលភាព និងពង្រីកដល់កម្រិតស្រុកនៅឆ្នាំ ២០២១ ដោយក្រសួងមហាផ្ទៃ[77] ផ្តល់អតិក្រមដ៏មានតម្លៃក្នុងការលើកកម្ពស់ការការពារដែលមានបរិយាបន្នយេនឌ័រនៅថ្នាក់មូលដ្ឋាន។ គោលនយោបាយនេះលើកឡើងពីបញ្ហាដែលមិនសូវត្រូវបានរាយការណ៍ និងតែងត្រូវបានមើលរំលង ដូចជា អំពើហិង្សាលើស្ត្រី និងក្មេងស្រី ការរំលោភបំពានផ្លូវភេទ និងការរើសអើង។ គោលនយោបាយនេះក៏មានគោលបំណងប្រយុទ្ធប្រឆាំងនឹងទម្រង់ផ្សេងៗនៃអំពើហិង្សាទាក់ទងនឹងយេនឌ័ររួមទាំងការជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារ និងបញ្ហាសន្តិសុខផ្សេងទៀតនៅកម្រិតសហគមន៍ ដែលពាក់ព័ន្ធនឹងបទល្មើសឆ្លងដែនផងដែរ។ នៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់ខេត្ត និងស្រុក (WCCC) មានកិច្ចប្រជុំជាទៀងទាត់ជាមួយគណៈអភិបាល ដើម្បីពិភាក្សាអំពីបញ្ហានារី កុមារ និងយុវជន។ គណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ-សង្កាត់ ក៏ជាយន្តការសំខាន់នៅថ្នាក់មូលដ្ឋានសម្រាប់ការលើកឡើងពីកង្វល់ និងចាត់វិធានការលើបញ្ហាទាក់ទងនឹងស្ត្រី កុមារ និងយុវជនផងដែរ។

នៅក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ កម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការពង្រឹងវិធានការគាំពារសង្គម និងធានាថា ប្រជាជនដែលងាយរងគ្រោះ និងជួបការលំបាក ជាពិសេសស្ត្រី ទទួលបានការគាំទ្រតាមរយៈរបបគាំពារសង្គមរបស់ខ្លួន។ ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន (២០២៣)[78] រួមបញ្ចូលអនុក្រឹត្យចំនួនបី (អនុក្រឹត្យលេខ ១៥២, ១៥៣ និង ១៥៤) ដែលផ្តោតលើជំនួយសង្គមសម្រាប់ក្រុមងាយរងគ្រោះ រួមទាំងស្ត្រី។ អនុក្រឹត្យលេខ ១៥២ ស្តីពីជំនួយសង្គមក្នុងគ្រាអាសន្ន បង្កើតក្របខណ្ឌមួយសម្រាប់ការផ្តល់ជំនួយក្នុងពេលមានវិបត្តិ។ អនុក្រឹត្យលេខ ១៥៣ ស្តីពីជំនួយសង្គមសម្រាប់ប្រជាជនងាយរងគ្រោះ ពង្រឹងបណ្តាញសុវត្ថិភាពសង្គមសម្រាប់ក្រុមងាយរងគ្រោះ រួមទាំងស្ត្រី កុមារ ចាស់ជរា និងជនមានពិការភាព។ អនុក្រឹត្យលេខ ១៥៤ ស្តីពីការសម្របសម្រួល និងការអនុវត្តកម្មវិធីជំនួយសង្គម មានគោលបំណងពង្រឹងការផ្តល់សេវា[79]។ ក្នុងអំឡុងពេលកូវីដ-១៩ មានការអនុវត្តវិធានការមួយចំនួន ដើម្បីជួយដល់ស្ត្រី និងក្មេងស្រី រួមទាំងការឧបត្ថម្ភសាច់ប្រាក់ក្នុងគ្រាអាសន្ន ជំនួយស្បៀងអាហារ និងសេវាសុខភាព[80]។

## ៣.២. ស្ត្រី និងការជួញដូរ និងបទល្មើសឆ្លងដែន

### ៣.២.១ បរិបទនៃស្ត្រី និងការជួញដូរ និងបទល្មើសឆ្លងដែន

អ្នកជួញដូរមនុស្ស កេងប្រវ័ញ្ចទាំងពលរដ្ឋខ្មែរ និងជនបរទេសនៅក្នុងប្រទេសកម្ពុជា ហើយពលរដ្ឋខ្មែរក៏ត្រូវបានជួញដូរទៅក្រៅប្រទេសផងដែរ។ នៅតំបន់អាស៊ីអាគ្នេយ៍ ទម្រង់ចម្បងនៃការជួញដូរមនុស្ស គឺសម្រាប់គោលបំណងកេងប្រវ័ញ្ចផ្លូវភេទ ដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងលើស្ត្រី និងក្មេងស្រី[81]។ គោលនយោបាយការពារជាតិ ឆ្នាំ ២០២២ របស់កម្ពុជា ចាត់ទុកការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន និងសកម្មភាពឆ្លងដែនខុសច្បាប់ផ្សេងទៀត ជាបញ្ហាធ្ងន់ធ្ងរ។ បទល្មើសទាំងនេះបង្កការគំរាមកំហែងចំពោះសន្តិភាព និងសន្តិសុខជាតិ និងអន្តរជាតិ ធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពសាធារណៈ អាចបង្កឱ្យមានការបែកខ្ញែក និងភាពតានតឹងក្នុងសង្គម នៅក្នុងព្រំដែន និងឆ្លងដែន និងបង្កើនហានិភ័យសម្រាប់សហគមន៍ដែលកំពុងងាយរងគ្រោះស្រាប់។ ក្រសួងការពារជាតិបានទទួលស្គាល់សារៈសំខាន់នៃការពង្រឹងយន្តការអន្តរស្ថាប័ន និងការបង្កើនកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ ដៃគូថ្នាក់តំបន់ និងអន្តរជាតិ ដើម្បីទប់ស្កាត់ និងឆ្លើយតបទៅនឹងបទល្មើសឆ្លងដែន។[82] ក្រសួងមហាផ្ទៃជាស្ថាប័នដឹកនាំ និងគ្រប់គ្រងកម្លាំងនគរបាលជាតិក្នុងបញ្ហាសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម[83] និងដើរតួនាទីជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NCCT)។

[75] ក្រសួងកិច្ចការនារី, ការវាយតម្លៃចុងក្រោយនៃផែនការ NAPVAW ទី ៣ ឆ្នាំ ២០១៩-២០២៣; ខែឧសភា ឆ្នាំ ២០២៣
[76] ប្រកាសលេខ ២៧១, ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០១៧, Ibid
[77] គោលដៅចម្បងទាំង៨៖ គ្មានសកម្មភាព លួច ឆក់ ប្លន់ គ្រប់ប្រភេទ; គ្មានបទល្មើសគ្រឿងញៀន; គ្មានរូបអាសអាភាស ពេស្យាចារ ការជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ ឬក្រុមក្មេងទំនើង; រក្សាអនាម័យ និងបរិស្ថានល្អ; ឆ្លើយតបទាន់ពេលវេលាទៅនឹងគ្រោះមហន្តរាយ ជំងឺឆ្លង និងការរាតត្បាតទាំងអស់; ផ្តល់សេវារដ្ឋបាល និងសាធារណៈប្រកបដោយគុណភាព និងតម្លាភាព; ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រកបដោយប្រសិទ្ធភាព; និងគ្មានគ្រោះថ្នាក់ចរាចរណ៍។
[78] រៀបចំឡើងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ និងក្រសួងផែនការ។
[79] ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ ២០២៣ ក្របខ័ណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ខែ កញ្ញា ឆ្នាំ ២០២៣
[80] របាយការណ៍ថ្នាក់ជាតិកម្ពុជា, BPfA+30 ខែ មិថុនា ឆ្នាំ ២០២៤
[81] របាយការណ៍សកលស្តីពីការជួញដូរមនុស្សរបស់ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម, ឆ្នាំ ២០២០
[82] ក្រសួងការពារជាតិ, យុទ្ធសាស្ត្រការពារជាតិឆ្នាំ ២០២២
[83] https://www.interior.gov.kh/en/about_moi

បណ្ដាប្រទេសក្នុងតំបន់អាស៊ាន ត្រូវបានចាត់ទុកថាជាប្រភព ចំណុចឆ្លងកាត់ និង/ឬគោលដៅសម្រាប់ការជួញដូរមនុស្ស។ អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង និងពិធីសារបន្ថែម ផ្ដោតលើការទប់ស្កាត់ ការការពារ ការបង្ក្រាប និងការកាត់ទោសការជួញដូរមនុស្ស។ ការជួញដូរមនុស្ស នៅតែជាបញ្ហាធ្ងន់ធ្ងរដែលប៉ះពាល់ដល់ជីវិតរបស់ស្ត្រី និងក្មេងស្រីនៅកម្ពុជា។ ទោះបីជាមិនមានទិន្នន័យអំពីអត្រាប្រេវ៉ាឡង់ថ្នាក់ជាតិក៏ដោយ ក៏គេដឹងថា ស្ត្រី និងក្មេងស្រីត្រូវបានជួញដូរសម្រាប់ការកេងប្រវ័ញ្ចពលកម្ម ការកេងប្រវ័ញ្ចផ្លូវភេទ និងការបង្ខំឱ្យសុំទាន។ របាយការណ៍ពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានកំណត់ក្រុមថ្មីៗដែលប្រឈមនឹងហានិភ័យ រួមទាំងស្ត្រីដែលត្រូវបានជួញដូរសម្រាប់ការរៀបការ ឬការដកហូតសរីរាង្គ។ ការពពោះជំនួសក៏បានលេចឡើងជាបញ្ហាផុសផុលនៅក្នុងករណីជួញដូរមនុស្សផងដែរ។[84] ការវិវត្តទាំងនេះទាមទារឱ្យមានការយល់ដឹងកាន់តែស៊ីជម្រៅ ដើម្បីធានាថា ស្ត្រីមិនត្រូវបានគេកេងប្រវ័ញ្ច ហើយសិទ្ធិរបស់ពួកគេត្រូវបានការពារ។

របាយការណ៍ឆ្នាំ ២០២៣ របស់អង្គការសហប្រជាជាតិ បានបង្ហាញឱ្យដឹងថា ប្រជាជនរាប់សែននាក់កំពុងត្រូវបានបង្ខំឱ្យចូលរួមក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំងនៅតំបន់អាស៊ីអាគ្នេយ៍ ដើម្បីប្រព្រឹត្តក្នុងបទល្មើសអនឡាញ ដូចជា សារបោកប្រាស់ដែលទាក់ទាញឱ្យចូលរួមវិនិយោគ (romance-investment scam) និងគ្រីបតូ (crypto) ការសម្អាតប្រាក់ និងល្បែងភ្នាល់ខុសច្បាប់[85]។ ស្ត្រីក៏កំពុងត្រូវបានគេកេងប្រវ័ញ្ចនៅក្នុងមជ្ឈមណ្ឌលសេវាអនឡាញបោកប្រាក់ (online scams center) នៅទូទាំងតំបន់នេះផងដែរ។ ជនរងគ្រោះនៃបទល្មើសទាំងនេះប្រឈមនឹងទម្រង់ផ្សេងៗជាច្រើននៃការរំលោភបំពាន និងការបៀតបៀន ដូចជា ការគំរាមកំហែងដល់សុវត្ថិភាព និងសន្តិសុខរបស់ពួកគេ។ ការដោះស្រាយការកើនឡើងនៃបទល្មើសអនឡាញ និងបទល្មើសបច្ចេកវិទ្យា (cybercrime) ទាមទារឱ្យមានការចូលរួមបែបបុរេសកម្មពីក្រុមហ៊ុនបច្ចេកវិទ្យា។ ក្រុមហ៊ុនទាំងនេះត្រូវធ្វើការប៉ាន់ស្មាន និងដោះស្រាយគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ (និងការប្រើប្រាស់ខុសន្ទវ) វេទិការបស់ខ្លួន ជាពិសេសពាក់ព័ន្ធនឹងផលប៉ះពាល់ផ្នែកសិទ្ធិមនុស្សលើក្រុម ឬប្រជាជនដែលកាន់តែងាយរងគ្រោះ ឬជួបការលំបាក។ ក្រៅពីនេះ ពួកគេក៏ត្រូវចូលរួមក្នុងវិធានការកែតម្រូវសមស្របផងដែរ។ ឧទាហរណ៍ ក្រុមហ៊ុន Meta បានធ្វើយុទ្ធនាការរយៈពេលខ្លីមួយនៅប្រទេសកម្ពុជា ក្នុងឆ្នាំ ២០២២ គឺយុទ្ធនាការ "តោះយើងនិយាយអំពីសារបោកប្រាស់តាមអនឡាញ" ដើម្បីជួយឱ្យប្រជាជនការពារខ្លួនពីការបោកប្រាស់តាមអនឡាញ។ ទោះជាយ៉ាងណា ចាំបាច់ត្រូវមានវិធានការជាច្រើនបន្ថែមទៀត ដើម្បីតាមដានសកម្មភាពឧក្រិដ្ឋជន ដោយមិនរឹតត្បិតលើសិទ្ធិជាមូលដ្ឋាន[86]។ កិច្ចខិតខំប្រឹងប្រែងកសាងការយល់ដឹង ក៏ត្រូវគ្របដណ្តប់ដល់តួអង្គអនុវត្តន៍ច្បាប់ ដើម្បីធានាថា ពួកគេអាចកត់សម្គាល់ជនរងគ្រោះនៃការឆបោកតាមអ៊ីនធឺណិត បទល្មើសតាមអ៊ីនធឺណិត ការរត់ពន្ធជនចំណាកស្រុកដោយឧក្រិដ្ឋជន និងប្រតិបត្តិការជួញដូរមនុស្ស និងធ្វើការបញ្ជូនសមស្របផងដែរ។

ការរីករាលដាលនៃជំងឺកូវីដ-១៩ បាននាំមកនូវការប្រែប្រួលហានិភ័យនៃការជួញដូរមនុស្ស ដោយស្ត្រីងាយរងគ្រោះខ្លាំងជាងបុរស។ ពលករទេសន្តរប្រវេសន៍ដែលត្រឡប់មកវិញ ជារឿយៗ ខ្វះសមត្ថភាពក្នុងការធានារបរចិញ្ចឹមជីវិតពេលត្រឡប់មកកម្ពុជាវិញ ព្រោះភាគច្រើន ពួកគេគ្មានការងារធ្វើ ឬមានការងារមិនគ្រប់គ្រាន់ ដែលធ្វើឱ្យពួកគេងាយរងគ្រោះខ្លាំងដោយការជួញដូរមនុស្ស។ ស្ត្រីងាយរងផលប៉ះពាល់ជាងបុរស ៖ ៦៦,៤ ភាគរយ នៃស្ត្រីជាពលករទេសន្តរប្រវេសក៍ដែលវិលត្រឡប់មកវិញ គ្មានប្រភពចំណូល (ធៀបនឹងបុរស ៤៨ ភាគរយ)[87]។ តាមសេចក្តីរាយការណ៍ ការបិទព្រំដែនបានបង្កើនហានិភ័យនៃការរំលោភបំពានដោយមេខ្យល់ សម្រាប់ជនចំណាកស្រុកដែលកំពុងស្វែងរកការងារ។ ហានិភ័យនៃការជួញដូរមនុស្សសម្រាប់ការពពោះជំនួសនៅតែមាន ដោយរបាយការណ៍មួយចំនួនបានឱ្យដឹងថា ការរៀបការបោកប្រាស់ត្រូវបានគេប្រើប្រាស់ដើម្បីគេចវេសពីច្បាប់ និងបទបញ្ញត្តិដែលពាក់ព័ន្ធនឹងការពពោះជំនួស។ បញ្ហានេះរួមផ្សំនឹងហានិភ័យជាបន្តបន្ទាប់នៃការជួញដូរមនុស្ស ដូចជា ការកេងប្រវ័ញ្ចពលកម្មដើម្បីសុំទាន (ទាំងមនុស្សពេញវ័យ និងកុមារ) ការបំពានការសន្យាផ្តល់ការងារ បន្ទាប់ពីការធ្វើទេសន្តរប្រវេសន៍ និងការជួញដូរមនុស្សឱ្យធ្វើការលើទូកនេសាទ។ ការកេងប្រវ័ញ្ច និងការរំលោភបំពានតាមប្រព័ន្ធអ៊ីនធឺណិតក៏បានក្លាយជាបញ្ហាកាន់តែធំក្នុងអំឡុងវិបត្តិកូវីដ-១៩ ផងដែរ ហើយវាបានបង្កើនហានិភ័យនៃការជួញដូរមនុស្ស។[88]

[84] (គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៦) *ការពិនិត្យពាក់កណ្ដាលអាណត្តិនៃផែនការសកម្មភាពជាតិ*
[85] https://bangkok.ohchr.org/wp-content/uploads/2023/08/ONLINE-SCAM-OPERATIONS-2582023.pdf
[86] Ibid
[87] NCCT and UN COVID-19 Response and Recovery Fund. Final Survey Report, Rapid Assessment on Social and Health Impact of COVID-19 Among returning Migrant Workers in Cambodia, November 2020
[88] (គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២) *ការពិនិត្យពាក់កណ្ដាលអាណត្តិនៃផែនការយុទ្ធសាស្ត្រជាតិ ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល៥ឆ្នាំ ២០១៩-២០២៣, ខែមីនា ឆ្នាំ២០២២*

អាជ្ញាធរថ្នាក់ក្រោមជាតិ ស្ត្រី និងយុវជននៅតំបន់ជនបទ រួមទាំងក្រុមជនជាតិដើម និងជនជាតិភាគតិច បានលើកឡើងពីកង្វល់ក្នុងពេលសម្ភាសន៍ ជុំវិញការជួញដូរគ្រឿងញៀន និងការកើនឡើងនៃការប្រើប្រាស់ និងការបំពានគ្រឿងញៀនដោយយុវជន។ ពួកគេលើកឡើងថា បញ្ហាទាំងនេះបានបង្កផលជះអវិជ្ជមានលើសហគមន៍ និងសុវត្ថិភាពគ្រួសារ ហើយអ្នកប្រើប្រាស់គ្រឿងញៀនភាគច្រើនគឺជាយុវជន។ អ្នកចូលរួមបានពណ៌នាពីការឧប្បត្តិហេតុកាន់តែច្រើននៃការលួច ប្លន់ និងសកម្មភាពទាក់ទងនឹងក្រុមក្មេងទំនើង និងគូសបញ្ជាក់ថា ស្ត្រី និងក្មេងស្រីមានអារម្មណ៍ថាងាយរងគ្រោះខ្លាំង និងភ័យខ្លាច នៅពេលធ្វើដំណើរក្រោយពេលមេឃងងឹត។[89]

### ៣.២.២ គោលនយោបាយ ផែនការ និងយន្តការជាតិ

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ចាត់ទុកការជួញដូរផ្លូវភេទ និងការជួញដូរពលកម្មជាបទល្មើសព្រហ្មទណ្ឌ និងចែងអំពីទោសទណ្ឌដែលតឹងរ៉ឹងគ្រប់គ្រាន់ ហើយសម្រាប់ការជួញដូរផ្លូវភេទ សមាមាត្រទៅនឹងបទល្មើសធ្ងន់ធ្ងរផ្សេងទៀត ដូចជា ការរំលោភសេពសន្ថវៈ។[90] ការផ្តន្ទាទោសឆ្លងដែននៅតែជាការលំបាក ដោយសារគោលនយោបាយស្តីពីបត្យាប័ន និងក្របខណ្ឌច្បាប់ខុសៗគ្នារវាងបណ្តាប្រទេសនានា។ ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស នៅតែជាបញ្ហាប្រឈមដដែល។[91]

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) គឺជាយន្តការចម្បងសម្រាប់ការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ។ រចនាសម្ព័ន្ធរបស់ គ.ជ.ប.ជ ធ្វើប្រតិបត្តិការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងរួមមានក្រសួងចំនួន ២២ អង្គភាពឯកទេសចំនួន ៥ ក្រុមការងារប្រធានបទអន្តរក្រសួង/ស្ថាប័នចំនួន ៦ អគ្គលេខាធិការដ្ឋានមួយ និងគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន ២៥។ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងក្នុងស្រុកគឺជាដៃគូសំខាន់របស់ គ.ជ.ប.ជ ក្នុងការរៀបចំផែនការ ការសម្របសម្រួល ការផ្តល់សេវា និងការរាយការណ៍ ជាពិសេសនៅថ្នាក់ក្រោមជាតិ។ ការពិនិត្យពាក់កណ្តាលអាណត្តិលើផែនការសកម្មភាពជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០១៩-២០២៣ បានរកឃើញថា ខណៈដែលសម្រេចបានវឌ្ឍនភាព ចាំបាច់ត្រូវបន្តកិច្ចខិតខំប្រឹងប្រែងនានា ដើម្បីពង្រឹងវិធានការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរ និងធានាថា យន្តការនានាដំណើរការពេញលេញ ដើម្បីទប់ស្កាត់ និងឆ្លើយតបទៅនឹងការជួញដូរមនុស្ស។[92]

ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨ (ផែនការ NSP-CTIP ដំណាក់កាលទី៤) ដែលជាផែនទីបង្ហាញផ្លូវលើកទីបួន ត្រូវបានបង្កើតឡើងស្របតាមផែនការសកម្មភាពរបស់អាស៊ានសម្រាប់អនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស (ACTIP) ដោយស្ថាបនាពីលើវឌ្ឍនភាព និងមេរៀនដែលទទួលបានពីការអនុវត្តផែនការសកម្មភាពជាតិមុនៗ។ យុទ្ធសាស្ត្រទាំងបួនគឺ ៖

១. ការទប់ស្កាត់គ្រប់ទម្រង់នៃការជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ
២. ការកែលម្អគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការឆ្លើយតបទៅនឹងគ្រប់ទម្រង់នៃការជួញដូរ
៣. ការកែលម្អគុណភាព និងប្រសិទ្ធភាពនៃកិច្ចការពារជនរងគ្រោះ និង
៤. ការពង្រឹងកិច្ចសហប្រតិបត្តិការ ការរៀបចំ និងការអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានច្បាប់។[93]

---

[89] ការសម្ភាសន៍សំខាន់ៗ/ការពិភាក្សាក្រុមគោលដៅជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ស្ត្រី និងយុវជន, ខែសីហា ឆ្នាំ២០២៤
[90] https://www.state.gov/reports/2023-trafficking-in-persons-report/cambodia/
[91] (គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៦) *ការពិនិត្យពាក់កណ្តាលអាណត្តិនៃផែនការសកម្មភាពជាតិ*, ភ្នំពេញ
[92] (គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២). *ការពិនិត្យពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រជាតិ ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល៥ឆ្នាំ ២០១៩-២០២៣*, ខែមីនា ឆ្នាំ២០២២
[93] ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០២៤-២០២៨។ អាចស្វែងរកបាននៅ៖ https://download.ncct.gov.kh/plans/ncct-action-plan-2024-2028-en.pdf

ខណៈដែលសម្រេចបានវឌ្ឍនភាព នៅតែមានការងារដែលត្រូវបន្ត ដើម្បីធានាថាមានវិធានការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរ ហើយយន្តការនានាដំណើរការយ៉ាងសមស្រប ដើម្បីទប់ស្កាត់ និងឆ្លើយតបនឹងការជួញដូរមនុស្ស។

គ.ជ.ប.ជ ដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការ ជាមួយប្រទេសពាក់ព័ន្ធនានានៅក្នុងអនុតំបន់ តំបន់ និងពិភពលោក ដើម្បីអនុវត្តលិខិតុបករណ៍អន្តរជាតិ និងលិខិតុបករណ៍តំបន់ដូចតទៅ ៖ អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស ផែនការកម្មវិធីអាស៊ាន កតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ គណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ និងក្រុមការងារសម្រាប់កិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនៅក្នុងមហាអនុតំបន់មេគង្គ។[94] ក្នុងនាមជាប្រធានក្រុមការងារទំនាក់ទំនងអន្តរជាតិអន្តរក្រសួងនៃ គ.ជ.ប.ជ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានចូលរួមយ៉ាងសកម្មក្នុងគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីមហាអនុតំបន់មេគង្គប្រឆាំងការជួញដូរមនុស្ស (COMMIT) ដោយបានរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ។ តាមរយៈក្របខណ្ឌនេះ វិសោធនកម្មអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ (COMMIT) ត្រូវបានធ្វើសេចក្តីព្រាង និងមានការចាត់តាំងគ្រូបង្គោលមកពីប្រទេសសមាជិក COMMIT នីមួយៗ។ នីតិវិធីប្រតិបត្តិស្តង់ដារស្តីពីការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មជនរងគ្រោះដោយការជួញដូររវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ ត្រូវបានផ្សព្វផ្សាយ សម្រាប់ការប្រើប្រាស់ជាផ្លូវការដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។[95]

ចាប់តាំងពីឆ្នាំ ២០១៨ មក កម្ពុជាបានពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន ដោយរដ្ឋាភិបាលបានអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងគ្រឿងញៀនថ្មីមួយ ដែលផ្តោតលើកិច្ចសហប្រតិបត្តិការឆ្លងដែន យុទ្ធនាការផ្សព្វផ្សាយជាសាធារណៈ ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងការពង្រឹងការអនុវត្តច្បាប់។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានរាយការណ៍អំពីសមិទ្ធផលជាច្រើនរួមមាន ការរឹបអូសគ្រឿងញៀនខុសច្បាប់ដែលមានការកើនឡើង ការចាប់ខ្លួន និងការផ្តន្ទាទោសជនល្មើសពាក់ព័ន្ធនឹងគ្រឿងញៀន ការពង្រីកសេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងការពង្រឹងកិច្ចសហប្រតិបត្តិការឆ្លងដែន។[96] គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាពរបស់កម្ពុជា (២០១០) ដែលបានធ្វើបច្ចុប្បន្នភាពនៅឆ្នាំ ២០២១ ដើម្បីរួមបញ្ចូលថ្នាក់ស្រុក ក្រោយការអនុវត្តបាន ១០ ឆ្នាំ មានវិធានការដើម្បីលុបបំបាត់ការជួញដូរគ្រឿងញៀនខុសច្បាប់ និងការជួញដូរមនុស្សជាដើម ដោយអនុលោមតាមគោលការណ៍ណែនាំលេខ ០៥២ របស់នាយកដ្ឋាននគរបាលជាតិ ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៦។

## ៣.៣. ស្ត្រី សន្តិភាព និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត

### ៣.៣.១ បរិបទនៃយេនឌ័រ និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងពិភពឌីជីថល

សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត គឺជាផ្នែកអាទិភាពដែលត្រូវបានទទួលស្គាល់កាន់តែច្រើនឡើងសម្រាប់គោលនយោបាយសន្តិសុខជាតិ និងអន្តរជាតិ ជាពិសេសក្នុងបរិបទនៃសន្ទុះឌីជីថលូបនីយកម្ម និងការគំរាមកំហែងដែលបង្កឡើងដោយបច្ចេកវិទ្យាទំនើប ការវាយប្រហារតាមប្រព័ន្ធបច្ចេកវិទ្យា (cyberwarfare) និងការវាយប្រហារលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ។ ខណៈដែលអ៊ីនធឺណិតបានបើកទូលាយឱកាសជាច្រើនសម្រាប់ការចូលរួមរបស់ពលរដ្ឋ ការកសាងសន្តិភាពឌីជីថល និងសកម្មភាពជាពិសេសសម្រាប់ស្ត្រី និងក្រុមជួបការលំបាក វេទិកាឌីជីថលត្រូវបានប្រើប្រាស់កាន់តែច្រើនឡើង ដើម្បីផ្សព្វផ្សាយព័ត៌មានមិនពិត ពាក្យសម្តីស្អប់ខ្ពើម មាតិកាបែបសម្អប់ស្ត្រី និងជ្រុលនិយម និងដើម្បីសម្រួលដល់សកម្មភាពខុសច្បាប់ ដូចជា ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ ដែលប៉ះពាល់ដល់ស្ត្រីយ៉ាងខ្លាំង។ ដោយសារភាពជាតំណាងមិនគ្រប់គ្រាន់របស់ស្ត្រីនៅក្នុងតួនាទីដឹកនាំ និងតួនាទីធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត ការអភិវឌ្ឍបច្ចេកវិទ្យា និងការកសាងសន្តិភាពវិធានការ ដើម្បីដោះស្រាយផលវិបាកផ្អែកតាមយេនឌ័រដោយសារហានិភ័យទាំងនេះ គឺមិនទាន់សភាពការណ៍នោះទេ[97]។

[94] ការពិនិត្យជាសកលតាមកាលកំណត់របស់កម្ពុជាឆ្នាំ២០២៤
[95] គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស, ការពិនិត្យពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រជាតិ ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២ ០១៩-២០២៣
[96] របាយការណ៍ពិនិត្យតាមដានថ្នាក់ជាតិដោយស្ម័គ្រចិត្តរបស់កម្ពុជាឆ្នាំ ២០២៣
[97] Project Brief, Women, Peace and Cybersecurity: Promoting Women's Peace and Security in the Digital World (2021-2023) for the Asia Pacific Region, UN Women ROAP

ខណៈពេលដែលកម្ពុជាកំពុងឈានទៅរកសង្គមដែលមានកាន់តែមានលក្ខណៈឌីជីថល ស្របទៅនឹងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិតបង្កើតការគំរាមកំហែងកាន់តែខ្លាំង។ គោលនយោបាយការពារជាតិ ឆ្នាំ ២០២២ ទទួលស្គាល់ថា បទល្មើសបច្ចេកវិទ្យាគឺជាការគំរាមកំហែងធំមួយដល់កម្ពុជា និងតំបន់ ខណៈដែលអាស៊ីអាគ្នេយ៍ក្លាយជាមជ្ឈមណ្ឌលសេដ្ឋកិច្ច ពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការយោធា។[98] ជាមួយនឹងការរីកចម្រើននៃទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មានទំនើប ឱកាស និងសមត្ថភាពក្នុងការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិតបានកើនឡើងយ៉ាងខ្លាំង។ ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង រួមទាំងអ្នកជួញដូរមនុស្ស និងគ្រឿងញៀន និងអ្នករត់ពន្ធអាវុធជាតិផ្ទុះច្រើនតែប្រើប្រាស់ឧបករណ៍ទាំងនេះសម្រាប់គោលបំណងឧក្រិដ្ឋ។ ការគំរាមកំហែងតាមប្រព័ន្ធអ៊ីនធឺណិត ប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថិរភាពសង្គម តាមរយៈការវាយប្រហារលើសេដ្ឋកិច្ច ការងារចារកិច្ច និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជា មន្ទីរពេទ្យ ប្រព័ន្ធទូរគមនាគមន៍ និងប្រព័ន្ធដឹកជញ្ជូនជាដើម[99]។ ការវាយប្រហារលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗអាចបង្កផលប៉ះពាល់ខ្លាំងលើស្ត្រី។ នៅតែមានគម្លាតធំមួយរវាងការអនុវត្តយ៉ាងឆាប់រហ័សនូវបច្ចេកវិទ្យាថ្មីៗនៅកម្ពុជា និងសមត្ថភាពថ្នាក់ជាតិក្នុងការគ្រប់គ្រង និងកាត់បន្ថយការគំរាមកំហែងតាមប្រព័ន្ធអ៊ីនធឺណិតដែលពាក់ព័ន្ធ។[100]

គិតត្រឹមដើមឆ្នាំ ២០២៤ កម្ពុជាមានអ្នកប្រើប្រាស់អ៊ីនធឺណិតជាង ៩,៦៦ លាននាក់ ដោយមានអត្រាប្រើប្រាស់អ៊ីនធឺណិត ៥៧ ភាគរយ និងអ្នកប្រើប្រាស់បណ្តាញសង្គមចំនួន ១១,៦៥ លាននាក់ ស្មើនឹង ៦៨ ភាគរយនៃចំនួនប្រជាជនសរុប។[101] អ្នកប្រើប្រាស់បណ្តាញសង្គមជាស្ត្រី មានចំនួនតិចជាង គឺ ៤៥ ភាគរយ បើធៀបនឹងបុរសដែលមាន ៥៥ ភាគរយ។ ទោះជាយ៉ាងណា យោងតាមក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MoPTC) មានប្រជាជនកម្ពុជាតែ ៣០ ភាគរយប៉ុណ្ណោះ ដែលមានជំនាញឌីជីថលកម្រិតមូលដ្ឋាន ដើម្បីប្រើប្រាស់ប្រព័ន្ធឌីជីថល។ មានគម្លាតគួរឱ្យកត់សម្គាល់រវាងតំបន់ទីក្រុង ឬទីប្រជុំជន និងជនបទ ក្នុងការទទួលបានអ៊ីនធឺណិត ក្នុងនោះការជាវប្រើប្រាស់អ៊ីនធឺណិត និងទូរស័ព្ទចល័តភាគច្រើនប្រមូលផ្តុំក្នុងតំបន់ទីក្រុង ឬទីប្រជុំជន។[102] បទសម្ភាសន៍ជាមួយមន្ត្រីរដ្ឋាភិបាលដែលបានធ្វើឡើងសម្រាប់របាយការណ៍វិភាគស្ថានភាពនេះ បានកត់សម្គាល់ថា ការធ្វើទំនើបកម្មបច្ចេកវិទ្យាយ៉ាងឆាប់រហ័សដោយគ្មានការគាំពារ ឬអក្ខរកម្មឌីជីថលគ្រប់គ្រាន់ បង្កើនភាពងាយរងគ្រោះរបស់ប្រជាជននៅតំបន់ជនបទ និងដាច់ស្រយាល ជាពិសេសស្ត្រី យុវជន និងសហគមន៍ជនជាតិដើមភាគតិច ចំពោះការកេងប្រវ័ញ្ច ការឆបោកតាមអ៊ីនធឺណិត រូបអាសអាភាស ការបៀតបៀនផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទ ក៏ដូចជាការលួចហែកគណនី។ អ្នកជំនាញសិទ្ធិឌីជីថលបានកំណត់កត្តាចម្បងបី ដែលធ្វើឱ្យជនជាតិដើមភាគតិចងាយរងគ្រោះដោយព័ត៌មានមិនពិតតាមអ៊ីនធឺណិត ៖ កង្វះជំនាញប្រើប្រាស់បណ្តាញសង្គម និងឌីជីថល កង្វះប្រភពព័ត៌មានដែលអាចទុកចិត្តបាន និងអាចចូលប្រើប្រាស់បាន និងការបន្តជួបការលំបាកដោយសារអត្តសញ្ញាណជាតិពន្ធុរបស់ពួកគេ ដូចជា កង្វះអក្ខរកម្មភាសាខ្មែរជាដើម។[103] ការបង្កើនអក្ខរកម្មឌីជីថលតាមរយៈសកម្មភាពបណ្តុះបណ្តាល និងកសាងការយល់ដឹង បូករួមនឹងការផ្សព្វផ្សាយព័ត៌មានជាភាសាជនជាតិដើមភាគតិច នឹងជួយឱ្យសហគមន៍ ការពារខ្លួនបានកាន់តែប្រសើរពីព័ត៌មានខុស។

ការទទួលបាន និងសុវត្ថិភាពរបស់ស្ត្រីនៅលើវេទិកាអនឡាញ គឺជាកត្តាសំខាន់សម្រាប់ធានាការចូលរួមប្រកបដោយសមភាពយេនឌ័រក្នុងជីវិតសាធារណៈ។ ការស្រាវជ្រាវដែលធ្វើឡើងដោយ EngageMedia ស្តីពីសុវត្ថិភាពឌីជីថល និងសេរីភាពអ៊ីនធឺណិតនៅតំបន់អាស៊ីទក្សិណ និងអាស៊ីអាគ្នេយ៍ រកឃើញថា ការវាយប្រហារឌីជីថលដែលគួរឱ្យព្រួយបារម្ភបំផុតសម្រាប់អ្នកឆ្លើយតបក្នុងការស្ទង់មតិនៅកម្ពុជា គឺការលួចហែកគណនី (account takeover) ការក្លែងបន្លំអត្តសញ្ញាណតាមអ៊ីនធឺណិត ការឃ្លាំមើល ការបៀតបៀនតាមអ៊ីនធឺណិត និងពាក្យសម្តីស្អប់ខ្ពើម។[104] អ្នកឆ្លើយតបជាង ៦០ ភាគរយបានលើកឡើងថា ពួកគេមានសមត្ថភាពទាបក្នុងការការពារខ្លួនប្រឆាំងនឹងការគំរាមកំហែងឌីជីថលបែបនេះ ដោយសារតែភាគច្រើន ពួកគេខ្វះការយល់ដឹង និងការត្រិះរិះពិចារណាក្នុងការប្រើប្រាស់បណ្តាញសង្គម ជំនាញអក្ខរកម្មឌីជីថលខ្សោយ និងកង្វះការអប់រំគ្រប់គ្រាន់អំពីឥរិយាបថតាមអនឡាញ។ ចាំបាច់ត្រូវមានអតិក្រមសង្គមទាំងមូល ដើម្បីប្រឆាំងនឹងព័ត៌មានមិនពិត ពាក្យសម្តីស្អប់ខ្ពើម និងការរើសអើង និងប្រកាន់ខ្ជាប់សិទ្ធិបញ្ចេញមតិរបស់ស្ត្រីតាមប្រព័ន្ធអ៊ីនធឺណិត ដោយមិនភ័យខ្លាចអំពើហិង្សា ការបៀតបៀន ឬការគាបសង្កត់។

[98] ក្រសួងការពារជាតិ, យុទ្ធសាស្ត្រការពារជាតិឆ្នាំ ២០២២
[99] ដូចខាងលើ
[100] អភិបាលកិច្ចអ៊ីនធឺណិតនៅកម្ពុជា៖ អភិក្រមផ្តែកលើហានិភ័យចំពោះសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត, វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា, ខែមករា ឆ្នាំ ២០២០
[101] https://datareportal.com/reports/digital-2024-cambodia
[102] ដូចខាងលើ; ក្របខណ្ឌសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០២៤-២០២៨ របស់អង្គការសហប្រជាជាតិ
[103] https://anfrel.org/cambodias-indigenous-peoples-struggle-with-digital-literacy-on-eve-of-elections/
[104] សុវត្ថិភាពឌីជីថល និងសេរីភាពអ៊ីនធឺណិតនៅតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍, EngageMedia ២០២២, អាចស្វែងរកបាននៅ https://engagemedia.org/projects/gif-report-digital-safety/

បច្ចេកវិទ្យាឌីជីថលមានសារៈសំខាន់សម្រាប់ការងាររបស់អង្គការសង្គមស៊ីវិលរបស់ស្ត្រី និងអ្នកការពារសិទ្ធិមនុស្សរបស់ស្ត្រី។ ទោះជាយ៉ាងណា ការគំរាមកំហែងក្នុងប្រព័ន្ធបច្ចេកវិទ្យា (cyberthreat) អាចរំខានដល់ការងាររបស់ពួកគេ បំផ្លាញកេរ្តិ៍ឈ្មោះ និងថែមទាំងបង្កគ្រោះថ្នាក់ និងរបួសទៀតផង ហើយនេះបង្កផលអាក្រក់កាន់តែខ្លាំងដល់សំឡេង និងការចូលរួមរបស់ស្ត្រីក្នុងសង្គម និងដំណើរការធ្វើឱ្យមានការផ្លាស់ប្តូរ។ ការសិក្សាឆ្នាំ ២០២៤ ដោយអង្គការ UN Women ស្តីពីការគំរាមកំហែងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត ក្នុងតំបន់អាស៊ីអាគ្នេយ៍ បានរកឃើញថា អង្គការសង្គមស៊ីវិលរបស់ស្ត្រីបានលើកឡើងពីមានការយល់ឃើញក្នុងកម្រិតខ្ពស់ចំពោះការគំរាមកំហែង និងការទទួលរងការគំរាមកំហែង ជាងអង្គការសង្គមស៊ីវិលដែលមិនពាក់ព័ន្ធនឹងស្ត្រី ជាពិសេសពាក់ព័ន្ធនឹងការបៀតបៀនតាមអនឡាញ (៧៣ ភាគរយ ទល់នឹង ៤៨ ភាគរយ) ការចំអក ឬការឌឺដង (trolling) (៧១ ភាគរយ ទល់នឹង ៥៥ ភាគរយ) និងការផ្សព្វផ្សាយព័ត៌មានឯកជនក្នុងចេតនាមិនល្អ (doxing) (៦១ ភាគរយ ទល់នឹង ៣២ ភាគរយ)[105]។ ការគំរាមកំហែងទាំងនេះ ច្រើនតែផ្អែកតាមយេនឌ័រ រួមទាំងការស្អប់ខ្ពើមស្ត្រី និងការបៀតបៀនផ្លូវភេទ។ ភាពងាយរងគ្រោះសំខាន់ៗ រួមមានកង្វះការការពារឧបករណ៍ ការប្រើប្រាស់សុសវែរ (software) ដែលគ្មានអាជ្ញាប័ណ្ណ និងកង្វះគោលនយោបាយ និងនីតិវិធីស្ថាប័ន។ លទ្ធផលរកឃើញទាំងនេះគូសបញ្ជាក់ពីភាពចាំបាច់នៃការបង្កើនចំណេះដឹងស្តីពីការគំរាមកំហែងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិតដែលផ្អែកលើយេនឌ័រ ការពង្រឹងអតិក្រមបែបសហការនៅក្នុងការរៀបចំគោលនយោបាយស្តីពីសន្តិសុខប្រព័ន្ធអ៊ីនធឺណិត និងការបង្កើតវិធានការដែលមានប្រសិទ្ធភាពសម្រាប់ការទប់ស្កាត់ និងឆ្លើយតបនឹងការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត ជាពិសេសសម្រាប់អង្គការសង្គមស៊ីវិលរបស់ស្ត្រី និងអ្នកការពារសិទ្ធិមនុស្សរបស់ស្ត្រី[106]។

នៅកម្ពុជា មាត្រា ៤៩៤ និង ៤៩៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ កំណត់និយមន័យ និងហាមឃាត់ពាក្យសម្តីស្អប់ខ្ពើម។[107] ទោះជាយ៉ាងណា ការសម្ភាសន៍ជាមួយអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ស្ត្រីជនបទ និងយុវជន សម្រាប់ការវិភាគស្ថានភាពនេះ បានបញ្ជាក់ថា ជារឿយៗ ស្ត្រីជាគោលដៅនៃអំពើគំរាមកំហែង ឬយាយីប្រើប្រាស់មធ្យោបាយអ៊ីនធឺណិត ការបៀតបៀនតាមអ៊ីនធឺណិត សារបែបរើសអើង ឬពាក្យសម្តីស្អប់ខ្ពើម។ របាយការណ៍ឆ្នាំ ២០២១ ស្តីពីការបៀតបៀនតាមបណ្តាញសង្គម រកឃើញថា អ្នកឆ្លើយតបចំនួន ៣៨ ភាគរយ បានទទួលរងការបៀតបៀនតាមអ៊ីនធឺណិត ដោយមានស្ត្រីយ៉ាងច្រើនដែលរាយការណ៍ថាបានទទួលសារដែលមិនចង់ទទួលបាន[108]។ អ្នកមកពីក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា (LGBTIQ+) សកម្មជន (រួមទាំងអ្នកការពារសិទ្ធិមនុស្សរបស់ស្ត្រី និងអ្នកដឹកនាំអង្គការសង្គមស៊ីវិលរបស់ស្ត្រី) និងយុវជន បានរាយការណ៍អំពីអត្រាកាន់តែខ្ពស់នៃការបៀតបៀនតាមអនឡាញ ជាងស្ត្រី និងបុរសជម្មតា[109] ដូចជា ការបៀតបៀនផ្លូវភេទ ពាក្យសម្តីស្អប់ខ្ពើម (hate speech) និងការថ្លែងបែបស្អប់ខ្ពើមស្ត្រី។ ស្ត្រីចំនួន ២០ ភាគរយ លើកឡើងថាបានទទួលបានសារ រូបថត វីដេអូ ឬសំណើផ្លូវភេទដែលមិនសមរម្យ។ តួលេខនេះគឺជិតពីរដង បើធៀបនឹងតួលេខដែលរាយការណ៍ដោយបុរស (១១ ភាគរយ)[110]។ ខណៈដែលស្ត្រី និងបុរស បានលើកឡើងពីការទទួលរងការបៀតបៀនតាមអនឡាញក្នុងកម្រិតប្រហាក់ប្រហែលគ្នា ការបៀតបៀនបែបនេះច្រើនតែមានធម្មជាតិ និងផលជះខុសគ្នា។ ២៧ ភាគរយនៃអ្នកឆ្លើយតបដែលបានទទួលរងការបៀតបៀនតាមអនឡាញ បានលើកឡើងពីការភ័យខ្លាចចំពោះសុវត្ថិភាពរូបរាងកាយ ឬសុវត្ថិភាពរបស់មនុស្សដែលជិតស្និទ្ធនឹងពួកគេ[111]។ ការភ័យខ្លាចនេះអាចបណ្តាលឱ្យស្ត្រីបោះបង់ចោលឱកាសអាជីព ឬឱកាសចូលរួមក្នុងជីវិតសាធារណៈ កម្រិតការបញ្ចេញមតិរបស់ពួកគេ និងរឹតត្បិតការប្រើប្រាស់អ៊ីនធឺណិត។ បទពិសោធន៍អន្តរជាតិបង្ហាញថា វិធីសាស្ត្រដែលមានប្រសិទ្ធភាពមួយសម្រាប់ការចូលរួមរបស់ស្ត្រីនៅក្នុងបច្ចេកវិទ្យា និងសុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត គឺតាមរយៈការសហការជាមួយអង្គការស្ត្រី និងអ្នកការពារសិទ្ធិមនុស្សជាស្ត្រី។[112]

ការវាយតម្លៃចុងក្រោយលើផែនការសកម្មភាពជាតិលើកទី៣ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី(NAPVAW) ឆ្នាំ ២០១៩-២០២៣ បានគូសបញ្ជាក់ពីកង្វល់របស់ភាគីពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដូចជាហានិភ័យពាក់ព័ន្ធនៃការជួញដូររូបភាពបែបផ្លូវភេទ រូបអាសអាភាសកុមារ និងការបោកបញ្ឆោត (Grooming) ដែលផ្តោតគោលដៅលើស្ត្រី ក្មេងស្រី និងកុមារ។[113] បទសម្ភាសន៍ជាមួយមន្ត្រីរដ្ឋាភិបាល និងស្ត្រីនៅក្នុងកងកម្លាំងនគរបាល បានទទួលស្គាល់ទាំងការគំរាមកំហែងកាន់តែច្រើនឡើងដោយបច្ចេកវិទ្យាអនឡាញដែលគ្មានការគ្រប់គ្រង និងបទល្មើសបច្ចេកវិទ្យា និងសមត្ថភាពមានកម្រិតរបស់ពួកគេ

[105] Cybersecurity Threats, Vulnerabilities and Resilience Among Women Human Rights Defenders and Civil Society in Southeast Asia, Research Summary, UNU Macao and UN Women, May 2024. Available at: https://asiapacific.unwomen.org/en/what-we-do/peace-and-security/cybersecurity
[106] Ibid
[107] អនុសញ្ញាអន្តរជាតិ ស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍, របាយការណ៍តាមកាលកំណត់លើកទី១៨ ដល់ទី២០ ដែលត្រូវបានរួមបញ្ចូលគ្នាដាក់ជូនដោយកម្ពុជា ក្រោមមាត្រា៩នៃអនុសញ្ញា, ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣ (CERD/C/KHM/18-20)
[108] https://engagemedia.org/2023/digital-safety-threats-cambodia/
[109] Status Update: Harassment on Social Media in Cambodia; LICADHO, November 2021
[110] Ibid
[111] Ibid
[112] សង្ខេបសកម្មភាព៖ ការលុបបំបាត់ការប្រើប្រាស់ពាក្យពេចន៍បែបសម្អប់តាមអ៊ីនធឺណិត ដើម្បីធានាការចូលរួមផ្នែកនយោបាយរបស់ស្ត្រី, អង្គការ UN Women
[113] ក្រសួងកិច្ចការនារី, ការវាយតម្លៃចុងក្រោយនៃផែនការ NAPVAW ទី៣, ខែឧសភា ឆ្នាំ២០២៣

ក្នុងការទប់ស្កាត់ និងឆ្លើយតបនឹងហានិភ័យបែបនេះ។ ដែនកំណត់ទាំងនេះរួមមានបញ្ហាប្រឈមក្នុងការកំណត់អត្តសញ្ញាណជនល្មើស ការសម្របសម្រួលក្នុងចំណោមអ្នកពាក់ព័ន្ធ និងការធ្វើការជាមួយក្រសួងពាក់ព័ន្ធ។ អ្នកដឹកនាំជាស្ត្រីនៅក្នុងស្ថាប័នអនុវត្តច្បាប់ និងស្ថាប័នផ្សេងទៀតបានបង្ហាញចំណាប់អារម្មណ៍ក្នុងការទទួលបានបណ្តុះបណ្តាល និងជំនាញឌីជីថលបន្ថែមស្តីពីសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត ដើម្បីដោះស្រាយបទល្មើសបច្ចេកវិទ្យា និងការពារស្ត្រី យុវជន និងកុមារឱ្យកាន់តែមានប្រសិទ្ធភាព។[114]

### ៣.៣.២ គោលនយោបាយ ផែនការ និងយន្តការជាតិ

កម្ពុជាកំពុងអភិវឌ្ឍក្របខណ្ឌអភិបាលកិច្ចតាមប្រព័ន្ធអ៊ីនធឺណិតរបស់ខ្លួន និងបានបញ្ចូលសមភាពយេនឌ័រ និងយុទ្ធសាស្ត្រការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ ផែនការ និងគោលការណ៍ណែនាំផ្សេងៗ។ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យានៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានបង្កើតនាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅក្នុងអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដោយមានការិយាល័យឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រ (CamCERT) ជាការិយាល័យមួយរបស់ខ្លួន។ នាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដើរតួនាទីសំខាន់ក្នុងការគាំទ្រ និងសម្របសម្រួលការឆ្លើយតបនឹងឧប្បត្តិហេតុតាមប្រព័ន្ធអ៊ីនធឺណិតនៅទូទាំងប្រទេសកម្ពុជា។[115] នាយកដ្ឋាននេះក៏ជួយដល់ក្រសួង ស្ថាប័ន និងក្រុមហ៊ុនវិស័យឯកជនផ្សេងទៀតក្នុងការបង្កើនជំនាញ និងពង្រឹងជំនាញកម្លាំងពលកម្មរបស់ពួកគេ រួមទាំងស្ត្រីផងដែរ។ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាដែលចំណុះឱ្យនគរបាលជាតិ ដែលបានបង្កើតឡើងនៅឆ្នាំ២០១៦ គឺជាទីភ្នាក់ងារតែមួយគត់ដែលជនរងគ្រោះដោយការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត អាចដាក់ពាក្យបណ្តឹង ជំរុញឱ្យមានការស្រាវជ្រាវ និងកសាងសំណុំរឿង ដើម្បីវែកមុខ និងផ្តន្ទាទោសជនល្មើស។[116]

ក្របខណ្ឌគោលនយោបាយស្តីពីសេដ្ឋកិច្ច និងសង្គមឌីជីថល រៀបរាប់អំពីចក្ខុវិស័យរយៈពេលវែង ដើម្បីកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលដ៏រស់រវើកមួយ ដោយផ្តោតជាពិសេសលើការបង្កើនអក្ខរកម្មឌីជីថលរបស់ស្ត្រី ការទទួលបាន និងការចូលរួមរបស់ស្ត្រីក្នុងវិស័យឌីជីថល។ គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ឆ្នាំ ២០២២-២០៣៥ គូសបញ្ជាក់ពីគោលដៅជាក់លាក់ក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំឌីជីថលរបស់ស្ត្រី នៅក្នុងស្ថាប័នរដ្ឋាភិបាល និងផ្តល់ផែនទីបង្ហាញផ្លូវការរៀបចំកម្មវិធីសម្រាប់ក្មេងស្រី និងស្ត្រីវ័យក្មេង ដើម្បីបិទគម្លាតយេនឌ័រក្នុងវិស័យឌីជីថល។ គោលនយោបាយនេះបានបញ្ចូលទស្សនវិស័យយេនឌ័រ ដើម្បីដោះស្រាយគម្លាតឌីជីថល តាមរយៈគំនិតផ្តួចផ្តើម និងកម្មវិធីនានា ដែលមានគោលដៅផ្តល់ឱ្យស្ត្រីនូវឧបករណ៍ និងចំណេះដឹងចាំបាច់ ដើម្បីចូលរួមពេញលេញក្នុងសេដ្ឋកិច្ចឌីជីថល។[117]

តាមរយៈផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ ឆ្នាំ ២០១៩-២០២៣ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MoPTC) យុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ ២០២០ និងគោលការណ៍ណែនាំស្តីពីការលើកកម្ពស់យេនឌ័រនៅក្នុងបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (CADT) ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ផ្តល់ការបណ្តុះបណ្តាលកម្រិតមូលដ្ឋានស្តីពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងការប្រើប្រាស់ទូរស័ព្ទឆ្លាតវៃដល់ក្រុមងាយរងគ្រោះ (រួមទាំងស្ត្រីជនក្រីក្រ ជនមានពិការភាព ចាស់ជរា និងជនជាតិភាគតិច) ដើម្បីពង្រឹងសមត្ថភាពផ្នែកបច្ចេកវិទ្យាព័ត៌មាន និងសេដ្ឋកិច្ចឌីជីថលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។[118] ឧទាហរណ៍វិជ្ជមានមួយទៀតនៃការចូលរួមរបស់យុវជនក្នុងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត គឺការប្រកួតប្រជែងប្រចាំឆ្នាំរបស់នាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់និស្សិតសាកលវិទ្យាល័យ និងសាធារណជនទូទៅ ដែលមានអាយុក្រោម ៣០ ឆ្នាំ។ "StaySafeOnlineCambodia" គឺជាយុទ្ធនាការថ្នាក់ជាតិ ដើម្បីបង្កើនការយល់ដឹងអំពីសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងបង្កើនការយល់ដឹងអំពីហានិភ័យតាមប្រព័ន្ធអ៊ីនធឺណិត។

ច្បាប់សំខាន់ៗចំនួនបីកំពុងស្ថិតក្នុងការពិចារណា រួមមានសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ និងសេចក្តីព្រាងច្បាប់ស្តីពីការពារទិន្នន័យផ្ទាល់ខ្លួន។ សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតមានគោលបំណងប្រយុទ្ធប្រឆាំងនឹងបទល្មើសដែលប្រព្រឹត្តដោយប្រព័ន្ធ កុំព្យូទ័រ និងធានាសុវត្ថិភាពនៃបច្ចេកវិទ្យាថ្មី។ សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ កំណត់គោលការណ៍ វិធាន និងយន្តការ ដើម្បីគ្រប់គ្រង និងធានាសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធព័ត៌មាន

[114] ការពិភាក្សាក្រុមគោលដៅ/ការសម្ភាសន៍សំខាន់ៗជាមួយភាគីពាក់ព័ន្ធរដ្ឋាភិបាល, ខែសីហា ឆ្នាំ២០២៤
[115] អភិបាលកិច្ចអ៊ីនធឺណិតនៅកម្ពុជា៖ អភិក្រមផ្អែកលើហានិភ័យចំពោះសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត, វិទ្យាស្ថាន CDRI, ខែមករា ឆ្នាំ២០២០
[116] ដូចខាងលើ
[117] https://mptc.gov.kh/en/2022/04/cambodia-digital-government-policy-2022-2035/
[118] របាយការណ៍ជាតិកម្ពុជា, BPfA+៣០, ខែមិថុនា ឆ្នាំ២០២៤

សំខាន់ៗ ក្នុងគោលបំណងធានាការផ្តល់សេវាជាតិសំខាន់ៗប្រកបដោយសុវត្ថិភាព និងចីរភាព។ សេចក្តីព្រាងច្បាប់ស្តីពីការការពារទិន្នន័យផ្ទាល់ខ្លួនមានគោលបំណងការពារសិទ្ធិឯកជនភាពរបស់បុគ្គល និងលើកកម្ពស់ការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនដោយស្របច្បាប់ និងប្រកបដោយការទទួលខុសត្រូវ។[119] វាជាការសំខាន់ដែលត្រូវបញ្ចូលទស្សនៈយេនឌ័រទៅក្នុងដំណើរការពិនិត្យសេចក្តីព្រាងច្បាប់ ដើម្បីធានាថា អង្គការរបស់ស្ត្រី សិទ្ធិ និងសេរីភាពសម្តែងមតិរបស់ស្ត្រី ត្រូវបានការពារស្របទៅតាមគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ និងស្តង់ដារអន្តរជាតិ។

## ៣.៤. ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី

### ៣.៤.១ បរិបទនៃការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី

របៀបវារៈ WPS ទទួលស្គាល់ថា សន្តិភាពមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសមភាពយេនឌ័រ និងភាពជាអ្នកដឹកនាំរបស់ស្ត្រី។ សន្ទស្សន៍គម្លាតយេនឌ័រសកល ឆ្នាំ ២០២៣ បានចាត់ចំណាត់ថ្នាក់កម្ពុជានៅលេខរៀងទី ៩៣ ក្នុងចំណោម ១៤៦ ប្រទេសនៅទូទាំងពិភពលោក និងលេខរៀងទី ១០ ក្នុងចំណោម ១៩ ប្រទេស នៅតំបន់អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក។ ខណៈដែលកម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ស្តីពីសមភាពយេនឌ័រក្នុងវិស័យអប់រំ សុខាភិបាល និងការរស់រានមានជីវិត ការបង្កើនភាពអង់អាចផ្នែកនយោបាយដល់ស្ត្រី នៅតែមានកម្រិតទាប (០,៣៧៤)។[120]

រដ្ឋាភិបាលបានប្តេជ្ញាបង្កើនការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី តាមរយៈគោលដៅដែលបានឆ្លុះបញ្ចាំងនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDG) ៥.៥.ស្តីពីសមភាពយេនឌ័រ (៥.៥.១-៥.៥.៥) និង គោលដៅ CSDG ១៦ (១៦.៧) ក៏ដូចជាក្នុងយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័ន និងកម្មវិធីនីមួយៗ។ ចំនួនសរុបនៃមន្ត្រីរាជការស៊ីវិលជាស្ត្រីបានកើនឡើងដល់ ៤២ ភាគរយនៅឆ្នាំ ២០២៤ ហើយចំនួនស្ត្រីនៅក្នុងមុខតំណែងដឹកនាំចាប់ពីអនុប្រធានការិយាល័យដល់អគ្គនាយក និងឋានៈប្រហាក់ប្រហែល បានកើនឡើងដល់ ២៧ ភាគរយ។ ស្ត្រីតំណាងឱ្យ ១៤,៧៧ ភាគរយនៃតួនាទីជារដ្ឋលេខាធិការ និង ១៥,៦៩ ភាគរយនៃតួនាទីជាអនុរដ្ឋលេខាធិការនៅថ្នាក់ជាតិ។[121] ខណៈដែលតួលេខទាំងនេះគូសបញ្ជាក់ពីវឌ្ឍនភាពក្តី ប៉ុន្តែវានៅតែទាបជាងតួលេខក្នុងសេចក្តីសម្រេចលេខ ១៩៩០/១៥ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ ដែលណែនាំឱ្យមានសមាមាត្រអប្បបរមា ៣០ ភាគរយនៃស្ត្រីនៅក្នុងមុខតំណែងដឹកនាំ ដើម្បីសម្រេចបានសមភាពយេនឌ័រ។

ទោះបីជាមានគំនិតផ្តួចផ្តើម និងគោលនយោបាយផ្សេងៗ ដើម្បីលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីក៏ដោយ ក៏ស្ត្រីនៅតែមានតំណាងតិចតួចក្នុងតួនាទីធ្វើសេចក្តីសម្រេច ដែលនេះបានរឹតត្បិតកម្រិតនៃការឆ្លុះបញ្ចាំងអាទិភាព និងទស្សនៈវិស័យរបស់ស្ត្រីនៅក្នុងគោលនយោបាយ និងអភិបាលកិច្ច។ ក្នុងតំបន់អាស៊ីអាគ្នេយ៍ ក៏មានការព្រួយបារម្ភផងដែរចំពោះភាពជាតំណាងដ៏សំខាន់ នៅពេលដែលអ្នកដឹកនាំជាស្ត្រីមិនមានទំនាក់ទំនងជិតស្និទ្ធជាមួយអង្គការស្ត្រី ឬតំណាងគ្រប់គ្រាន់ឱ្យបញ្ហាយេនឌ័រ និងបញ្ហាប្រឈមរបស់ក្រុមស្ត្រីផ្សេងៗ ជាពិសេសស្ត្រីជួបការលំបាក។ ឧទាហរណ៍ ស្ត្រីមានតែ ១៤,៤ ភាគរយប៉ុណ្ណោះនៃសមាជិកសភានៅឆ្នាំ ២០២៤ ដែលជាការធ្លាក់ចុះពី ២១ ភាគរយនៅឆ្នាំ ២០១៨ ទោះបីជាចំនួនសមាជិកព្រឹទ្ធសភាជាស្ត្រីបានកើនដល់ ១៧,៧ ភាគរយនៅឆ្នាំ២០២៤ ក៏ដោយ។ ចំនួនមេឃុំ/ចៅសង្កាត់ជាស្ត្រី បានកើនដល់ ១៧៦ នាក់ (១០,៧៥ ភាគរយ) ក្នុងឆ្នាំ ២០២២ កើនពី ១៣០ នាក់ (៧,៩ ភាគរយ) ក្នុងឆ្នាំ ២០១៧ ហើយភាគរយរបស់ស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់ បានកើនដល់ ២២ ភាគរយនៅឆ្នាំ ២០២២ កើនពី ១៧,៧ ភាគរយក្នុងឆ្នាំ ២០១៧។[122]

កម្រិតទាបនៃអ្នកដឹកនាំជាស្ត្រីនេះ បានរួមចំណែកធ្វើឱ្យមានកង្វះបុគ្គលគំរូ និងរឿងរ៉ាវជោគជ័យដ៏លេចធ្លោ ដែលជាលទ្ធផលធ្វើឱ្យការផ្លាស់ប្តូរសង្គម និងការរីកចម្រើនផ្នែកយេនឌ័រមានភាពយឺតយ៉ាវ។ បទសម្ភាសន៍ជាមួយស្ត្រីនៅក្នុងរដ្ឋបាលមូលដ្ឋាន បានកត់សម្គាល់ថា ឧបសគ្គនានា ដូចជា កង្វះការគាំទ្រពីគ្រួសារ ការប្រឈមនឹងសម្ពាធគ្រួសារឱ្យលាឈប់ដោយសារកង្វល់អំពីសុវត្ថិភាព (ជាពិសេសនៅពេលដែលភារកិច្ចការងារតម្រូវឱ្យពួកគេធ្វើដំណើរនៅពេលយប់) និងកង្វះការគាំទ្រពីសហការីបុរស បានរារាំងការចូលរួមរបស់ស្ត្រី។[123]

[119] អភិបាលកិច្ចអ៊ីនធឺណិតនៅកម្ពុជា៖ អភិក្រមផ្អែកលើហានិភ័យចំពោះសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត, វិទ្យាស្ថាន CDRI, ខែមករា ឆ្នាំ២០២០; ការវិភាគផ្លូវច្បាប់៖ សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិតរបស់កម្ពុជា, Access Now និង ICJ, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣; ច្បាប់ការពារទិន្នន័យនៃពិភពលោក, កម្ពុជា, DLA Piper, ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤
[120] វេទិកាសេដ្ឋកិច្ចពិភពលោក, សន្ទស្សន៍គម្លាតយេនឌ័រសកល ឆ្នាំ២០២៣។ អាចស្វែងរកបាននៅ https://www.weforum.org/publications/global-gender-gap-report-2023/
[121] របាយការណ៍ជាតិកម្ពុជា BPfA+30, ខែមិថុនា ឆ្នាំ២០២៤
[122] Ibid
[123] ការសម្ភាសន៍សំខាន់ៗ/ការពិភាក្សាក្រុមគោលដៅជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ, ខែសីហា ឆ្នាំ២០២៤។

ការសិក្សាថ្មីៗដោយវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ស្តីពីស្ត្រីនៅក្នុងរដ្ឋាភិបាលមូលដ្ឋាន បានបង្ហាញថា សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ជាបុរស និងស្ត្រីភាគច្រើន រាយការណ៍ថាមានការពេញចិត្តចំពោះកម្រិតបច្ចុប្បន្ននៃភាពជាតំណាងរបស់ស្ត្រីនៅក្នុងក្រុមប្រឹក្សារបស់ពួកគេ ហើយ ៩៦ ភាគរយជឿថា រដ្ឋាភិបាលបានធ្វើសកម្មភាពគ្រប់គ្រាន់ ដើម្បីធានានូវឱកាសស្មើភាពគ្នាសម្រាប់ស្ត្រី និងបុរស ក្នុងការបម្រើការងារក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់។[124] ការសិក្សានេះណែនាំថា ប្រសិនបើមិនមានគោលនយោបាយបែបបុរេសកម្មទេ ការបង្កើនសមភាពយេនឌ័រអាចនឹងត្រូវបានបង្អាក់ ព្រោះតួអង្គភាគច្រើនលើកឡើងអំពីការមិនពេញចិត្តចំពោះស្ថានភាពបច្ចុប្បន្ន។

ស្ត្រីកម្ពុជាចំណាយពេលច្រើនលើកិច្ចការផ្ទះ និងកិច្ចការថែទាំដោយមិនទទួលបានប្រាក់ឈ្នួល ជាស្ត្រីនៅក្នុង ប្រទេសសមាជិកអាស៊ានផ្សេងទៀត។ តាមធម្មតា ស្ត្រីនៅកម្ពុជាត្រូវរក្សាតុល្យភាពរវាងការងារទទួលបានប្រាក់ឈ្នួល និងភារៈថែទាំគ្រួសារ ដែលជារឿយៗ ការណ៍នេះបានកម្រិតសមត្ថភាពរបស់ពួកគេក្នុងការចូលរួមក្នុងសកម្មភាពនានានៅក្រៅផ្ទះ។ គ្រួសារនៅតែបន្តពង្រឹងការបែងចែកការងារតាមយេនឌ័រ ដោយធ្វើសង្គមនីយកម្មស្ត្រី និងក្មេងស្រីឱ្យទទួលខុសត្រូវលើការងារថែទាំ។[125] ការទទួលខុសត្រូវលើការថែទាំ និងការងារផ្ទះដោយមិនទទួលបានប្រាក់ឈ្នួល គឺជាឧបសគ្គធំបំផុតមួយចំពោះសមភាពយេនឌ័រនៅកម្ពុជា ប៉ុន្តែកម្រត្រូវបានដោះស្រាយក្នុងគោលនយោបាយសាធារណៈ ឬកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍។[126] ការងារថែទាំគ្មានប្រាក់ឈ្នួល ដែលមានលក្ខណៈផ្អែកតាមយេនឌ័រខ្លាំង មានតម្លៃទាប និងគ្មានការគាំទ្រ រារាំងដល់កិច្ចខិតខំប្រឹងប្រែងបង្កើនការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីក្នុងដំណើរការសន្តិភាព និងសន្តិសុខ រួមទាំងការទប់ស្កាត់ជម្លោះ ការឆ្លើយតប ការកសាងសន្តិភាព និងការស្តារឡើងវិញ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍គឺលទ្ធផលរកឃើញពីការសិក្សាថ្មីៗរបស់វិទ្យាស្ថាន CDRI ស្តីពីស្ត្រីនៅក្នុងរដ្ឋាភិបាលមូលដ្ឋាន បានលើកឡើងថា សមាជិកក្រុមប្រឹក្សាជាស្ត្រីភាគច្រើន អាចគ្រប់គ្រងការទទួលខុសត្រូវឯកជនផ្ទាល់ខ្លួន និងជីវិតសាធារណៈរបស់ពួកគេដោយមិនមានការលំបាកច្រើនឡើយ។[127] ស្របពេលជាមួយគ្នានេះ សមាជិកក្រុមប្រឹក្សាជាស្ត្រី (៣៧ ភាគរយ) ច្រើនជាងបុរស (១៣ ភាគរយ) បានលើកឡើងថា សមាជិកគ្រួសារដើរតួនាទីធំបំផុតក្នុងការលើកទឹកចិត្តពួកគេឱ្យឈរឈ្មោះបោះឆ្នោត ដែលបង្ហាញថា ការគាំទ្រពីគ្រួសារគឺជាកត្តាសំខាន់ក្នុងបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងតួនាទីជាអ្នកដឹកនាំសាធារណៈ។

ទោះបីជាមានការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការបង្កើនចំនួនស្ត្រីក្នុងតួនាទីដឹកនាំក៏ដោយ ក៏ការពិភាក្សាជាមួយភាគីពាក់ព័ន្ធ (រួមមានមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ក្រុមយុវជន ស្ថាប័នសិក្សា និងស្ត្រី និងយុវជននៅជនបទ) បានបង្ហាញពីកង្វល់រួមមួយចំនួនអំពីភាពជាអ្នកតំណាងនៅមានកម្រិតរបស់ស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំ និងតួនាទីធ្វើសេចក្តីសម្រេចចិត្តនៅក្នុងរដ្ឋាភិបាល និងស្ថាប័នសាធារណៈផ្សេងទៀត។ អ្នកចូលរួមក្នុងការពិភាក្សាក៏បានលើកឡើងពីការបៀតបៀនតាមពាក្យសម្តី ការគំរាមកំហែង និងឥរិយាបថរើសអើងចំពោះស្ត្រីជាអ្នកដឹកនាំក្នុងកន្លែងការងារផងដែរ។

កង្វះការចូលរួម និងការដាត់ចេញក្រុមស្ត្រី និងយុវជនដែលទទួលបានឱកាសតិចតួច ជាពិសេសជនជាតិដើម ជនជាតិភាគតិចក្រុមភាគតិចខាងសាសនា និងវប្បធម៌ និងជនក្រីក្រនៅជនបទ ត្រូវបានលើកឡើងថាជាឧបសគ្គចម្បងដែលរារាំងការចូលរួមក្នុងរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ និងការពន្លឿនសមភាពយេនឌ័រ។ ការសិក្សាថ្មីៗមួយស្តីពីសិទ្ធិស្ត្រីជនជាតិភាគតិចនៅកម្ពុជា បានបង្ហាញថា អ្នកឆ្លើយតបចំនួន ៦១ ភាគរយ បានលើកឡើងថា ស្ត្រីមិនដែល ឬកម្រចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងកម្រិតសហគមន៍ ដើម្បីដោះស្រាយបញ្ហា ឬការអភិវឌ្ឍមូលដ្ឋានណាស់។ មូលហេតុដែលបានលើកឡើង រួមមានភារៈការងារថែទាំដោយមិនទទួលបានប្រាក់ឈ្នួល បទដ្ឋានសង្គមដែលមិនលើកទឹកចិត្តឱ្យស្ត្រីចូលរួមក្នុងកិច្ចការសាធារណៈ ឬនយោបាយ កង្វះការអញ្ជើញឱ្យចូលរួម ឬការផ្តល់ចន្លោះសុវត្ថិភាព ដើម្បីចែករំលែកទស្សនៈ និងភាពរសើបផ្នែកនយោបាយ ជាពិសេសស្តីពីបញ្ហាដីធ្លី។[128]

[124] វិទ្យាស្ថាន CDRI, ស្ថានភាពស្ត្រីនៅក្នុងរដ្ឋាភិបាលឃុំ/សង្កាត់, ខែមិថុនា ឆ្នាំ២០២៤
[125] គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (២០២២)
[126] ក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា (២០២៣)
[127] ស្ថានភាពស្ត្រីនៅក្នុងរដ្ឋាភិបាលឃុំ/សង្កាត់, វិទ្យាស្ថាន CDRI, ខែមិថុនា ឆ្នាំ២០២៤
[128] *សំឡេង និងភាពមើលឃើញ៖ ការស្វែងយល់ដោយការចូលរួមអំពីសិទ្ធិមនុស្សរបស់ស្ត្រីជនជាតិភាគតិចនៅកម្ពុជា*,  អង្គការនារីដើម្បីសន្តិភាព, ខែមករា ឆ្នាំ២០២៤

បទសម្ភាសន៍ជាមួយស្ត្រីជាអ្នកដឹកនាំជាន់ខ្ពស់មួយចំនួននៅក្នុងរដ្ឋាភិបាល បានទទួលស្គាល់ថា ការគាំទ្រពីអ្នកដឹកនាំជាន់ខ្ពស់ និងសហការីជាបុរស មានសារៈសំខាន់ក្នុងការបង្កើតបរិយាកាសការងារល្អ និងឱកាសសម្រាប់ស្ត្រីក្នុងការឈានទៅកាន់មុខតំណែងធ្វើសេចក្តីសម្រេចចិត្ត។[129] ឧទាហរណ៍ច្បាស់លាស់មួយនៃការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី គឺកិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី ២ ដែលបានធ្វើឡើងនៅខែ តុលា ឆ្នាំ ២០២២ និងធ្វើជាប្រធានដោយសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាក្នុងពេលនោះ។ កិច្ចប្រជុំកំពូលនោះត្រូវបានរៀបចំឡើង ក្រោមប្រធានបទនៃសេចក្តីប្រកាសស្តីពី "ការកសាងអនាគតប្រកបដោយចីរភាព បរិយាបន្ន និងកាន់តែរឹងមាំ ៖ បំផុសសហគ្រិនភាពរបស់ស្ត្រីនៅក្នុងអាស៊ាន"[130]។ ក្នុងសុន្ទរកថាសម្តេចតេជោ ហ៊ុន សែន បានគូសបញ្ជាក់ថាចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីបង្ហាញសក្តានុពលរបស់ស្ត្រី និងបង្កើតបរិយាកាសដែលអំណោយផលសម្រាប់កំណើនសហគ្រិនភាពរបស់ស្ត្រីនៅក្នុងតំបន់។

ការសិក្សាថ្មីៗមួយស្តីពីស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់ បានបង្ហាញថា ១៨ ភាគរយនៃសមាជិកក្រុមប្រឹក្សាជាស្ត្រី បានលើកឡើងថា មេឃុំ/ចៅសង្កាត់របស់ពួកគេជាអ្នកដែលបានផ្តល់ការលើកទឹកចិត្តច្រើនបំផុតឱ្យពួកគេទទួលបានការតែងតាំង ឬបោះឆ្នោតជ្រើសតាំង។

ទោះយ៉ាងណា នៅតែមានឥរិយាបថរើសអើងចំពោះស្ត្រីនៅក្នុងមុខតំណែងជាអ្នកដឹកនាំនៅកម្រិតរដ្ឋាភិបាលមូលដ្ឋាន ៖ ៤៦ភាគរយនៃសមាជិកក្រុមប្រឹក្សាជាបុរសដែលបានសម្ភាសន៍ (ធៀបនឹង ២១ ភាគរយនៃសមាជិកក្រុមប្រឹក្សាជាស្ត្រីដែលបានសម្ភាសន៍) បានបង្ហាញថា បុរសដើរតួនាទីជាអ្នកដឹកនាំនយោបាយប្រសើរជាងស្ត្រី។[131] នេះជាសញ្ញាបង្ហាញថា ត្រូវការកិច្ចខិតខំប្រឹងប្រែងបន្តទៀត ដើម្បីដោះស្រាយឥរិយាបថរើសអើង និងលើកកម្ពស់ សមភាពយេនឌ័រក្នុងតួនាទីជាអ្នកដឹកនាំ។

### ៣.៤.២ គោលនយោបាយ ផែនការ និងយន្តការជាតិ

យន្តការជាតិសម្រាប់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី រួមមានក្រសួងកិច្ចការនារី (MoWA) និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (CNCW) ហើយត្រូវបានពង្រឹងដោយក្រុមការងារបច្ចេកទេសស្តីពីយេនឌ័រ (TWG-G) និងក្រុមការងារបញ្ជ្រាបយេនឌ័រ (GMAGs) នៅតាមក្រសួង និងស្ថាប័នពាក់ព័ន្ធ។

តាមរយៈផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំរបស់ខ្លួន (ផែនការនារីរតនៈ) ក្រសួងកិច្ចការនារី ខិតខំពង្រីកការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីជាតិ និងលើកកម្ពស់គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើមដែលឆ្លើយតបនឹងយេនឌ័រ។ គោលបំណងយុទ្ធសាស្ត្រទី ៥ នៃផែនការយុទ្ធសាស្ត្រនារីរតនៈទី ៤ ឆ្នាំ ២០២៤-២០២៨ ស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច គឺដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនការចូលរួមរបស់ស្ត្រី និងក្មេងស្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិតក្នុងវិស័យសាធារណៈ។[132] ដោយកត់សម្គាល់ថា ការងារផ្ទះ និងការងារថែទាំដែលមិនផ្តល់ប្រាក់ឈ្នួល គឺជាឧបសគ្គចម្បងដែលរារាំងការបង្កើនភាពអង់អាចដល់ស្ត្រី ក្រសួងកិច្ចការនារី បានធ្វើការស្រាវជ្រាវ ចងក្រងមេរៀនដែលទទួលបាន និងបានចាប់ផ្តើមកិច្ចពិគ្រោះយោបល់ក្នុងឆ្នាំ ២០២១ ដើម្បីរៀបចំសេចក្តីព្រាងក្របខណ្ឌស្តីពីសេដ្ឋកិច្ចដែលគិតគូរពីសុខុមាលភាព និងផែនការសកម្មភាព។ ផែនការនេះផ្តោតលើផ្នែកសំខាន់ ៤ ៖ ហេដ្ឋារចនាសម្ព័ន្ធថែទាំ សេវាថែទាំ គោលនយោបាយថែទាំដែលពាក់ព័ន្ធនឹងការងារ និងកិច្ចគាំពារសង្គមដែលពាក់ព័ន្ធនឹងការថែទាំ[133]។

យន្តការសំខាន់មួយនៅថ្នាក់ជាតិ គឺក្រុមការងារបញ្ជ្រាបយេនឌ័រតាមវិស័យ (GMAGs) ដែលត្រូវបានបង្កើតឡើងនៅក្នុងក្រសួង និងស្ថាប័នជំនាញពាក់ព័ន្ធ។ ក្រុមការងារទាំងនេះធានាការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយស្ថាប័ន ផែនការ និងកម្មវិធីតាមវិស័យ តាមរយៈផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ (GMAPs) និងផែនការសកម្មភាពបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ ក្រសួងពាក់ព័ន្ធភាគច្រើនរួមបញ្ចូលគំនិតផ្តួចផ្តើមអភិវឌ្ឍន៍សមត្ថភាព ដើម្បីបង្កើនចំនួនស្ត្រីនៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត និងបានកំណត់គោលដៅ ដើម្បីបង្កើនចំនួនស្ត្រីនៅក្នុងមុខតំណែងជាអ្នកដឹកនាំ ទាំងនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។[134]

---

[129] ការសម្ភាសន៍សំខាន់ៗជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់របស់រដ្ឋាភិបាល (រដ្ឋសភា និងឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ), ខែសីហា ឆ្នាំ២០២៤
[130] https://www.mfaic.gov.kh/posts/2022-10-17-News-The-2nd-ASEAN-Women-Leaders--Summit---12-October-2022----08-39-05
[131] វិទ្យាស្ថាន CDRI, ស្ថានភាពស្ត្រីនៅក្នុងរដ្ឋាភិបាលឃុំ/សង្កាត់, ខែមិថុនា ឆ្នាំ២០២៤
[132] ក្រសួងកិច្ចការនារី, ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ២០២៤-២០២៨
[133] Ibid
[134] របាយការណ៍ជាតិកម្ពុជា BPfA+30, ខែមិថុនា ឆ្នាំ២០២៤

ក្រោមកម្មវិធីជាតិសម្រាប់រដ្ឋបាលសាធារណៈ ឆ្នាំ២០២១-២០៣០ ក្រសួងនានាកំពុងអនុវត្តគោលការណ៍ណែនាំរបស់ក្រសួងមុខងារសាធារណៈ ស្តីពីការជ្រើសរើសបេក្ខភាពជាស្ត្រីចាប់ពី ២០ ទៅ ៥០ ភាគរយ ទៅក្នុងក្របខណ្ឌមុខងារសាធារណៈ ដើម្បីសម្រេចគោលដៅ ៤៤ ភាគរយនៃមន្ត្រីរាជការស៊ីវិលជាស្ត្រីនៅឆ្នាំ ២០២៣ និងគោលដៅ ២៧ ភាគរយនៃស្ត្រីនៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) ដើម្បីបង្កើនចំនួនស្ត្រីនៅក្នុងមុខតំណែងថ្នាក់គ្រប់គ្រង នៅថ្នាក់ក្រោមជាតិ ឆ្នាំ ២០២៤-២០២៨ និងគោលនយោបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្នាំ២០១៩ មានការផ្តោតសំខាន់លើការបង្កើនចំនួនមន្ត្រីរាជការជាស្ត្រី និងការពង្រឹងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅថ្នាក់ក្រោមជាតិ។

## ៣.៥. ស្ត្រីក្នុងវិស័យសន្តិសុខ ការទូតអន្តរជាតិ និងកងកម្លាំងរក្សាសន្តិភាព

### ៣.៥.១ ស្ត្រីក្នុងវិស័យអនុវត្តច្បាប់នៅកម្ពុជា

ស្ត្រីនៅក្នុងវិស័យសន្តិសុខដើរតួនាទីសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពប្រតិបត្តិការនៃការអនុវត្តច្បាប់ រួមទាំងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងការជួញដូរក្នុងតំបន់ព្រំដែន។ ការស្រាវជ្រាវស្តីពីស្ត្រីក្នុងវិស័យអនុវត្តច្បាប់នៅក្នុងតំបន់អាស៊ានបានរកឃើញហេតុផលចំនួនប្រាំ ដែលចាំបាច់ត្រូវមានការចូលរួមរបស់ស្ត្រី ៖

១. ការបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព តាមរយៈកម្លាំងពលកម្មដែលមានភាពចម្រុះ និងបរិយាបន្ន ដែលធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងារ
២. ការបង្កើនជំនឿទុកចិត្តរបស់សហគមន៍ និងធម្មានុរូបភាពរបស់ស្ថាប័ន
៣. ការឆ្លើយតបកាន់តែប្រសើរឡើងទៅនឹងអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ
៤. ការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនការអនុលោមតាមការប្តេជ្ញាចិត្តជាតិ និងអន្តរជាតិ និង
៥. ការបំពេញការងារនគរបាលប្រកបដោយវិជ្ជាជីវៈ។[135]

មានកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ ដើម្បីកែលម្អគុណភាព និងការឆ្លើយតបនឹងយេនឌ័រនៃការអនុវត្តច្បាប់នៅកម្ពុជា។ ក្នុងនាមជាអ្នកផ្តល់សេវាជួរមុខ មន្ត្រីនគរបាលទទួលបានការបណ្តុះបណ្តាលស្តីពីការឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដូចជា ទំនាក់ទំនងកម្រិតមូលដ្ឋាន ការសម្របសម្រួលសេវា និងទិន្នន័យ ក្រុមការងារនគរបាលសហគមន៍ សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រសម្រាប់ស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សា និងស្តង់ដារសេវាអប្បបរមាចាំបាច់ដែលផ្តល់ដោយក្រុមការងារស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។[136]

របាយការណ៍ស្រាវជ្រាវស្តីពីស្ត្រីក្នុងវិស័យអនុវត្តច្បាប់នៅក្នុងតំបន់អាស៊ាន បានបញ្ជាក់ពីតួនាទីសំខាន់របស់ស្ត្រីក្នុងការកាត់បន្ថយជម្លោះ និងការបង្កើតយន្តការទុកចិត្តទៅវិញទៅមករវាងអង្គភាពនគរបាល និងសហគមន៍មូលដ្ឋាន។ ការចូលរួមរបស់មន្ត្រីនគរបាលជាស្ត្រីពាក់ព័ន្ធនឹងកិច្ចសហការកាន់តែច្រើនពីសហគមន៍ និងការគិតវិជ្ជមានចំពោះធម្មានុរូបរបស់នគរបាល។ ទោះជាយ៉ាងណា ភាគរយនៃស្ត្រីនៅក្នុងទីភ្នាក់ងារអនុវត្តច្បាប់នៅបណ្តាប្រទេសសមាជិកអាស៊ាននៅតែមានកម្រិតទាប ដែលមានចាប់ពី ៦ ភាគរយនៅប្រទេសឥណ្ឌូណេស៊ី ដល់២០ ភាគរយនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ[137] ដោយកម្ពុជាមានប្រមាណ ១១ ភាគរយក្នុងឆ្នាំ ២០២៤។ មានគម្លាតយេនឌ័រកាន់តែធំ នៅក្នុងមុខតំណែងកាន់តែខ្ពស់។ ខណៈដែលកម្ពុជាមិនទាន់មានចំណុចដៅ ឬកូតាផ្លូវការសម្រាប់ចំនួនមន្ត្រីនគរបាលជាស្ត្រី ផែនការសកម្មភាពបញ្ជ្រាបយេនឌ័ររបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ឆ្នាំ ២០១៩-២០២៣[138] និងឆ្នាំ ២០២៤-២០២៨ ដោយស្របទៅនឹងគោលការណ៍ណែនាំស្តីពីការជ្រើសរើសមន្ត្រីរបស់ក្រសួងមុខងារសាធារណៈ ស្នើឱ្យមានស្ត្រីយ៉ាងតិច ២០ ភាគរយ ក្នុងកងកម្លាំងដែលជ្រើសរើសថ្មី។

[135] ស្ត្រីក្នុងវិស័យអនុវត្តច្បាប់នៅក្នុងតំបន់អាស៊ាន, របាយការណ៍សង្ខេប, ស្ថាប័នអាំងទែប៉ូល, ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម និងអង្គការ UN Women, ២០២០
[136] ក្រសួងកិច្ចការនារី, ការវាយតម្លៃចុងក្រោយនៃ NAPVAW III, ខែឧសភា ឆ្នាំ២០២៣
[137] ស្ត្រីក្នុងការអនុវត្តច្បាប់នៅក្នុងតំបន់អាស៊ាន, របាយការណ៍សង្ខេប, ស្ថាប័នអាំងទែប៉ូល, ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម និងអង្គការ UN Women, ២០២០
[138] ដូចខាងលើ

បទសម្ភាសន៍ជាមួយមន្ត្រីក្រសួងមហាផ្ទៃ និងមន្ត្រីនគរបាលជាស្ត្រី បានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់ពួកគេក្នុងការចូលរួម និងជំរុញរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា និងការបន្តកិច្ចសហការជាមួយក្រសួងកិច្ចការនារី ជាពិសេសក្នុងការអនុវត្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ និងការលើកកម្ពស់ស្ត្រីកាន់តែច្រើននៅក្នុងតួនាទីដឹកនាំ និងការធ្វើសេចក្តីសម្រេចចិត្ត។ ពួកគេបានបង្ហាញចំណាប់អារម្មណ៍ជាពិសេសចង់ឱ្យមានស្ត្រីកាន់តែច្រើនចូលរួម និងការបង្កើនអក្ខរកម្មឌីជីថល និងជំនាញបច្ចេកវិទ្យារបស់ពួកគេ ដើម្បីដោះស្រាយការគំរាមកំហែងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងបទល្មើសបច្ចេកវិទ្យាដែលកំពុងកើនឡើងប្រឆាំងនឹងស្ត្រី និងក្មេងស្រី។[139] ពួកគេក៏បានគូសបញ្ជាក់ផងដែរអំពីសារៈសំខាន់នៃការមានមន្ត្រីនគរបាលជាស្ត្រីកាន់តែច្រើនក្នុងការិយាល័យរដ្ឋបាលតាមសហគមន៍ ដោយបានលើកឡើងពីសមត្ថភាពរបស់មន្ត្រីនគរបាលជាស្ត្រីក្នុងការឆ្លើយតបទៅនឹងស្ថានភាពជម្លោះដែលអាចកើតមាន និងបម្រើស្ត្រី និងគ្រួសារបានកាន់តែប្រសើរ។ ការទទួលបានការបណ្តុះបណ្តាលភាសាត្រូវបានគេចាត់ទុកថា មានសារៈសំខាន់សម្រាប់វឌ្ឍនភាពអាជីព និងការអភិវឌ្ឍជំនាញជាពិសេសសម្រាប់មុខតំណែងជាអ្នកដឹកនាំ និងការចូលរួមនៅថ្នាក់តំបន់ និងអន្តរជាតិ។

## ៣.៥.២ បរិបទរបស់ស្ត្រីនៅក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការកសាងសន្តិភាព

កិច្ចសហប្រតិបត្តិការអន្តរជាតិ គឺជាអាទិភាពសំខាន់មួយដូចដែលបានគូសបញ្ជាក់នៅក្នុងគោលនយោបាយការពារជាតិឆ្នាំ២០២២។ ពីប្រទេសដែលរងគ្រោះដោយសង្គ្រាមទៅជាប្រទេសដែលរួមចំណែកក្នុងការកសាងសន្តិភាព កម្ពុជា បាននិងកំពុងមានភាពសកម្ម និងប្តេជ្ញាចិត្តធានាឱ្យមានការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីក្នុងដំណើរការសន្តិភាព និងសេវាសន្តិសុខនៅតាមតំបន់ជម្លោះសង្គ្រាមផ្សេងៗនៅលើពិភពលោក។[140] ស្ត្រីកម្ពុជាបានចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ក្រោមមជ្ឈមណ្ឌលជាតិសម្រាប់ការគ្រប់គ្រងកងកម្លាំង រក្សាសន្តិសុខ បោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម (NPMEC) តាំងពីឆ្នាំ ២០០៦។

គិតត្រឹមខែ ធ្នូ ឆ្នាំ ២០២៤ កម្ពុជាជាប់ចំណាត់ថ្នាក់លេខរៀងទី ១៤ ក្នុងចំណោម ១២០ ប្រទេសដែលបញ្ជូនស្ត្រីទៅបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។[141] ក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន កម្ពុជាជាប្រទេសឈានមុខគេ ដោយមានយោធិននារី ២១,២ ភាគរយក្នុងកងកម្លាំងរក្សាសន្តិភាពសរុបរបស់ខ្លួន[142] ដែលលើសពីគោលដៅកំណត់ ១៥ ភាគរយរបស់អង្គការសហប្រជាជាតិ។ កម្ពុជាបានបំពេញការប្តេជ្ញាចិត្តថ្នាក់ជាតិរបស់ខ្លួនក្នុងការបញ្ជូនកងកម្លាំងរក្សាសន្តិភាពជាស្ត្រីលើសពី ២០ ភាគរយក្នុងឆ្នាំ ២០២៤ ដោយទទួលស្គាល់សារៈសំខាន់ក្នុងការបង្កើនការចូលរួមរបស់ពួកគេនៅក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។[143]

ទោះបីជារាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងពង្រីកសារៈសំខាន់នៃសេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCR 1325) លើឆាកអន្តរជាតិក៏ដោយ ក៏ការស្ទង់មតិមួយបានបង្ហាញពីការយល់ដឹងមានកម្រិតក្នុងចំណោមកងកម្លាំង RCAF ៖ អ្នកឆ្លើយតប ៨៩ ភាគរយ (បុរស ៩៣ ភាគរយ និងស្ត្រី ៩១ ភាគរយ) បានលើកឡើងថា ពួកគេមិនដែលបានដឹងឮអំពីសេចក្តីសម្រេចនេះទេ[144]។

លទ្ធផលរកឃើញសំខាន់ៗពីរបាយការណ៍ស្តីពីលទ្ធផលនៃការវាស់ស្ទង់ឱកាសសម្រាប់ស្ត្រី នៅក្នុងប្រតិបត្តិការរក្សាសន្តិភាព (MOWIP) ឆ្នាំ ២០២៣ បានបង្ហាញថា កងយោធពលខេមរភូមិន្ទ (RCAF) មិនបានដាក់កំហិតណាមួយលើស្ត្រីដែលបម្រើការក្នុងបេសកកម្មរក្សាសន្តិភាពឡើយ។ បុរស និងស្ត្រី បម្រើការដោយស្មើភាពគ្នានៅក្នុងតួនាទីដឹកនាំ (សូម្បីតែបន្ទាប់ពីពិចារណាលើឋានន្តរសក្តិ) និងក្នុងតួនាទីប្រយុទ្ធ និងប្រតិបត្តិការ នៅពេលបំពេញបេសកកម្ម។[145] ស្ត្រីភាគច្រើន (៧៩ ភាគរយ) មានយ៉ាងហោចណាស់អ្នកណែនាំម្នាក់នៅក្នុងកងយោធពលខេមរភូមិន្ទ (RCAF) និងមានសម្ព័ន្ធមិត្តជាបុរសដែលខិតខំគាំទ្រសិទ្ធិស្ត្រី។ ក្នុងនោះផងដែរ អ្នកឆ្លើយតបជាបុរស និងស្ត្រីភាគច្រើន មិនមានជំនឿតឹងរ៉ឹងអំពីតួនាទីយេនឌ័រតាមបែបប្រពៃណីនោះទេ។[146] ទោះយ៉ាងណា មន្ត្រីជាស្ត្រីភាគច្រើន(២៤ ភាគរយ) បើធៀបនឹងបុរស (៨ ភាគរយ) បានលើកឡើងពីការប្រឈមនឹងការមាក់ងាយពីសង្គម ប្រសិនបើពួកគេត្រូវបានបញ្ជូនទៅប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ដោយការមាក់ងាយភាគច្រើនគឺមកពីសមាជិកគ្រួសារ។

[139] ការពិភាក្សាក្រុមគោលដៅជាមួយក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ, ខែសីហា ឆ្នាំ២០២៤
[140] https://www.phnompenhpost.com/opinion/gender-equality-cambodia-women-leadership-peace-and-security
[141] https://peacekeeping.un.org/sites/default/files/02_country_ranking_81_december_2024.pdf
[142] Ibid
[143] កងយោធពលខេមរភូមិន្ទ. (២០២២). គោលនយោបាយការពារជាតិ២០២២
[144] របាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃការវាស់ស្ទង់ឱកាសសម្រាប់ស្ត្រីនៅក្នុងប្រតិបត្តិការរក្សាសន្តិភាព (MOWIP) របស់កងយោធពលខេមរភូមិន្ទឆ្នាំ ២០២៤
[145] របាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃការវាស់ស្ទង់ឱកាសសម្រាប់ស្ត្រីនៅក្នុងប្រតិបត្តិការរក្សាសន្តិភាព (MOWIP) របស់កងយោធពលខេមរភូមិន្ទឆ្នាំ២០២៣, ២០២៤
[146] ដូចខាងលើ

នៅឆ្នាំ ២០២៣ ស្ត្រីពីរនាក់ត្រូវបានដំឡើងឋានៈទៅជាឧត្តមសេនីយ៍ត្រី និងឧត្តមសេនីយ៍ឯក ស្របតាមការប្ដេជ្ញាចិត្តរបស់ RCAF ក្នុងការដោះស្រាយបញ្ហាយេនឌ័រ។ ប៉ុន្តែទោះបីជាមានការប្តេជ្ញាចិត្តយ៉ាងខ្លាំងពីរដ្ឋាភិបាលក៏ដោយ ក៏នៅតែមានចំនួនស្ត្រីតិចតួចនៅក្នុង RCAF និងក្នុងមុខតំណែងដឹកនាំ ៖ ជាធម្មតា អង្គភាពយោធា និងកងកម្លាំងនគរបាលដែលបានបង្កើតឡើង មានស្ត្រីតិចជាង ២០ ភាគរយ ហើយអង្គភាពប្រតិបត្តិការតែ ១០ ភាគរយប៉ុណ្ណោះដែលរួមបញ្ចូលស្ត្រី និងមានស្ត្រីតែ ១០ ភាគរយប៉ុណ្ណោះ ដែលបានកាន់មុខតំណែងដឹកនាំ ។

ការបណ្តុះបណ្តាលមុនពេលបញ្ជូនគឺជាលក្ខខណ្ឌតម្រូវមួយ ហើយស្ត្រី និងបុរស ៩៣ ភាគរយ បាននិយាយថាពួកគេបានចូលរួមក្នុងការបណ្តុះបណ្តាលនោះ[148]។ ការបណ្តុះបណ្តាលផ្នែកយេនឌ័រមិនមែនជាលក្ខខណ្ឌចាំបាច់សម្រាប់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ (RCAF) ឡើយ ទោះបីជាពួកគេបានទទួលព័ត៌មានស្តីពីកម្មវិធីពាក់ព័ន្ធនឹងយេនឌ័រ និងសារៈសំខាន់នៃការសម្រេចបានសមភាពយេនឌ័រក៏ដោយ។ ទោះជាយ៉ាងណា មានថ្នាក់ដឹកនាំជាន់ខ្ពស់ និងកងកម្លាំងតិចជាងពាក់កណ្តាល ដែលបានទទួលការបណ្តុះបណ្តាលស្តីពីយេនឌ័រ។ ក្នុងចំណោមថ្នាក់ដឹកនាំ មានបុរស និងស្ត្រីចំនួន ៤៣ ភាគរយ ដែលបានចូលរួមការបណ្តុះបណ្តាលស្តីពីយេនឌ័រ ដែលត្រូវបានរៀបចំឡើងជាពិសេសសម្រាប់ថ្នាក់ដឹកនាំ។ បុរសចំនួន ១៩ ភាគរយ និងស្ត្រីចំណួន ២៤ ភាគរយ បានចូលរួមការបណ្តុះបណ្តាលទូទៅស្តីពីយេនឌ័រសម្រាប់មន្ត្រីគ្រប់ឋានន្តរសក្តិ ហើយបុរសចំនួន ៤៣ ភាគរយ និងស្ត្រី ៥៧ ភាគរយ លើកឡើងថាបានចូលរួមការបណ្តុះបណ្តាលស្តីពីយេនឌ័រនៅកម្រិតបណ្ឌិតសភាមូលដ្ឋាន[149]។

តួលេខទាំងនេះបញ្ជាក់ពីលទ្ធផលរកឃើញពីការសិក្សាផ្សេងទៀត ៖ ការចូលរួមរបស់បុរសច្រើនតែមានកម្រិតទាប នៅពេលដែលការបណ្តុះបណ្តាលផ្នែកយេនឌ័រក្នុងពេលបម្រើការងារនោះ មិនមែនជាកាតព្វកិច្ច។[150]

ការវាយតម្លៃនេះក៏បានកត់សម្គាល់ផងដែរថា ជំនឿមួយចំនួនស្តីពីយេនឌ័រក្នុងចំណោមថ្នាក់ដឹកនាំ RCAF នៅតែរារាំងការចូលរួមរបស់ស្ត្រីក្នុងបេសកកម្មរក្សាសន្តិភាព។ របាយការណ៍ឆ្នាំ ២០២៣ ស្តីពីលទ្ធផលនៃការវាស់ស្ទង់ឱកាសសម្រាប់ស្ត្រីនៅក្នុងប្រតិបត្តិការរក្សាសន្តិភាព ស្នើឱ្យតម្រូវថ្នាក់ដឹកនាំចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងយល់ដឹងអំពីយេនឌ័រប្រចាំឆ្នាំ ដើម្បីកាត់បន្ថយការពឹងផ្អែកលើផ្នត់គំនិតយេនឌ័រ និងស្នើឱ្យអនុវត្តកម្មវិធីអប់រំ និងលើកកម្ពស់យល់ដឹង ដើម្បីដោះស្រាយការយល់ខុសទាក់ទងនឹងការបញ្ជូនស្ត្រីឱ្យចូលរួមប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។

RCAF មានក្របខណ្ឌច្បាប់សម្រាប់ដោះស្រាយការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (SEA) ហើយការបណ្តុះបណ្តាលមុនពេលបញ្ជូន មានមាតិកាស្តីពីក្រមប្រតិបត្តិ RCAF និងគោលនយោបាយ SEA ក៏ដូចជាសិទ្ធិមនុស្ស និងការបៀតបៀនផ្លូវភេទ។ ការហ្វឹកហ្វឺនរួមគ្នាត្រូវបានទទួលយកយ៉ាងទូលំទូលាយ (៩៥ ភាគរយ) ហើយបុរស និងស្ត្រីឧស្សាហ៍បានធ្វើការជាមួយគ្នា (៧៥ ភាគរយ) ជាញឹកញាប់ គឺរៀងរាល់ថ្ងៃ (អ្នកឆ្លើយតបជាបុរស ៦៨ ភាគរយ និងអ្នកឆ្លើយតបជាស្ត្រី ៨៥ ភាគរយ)។ ក្រៅពីនេះ អ្នកឆ្លើយតប ៥៧ ភាគរយ (បុរស ៤៩ ភាគរយ និងស្ត្រី ៦៩ ភាគរយ) បានលើកឡើងថា ពួកគេប្រាស្រ័យទាក់ទងជាមួយសមាជិកដែលមានភេទផ្ទុយគ្នាជារៀងរាល់ថ្ងៃ។ នេះជាសញ្ញាបង្ហាញពីសនិទ្ទពលសង្គមវិជ្ជមានក្នុងស្ថាប័ន។

ទោះជាយ៉ាងណា របាយការណ៍ឆ្នាំ ២០២៣ ស្តីពីលទ្ធផលនៃការវាយតម្លៃ MOWIP បានរកឃើញថា ក្នុងចំណោមកងកម្លាំងដែលបានស្ទង់មតិ មានកងកម្លាំងតែ ៥៨ ភាគរយប៉ុណ្ណោះដែលបានដឹងអំពីគោលនយោបាយបៀតបៀនផ្លូវភេទ គ្មានប្រព័ន្ធបណ្តឹងផ្ទៃក្នុង ហើយកងកម្លាំងភាគច្រើន (បុរស ៦០ ភាគរយនិងស្ត្រី ៧៥ ភាគរយ) ព្រួយបារម្ភអំពីការចោទប្រកាន់មិនពិតលើករណីបៀតបៀនផ្លូវភេទ ដោយមន្ត្រីរួមការងារ។ មានឱកាសបណ្តុះបណ្តាលយេនឌ័រនៅពេលបញ្ជូនទៅបេសកកម្ម ប៉ុន្តែអត្រាចូលរួមគឺកាន់តែទាប ៖ មានបុរសតែ ៥០ ភាគរយ និងស្ត្រីតែ ៣៩ ភាគរយប៉ុណ្ណោះ ដែលបានទទួលការបណ្តុះបណ្តាលស្តីពីការទប់ស្កាត់ SEA ហើយមានបុរសតែ ៤០ ភាគរយ និងស្ត្រីតែ ២៩ ភាគរយប៉ុណ្ណោះដែលបានចូលរួមវគ្គយេនឌ័រឯកទេស ដូចជា វគ្គស្តីពីការទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាលើជនស៊ីវិល។ ការវាយតម្លៃ MOWIP បានស្នើឱ្យអនុវត្តការបណ្តុះបណ្តាលជាកាតព្វកិច្ចស្តីពីយេនឌ័រ និង SEA នៅដំណាក់កាលមុនពេលចល័តកម្លាំង ដំណាក់កាលកំពុង

[147] របាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃការវាស់ស្ទង់ឱកាសសម្រាប់ស្ត្រីនៅក្នុងប្រតិបត្តិការរក្សាសន្តិភាព (MOWIP) របស់កងយោធពលខេមរភូមិន្ទឆ្នាំ២០២៣, ២០២៤
[148] ដូចខាងលើ ទំ. ៤៨
[149] ដូចខាងលើ ទំ. ៩៦
[150] ស្ត្រីក្នុងវិស័យអនុវត្តច្បាប់នៅក្នុងតំបន់អាស៊ាន, របាយការណ៍សង្ខេប, ស្ថាប័នអាំងទែប៉ូល, ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម និងអង្គការ UN Women, ២០២០

បម្រើការ និងដំណាក់កាលចល័តកម្លាំង សម្រាប់កងកម្លាំងទាំងអស់ និងធានាការរួមបញ្ចូលនីតិវិធីបណ្តឹង និងការការពារអ្នកផ្តល់ដំណឹង។

ការពិភាក្សាក្រុមជាមួយកងកម្លាំងរក្សាសន្តិភាពជាស្ត្រី បានបង្ហាញថា ពួកគេមានមោទនភាពក្នុងការបម្រើប្រទេសរបស់ខ្លួន ទទួលបានទំនុកចិត្តលើខ្លួនឯងតាមរយៈការបណ្តុះបណ្តាល និងបទពិសោធន៍ និងត្រូវបានទទួលស្គាល់ដោយថ្នាក់លើថាជាអ្នកសម្រុះសម្រួលដ៏ស្ទាត់ជំនាញ ដែលអាចដោះស្រាយជម្លោះក្នុងសហគមន៍មូលដ្ឋាន ជាពិសេសជម្លោះដែលពាក់ព័ន្ធនឹងស្ត្រី។ ស្ត្រីជាច្រើនបានលើកឡើងថា ពួកគេមានការគាំទ្រពីគ្រួសារ ដែលជាកត្តាជំរុញទឹកចិត្តឱ្យពួកគេចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។ បញ្ហាសុវត្ថិភាព និងសន្តិសុខដែលបានលើកឡើង រួមមានកង្វះទឹកស្អាត និងសម្ភារៈអនាម័យនៅពេលបំពេញបេសកកម្ម ភាពងាយរងគ្រោះក្នុងអំឡុងពេលធ្វើដំណើរ និងការទទួលរងការបំភិតបំភ័យ ឬការបៀតបៀនតាមរយៈពាក្យសម្តីពីបុរសក្នុងមូលដ្ឋាន នៅពេលបំពេញបេសកកម្មនៅក្រៅប្រទេស។[151]

ក្នុងអំឡុងកិច្ចពិភាក្សាក្រុមគោលដៅ កងកម្លាំងរក្សាសន្តិភាពជាបុរសបានទទួលស្គាល់ថា កងកម្លាំងរក្សាសន្តិភាពជាស្ត្រីមានភាពងាយរងគ្រោះខ្លាំងដោយការបៀតបៀន និងការរំលោភបំពានផ្លូវភេទ នៅពេលបម្រើការងារជាកងកម្លាំងរក្សាសន្តិភាព អ.ស.ប នៅក្រៅប្រទេស។ ពួកគេក៏បានកត់សម្គាល់ផងដែរថា បទដ្ឋាន និងផ្នត់គំនិតយេនឌ័រទូទៅស្តីពីតួនាទីរបស់ស្ត្រីក្នុងការរក្សាសន្តិភាព បានដាក់កំហិតលើប្រភេទនៃការបណ្តុះបណ្តាល និងជំនាញដែលស្ត្រីទទួលបានក្នុងអំឡុងពេលមុនការចេញដំណើរ។ កងកម្លាំងរក្សាសន្តិភាពជាបុរសមួយចំនួនទទួលស្គាល់ថា ពួកគេស្ទាក់ស្ទើរមិនចង់ឱ្យសហការីជាស្ត្រីចូលរួមជាមួយពួកគេ ក្នុងពេលចុះល្បាត ដោយបញ្ជាក់ថា ពួកគេមានអារម្មណ៍ថាមានបន្ទុក និងការទទួលខុសត្រូវលើការធានាសុវត្ថិភាពផ្លូវកាយរបស់សហការីជាស្ត្រីរបស់ខ្លួន។ បុរសផ្សេងទៀតបានសម្តែងការព្រួយបារម្ភថា ស្ត្រីមួយចំនួនមិនសូវចេះសម្របខ្លួនក្រោមស្ថានភាពតានតឹង (ឧ. ឆាប់ស្លន់) ឬខ្វះការបណ្តុះបណ្តាលគ្រប់គ្រាន់ក្នុងការដំណើរការ ឬថែទាំយានយន្ត ឬគ្រឿងចក្រធ្ងន់ៗ ដូច្នេះហើយពួកគេមិនសូវអាចជួយអ្វីបានច្រើនទេ ក្នុងអំឡុងពេលបំពេញបេសកកម្មនៅក្រៅប្រទេស។[152]

ទោះបីជាមានកង្វល់មួយចំនួនទាំងនេះក៏ដោយ ក៏មានការគាំទ្រយ៉ាងខ្លាំងពីស្ត្រី និងបុរស ក្នុងការបន្តបង្កើនចំនួនស្ត្រីកម្ពុជានៅក្នុងកងកម្លាំងការពារជាតិ កាត់បន្ថយផ្នត់គំនិតយេនឌ័រ តាមរយៈការផ្តល់ការបណ្តុះបណ្តាលមុនពេលចេញដំណើរប្រកបដោយសមភាព និងទូលំទូលាយ (រួមទាំងការបណ្តុះបណ្តាលស្តីពីភាសា សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងអក្ខរកម្មឌីជីថល) និងលើកកម្ពស់ភាពជាគំរូរបស់ស្ត្រីកាន់តែច្រើន ដែលរួមចំណែកដល់ដំណើរការកសាងសន្តិភាព ទាំងនៅកម្រិតជាតិ និងអន្តរជាតិ។ លើសពីនេះ អ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅបានស្នើឱ្យរៀបចំផែនការច្បាស់លាស់មួយ ដើម្បីគាំទ្រស្ត្រីឱ្យឡើងកាន់មុខតំណែងដឹកនាំកាន់តែខ្ពស់ ក្នុងការរក្សាសន្តិភាព និងការចរចា ដោយយកគំរូតាម ឧ. ប្រទេសជប៉ុន និងអេស្ប៉ាញ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MoFAIC) ទទួលស្គាល់តួនាទីសំខាន់របស់ស្ត្រីក្នុងការរួមចំណែកដល់ស្ថិរភាពនយោបាយ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម និងសន្តិភាព ក៏ដូចជាការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើតឱកាសឱ្យស្ត្រីបម្រើការជាមន្ត្រីរាជការ។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MoFAIC) ក៏ដើរតួនាទីសំខាន់ផងដែរក្នុងការការពារពលរដ្ឋកម្ពុជានៅក្រៅប្រទេស រួមទាំងតាមរយៈអន្តរាគមន៍ ដើម្បីជួយប្រជាជនកម្ពុជាដែលងាយរងគ្រោះ ជាពិសេសស្ត្រី និងកុមារ ដែលជាជនរងគ្រោះដោយការជួញដូរ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយក្រសួងពាក់ព័ន្ធនានារបស់កម្ពុជា រដ្ឋាភិបាលបរទេស ទីភ្នាក់ងារអន្តរជាតិ និងអង្គការក្នុងស្រុក។ សកម្មភាពអាទិភាព រួមមានការពង្រីកឱកាសសម្រាប់ការបណ្តុះបណ្តាលភាសា និងជំនាញសម្រាប់មន្ត្រីរាជការស៊ីវិលជាស្ត្រី និងការលើកកម្ពស់ស្ត្រីកាន់តែច្រើននៅក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិត និងនៅក្នុងវេទិកាថ្នាក់តំបន់ និងអន្តរជាតិទាំងអស់។[153]

[151] ការពិភាក្សាក្រុមគោលដៅជាមួយកងកម្លាំងរក្សាសន្តិភាពជាស្ត្រីកម្ពុជា, ភ្នំពេញ, ខែសីហា ឆ្នាំ២០២៤
[152] ការពិភាក្សាក្រុមគោលដៅជាមួយកងកម្លាំងរក្សាសន្តិភាពជាបុរសកម្ពុជា, ភ្នំពេញ, ខែសីហា ឆ្នាំ២០២៤
[153] ផែនការសកម្មភាពស្តីពីសេចក្តីសង្កេតសន្និដ្ឋាននៃអនុសញ្ញា CEDAW របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី២០២០-២០២៣

ស្ត្រីកំពុងចូលរួមយ៉ាងសកម្មក្នុងកិច្ចការបរទេស និងវេទិកាអន្តរជាតិ។ នៅឆ្នាំ ២០២៤ ស្ត្រីចំនួនប្រាំពីរនាក់តំណាងឱ្យកម្ពុជាក្នុងនាមជាឯកអគ្គរដ្ឋទូតនៅស្ថានទូតចំនួន ២៧ និងស្ថានទូតបេសកកម្មអចិន្ត្រៃយ៍កម្ពុជាចំនួន ៤ នៅបរទេស ដោយមានស្ត្រីពីរនាក់បន្ថែមទៀតបំពេញតួនាទីជាអគ្គកុងស៊ុល[154]។ សមាមាត្រនៃការចូលរួមរបស់ស្ត្រីកម្ពុជាក្នុងកិច្ចការការទូត គឺ ១៦ ភាគរយ ដែលច្រើនជាងបន្តិច បើធៀបនឹងមធ្យមភាគសកល ១៥ ភាគរយ[155]។ ទោះបីជាមានអត្រាខ្ពស់ជាងមធ្យមភាគនៃភាពជាតំណាងនៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្តកម្រិតខ្ពស់នៅកម្រិតអន្តរជាតិក៏ដោយ ក៏ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីពន្លឿនការលើកកម្ពស់ស្ត្រីនៅក្នុងមុខតំណែងជាអ្នកដឹកនាំនៅក្នុងកម្រិតអន្តរជាតិ និងវិស័យការទូត ដើម្បីសម្រេចបានសមភាពយេនឌ័រ។

### ៣.៥.៣ គោលនយោបាយ ផែនការ និងយន្តការជាតិ

គោលនយោបាយការពារជាតិឆ្នាំ ២០២២ គូសបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការការពារសន្តិភាព សន្តិសុខ និងស្ថិរភាពនៅក្នុងតំបន់ និងការរួមចំណែកដល់ប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិជាសកល។ ក្រសួងការពារជាតិមានគោលនយោបាយបញ្ជ្រាបយេនឌ័រដឹកនាំដោយក្រុមបញ្ជ្រាបយេនឌ័រ ដែលមាន សកម្មភាពសំខាន់ៗ ដូចជា កិច្ចខិតខំប្រឹងប្រែងបង្កើនចំនួនស្ត្រីនៅក្នុងមុខតំណែងជាអ្នកដឹកនាំ និងការធ្វើសេចក្តីសម្រេចចិត្ត។ បច្ចុប្បន្ន មានស្ត្រីបម្រើការជារដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៅក្នុងក្រសួងការពារជាតិ។

នៅថ្នាក់ជាតិ កិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់តួនាទីស្ត្រីក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិដឹកនាំដោយមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម (NPMEC)។ ការបណ្តុះបណ្តាលមុនពេលចេញដំណើរមានបីកម្មវិធី ៖ ១) កម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិ ដែលជាកាតព្វកិច្ច ២) កម្មវិធីសម្ភារៈបណ្តុះបណ្តាលស្នូលមុនពេលចេញដំណើរ ជាកម្មវិធីបណ្តុះបណ្តាលរៀបចំឡើងដោយអង្គការសហប្រជាជាតិ និង ៣) វគ្គសិក្សាសម្ភារៈបណ្តុះបណ្តាលឯកទេស។ យោងតាមការសិក្សាស្តីពីការវាស់ស្ទង់ឱកាសសម្រាប់ស្ត្រីនៅក្នុងប្រតិបត្តិការរក្សាសន្តិភាព ឆ្នាំ ២០២៣ បុរសភាគច្រើន (៨០ ភាគរយ) និងស្ត្រី (៧៩ ភាគរយ) បានចូលរួមការបណ្តុះបណ្តាលមុនពេលចេញដំណើរនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលកម្លាំងរក្សាសន្តិភាពជាតិ។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិទទួលខុសត្រូវលើការតាមដាន និងសម្របសម្រួលជាមួយមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាមនៃក្រសួងការពារជាតិ និងគណៈកម្មាធិការសម្របសម្រួលជាតិកម្ពុជាស្តីពីការបញ្ជូនកងទ័ពទៅបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។

ក្នុងផ្នែកមួយនៃកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ដែលកំពុងបន្ត កម្ពុជាបានបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក/NAADR) នៅឆ្នាំ ២០២៣ និងបានដាក់បញ្ចូលទស្សនៈយេនឌ័រទៅក្នុងក្របខណ្ឌគោលនយោបាយរបស់ខ្លួន និងគោលការណ៍ណែនាំប្រតិបត្តិ។[156] នេះរួមបញ្ចូលកម្មវិធីបណ្តុះបណ្តាលមួយចំនួនដើម្បីកសាងការយល់ដឹងរបស់អ្នកសម្របសម្រួល និងបុគ្គលិកផ្សេងទៀតស្តីពីបញ្ហាយេនឌ័រ ធានាការចូលរួមរបស់អ្នកសម្របសម្រួល និងអ្នកធ្វើសេចក្តីសម្រេចចិត្តជាស្ត្រី និងផ្តល់ការគាំទ្រឯកទេសសម្រាប់ជម្លោះដែលពាក់ព័ន្ធនឹងបញ្ហាផ្អែកលើយេនឌ័រ។ ការរួមបញ្ចូលសមភាពយេនឌ័រ និងការព្រួយបារម្ភរបស់ស្ត្រី ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តចំពោះបរិយាកាសកាន់តែមានសមធម៌ និងការគាំទ្រសម្រាប់អ្នកដែលស្វែងរកសេវាដោះស្រាយវិវាទ។

គោលបំណងសំខាន់មួយរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺការសហការជាមួយអង្គការស្ត្រី និងអង្គការសង្គមស៊ីវិល ដើម្បីផ្តល់ការគាំទ្រគ្រប់ជ្រុងជ្រោយដល់ស្ត្រីដែលពាក់ព័ន្ធក្នុងវិវាទ។[157] អ.ដ.ក. គឺជាយន្តការថ្មីមួយ ដែលមានគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងភាពរហ័សរហួនក្នុងការដោះស្រាយវិវាទ តាមរយៈការផ្សះផ្សាក្រៅប្រព័ន្ធតុលាការ និងនាំប្រព័ន្ធដោះស្រាយវិវាទឱ្យកាន់តែខិតជិតសហគមន៍ ដោយស្របទៅនឹងគោលការណ៍មិនទុកនរណាម្នាក់ចោល។ ការសិក្សានាពេលថ្មីៗនេះស្តីពីសិទ្ធិស្ត្រីជនជាតិភាគតិច បានបង្ហាញថា ការភាន់ច្រឡំជុំវិញការអនុញ្ញាតឱ្យមានការ

[154] រួមមានចិន ឥណ្ឌា ចក្រភពអង់គ្លេស វៀតណាម សាធារណរដ្ឋកូរ៉េ បែលហ្ស៊ិក និងអង្គការយូណេស្កូ។
[155] https://www.phnompenhpost.com/opinion/gender-equality-cambodia-women-leadership-peace-and-security
[156] ព្រះរាជក្រឹត្យលេខ នស/រកត/១១២៣/២៣៨១
[157] របាយការណ៍ជាតិកម្ពុជា BPfA+៣០, ខែមិថុនា ឆ្នាំ២០២៤

ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងមូលដ្ឋាន ក្នុងករណីអំពើហិង្សាទាក់ទងនឹងលើយេនឌ័រកាន់តែមានភាពស្មុគស្មាញ ដោយសារកង្វះការណែនាំប្រកបដោយប្រសិទ្ធភាពសម្រាប់អាជ្ញាធរមូលដ្ឋាន និងការពិតដែលថា ការដោះស្រាយវិវាទបែបនេះក៏ត្រូវបានអនុវត្តដោយតួអង្គនានាផងដែរ រួមទាំងសមាជិកគ្រួសារ អ្នកដឹកនាំវប្បធម៌ ឬសាសនា និងមន្ត្រីនគរបាល។[158]

ក្នុងសេដ្ឋកិច្ចបើកចំហ កម្ពុជាងាយរងគ្រោះដោយការប្រែប្រួល និងវិបត្តិខាងក្រៅ ដូចការស្តែងបញ្ជាក់ដោយវិបត្តិកូវីដ-១៩។ យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ២០២១-២០២៣ របស់កម្ពុជា កំណត់ភាពពាក់ព័ន្ធគ្នារវាងគោលនយោបាយការបរទេស និងការទូត និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ក៏ដូចជាទទួលស្គាល់សារៈសំខាន់នៃការធានាសន្តិសុខសេដ្ឋកិច្ច[159]។ ទោះបីជាយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ (២០២៤-២០២៨) និងគោលនយោបាយ និងក្របខណ្ឌតាមវិស័យជាច្រើន ទទួលស្គាល់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងការរួមចំណែករបស់ស្ត្រីដល់សន្តិភាព និងសន្តិសុខក៏ដោយ ក៏ការដាក់បញ្ចូលទស្សនៈយេនឌ័រ និងចក្ខុវិស័យ WPS នឹងពង្រឹងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ២០២៤-២០២៨ តាមរយៈការគូសបញ្ជាក់ពីតួនាទីរបស់ស្ត្រីនៅក្នុងសន្តិភាព សន្តិសុខ និងការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្រិតជាតិ កម្រិតតំបន់ និងកម្រិតអន្តរជាតិ។

## ៣.៦. ស្ត្រី និងអាកាសធាតុ សន្តិភាព និងសន្តិសុខ

### ៣.៦.១ ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ

សន្តិសុខអាកាសធាតុសំដៅលើគំនិតដែលយល់ថា ការប្រែប្រួលអាកាសធាតុបង្កឱ្យមានការគំរាមកំហែងយ៉ាងខ្លាំងដល់សន្តិសុខជាតិ និងពិភពលោក ហើយផលប៉ះពាល់របស់វាអាចនាំឱ្យមានអស្ថិរភាពសង្គម នយោបាយ និងសេដ្ឋកិច្ច។ កង្វល់សន្តិសុខដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ រួមមានផលប៉ះពាល់លើការផ្គត់ផ្គង់ស្បៀងអាហារ ទឹក និងថាមពល ការប្រជែងដណ្តើមធនធានធម្មជាតិកាន់តែខ្លាំង ការបាត់បង់របរចិញ្ចឹមជីវិត គ្រោះមហន្តរាយដែលទាក់ទងនឹងអាកាសធាតុ និងការធ្វើចំណាកស្រុក និងការផ្លាស់ទីលំនៅដោយបង្ខំ។ ជាញឹកញាប់ ស្ត្រីស្ថិតក្នុងចំណោមជនងាយរងគ្រោះខ្លាំងបំផុតដោយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ប៉ុន្តែស្ត្រីមិនមែនត្រឹមតែជាអ្នករងផលប៉ះពាល់នោះទេ ពោលគឺស្ត្រីក៏ជាភ្នាក់ងារនៃការផ្លាស់ប្តូរដ៏មានឥទ្ធិពលផងដែរ និងដើរតួនាទីសំខាន់ក្នុងសន្តិសុខអាកាសធាតុ។

របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS) និងផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ASEAN RPA-WPS) ផ្តល់ក្របខណ្ឌមួយសម្រាប់បញ្ចូលការវិភាគយេនឌ័រទៅក្នុងរចនាសម្ព័ន្ធសន្តិសុខអាកាសធាតុ។ នេះរួមមានការយល់ដឹងអំពីភាពងាយរងគ្រោះរបស់ស្ត្រីដោយការប្រែប្រួលអាកាសធាតុ និងការទទួលស្គាល់ភាពប្រទាក់ក្រឡាគ្នារវាងការបង្កើនភាពអង់អាចដល់ស្ត្រី និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីប្រើប្រាស់សក្តានុពលរបស់ស្ត្រីកសាងអនាគតដែលមាននិរន្តរភាព និងភាពធន់[160]។

កម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលងាយរងគ្រោះបំផុតដោយការប្រែប្រួលអាកាសធាតុ (លេខរៀងទី ១៤៩ ក្នុងចំណោម ១៨២ ប្រទេស ក្នុងសន្ទស្សន៍ ND-GAIN ឆ្នាំ ២០២០) ដែលមួយផ្នែកដោយសារការពឹងផ្អែកលើកសិកម្មពឹងផ្អែកលើទឹកភ្លៀងដើម្បីរក្សាការប្រកបរបរចិញ្ចឹមជីវិត ភាពងាយរងគ្រោះដោយសារទឹកជំនន់ និងផលប៉ះពាល់នៃការកើនឡើងសីតុណ្ហភាពលើសុខភាពមនុស្ស និងផលិតភាព ហើយបញ្ហាទាំងអស់នេះគួបផ្សំនឹងសមត្ថភាពបន្សាំទាប។ ដោយសារសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកលើវិស័យកសិកម្ម ទឹកជំនន់ និងរាំងស្ងួតត្រូវបានទទួលស្គាល់ថាជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរលើការអភិវឌ្ឍប្រទេស ហើយការត្រៀមបង្ការត្រូវបានកំណត់ជាអាទិភាពកំពូលនៃរបៀបវារៈសន្តិសុខជាតិ។[161] ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុរួមផ្សំនឹងការរេចរិលបរិស្ថាន អាចបង្កើនហានិភ័យនៃជម្លោះ និងការបែងចែកសង្គម ហើយទំនងជានឹងប៉ះពាល់យ៉ាងខ្លាំងដល់ស្ត្រីជនបទ ដែលតំណាងឱ្យសមាមាត្រដែលកំពុងកើនឡើងនៃកសិករប្រកបកសិកម្មដាំដុះស្រូវ។[162] ការប្រែប្រួលអាកាសធាតុក៏អាចពង្រីកវិសមភាពយេនឌ័រដែលមានស្រាប់ផងដែរដែលធ្វើឱ្យស្ត្រីកាន់តែងាយរងគ្រោះនៅក្នុងតំបន់រងផលប៉ះពាល់ដោយជម្លោះ។ ឧទាហរណ៍ ភាពខ្វះខាតធនធានអាចនាំឱ្យមានអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការកេងប្រវ័ញ្ចកាន់តែច្រើន[163]។

[158] សំឡេង និងភាពមើលឃើញ៖ ការស្វែងយល់ដោយការចូលរួមអំពីសិទ្ធិមនុស្សរបស់ស្ត្រីជនជាតិភាគតិចនៅកម្ពុជា, អង្គការនារីដើម្បីសន្តិភាព, ខែមករា ឆ្នាំ២០២៤
[159] MoFAIC, Economic Diplomacy Strategy 2021-2023
[160] NTS Insight, no IN24-01, May 2024; Engaging WPS in Climate Security – ASEAN Perspectives, by Tamara Nair
[161] កងយោធពលខេមរភូមិន្ទ, (២០២២), គោលនយោបាយការពារជាតិ។ អាចស្វែងរកបាននៅ៖ https://dot.mod.gov.kh/wp-content/uploads/2022/05/Cambodias-Defence-Policy-EN.pdf
[162] ក្របខណ្ឌសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០២៤-២០២៨ របស់អង្គការសហប្រជាជាតិខែមីនា ឆ្នាំ២០២៤។ អាចស្វែងរកបាននៅ៖ https://cambodia.un.org/en/252482-united-nations-sustainable-development-cooperation-framework-2024-2028
[163] UN Women 2024; Women, Peace and Climate Security in Asia and the Pacific, In Brief

សន្ទស្សន៍ភាពធន់របស់ស្ត្រីកម្ពុជារកឃើញថា ស្ត្រីមានភាពធន់តិចជាងបុរស ក្នុងពេលមានគ្រោះមហន្តរាយ។ កត្តាធម្មតារួមមានប្រភពចំណូលមិនស្ថិតស្ថេរ និងមិនមានសុវត្ថិភាព លទ្ធភាពមានកម្រិតក្នុងការទទួលបានហេដ្ឋារចនាសម្ព័ន្ធការពារជម្រកសុវត្ថិភាព និងប្រព័ន្ធជូនដំណឹងជាមុន លំនៅឋានទ្រុឌទ្រោម និងបណ្តាញ និងសំណាញ់សុវត្ថិភាពសង្គមខ្សោយ។[164] លើសពីនេះទៀត ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ បង្កើនបន្ទុក និងផ្លាស់ប្តូរធម្មជាតិនៃការងារថែទាំដែលមិនទទួលបានប្រាក់ឈ្នួលនៅក្នុងតំបន់រងផលប៉ះពាល់។ បទដ្ឋានយេនឌ័រដែលមានលក្ខណៈរឹតត្បិត ត្រូវបានឆ្លុះបញ្ចាំងក្នុងបំណែងចែកមិនស្មើភាពគ្នាយ៉ាងខ្លាំងនៃការងារផ្ទះ និងការងារថែទាំដែលមិនទទួលបានប្រាក់ឈ្នួល ដោយជាមធ្យម ស្ត្រីទទួលរ៉ាប់រងប្រមាណ ៩០ ភាគរយនៃការងារនោះ។[165] បញ្ហាយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ក៏ជាប់ទាក់ទងផងដែរនឹងការទទួលបានសេវាសាធារណៈ និងសេវាឯកជនមិនស្មើគ្នា ធនធានហិរញ្ញវត្ថុ ការថែទាំសុខភាព និងសិទ្ធិធនធានធម្មជាតិ ឱកាសអប់រំ និងឱកាសសេដ្ឋកិច្ច និងការចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។[166]

ការសិក្សាថ្មីមួយដោយអង្គការ UN Women ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខអាកាសធាតុនៅតំបន់អាស៊ីប៉ាស៊ីហ្វិក បង្ហាញថា ការប្រែប្រួលអាកាសធាតុមិនត្រឹមតែបង្កការគំរាមកំហែងយ៉ាងខ្លាំងដល់សុខភាព និងសុខុមាលភាពមនុស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគំរាមកំហែងដល់សន្តិភាព និងសន្តិសុខទៀតផង[167]។ ការប្រែប្រួលអាកាសធាតុបង្ខំឱ្យសហគមន៍កំណត់ឡើងវិញថាតើសន្តិភាព និងសន្តិសុខ មានអត្ថន័យដូចម្តេចចំពោះពួកគេ និងចំពោះមនុស្សជំនាន់ក្រោយទៀត។ ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ការរេចរិលបរិស្ថាន និងការខ្សត់ធនធានធម្មជាតិ កំពុងរួមចំណែកបង្កឱ្យមានអសន្តិសុខ និងអស្ថិរភាពកាន់តែខ្លាំងទាំងនៅជុំវិញពិភពលោក ក៏ដូចជាក្នុងប្រទេសកម្ពុជា។ បញ្ហាប្រឈមទាំងនេះជះឥទ្ធិពលលើសន្តិសុខតាមវិធីផ្សេងៗដូចជា ការផ្លាស់ប្តូរគំរូនៃការធ្វើទេសន្តរប្រវេសន៍ និងការបាត់បង់ទីលំនៅ ការបង្កើនការប្រជែងដណ្តើមធនធានដី ធនធានទឹក និងធនធានផ្សេងទៀត ការធ្វើឱ្យថយចុះសន្តិសុខស្បៀង និងភាពយ៉ាប់យ៉ឺននៃជីវភាពរស់នៅ ការគំរាមកំហែងសុខភាពសាធារណៈ ការប្រែប្រួលសេដ្ឋកិច្ចពណ៌ខៀវ (blue economy) ការប្រែប្រួលគំរូនៃឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង រួមទាំងបទល្មើសបរិស្ថាន[168]។ចាំបាច់ត្រូវមានការយល់ដឹងអំពីវិមាត្រយេនឌ័រនៃហានិភ័យសន្តិសុខដែលទាក់ទងនឹងអាកាសធាតុ ដើម្បីបញ្ចៀសការបង្កើនភាពងាយរងគ្រោះ ក៏ដូចជាកំណត់រកឱកាសលើកកម្ពស់សមភាពយេនឌ័រ បង្កើនភាពធន់នឹងអាកាសធាតុ និងរក្សាសន្តិភាព។

រដ្ឋាភិបាលទទួលស្គាល់ថា នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និងការធ្វើទេសន្តប្រវេសន៍ ស្ត្រីជនបទទទួលខុសត្រូវលើការងារផ្ទះ និងកសិកម្ម និងការពឹងផ្អែកលើធនធានធម្មជាតិ ដើម្បីផ្គត់ផ្គង់គ្រួសាររបស់ពួកគេ។ ទោះជាយ៉ាងណា ស្ត្រីភាគច្រើនខ្វះការទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយស្តីពីការការពារបរិស្ថាន ភាពធន់នឹងអាកាសធាតុ និងការអភិវឌ្ឍបៃតង។[169]

ការបង្កើនភាពអង់អាចរបស់ស្ត្រីតាមរយៈការអប់រំ ឱកាសសេដ្ឋកិច្ច និងតួនាទីដឹកនាំ មានផលជះជ្រាលជ្រៅ និងទូលំទូលាយលើការកសាងភាពធន់របស់សហគមន៍ ការទប់ស្កាត់ជម្លោះ និងការគាំទ្រសន្តិភាពប្រកបដោយនិរន្តរភាព។ នៅពេលស្ត្រីអាចទទួលបានធនធាន និងអំណាចសេដ្ឋកិច្ច ស្ត្រីកាន់តែមានសមត្ថភាពវិនិយោគលើការអនុវត្តដែលមាននិរន្តរភាព និងបច្ចេកវិទ្យាដែលកាត់បន្ថយផលប៉ះពាល់អាកាសធាតុ។

ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចក៏ជួយកាត់បន្ថយភាពក្រីក្រ ដែលជាចលករចម្បងមួយនៃភាពងាយរងគ្រោះដោយអាកាសធាតុផងដែរ។ ស្ត្រីដែលត្រូវបានបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ច អាចជួយទំនុកបម្រុងគ្រួសារ និងសហគមន៍បានកាន់តែប្រសើរក្នុងអំឡុងវិបត្តិដែលពាក់ព័ន្ធនឹងអាកាសធាតុ។ ស្ត្រីដែលកាន់តួនាទីដឹកនាំ អាចជះឥទ្ធិពលលើគោលនយោបាយ និងការធ្វើសេចក្តីសម្រេច ដើម្បីធានាការដាក់បញ្ចូលទស្សនៈយេនឌ័រទៅក្នុងផែនការសកម្មភាពអាកាសធាតុ។

ជាញឹកញាប់ ថ្នាក់ដឹកនាំជាស្ត្រី ផ្តោតអាទិភាពលើសុខុមាលភាពសហគមន៍ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលនាំទៅរកយុទ្ធសាស្ត្រប្រកបដោយបរិយាបន្ន និងប្រសិទ្ធភាពស្តីពីភាពធន់។ ការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការកសាងសន្តិភាពធានាការទទួលស្គាល់តម្រូវការជាក់លាក់ និងការរួមចំណែករបស់ស្ត្រី ហើយនេះនឹងជួយលើកកម្ពស់កិច្ចព្រមព្រៀង

---

[164] យោងតាមគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យកសិកម្ម ឆ្នាំ២០២២-២០២៦, អង្គការ UN Women និង CDRI (ឆ្នាំ២០២១)
[165] ការស្រាវជ្រាវស៊ីជម្រៅអំពីសមភាពយេនឌ័រសម្រាប់កម្ពុជា ការវិភាគប្រទេសរួម ក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា ២០២២
[166] ដូចខាងលើ យោងតាម Goh, A.H.X (២០១២) "ការពិនិត្យឡើងវិញនូវអក្សរសាស្ត្រស្តីពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុបែងចែកតាមយេនឌ័រ ទៅលើទ្រព្យសម្បត្តិ និងសុខុមាលភាពរបស់ស្ត្រី និងបុរសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍" ទំព័រ១០
[167] UN Women 2024; Women, Peace and Climate Security in Asia and the Pacific, In Brief
[168] Ibid
[169] របាយការណ៍ស្តីពីការត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តរបស់កម្ពុជា ឆ្នាំ២០២៣

សន្តិភាពដែលកាន់តែគ្រប់ជ្រុងជ្រោយ និងយូរអង្វែង[170]។ ក្រៅពីនេះ នៅពេលដែលអ្នកដឹកនាំជាបុរសក៏យល់ និងរួមបញ្ចូលវិមាត្រយេនឌ័រទៅក្នុងការងាររបស់ពួកគេផងដែរនោះ វានឹងបង្កបរិយាកាសដែលកាន់តែមានភាពអនុគ្រោះ និងការគាំទ្រ ដើម្បីពន្លឿនរបៀបវារៈ WPS។

បញ្ហាបរិស្ថានសំខាន់ៗដែលប៉ះពាល់ដល់កម្ពុជារួមមាន ៖ ការអនុវត្តការគ្រប់គ្រងទឹកលើផ្ទៃដីមិនល្អ ការបែងចែក និងការប្រើប្រាស់ដីមិនបានគ្រប់គ្រាន់ ការរេចរិលព្រៃឈើ និងដីដោយសារការអនុវត្តកសិកម្មដែលគ្មាននិរន្តរភាព។ បទសម្ភាសន៍ជាមួយក្រុមស្ត្រី និងយុវជន និងអាជ្ញាធរថ្នាក់ក្រោមជាតិនៅក្នុងខេត្តបី បានបញ្ជាក់ពីផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ (គ្រោះរាំងស្ងួត ទឹកជំនន់ និងកម្ដៅខ្លាំង) លើសន្តិសុខសេដ្ឋកិច្ចរបស់ស្ត្រី និងធនធានគ្រួសារ។ ក្នុងករណីខ្លះ នេះបានបណ្តាលឱ្យមានភាពតានតឹងក្នុងសហគមន៍ និងជាមួយអាជ្ញាធរមូលដ្ឋានលើការទទួលបានធនធានទឹកដែលកំពុងខ្វះខាតសម្រាប់ធ្វើកសិកម្ម។ ការរេចរិលបរិស្ថាន និងការកាប់បំផ្លាញព្រៃឈើក៏ធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន និងរួមចំណែកបង្កឱ្យមានវិវាទជាមួយអាជ្ញាធរមូលដ្ឋានលើសិទ្ធិប្រើប្រាស់ដីធ្លីផងដែរ ជាពិសេសនៅក្នុងសហគមន៍ជនជាតិដើមភាគតិច។[171] ការចូលរួមរបស់ស្ត្រីក្នុងយុទ្ធសាស្ត្រកសាងសន្តិភាព និងយុទ្ធសាស្ត្របន្សាំនឹងអាកាសធាតុ អាចបង្កើនភាពធន់ និងស្ថិរភាព។ ទស្សនៈ និងចំណេះដឹងពិសេសរបស់ស្ត្រីអាចជួយពង្រឹងដំណោះស្រាយដែលកាន់តែមាននិរន្តរភាព និងបរិយាបន្ន[172]។

### ៣.៦.២ គោលនយោបាយ ផែនការ និងយន្តការជាតិ

ភស្តុតាងបង្ហាញថា គោលនយោបាយ និងកម្មវិធីដែលរួមបញ្ចូលការពិចារណាយេនឌ័រទៅក្នុងសកម្មភាពអាកាសធាតុ និងកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាព សុទ្ធតែសំខាន់។ នេះរួមបញ្ចូលការធានាការចូលរួមរបស់ស្ត្រីក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិត និងការដោះស្រាយតម្រូវការជាក់លាក់របស់ស្ត្រីនៅក្នុងគោលនយោបាយស្តីពីអាកាសធាតុ និងសន្តិសុខ។ រាជរដ្ឋាភិបាលកម្ពុជាបានលើកកម្ពស់ភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង ជាអាទិភាព តាមរយៈយុទ្ធសាស្ត្របញ្ចកោណ ឆ្នាំ ២០២៤-២០២៨ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

បញ្ចកោណទី ៤ (ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន) រួមបញ្ចូលការលើកកម្ពស់សមភាពយេនឌ័រ និងការធានានិរន្តរភាពបរិស្ថាន ការបង្កើនត្រៀមខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និង ការលើកកម្ពស់សេដ្ឋកិច្ចបៃតង[173]។ សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ត្រូវបានផ្តល់អាទិភាពក្នុងរបៀបវារៈប្រែប្រួលអាកាសធាតុ រួមទាំងកំណើនបៃតង។ ក្នុងនាមជាសមាជិកនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងកិច្ចការនារីធ្វើការស្វែងរកការគាំទ្រមតិឱ្យមានការរៀបចំ និងអនុវត្តគោលនយោបាយឆ្លើយតបនឹងយេនឌ័រ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍកំណើនបៃតង ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

ក្រៅពីនេះ ក្រសួងកិច្ចការនារីទទួលបានជោគជ័យក្នុងស្វែងរកការគាំទ្រមតិសម្រាប់ការបញ្ចូលទស្សនៈយេនឌ័រទៅក្នុងគោលនយោបាយស្តីពីបរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសតាមរយៈការរៀបចំ និងការសម្របសម្រួលផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៨-២០៣០ ដោយសហការជាមួយក្រសួងបរិស្ថាន និងនាយកដ្ឋានប្រែប្រួលអាកាសធាតុ។ ព័ត៌មានបច្ចុប្បន្នភាពរបស់កម្ពុជាក្នុងការរួមចំណែករបស់ជាតិ (NDC) រួមបញ្ចូលវិធានការបន្សាំដែលផ្តោតលើយេនឌ័រ និងដាក់បញ្ចូលការវាយតម្លៃ និងការប៉ាន់ប្រមាណផលប៉ះពាល់យេនឌ័រ។

គោលនយោបាយ និងផែនការសំខាន់ៗដែលបានបង្កើត និងអនុវត្ត រួមមាន ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់យេនឌ័រ និងការប្រែប្រួលអាកាសធាតុឆ្នាំ២០១៣-២០២៣ និងផែនការសកម្មភាពស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៩-២០២៣។ ការបញ្ជ្រាបយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុក៏ត្រូវបានបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រ និងគោលនយោបាយរបស់ក្រសួងអាទិភាព រួមទាំងផែនការ និងយុទ្ធសាស្ត្រស្តីពីបរិស្ថាន ការអភិវឌ្ឍជនបទ កសិកម្ម សុខាភិបាល ធនធានទឹក និងសាធារណការ និងដឹកជញ្ជូនផងដែរ។[175]

---

[170] UN Women 2024; Women, Peace and Climate Security in Asia and the Pacific, In Brief
[171] ការសម្ភាសន៍សំខាន់ៗ/ការពិភាក្សាក្រុមគោលដៅជាមួយស្ត្រី យុវជន និងអាជ្ញាធរថ្នាក់ក្រោមជាតិនៅក្នុងខេត្តចំនួន៣ ខែសីហា ឆ្នាំ២០២៤
[172] UN Women 2024; Women, Peace and Climate Security in Asia and the Pacific, In Brief
[173] RGC Pentagonal Strategy Phase 1: 2024-2028, pg. 25
[174] ក្រសួងកិច្ចការនារី, (២០១៩), ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ (ឆ្នាំ២០១៩-២០២៣)។ អាចស្វែងរកបាននៅ៖
[175] របាយការណ៍ថ្នាក់ជាតិកម្ពុជា BPfA+៣០ ខែមិថុនា ឆ្នាំ២០២៤

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ទទួលខុសត្រូវលើការអនុវត្តផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ ២០១៩-២០២៣ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ (២០១៥) និងសេចក្តីសម្រេចលេខ ០០១ (ឆ្នាំ ២០១៩)។ មាត្រា ១៨ នៃច្បាប់នេះចែងយ៉ាងច្បាស់អំពីស្ត្រី ដោយអំពាវនាវឱ្យអាជ្ញាធរពាក់ព័ន្ធត្រូវ "យកចិត្តទុកដាក់ខ្ពស់ចំពោះតម្រូវការរបស់ស្ត្រី កុមារ មនុស្សចាស់ ជនពិការ និងជនបាត់បង់លទ្ធភាពពលកម្ម" ក្នុងពេលមានគ្រោះមហន្តរាយ។ មាត្រា ៣៥-៣៧ រៀបរាប់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលពាក់ព័ន្ធនឹងការការពារ ព័ត៌មាន ធនធាន និងការចូលរួមក្នុងសកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (CCA)។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ទទួលស្គាល់សារៈសំខាន់នៃការបញ្ជ្រាបយេនឌ័រទៅក្នុងសកម្មភាពអាកាសធាតុ ក៏ដូចជាតួនាទីដ៏សំខាន់របស់ស្ត្រី កុមារ និងយុវជន។[176]

កងយោធពលខេមរភូមិន្ទក៏ដើរតួនាទីសំខាន់ផងដែរក្នុងប្រតិបត្តិការជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយ និងមានកាតព្វកិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធទាំងអស់ ជាពិសេសគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។[177]

យុទ្ធសាស្ត្រ ផែនការ និងគោលការណ៍ណែនាំមួយចំនួន ដែលឆ្លើយតបនឹងយេនឌ័រស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានដាក់ឱ្យអនុវត្ត។ គោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយបរិយាបន្នឆ្នាំ ២០២១ (គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងក្រសួងកិច្ចការនារី) ផ្តល់ការណែនាំស្តីពីការដាក់បញ្ចូលយេនឌ័រ និងបរិយាបន្នសង្គម ទៅក្នុងវដ្តទាំងមូលនៃការគ្រប់គ្រងគ្រោះមហន្តរាយ រួមទាំងការទប់ស្កាត់ ការកាត់បន្ថយ ការត្រៀមបង្ការ និងការឆ្លើយតប។[178] ផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០២៤-២០២៨ ដែលទើបត្រូវបានអនុម័តនាពេលថ្មីៗនេះ រួមបញ្ចូលយេនឌ័រ និងបរិយាបន្នបន្ថែមទៀត និងពង្រឹងតួនាទីរបស់ស្ត្រីនៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ។

យុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់វិស័យសុខាភិបាល ឆ្នាំ ២០២០-២០២៤ គាំទ្រតម្រូវការរបស់ស្ត្រី និងក្មេងស្រី ដោយបញ្ចូលក្រុមការងារអន្តរទីភ្នាក់ងារស្តីពីកញ្ចប់សេវាបឋមអប្បបរមា (MISP) សុខភាពបន្តពូជក្នុងគ្រាវិបត្តិ។ កញ្ចប់សេវានេះលើកឡើងពីសេវាសុខភាពមាតា សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ក៏ដូចជាការទប់ស្កាត់ និងការគ្រប់គ្រងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រាអាសន្ន។[179]

ក្រមបរិស្ថាន និងធនធានធម្មជាតិរបស់កម្ពុជា ដែលត្រូវបានអនុម័តនៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០២៣ ជំនួសច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦។ ក្រមថ្មីនេះពង្រឹងបទប្បញ្ញត្តិសម្រាប់ការអភិរក្សធនធានធម្មជាតិ និងសត្វព្រៃ ការកសាងភាពធន់នឹងអាកាសធាតុ ការលើកកម្ពស់ការប្រើប្រាស់ថាមពលកកើតឡើងវិញ និងការកសាងបរិស្ថានទីក្រុងប្រកបដោយចីរភាព ដែលមានសមត្ថភាពគ្រប់គ្រងសំណល់ និងការបំពុលប្រកបដោយប្រសិទ្ធភាព។ ក្នុងក្រមនេះមានការយោងយ៉ាងច្បាស់ទៅលើសមភាពយេនឌ័រ ការចូលរួមរបស់ស្ត្រី និងការមិនរើសអើង ដើម្បីធានាថាមានការយកចិត្តទុកដាក់ជាពិសេសលើតម្រូវការរបស់ក្រុមងាយរងគ្រោះ ឬក្រុមជួបការលំបាក។

ផែនការយុទ្ធសាស្ត្រនៃក្រមបរិស្ថាន និងធនធានធម្មជាតិសម្រាប់ការអភិវឌ្ឍសហគមន៍មូលដ្ឋាន ឆ្នាំ ២០២៤-២០២៨ រួមបញ្ចូលការបង្កើតតំបន់ការពារសហគមន៍ (CPA) និងបណ្តាញស្ត្រីសហគមន៍មូលដ្ឋាន AC។[180]

[176] ការវិភាគប្រទេសរួមរបស់ក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា ខែ មករា ឆ្នាំ២០២៣ ទំព័រ៤២។ អាចស្វែងរកបាននៅ https://cambodia.un.org/en/239810-cambodia-common-country-analysis
[177] ក្រសួងការពារជាតិ យុទ្ធសាស្ត្រការពារជាតិ ២០២២
[178] គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ឆ្នាំ២០២១ គោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយបរិយាបន្ន ឆ្នាំ២០២១
[179] មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន ឆ្នាំ២០២១
[180] របាយការណ៍ជាតិរបស់កម្ពុជា BPfA+30, ខែមិថុនា ឆ្នាំ២០២៤

## ៣.៧. របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងលទ្ធភាពទទួលបានសន្តិសុខសេដ្ឋកិច្ច ឱកាសរបរចិញ្ចឹមជីវិត ធនធានធម្មជាតិ និងសន្តិសុខមនុស្ស

### ៣.៧.១ បញ្ហាសន្តិសុខសំខាន់ៗក្នុងការចូលរួមផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី

ស្ត្រីដើរតួនាទីសំខាន់ក្នុងសកម្មភាពសន្តិភាព និងសន្តិសុខ រួមទាំងការពន្លឿនការងើបឡើងវិញផ្នែកសេដ្ឋកិច្ចក្រោយជម្លោះ និងការរួមចំណែកដល់សន្តិភាពប្រកបដោយចីរភាព។[181] នៅកម្ពុជា កសិកម្មជាវិស័យដ៏សំខាន់សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រឹងសេដ្ឋកិច្ចជនបទ និងការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព។ កម្ពុជាមានអត្រាចូលរួមរបស់ស្ត្រីក្នុងកម្លាំងពលកម្មខ្ពស់បំផុតមួយក្នុងតំបន់ គឺ ៧៨,៩ ភាគរយ។[182] ទោះយ៉ាងណា នៅក្នុងវិស័យកសិកម្ម ស្ត្រីភាគច្រើនប្រឡូកក្នុងតួនាទីដែលមានជំនាញទាប និងប្រាក់ឈ្នួលទាប។ ស្ត្រីជនបទប្រមាណ ២៥,៧ ភាគរយទទួលបន្ទុកការងារគ្រួសារដោយមិនទទួលបានប្រាក់ឈ្នួល ដែលខ្ពស់ជាងពីរដងបើធៀបនឹងបុរសជនបទដែលមាន ១១,៥ ភាគរយ។ សមាជិកគ្រួសារជាស្ត្រីភាគច្រើនដែលធ្វើការងារកសិកម្ម មិនទទួលបានប្រាក់ឈ្នួលសម្រាប់ការរួមចំណែករបស់ពួកគេ។[183]

ស្ត្រីជនបទជាច្រើនចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចបែបប្រពៃណីផ្សេងទៀត តាមរយៈការកាន់កាប់ និងដំណើរការសហគ្រាសខ្នាតតូច ឬចូលរួមក្នុងសកម្មភាពបង្កើតប្រាក់ចំណូលផ្សេងៗ។ សកម្មភាពទាំងនេះ (ទោះតាមរដូវកាល ក្រៅផ្លូវការ ពេញម៉ោង ឬក្រៅម៉ោង) សុទ្ធតែផ្តល់ប្រាក់ចំណូលបន្ថែមដល់គ្រួសារ និងបង្កើនសន្តិសុខប្រាក់ចំណូល។ យ៉ាងណាមិញ ការងារទាំងនេះមិនសូវផ្តល់ឱកាសការងារសមរម្យ ឬជាលក្ខណៈក្នុងប្រព័ន្ធ ឬផ្លូវការដល់ស្ត្រីជនបទទេ។[184] បទសម្ភាសន៍ជាមួយស្ត្រីជនបទ និងយុវជនដែលប្រឡូកក្នុងវិស័យកសិកម្ម ក៏ដូចជាពលករទេសន្តរប្រវេសក៍ជាស្ត្រី បានលើកឡើងពីកង្វះឱកាសសេដ្ឋកិច្ចក្នុងមូលដ្ឋាន និងការលំបាកក្នុងការស្វែងរកការងារតាមរដូវកាលសមរម្យនៅជិតផ្ទះរបស់ពួកគេ។ បញ្ហាប្រឈមទាំងនេះជំរុញឱ្យមានអសន្តិសុខស្បៀងអាហារ និងការប្រកបរបរចិញ្ចឹមជីវិត ហើយជារឿយៗ នាំឱ្យមានការធ្វើចំណាកស្រុកក្នុងប្រទេស ឬទៅក្រៅប្រទេស ដើម្បីស្វែងរកការងារ។[185]

ទេសន្តរប្រវេសន៍ គឺជាជីវិតសេដ្ឋកិច្ចដ៏សំខាន់មួយ និងជាកត្តាជំរុញចល័តភាពសង្គមសម្រាប់គ្រួសារកម្ពុជាជាច្រើន។ ក្នុងលំហូរទេសន្តរប្រវេសន៍សរុប ការធ្វើចំណាកស្រុកពីជនបទទៅជនបទមានចំនួន ១៣ ភាគរយ ការធ្វើចំណាកស្រុកពីជនបទទៅទីក្រុងមាន ៥៧ ភាគរយ និងការធ្វើចំណាកស្រុកឆ្លងដែនមានចំនួន ៣១ ភាគ ដោយក្នុងនោះរាជធានីភ្នំពេញ និងប្រទេសថៃជាគោលដៅទូទៅបំផុត។[186]

ក្នុងចំណោមជនទេសន្តរប្រវេសក៍ ៥ នាក់ ៤ នាក់ មានអាយុចន្លោះពី ១៧ ទៅ ៣៥ ឆ្នាំ។ ខណៈដែលការធ្វើទេសន្តរប្រវេសន៍បានជួយឱ្យយុវជនវ័យក្មេងជាច្រើនរកបានការងារធ្វើ និងទ្រទ្រង់គ្រួសាររបស់ពួកគេ វាក៏បង្កការព្រួយបារម្ភជុំវិញការអភិវឌ្ឍជំនាញមានកម្រិត ការបោះបង់ការសិក្សា ផលប៉ះពាល់អវិជ្ជមានលើកុមារដែលធ្វើដំណើរជាមួយ និងសុវត្ថិភាព និងភាពងាយរងគ្រោះរបស់ជនទេសន្តប្រវេសក៍ផងដែរ។ បទសម្ភាសន៍ជាមួយមន្ត្រីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល បានគូសបញ្ជាក់ពីហានិភ័យនៃការធ្វើទេសន្តរប្រវេសន៍ដែលមិនមានសុវត្ថិភាព សម្រាប់ស្ត្រីជនបទជាច្រើនដែលស្វែងរកការងារសមរម្យ ក៏ដូចជាផលប៉ះពាល់អវិជ្ជមានលើសុវត្ថិភាពរបស់ស្ត្រី និងស្ថិរភាពគ្រួសារ។ ស្ថានភាពបែបនេះនៅតែបន្តកើតមានឡើង បើទោះបីជាមានគោលនយោបាយ និងផែនការរបស់រដ្ឋាភិបាលដែលឆ្លើយតបនឹងយេនឌ័រ ដែលដោះស្រាយទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព ការគាំទ្រដល់ស្ត្រីក្នុងវិស័យកសិកម្ម កម្មវិធីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ក្តី។

គោលនយោបាយបញ្ជ្រាបយេនឌ័រ និងក្របខណ្ឌយុទ្ធសាស្ត្រក្នុងវិស័យកសិកម្ម ឆ្នាំ ២០២២-២០២៦ គូសបញ្ជាក់ថា ស្ត្រីចូលរួមដោយផ្ទាល់ក្នុងបរិស្ថានធម្មជាតិ ច្រើនជាងបុរស។ ស្ត្រីទទួលខុសត្រូវលើការចម្អិនអាហារ ការថែទាំ និងការចិញ្ចឹមកុមារ និងដើរតួនាទីសំខាន់ក្នុងការធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងគ្រួសារ។ ទោះជាយ៉ាងណា ភាពជាតំណាងរបស់ស្ត្រី

[181] សេចក្តីសង្ខេបសកម្មភាពរបស់អង្គការ UN Women៖ ស្ត្រី សន្តិភាព និងសន្តិសុខ និងជំងឺកូវីដ១៩ នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក
[182] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ឆ្នាំ២០២២៖ ការធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០២១ ភ្នំពេញ សៀវភៅប្រចាំឆ្នាំស្ថិតិអាស៊ាន ឆ្នាំ២០២៣ ហ្សាកាតា លេខាធិការដ្ឋានអាស៊ាន ខែធ្នូ ឆ្នាំ២០២៣
[183] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ឆ្នាំ២០២២, ការធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០២១
[184] អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ឆ្នាំ២០២៤
[185] ការពិភាក្សាក្រុមគោលដៅ/ការសម្ភាសន៍សំខាន់ៗជាមួយស្ត្រីជនបទ និងយុវជន ខែសីហា ឆ្នាំ២០២៤
[186] កម្មវិធីស្បៀងអាហារពិភពលោក ឆ្នាំ២០១៩, ភាពងាយរងគ្រោះ និងទេស្តរប្រវេសន៍នៅកម្ពុជា

នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យសាធារណៈ នៅតែមានកម្រិតទាប ទស្សនៈរបស់ស្ត្រីច្រើនតែត្រូវបានគេមើលរំលង ហើយសំឡេងរបស់ស្ត្រីនៅក្នុងការគ្រប់គ្រងធនធានបរិស្ថាន និងធនធានធម្មជាតិ កម្រត្រូវបានពិចារណា[187]។ ស្ត្រីក៏មានឱកាសតិចជាងបុរសក្នុងការកសាងសមត្ថភាពផងដែរ ហើយស្ត្រីមានលទ្ធភាពតិចជាងបុរសក្នុងការទទួលបានព័ត៌មាន និងការអប់រំ[188]។

គ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះគឺជាកេរដំណែលដ៏អន្តរាយនៃជម្លោះរាប់ទសវត្សរ៍កន្លងមករបស់កម្ពុជា ដោយមានគ្រាប់មីនប្រមាណ ៦ លានគ្រាប់ត្រូវបានដាក់ពង្រាយ ហើយភាគច្រើននៅក្នុងបណ្តាខេត្តភាគពាយព្យ។ រដ្ឋាភិបាលបានផ្តល់អាទិភាពដល់ការបោសសម្អាតគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (ERW) និងបានបញ្ចូលសកម្មភាពមីនទៅក្នុងយុទ្ធសាស្ត្រជាតិសំខាន់ៗ ដើម្បីកាត់បន្ថយភាពក្រីក្រ និងទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ កម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ហើយកម្ពុជាមានគោលដៅសម្រេចឱ្យបាន កម្ពុជាគ្មានមីន នៅឆ្នាំ ២០២៥។[189]

ស្របតាមគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពមីន ស្ត្រីកម្ពុជាកំពុងដើរតួនាទីកាន់តែសំខាន់ក្នុងការបោសសម្អាតមីន ដោយមានស្ត្រីជាង ៨០០ នាក់កំពុងកាន់មុខតំណែងប្រតិបត្តិការ ក្នុងឆ្នាំ ២០២៣ ស្មើនឹង ៣៤ ភាគរយនៃចំនួនបុគ្គលិកប្រតិបត្តិការសរុប។[190] បច្ចុប្បន្ន មានស្ត្រីប្រមាណ ២២ ភាគរយ កំពុងកាន់មុខតំណែងគ្រប់គ្រង ឬមុខតំណែងជាប្រធានត្រួតពិនិត្យ។ នេះជាការលុបបំបាត់របាំងក្នុងវិស័យដែលធ្លាប់តែមានបុរសច្រើនលើសលប់។ ទោះជាសម្រេចបានវឌ្ឍនភាពទាំងនេះក្តី ក៏គ្រាប់មីននៅតែបន្តបង្កហានិភ័យធ្ងន់ធ្ងរដល់ជីវិត និងការអភិវឌ្ឍ។ ផលប៉ះពាល់នៃគ្រាប់មីនមានភាពខុសគ្នាសម្រាប់ស្ត្រី ក្មេងស្រី ក្មេងប្រុស និងបុរស។ ស្ត្រីច្រើនតែរងផលប៉ះពាល់ដោយប្រយោល និងច្រើនតែបំពេញតួនាទីថែទាំជនរងគ្រោះ និងរ៉ាប់រងបន្ទុកហិរញ្ញវត្ថុកាន់តែធ្ងន់[191]។ ក្មេងស្រីក៏ច្រើនតែត្រូវបានបញ្ឈប់ពីការសិក្សា ឬរៀបការនៅវ័យក្មេងផងដែរ នៅពេលដែលធនធានរបស់គ្រួសារមានកម្រិត ក្រោយជួបឧប្បត្តិហេតុគ្រាប់មីន។

បុរស និងក្មេងប្រុស មាន ៨០ ភាគរយនៃចំនួនជនរងគ្រោះដោយសារគ្រាប់មីននៅកម្ពុជា ប៉ុន្តែស្ត្រី និងក្មេងស្រីដែលរងរបួស ប្រឈមមុខនឹងផលលំបាកយ៉ាងខ្លាំងពេញមួយជីវិតរបស់ពួកគេ ដោយសារតែតួនាទីផ្អែកតាមយេនឌ័រ លទ្ធភាពក្នុងការទទួលបានសេវាខុសគ្នា និងឥរិយាបថសង្គមទូទៅ។[192] ក្នុងតំបន់ដែលមានយុទ្ធភណ្ឌមិនទាន់ផ្ទុះ ស្ត្រី និងក្មេងស្រីក៏ប្រឈមនឹងហានិភ័យខ្ពស់នៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទផងដែរ។ ក្រៅពីការគំរាមកំហែងដោយផ្ទាល់លើសុវត្ថិភាព គ្រាប់មីនបង្កើនអសន្តិសុខស្បៀង កម្រិតបំលាស់ទី និងធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ។ ស្ត្រីនៅក្នុងគ្រួសារដែលរងផលប៉ះពាល់ ទទួលរងបន្ទុកសុខភាពផ្លូវកាយ និងផ្លូវចិត្ត ដោយសារតែពួកគេត្រូវមើលថែជនរងគ្រោះ និងចាត់ចែងការទទួលខុសត្រូវកាន់តែច្រើនឡើង។

### ៣.៧.២ ដីធ្លី ធនធានធម្មជាតិ និងរបរចិញ្ចឹមជីវិត

ជីវចម្រុះដ៏សំបូរបែប និងប្រព័ន្ធអេកូឡូស៊ីរបស់កម្ពុជា មានសារៈសំខាន់សម្រាប់ជីវភាពរស់នៅក្នុងជនបទ និងផ្តល់តម្លៃអេកូឡូស៊ី និងតម្លៃសេដ្ឋកិច្ចសំខាន់ដល់ការអភិវឌ្ឍរបស់កម្ពុជា។ ទោះជាយ៉ាងណា ភាពរីកចម្រើនយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចកម្ពុជា និងអន្តរកាលឆ្ពោះទៅរកសេដ្ឋកិច្ចផ្អែកលើទីផ្សារ កំពុងដាក់សម្ពាធកាន់តែខ្លាំងលើធនធានធម្មជាតិរបស់ប្រទេសនេះ[193]។ ដូចប្រទេសជាច្រើនផ្សេងទៀតដែរ ស្ត្រីជនបទនៅកម្ពុជាជាបុគ្គលចម្បងដែលប្រមូល និងផ្គត់ផ្គង់ធនធានធម្មជាតិ និងពឹងផ្អែកលើធនធានទាំងនោះដើម្បីទ្រទ្រង់ជីវិត និងជីវភាព។ ការស្រាវជ្រាវដោយអង្គការ UN Women ស្តីពីយេនឌ័រ សន្តិភាព និងសន្តិសុខក្នុងការគ្រប់គ្រងធនធានធម្មជាតិ បង្ហាញថា សិទ្ធិ និងលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានធនធានធម្មជាតិ និងអត្ថប្រយោជន៍របស់ពួកគេ នៅតែស្ថួចស្តើង ហើយច្រើនតែគ្មានសំឡេង និងទស្សនៈរបស់ពួកគេនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច[194]។ លើសពីនេះ នៅពេលមានការប្រជែង ដណ្តើមធនធានធម្មជាតិ ឬការដាក់សម្ពាធលើធនធានទាំងនេះ ស្ត្រីមានឱកាស ឬអំណាចតិចតួចក្នុងការចូលរួមក្នុងដំណើរការនៃការចរចា ការសម្រេចចិត្ត ឬការផ្សះផ្សាលទ្ធផល។

---

[187] UN Women and CDRI 2021: State of Gender Equality and Climate Change
[188] Ibid
[189] របាយការណ៍ស្តីពីការត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តរបស់កម្ពុជា ឆ្នាំ២០២៣
[190] https://www.mineactionreview.org/assets/downloads/Cambodia_Clearing_the_Mines_2024.pdf
[191] Gender and Diversity in the Anti-Personnel Mine Ban Convention (APMBC), UNIDIR. Available at: https://unidir.org/wp-content/uploads/2023/11/UNIDIR_Factsheet_Gender_and_Diversity_in_the_APMBC.pdf
[192] អាចស្វែងរកបាននៅ៖ https://www.undp.org/cambodia/speeches/technical-working-group-mine-action
[193] UNCT Cambodia CCA, January 2023
[194] Gender, Peace and Natural Resource Management, Research Brief, UN Women, December 2022

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីដោះស្រាយបញ្ហាវិវាទដីធ្លី ដែលជាប្រភពនៃជម្លោះយូរមកហើយនៅក្នុងប្រទេស។[195] គិតត្រឹមខែ វិច្ឆិកា ឆ្នាំ ២០២៣ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) បានចេញប័ណ្ណកម្មសិទ្ធិដីធ្លីចំនួន ៧.១៦៣.៧៦៤ និងបានដោះស្រាយករណីវិវាទដីធ្លីគ្រប់ប្រភេទសរុបចំនួន ១២.៦៧៦ ករណី និងកំពុងពិនិត្យ ២.៦៣៦ ករណីផ្សេងទៀត។[196]

ប្រមាណ ៤០ ភាគរយនៃករណីវិវាទដីធ្លីដែលបានដោះស្រាយ រួមបញ្ចូលស្ត្រីជាភាគីចម្បង ឬភាគីបន្ទាប់បន្សំ ហើយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានខិតខំប្រឹងប្រែងធានាថាសិទ្ធិ និងផលប្រយោជន៍របស់ពួកគេត្រូវបានការពារក្នុងដំណើរការដោះស្រាយទាំងមូល។ ដីកសិកម្ម ១០ ភាគរយកាន់កាប់ដោយគ្រួសារដែលមានមេគ្រួសារជាស្ត្រី[197] ខណៈដែលស្ត្រីកាន់កាប់ ១៨ ភាគរយនៃប័ណ្ណកម្មសិទ្ធិដីធ្លីទាំងអស់ និងមាន ៦៨ ភាគរយត្រូវបានកាន់កាប់រួមគ្នា។[198] ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងសមធម៌យេនឌ័រក្នុងការកាន់កាប់ដីធ្លីក្តី ក៏ស្ត្រីជនបទជាច្រើននៅតែខ្វះព័ត៌មានស្តីពីសិទ្ធិដីធ្លី និងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ហើយភាពលំអៀងយេនឌ័របន្តរារាំងពួកគេមិនឱ្យអនុវត្តសិទ្ធិផ្ទាល់ខ្លួន។[199] ដូច្នេះហើយទើបនៅតែមានទំនាស់ពាក់ព័ន្ធនឹងដីធ្លី។

គំនិតផ្តួចផ្តើមជាច្រើនដែលមានគោលបំណងលើកកម្ពស់សិនិទ្ធពលសង្គមកាន់តែខ្លាំង និងការចូលរួមរបស់សហគមន៍ ត្រូវបានចាប់ផ្តើមដោយមានការគាំទ្រពីរដ្ឋាភិបាល ដូចជា ការកសាងសន្តិភាពសហគមន៍ និងការកាត់បន្ថយជម្លោះ ដែលដឹកនាំដោយសម្ព័ន្ធដើម្បីការផ្លាស់ប្តូរជម្លោះ។[200] គម្រោងនេះទទួលស្គាល់តួនាទីដ៏សំខាន់របស់ស្ត្រីក្នុងការកសាង និងរក្សាសន្តិភាព និងមានគោលបំណងបង្កើតបរិយាកាសមួយ ដែលការរួមចំណែករបស់ពួកគេត្រូវបានផ្តល់តម្លៃ និងគាំទ្រ។ ទោះជាយ៉ាងណានៅតែមានបញ្ហាប្រឈមក្នុងការសម្រេចបានពេញលេញនូវសិទ្ធិសហគមន៍ ជាពិសេសសិទ្ធិរបស់ស្ត្រី ក្នុងការទទួលបានធនធានធម្មជាតិ ដោយស្ត្រីជនបទដែលរស់នៅក្នុងភាពក្រីក្រ រងផលប៉ះពាល់ធ្ងន់ធ្ងរ ព្រោះការទទួលខុសត្រូវក្នុងគ្រួសាររបស់ពួកគេ ពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងធនធានធម្មជាតិក្នុងមូលដ្ឋាន។

ខណៈដែលកម្ពុជាកំពុងខិតខំជំរុញការចូលរួមកាន់តែច្រើនឡើងរបស់សហគមន៍ ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងតំបន់ការពាររបស់កម្ពុជាតិចជាង ១០ ភាគរយ ស្ថិតក្រោមការគ្រប់គ្រងរបស់សហគមន៍[201]។ ការចូលរួមរបស់ស្ត្រីក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត នៅតែមានកម្រិត ៖ មានស្ត្រីត្រឹមតែ ២១,៥ ភាគរយប៉ុណ្ណោះនៅក្នុងសមាសភាពគណៈកម្មាធិការគ្រប់គ្រងព្រៃឈើ ទោះបីជាពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការនេះ គឺជាស្ត្រីក៏ដោយ[202]។

ជនជាតិដើមភាគតិចរបស់កម្ពុជា ដែលជារឿយៗរស់នៅតំបន់ភូមិសាស្ត្រដាច់ស្រយាល ពឹងផ្អែកលើធនធានធម្មជាតិសម្រាប់ជីវភាពរស់នៅតាមប្រពៃណីរបស់ពួកគេ និងគ្មានប័ណ្ណកម្មសិទ្ធិស្របច្បាប់លើដីដូនតារបស់ពួកគេ កាន់តែងាយរងគ្រោះដោយសារការលំបាកផ្នែកសេដ្ឋកិច្ច ដែលបណ្តាលមកពីការបាត់បង់ដីធ្លី។ ក្រោមគោលនយោបាយស្តីពីការចុះបញ្ជីដីធ្លី និងសិទ្ធិប្រើប្រាស់ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិចមានសហគមន៍តែ៤២ប៉ុណ្ណោះក្នុងចំណោមប្រមាណ៥០០សហគមន៍ដែលមានសិទ្ធិទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព គិតត្រឹមដើមឆ្នាំ ២០២៤។ កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើង ដើម្បីកែសម្រួលទម្រង់ និងនីតិវិធីសម្រាប់ការចុះបញ្ជីដីសមូហភាព ដើម្បីឱ្យដំណើរការនេះកាន់តែងាយស្រួល និងលឿនរហ័សជាងមុន។[203]

ស្ត្រីជនជាតិដើមភាគតិចនៅតំបន់ជនបទ មានបន្ទុកធ្ងន់ជាពិសេសក្នុងការងារផ្ទះ កសិកម្ម ការចិញ្ចឹមសត្វ តម្បាញ កាបូប និងកន្ទេល និងការប្រមូលអាហារពីក្នុងព្រៃ ជាពិសេសក្នុងពេលខ្វះខាតអាហារ។[204] សហគមន៍ទាំងនេះក៏រងផលប៉ះពាល់ដោយសម្បទានដីសេដ្ឋកិច្ច សម្បទានរ៉ែ និងទំនប់វារីអគ្គិសនីផងដែរ ដែលជារឿយៗបណ្តាលឱ្យមានការផ្លាស់ទីលំនៅដោយបង្ខំ និងបង្កឱ្យមានវិវាទដីធ្លី។[205] ជនជាតិដើមភាគតិចកម្ពុជា នៅតែបន្តប្រឈមនឹងការរើសអើង និងការផ្លាស់ទីលំនៅចេញពីដីធ្លីរបស់ពួកគេ ដែលជាការគំរាមកំហែងដល់អត្តិភាពរបស់ពួកគេក្នុងនាមជាក្រុមដែលមានលក្ខណៈពិសេស។[206]

[195] របាយការណ៍ស្តីពីការត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តរបស់កម្ពុជា ឆ្នាំ២០២៣
[196] របាយការណ៍ស្តីពីការពិនិត្យឡើងវិញតាមកាលកំណត់ជាសកលរបស់កម្ពុជា ឆ្នាំ២០២៤
[197] ការធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០២១
[198] អង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ ២០២៤
[199] ដូចខាងលើ
[200] របាយការណ៍ស្តីពីការត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តរបស់កម្ពុជា ឆ្នាំ២០២៣
[201] UNCT Cambodia CCA, January 2023
[202] FAO 2024
[203] របាយការណ៍ស្តីពីការពិនិត្យជាសកលតាមកាលកំណត់របស់កម្ពុជា ឆ្នាំ២០២៤
[204] អង្គការ UN Women និងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (២០២១); យោងតាម AIPP ២០១៣។ "ការស្រាវជ្រាវស្តីពីតួនាទីនិងការរួមចំណែករបស់ស្ត្រីជនជាតិដើមភាគតិចក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាពនៅប្រទេសតំបន់ទន្លេមេគង្គ/អាស៊ី"
[205] Hennings, A., & Pen, A. (២០២១) កម្ពុជា៖ បរិបទនិងអភិបាលកិច្ចដីធ្លី
[206] គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ "សេចក្តីសន្និដ្ឋានសង្កេតលើរបាយការណ៍រួមគ្នាលើកទី១៤ ដល់ទី១៧ របស់កម្ពុជា" ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩

ការស្រាវជ្រាវបង្ហាញថា ដំណើរការឆ្លើយតបនឹងយេនឌ័រដែលកាន់ប្រកបដោយបរិយាបន្ន នឹងដោះស្រាយដោយប្រសិទ្ធភាព នូវការព្រួយបារម្ភដែលពាក់ព័ន្ធនឹងស្ត្រី ការគ្រប់គ្រងព្រៃឈើ និងបរិស្ថានប្រកបដោយនិរន្តរភាព[207]។

បទសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធបានសម្ដែងការព្រួយបារម្ភថា គោលនយោបាយសេដ្ឋកិច្ចមួយចំនួនរបស់កម្ពុជា ជាពិសេស គោលនយោបាយដែលផ្សារភ្ជាប់នឹងកំណើនលឿនរហ័ស និងផ្ដោតលើប្រាក់ចំណេញ អាចនាំឱ្យមានអស្ថិរភាព ឬជម្លោះ ប្រសិនបើ គោលនយោបាយទាំងនោះដាក់សម្ពាធលើធនធានក្នុងមូលដ្ឋាន។ អាចកើតមានភាពតានតឹង ប្រសិនបើគោលនយោបាយ សេដ្ឋកិច្ចផ្សេងៗ ផ្លាស់ទីលំនៅសហគមន៍ ឬធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅក្នុងមូលដ្ឋាន។[208] ភាគីពាក់ព័ន្ធដែលបាន សម្ភាសន៍ រួមមានមន្ត្រីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងក្រុមយុវជន បានអំពាវនាវឱ្យបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើនការយល់ដឹងអំពីសិទ្ធិរបស់ជនជាតិដើមភាគតិច និងការពារសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច។ កិច្ចខិតខំប្រឹងប្រែង ទាំងនេះគួរតែស្របទៅនឹងគោលនយោបាយ និងយន្តការរបស់រដ្ឋាភិបាល ដូចជា នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិដើមភាគតិច ក្រោមក្រសួងអភិវឌ្ឍន៍ជនបទ គណៈកម្មាធិការអន្តរក្រសួងដើម្បីអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងគណៈកម្មាធិការអន្តរក្រសួង ដើម្បីអភិវឌ្ឍន៍ប្រជាជននៅតំបន់ភ្នំ។

ការគ្រប់គ្រងធនធានធម្មជាតិដើរតួនាទីយ៉ាងសំខាន់ ក្នុងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ តាមរយៈ ការលើកកម្ពស់ការអនុវត្តដែលមាននិរន្តរភាព និងការផ្ដល់យន្តការនានា ដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងធនធានដែល កម្រ និងរងការគំរាមកំហែង ដែលជួយទប់ស្កាត់ហានិភ័យសន្តិសុខមិនឱ្យរីកធំឡើង។ សមភាពយេនឌ័រ និងការបង្កើនភាព អង់អាចដល់ស្ត្រីគឺជាចំណុចស្នូលនៃដំណើរការនេះ ទាំងសម្រាប់ផលប៉ះពាល់ (ព្រោះស្ត្រីរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារ ការរេចរិលបរិស្ថាន និងអសន្តិសុខ) និងការបង្កើនភាពអង់អាច (ពាក់ព័ន្ធនឹងសមត្ថភាពរបស់ស្ត្រីក្នុងការចូលរួមក្នុងការធ្វើ សេចក្ដីសម្រេច ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធាន និងការកាត់បន្ថយហានិភ័យ)។ មានសក្ដានុពលយ៉ាងច្រើនសម្រាប់ ឱ្យស្ត្រីបំពេញតួនាទីជាអ្នកដឹកនាំកាន់តែច្រើន ក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ការអភិវឌ្ឍសហគមន៍ ដែលធន់នឹងអាកាសធាតុ និងការពង្រឹងសន្តិភាព និងស្ថិរភាព[209]។ ការស្រាវជ្រាវដោយអង្គការ UN Women ស្ដីពី យេនឌ័រ សន្តិភាព និងការគ្រប់គ្រងធនធានធម្មជាតិ បង្ហាញថា អភិបាលកិច្ចដែលកាន់តែមានបរិយាបន្ន ដោយមានការចូលរួម ពេញលេញរបស់ស្ត្រី និងការយកចិត្តទុកដាក់ចំពោះចំណេះដឹង និងតម្រូវការរបស់ស្ត្រី អាចជួយរក្សាឱ្យសហគមន៍កាន់តែមាន សន្តិភាព និងសន្តិសុខ[210]។

### ៣.៧.៣ គោលនយោបាយ ផែនការ និងយន្តការជាតិ

រាជរដ្ឋាភិបាលកម្ពុជា កំពុងអនុវត្តគោលនយោបាយបរិស្ថាន និងកំណែទម្រង់អភិបាលកិច្ច ដើម្បីប្រែក្លាយម៉ូឌែលនៃការ អភិវឌ្ឍសេដ្ឋកិច្ចបច្ចុប្បន្ន ទៅជាម៉ូឌែលដែលកាន់តែមាននិរន្តរភាព និងគ្រប់ជ្រុងជ្រោយ ដើម្បីបំពេញតម្រូវការរបស់ប្រជាជន និងប្រព័ន្ធអេកូឡូស៊ីក្នុងពេលតែមួយ ដោយយកត់សម្គាល់ថា ផ្នែកទាំងពីរនេះពឹងផ្អែកលើគ្នាទៅវិញទៅមក[211]។

ក្រោមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី នៅតែជាអាទិភាព និងត្រូវ បានគាំទ្រតាមរយៈគោលនយោបាយ និងយុទ្ធសាស្ត្រតាមវិស័យសំខាន់ៗ រួមទាំងផែនការនារីរតនៈទី ៦ ឆ្នាំ ២០២៤-២០២៨ (យុទ្ធសាស្ត្រទី ១ ៖ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី) គោលនយោបាយជាតិស្ដីពីមុខរបរ និងការងារ ឆ្នាំ ២០១៥-២០២៥ គោលនយោបាយជាតិស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ យុទ្ធសាស្ត្រជាតិ ស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ ២០២៣-២០២៨ និងយុទ្ធសាស្ត្រជាតិស្ដីពីបរិយាបន្នហិរញ្ញវត្ថុ (NFIS) ឆ្នាំ២០១៩-២០២៥។ បច្ចុប្បន្ន មានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី តាមរយៈការពង្រីកការអប់រំ បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ[212]។ ខណៈដែលមានយុទ្ធសាស្ត្រយេនឌ័រច្បាស់លាស់ វិបត្តិកូវីដ-១៩ បានរំលេច សារៈសំខាន់នៃការដោះស្រាយសេដ្ឋកិច្ចដែលគិតគូរពីសុខមាលភាព ដើម្បីកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី នៅមុន ក្នុងអំឡុង និងក្រោយវិបត្តិ និងគ្រោះអាសន្ន[213]។

[207] UN Women and CDRI 2021; FAO 2024
[208] ការសម្ភាសន៍អ្នកផ្ដល់ព័ត៌មានសំខាន់ៗជាមួយដៃគូអភិវឌ្ឍន៍ រាជធានីភ្នំពេញ ខែសីហា ឆ្នាំ២០២៤
[209] Gender, Peace and Natural Resource Management, Research Brief, UN Women, December 2022
[210] Ibid
[211] UNCT Cambodia CCA, January 2023
[212] របាយការណ៍ជាតិកម្ពុជា, BPfA+30, ខែ មិថុនា ឆ្នាំ ២០២៤
[213] ក្រសួងកិច្ចការនារី, ផែនការនារីរតនៈទី ៦ ២០២៤-២០២៨

សព្វថ្ងៃនេះ កម្ពុជាមានក្របខណ្ឌច្បាប់ជឿនលឿនសម្រាប់ការកាន់កាប់ និងការគ្រប់គ្រងដីធ្លី។ ច្បាប់ភូមិបាលឆ្នាំ ២០០១ បង្កើតប្រព័ន្ធមួយសម្រាប់ការចេញប័ណ្ណកម្មសិទ្ធិដីធ្លីជាលក្ខណៈប្រព័ន្ធ បង្កើតប្រព័ន្ធដោះស្រាយវិវាទគ្រប់ជ្រុងជ្រោយ និងគ្រប់គ្រងសិទ្ធិភតិ (ការជួល)។ សេចក្តីប្រកាសគោលនយោបាយដីធ្លីឆ្នាំ ២០០៨ បានដាក់ចេញការផ្លាស់ប្តូរដំណើរការចេញប័ណ្ណកម្មសិទ្ធិដីធ្លី ដើម្បីពង្រឹងលទ្ធភាពទទួលបានការកាន់កាប់ដីធ្លីរបស់ស្ត្រី តាមរយៈការផ្តល់ឱ្យមានការចុះឈ្មោះសហព័ទ្ធទាំងពីរនាក់។ វិញ្ញាបនបត្រប័ណ្ណកម្មសិទ្ធិដីធ្លីអាចត្រូវបានផ្តល់ដោយការិយាល័យរដ្ឋបាលសុរិយោដីក្នុងមូលដ្ឋាន។ ទោះយ៉ាងណា ស្ត្រីជាច្រើននៅតែជួបការលំបាកក្នុងការចុះបញ្ជីដីក្នុងឈ្មោះរបស់ពួកគេ ដោយសារកង្វះព័ត៌មានអំពីសិទ្ធិដីធ្លី និងដំណើរការចេញប័ណ្ណកម្មសិទ្ធិដីធ្លីក្រោមច្បាប់នេះ។[214]

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានយន្តការជាច្រើនដើម្បីដោះស្រាយបណ្តឹងតវ៉ា ដែលពាក់ព័ន្ធនឹងដីធ្លី និងការសាងសង់ប្រកបដោយប្រសិទ្ធភាព ដូចជា ៖

- អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី (ដីរដ្ឋ)
- គណៈកម្មការសុរិយោដីនៅថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ (ដីដែលគ្មានប័ណ្ណកម្មសិទ្ធិ)
- ក្រុមដោះស្រាយវិវាទដីធ្លីចល័ត (តំបន់ចុះបញ្ជីជាប្រព័ន្ធ)
- ក្រុមដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការចំនួន ២៥ (មួយក្រុមក្នុងមួយខេត្ត) និង
- ក្រុមអធិការកិច្ចសំណង់ (វិវាទសំណង់ និងសុវត្ថិភាពការដ្ឋាន)។

ក្រោមយន្តការនៃក្រុមដោះស្រាយវិវាទដីធ្លី និងសំណង់ ក្រុមការងារនីមួយៗមានស្ត្រីចូលរួមយ៉ាងតិច មួយភាគបី[215]។

ដីធ្លី គឺជាប្រធានបទស្នូលនៃការជជែកវែកញែកស្តីពីការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា ហើយកសិកម្មនៅតែជាប្រភពចំណូលចម្បងសម្រាប់ប្រជាជនកម្ពុជា ប្រមាណបីភាគបួន។ គោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យកសិកម្ម (GMPSFA) ឆ្នាំ ២០២២-២០២៦ មានលក្ខណៈបរិវត្តកម្មយេនឌ័រនៅក្នុងការតាក់តែង។ យុទ្ធសាស្ត្រនេះផ្តល់ការវិភាគលម្អិតអំពីយេនឌ័រ និងកសិកម្ម រួមទាំងឧបសគ្គ និងបញ្ហាប្រឈមរបស់ស្ត្រីនៅក្នុងកម្លាំងពលកម្ម ផលិតកម្ម ការប្រមូលផល ការកែច្នៃ ការធ្វើទីផ្សារ និងខ្សែច្រវាក់ផ្គត់ផ្គង់កសិ-អាហារ បន្ទុកការងារផ្ទះ និងការថែទាំកូន សំឡេងមានកម្រិតរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅកម្រិតគ្រួសារ និងសហគមន៍ និងផលប៉ះពាល់ផ្អែកតាមយេនឌ័រនៃការប្រែប្រួលអាកាសធាតុ។ យុទ្ធសាស្ត្រនេះក៏មានគោលបំណង និងសូចនាករ ដែលដោះស្រាយ និងវាស់វែងការផ្លាស់ប្តូរក្នុងសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីផងដែរ។[216]

យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ (២០១៦-២០២៣) ដែលស្ថិតក្រោមការត្រួតពិនិត្យពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD) មានគោលបំណងធានាការគ្រប់គ្រងធនធានបរិស្ថាន និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព ដោយបន្សីគ្នានឹងរបៀបវារៈឆ្នាំ ២០៣០។ លិខិតុបករណ៍នេះក៏ខិតខំកៀរគរធនធានសម្រាប់របរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពផងដែរ ដោយផ្តោតសំខាន់លើក្រុមងាយរងគ្រោះ (ជាពិសេសស្ត្រី កុមារ និងសហគមន៍ជនជាតិភាគតិច) ដែលរងផលប៉ះពាល់ខ្លាំងដោយសារវិបត្តិដែលពាក់ព័ន្ធនឹងអាកាសធាតុ និងវិបត្តិផ្សេងទៀត។ ថ្មីៗនេះ ក្រសួងបរិស្ថានបានរៀបចំផែនការយុទ្ធសាស្ត្រការពារបរិស្ថាន ២០២៤-២០២៨ ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ២០២៣-២០២៨។ យុទ្ធសាស្ត្រនេះសង្កត់ធ្ងន់លើការធ្វើឱ្យប្រសើរឡើងនូវគុណភាពបរិស្ថាន ការពង្រឹងក្របខណ្ឌគតិយុត្តិ និងការកសាងសមត្ថភាពស្ថាប័ន ដើម្បីដោះស្រាយបញ្ហាប្រឈមបរិស្ថាននៅចំពោះមុខ។

អាជ្ញាធរមីនកម្ពុជា (CMAA) ដែលបានបង្កើតឡើងនៅឆ្នាំ ២០០០ ដើរតួនាទីជាអាជ្ញាធរនិយ័តកម្មថ្នាក់ជាតិលើសកម្មភាពមីន។ អាជ្ញាធរនេះសម្របសម្រួលគោលនយោបាយ និងនីតិវិធីបោសសម្អាតមីន និងបានចាប់ផ្តើមផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពមីនលើកទីបីរបស់ខ្លួន ឆ្នាំ ២០២១-២០២៥។ ក្រុមគ្រប់គ្រងគុណភាពរបស់អាជ្ញាធរមីនកម្ពុជា និងអង្គភាព

[214] អង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ ២០២៤; យោងតាមច្បាប់ភូមិបាលកម្ពុជា ឆ្នាំ២០០៨
[215] CNCW COB Action Plan 2020-2023, MLMUPC submission
[216] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០២២

គ្រប់គ្រង និងរៀបចំផែនការសកម្មភាពមីន (MAPUs) បានទទួលការបណ្តុះបណ្តាលស្តីពីការអនុវត្តការបញ្ជ្រាបយេនឌ័រ។ គិតត្រឹមចុងឆ្នាំ ២០២៣ ស្ត្រីមានប្រមាណមួយភាគបួននៃចំនួនបុគ្គលិករបស់អាជ្ញាធរមីនកម្ពុជា និង ១៩ ភាគរយនៃបុគ្គលិកគ្រប់គ្រង។

អាជ្ញាធរមីនកម្ពុជា ក៏មានក្រុមការងារបញ្ជ្រាបយេនឌ័រ ដែលសម្របសម្រួលជាមួយក្រុមគំរូបច្ចេកទេសលើបញ្ហាយេនឌ័រផងដែរ។ នៅឆ្នាំ ២០២៣ កម្ពុជាបានក្លាយជាប្រទេសដំបូងគេដែលបានដាក់ចេញស្តង់ដារជាតិស្តីពីការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះក្នុងសកម្មភាពមីន។[217] ស្តង់ដារសកម្មភាពមីនកម្ពុជា (CMAS) ពង្រឹងការបញ្ជ្រាបយេនឌ័រក្នុងផែនការសកម្មភាពមីន។ មានកម្លាំងផ្ទុយគ្នាយ៉ាងខ្លាំងរវាងគោលនយោបាយ និងនីតិវិធីសកម្មភាពមីនរបស់កម្ពុជា ក្រោមគោលដៅទី ១៨ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ទាំងនេះរួមមានការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពមីន ការទប់ស្កាត់តាមរយៈការអប់រំដែលគិតគូរពីយេនឌ័រ និងភាពចម្រុះ ការការពារតាមរយៈជំនួយជនរងគ្រោះដែលគាំទ្រសិទ្ធិរបស់ជនរងគ្រោះ និងដោះស្រាយកម្រិតខ្ពស់នៃអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ ដែលជាបញ្ហាប្រឈមរបស់ស្ត្រីមានពិការភាព និងការសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញតាមរយៈការបោសសម្អាតមីនដែលអាចដោះស្រាយអតុល្យភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងសហគមន៍[218]។

## ៣.៨. ស្ត្រី និងសិទ្ធិពលសង្គម

### ៣.៨.១. ស្ត្រី និងបរិបទសង្គម-វប្បធម៌

យោងតាមជំរឿនទូទៅប្រជាជន ឆ្នាំ ២០១៩ កម្ពុជាមានចំនួនប្រជាជនសរុប ១៥,៦ លាននាក់ ដោយប្រជាជន ៣៩,៤ភាគរយ រស់នៅតំបន់ប្រជុំជន។ អាយុមេធ្យាររបស់ប្រជាជនគឺ ២៧ ឆ្នាំ ដោយប្រជាជន ២៩,៤ ភាគរយ មានអាយុ ១៥ ឆ្នាំចុះ និង ៨,៩ ភាគរយមានអាយុ ៦០ ឆ្នាំឡើងទៅ។ ប្រជាជនជិត ៦២ ភាគរយមានអាយុចន្លោះពី ១៥ ទៅ ៥៩ ឆ្នាំ។ នៅឆ្នាំ ២០១៩ ៤,៩ ភាគរយនៃប្រជាជនសរុបដែលមានអាយុលើស ៥ ឆ្នាំ (ស្ត្រី ៥,៥ ភាគរយ និងបុរស ៤,២ ភាគរយ) បានរាយការណ៍អំពីទម្រង់ពិការភាពមួយចំនួន។ ភាសាខ្មែរ គឺជាភាសាកំណើតរបស់ប្រជាជនជាង ៩៥,៨ ភាគរយ ដោយភាសាជនជាតិភាគតិច មានប្រមាណ ២,៩ ភាគរយ (ស្មើនឹងជិត ៤៥០.០០០ នាក់)។[219]

កម្ពុជាសម្បូរដោយសម្បត្តិវប្បធម៌ចម្រុះ រួមទាំងជនជាតិភាគតិច និងជនជាតិដើមភាគតិច។ មានក្រុមជនជាតិដើមភាគតិចប្រមាណ ២២ ក្រុម សរុបប្រហែល ២២០.០០០ នាក់ ដែលភាគច្រើនរស់នៅក្នុងខេត្តប្រាំ ឬប្រាំមួយនៅភាគឦសាន។ ក្រុមជនជាតិភាគតិចសំខាន់ៗផ្សេងទៀត រួមមានខ្មែរមូស្លីម ឬចាម (ប្រមាណ ៣៧០.០០០ នាក់) និងវៀតណាម (លើស ៩០.០០០ នាក់) ខណៈដែលសហគមន៍ឡាវ ថៃ និងខ្មែរកម្ពុជាក្រោម មានចំនួនសរុបប្រមាណ ២៥.០០០ នាក់។[220]

កម្ពុជាបានបោះជំហានសំខាន់ៗក្នុងការទទួលស្គាល់ និងការពារសិទ្ធិរបស់ក្រុមជនជាតិភាគតិច និងក្រុមជនជាតិដើមភាគតិច តាមរយៈគោលនយោបាយ និងគំនិតផ្តួចផ្តើមនានា ដែលមានគោលបំណងលើកកម្ពស់បរិយាបន្ន អភិរក្សបេតិកភណ្ឌវប្បធម៌ និងដោះស្រាយបញ្ហានានា ដូចជា សិទ្ធិដីធ្លី។ ទាំងនេះមានជាអាទិ៍រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣) ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ (១៩៩៦) គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច (២០០៩) ក្រមបរិស្ថាន និងធនធានធម្មជាតិ (២០២៣)[221] និងកម្មវិធីអប់រំពហុភាសា របស់ក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ២៦៥ ដល់ ២៧០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ ហាមឃាត់យ៉ាងច្បាស់នូវគ្រប់ទម្រង់នៃការរើសអើងពូជសាសន៍ រួមទាំងការរើសអើងដោយសារជាតិពន្ធុ សញ្ជាតិ ឬជាតិសាសន៍ ស្របតាមមាត្រា ១ នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (CERD)។ ប្រជាពលរដ្ឋមានសិទ្ធិដាក់ពាក្យបណ្តឹង ហើយវគ្គបណ្តុះបណ្តាលបង្កើនការយល់ដឹងអំពីនីតិវិធីបណ្តឹង ត្រូវបានធ្វើឡើងដោយក្រសួងយុត្តិធម៌ ក្រោមកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (CHCR)។ ទោះជាយ៉ាងណា មិនមានការដាក់បណ្តឹងនៃការរើសអើងពូជសាសន៍ទៅតុលាការក្នុងមូលដ្ឋានទេ។[222]

[217] https://www.mineactionreview.org/assets/downloads/Cambodia_Clearing_the_Mines_2024.pdf
[218] Gender and Diversity in the Anti-Personnel Mine Ban Convention (APMBC), UNIDIR. Available at: https://unidir.org/wp-content/uploads/2023/11/UNIDIR_Factsheet_Gender_and_Diversity_in_the_APMBC.pdf
[219] វិទ្យាស្ថានជាតិស្ថិតិ ២០២០ ជំរឿនទូទៅនៃប្រជាជនព្រះរាជាណាចក្រកម្ពុជា
[220] អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ របាយការណ៍តាមកាលកំណត់រួមគ្នាលើកទី១៨ ដល់ទី២០ ដែលបានដាក់ជូនដោយកម្ពុជាក្រោមប្រការទី៩ នៃអនុសញ្ញា ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣ (CERD/C/KHM/18-20)
[221] https://opendevelopmentcambodia.net/topics/ethnic-minorities-and-indigenous-people-policy-and-rights/
[222] ICERD, Combined eighteenth to twentieth periodic reports submitted by Cambodia under Article 9 of the Convention, 3 May 2023 (CERD/C/KHM/18-20)

ស្ត្រី និងក្មេងស្រីជនជាតិដើមភាគតិច និងជនជាតិភាគតិចផ្សេងទៀតនៅកម្ពុជា នៅតែងាយរងគ្រោះ និងប្រឈមនឹងទម្រង់ចម្រុះនៃការរើសអើង ការទទួលបានឱកាសតិចតួច និងការប្រឈមនឹងអំពើហិង្សា។ នៅក្នុងសហគមន៍របស់ពួកគេ ផ្នត់គំនិតយេនឌ័រច្រើនតែបន្ទចបង្អាក់មិនឱ្យពួកគេបញ្ចេញមតិ បន្តទៅឧត្តមសិក្សា ធ្វើការងារក្រៅផ្ទះ ឬការតំណាងឱ្យសហគមន៍របស់ពួកគេ។ ពួកគេក៏ប្រឈមនឹងផ្នត់គំនិតអវិជ្ជមាននៅក្នុងសង្គមកម្ពុជាផងដែរ។[223] យោងតាមរបាយការណ៍តាមប្រធានបទនៃជំរឿនទូទៅប្រជាជនឆ្នាំ ២០១៩ ស្តីពីជនជាតិភាគតិច អត្រាកំណើតនៅក្នុងចំណោមប្រជាជនជនជាតិភាគតិចខ្ពស់ជាងប្រជាជនកម្ពុជាទូទៅ។

បទសម្ភាសន៍ជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ស្ត្រី និងយុវជន សម្រាប់ការវិភាគស្ថានភាពនេះ បានបញ្ជាក់ថា ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង នៅតែកើតមានជាទូទៅក្នុងចំណោមសហគមន៍ជនជាតិភាគតិច និងជះផលអវិជ្ជមានលើក្មេងស្រីវ័យក្មេង គ្រួសារ និងសហគមន៍ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ដោយសហគមន៍ និងរដ្ឋាភិបាល ដើម្បីទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះក្នុងវ័យជំទង់ក៏ដោយ។[224] យោងតាមការសិក្សាថ្មីៗមួយស្តីពីសិទ្ធិស្ត្រីជនជាតិភាគតិចក្នុងចំណោមអ្នកដែលត្រូវបានស្ទង់មតិ ស្ត្រីជនជាតិដើមភាគតិចចំនួន ១០០ ភាគរយ ស្ត្រីជនជាតិវៀតណាមចំនួន ៧៩ ភាគរយ ស្ត្រីខ្មែរអ៊ីស្លាមចំនួន ៧២,៩ ភាគរយ និងស្ត្រីខ្មែរក្រោមចំនួន ៤៥,២ ភាគរយ បានលើកឡើងថាបានមើលឃើញការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង ឬវ័យកុមារ ក្នុងសហគមន៍របស់ពួកគេ។[225]

បើគិតពីសន្តិសុខមនុស្ស សុខភាព និងសន្តិសុខរបស់ស្ត្រី និងក្មេងស្រីដែលឆាប់រៀបការវ័យក្មេង ច្រើនតែងាយប្រឈមនឹងហានិភ័យកាន់តែខ្លាំងក្នុងពេលមានជម្លោះ ឬគ្រាអាសន្ន ហើយការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង គួបផ្សំជាមួយនឹងហានិភ័យទាំងនេះ។ ជម្លោះ និងគ្រាអាសន្នក៏អាចធ្វើឱ្យការប្រើប្រាស់អំពើហិង្សាក្នុងការដោះស្រាយបញ្ហាគ្រួសារ ក្លាយជារឿងធម្មតា ហើយវាអាចបន្សាយផលជះទៅក្នុងជម្លោះសហគមន៍ទាំងមូល។ លទ្ធផលវិជ្ជមានពីផែនការសកម្មភាពស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះវ័យជំទង់ខេត្តរតនគិរី ២០១៧-២០២១ (ពន្យារពេលរហូតដល់ឆ្នាំ២០២៣) រួមទាំងការថយចុះអាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះវ័យជំទង់ បានជំរុញឱ្យមានការពិចារណារៀបចំផែនការសកម្មភាពជាតិសម្រាប់ឆ្នាំ២០២៤-២០៣០[226]។

នៅជុំវិញពិភពលោក ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងស្ថានភាពជានិរបេតិកជន (ជនគ្មានសញ្ជាតិ) ឬគ្មានស្ថានភាពស្របច្បាប់ច្បាស់លាស់ ងាយប្រឈមនឹងអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រក្នុងកម្រិតខ្ពស់ ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចហានិភ័យដែលបណ្តាលមកពីឧបសគ្គផ្នែករចនាសម្ព័ន្ធ ដូចជា កង្វះលទ្ធភាពទទួលបានការអប់រំ ការរឹតត្បិតការធ្វើដំណើរដោយសារការភ័យខ្លាចអាជ្ញាធរ អសមត្ថភាពក្នុងការទទួលបានការងារផ្លូវការ និងការលំបាកក្នុងការកាន់កាប់ដីធ្លី។[227]

នៅកម្ពុជា មាត្រា ៩ និង ១០ នៃច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ ២០១៨ កំណត់វិធានសម្រាប់ការទទួលបានសញ្ជាតិសម្រាប់កុមារដែលកើតនៅកម្ពុជា។ រដ្ឋាភិបាលក៏បានដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម (២០១៧-២០២៦) ផងដែរ ជាមួយនឹងចក្ខុវិស័យ "មនុស្សគ្រប់រូបត្រូវបានកំណត់អត្តសញ្ញាណ។"[228] ទោះជាយ៉ាងណា ការសិក្សារបស់អង្គការមិនមែនរដ្ឋាភិបាល ឆ្នាំ ២០២៤ ស្តីពីសិទ្ធិស្ត្រីជនជាតិភាគតិច បានរកឃើញថា ស្ត្រីជនជាតិភាគតិចជាច្រើន បន្តប្រឈមនឹងការលំបាកក្នុងការទទួលបានឯកសារស្របច្បាប់នៅកម្រិតមូលដ្ឋាន ទោះបីជាមានប្រការចែងសមស្របនៅក្នុងគោលនយោបាយជាតិក៏ដោយ[229]។ គម្លាតក្នុងការអនុវត្តនេះបានរួមចំណែកបង្កជាអសន្តិសុខ អស្ថិរភាព និងលទ្ធភាពនៃការកើតមានជម្លោះក្នុងសហគមន៍រងផលប៉ះពាល់។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បញ្ជាក់ពីសិទ្ធិស្មើគ្នារបស់បុរស និងស្ត្រី និងធានាសេរីភាពក្នុងការដើរហើរ (មាត្រា ៣១ និងមាត្រា ៤០)។ ទោះជាយ៉ាងណា ការសិក្សាថ្មីមួយបង្ហាញថា ៦៤ ភាគរយនៃអ្នកឆ្លើយតបដែលជាស្ត្រីជនជាតិភាគតិចបានលើកឡើងថា ពួកគេមិនយល់ថា ពួកគេមានសេរីភាពដើរហើរក្រៅផ្ទះដូចបុរសឡើយ[230]។ បទសម្ភាសន៍ជាមួយស្ត្រីខ្មែរអ៊ីស្លាមនៅខេត្តកំពង់ឆ្នាំង បានគូសបញ្ជាក់ថា ពួកគេមានអារម្មណ៍ថា ពួកគេមានលទ្ធភាពមានកម្រិតក្នុងការទទួលបានព័ត៌មានអំពីកម្មវិធីរបស់រដ្ឋាភិបាល ដោយសារតែពួកគេមិនសូវបានចូលរួមក្នុងសកម្មភាពសហគមន៍ និងភាពជាតំណាងមានកម្រិតនៃសហគមន៍ខ្មែរអ៊ីស្លាមនៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាល។ នៅពេលគ្មានភាពជាតំណាង ឬការចូលរួមគ្រប់គ្រាន់ ពួកគេងាយនឹងឯកោ ហើយគ្មាននរណាគិតគូរពីកង្វល់របស់ពួកគេឡើយ។ បញ្ហានេះអាចបង្កើនអសន្តិសុខ និងភាពតានតឹងនៅក្នុង និងរវាងសហគមន៍នានា។

[223] សម្លេង និងភាពអាចមើលឃើញ៖ ការស្វែងយល់ដោយការចូលរួមអំពីសិទ្ធិមនុស្សរបស់ស្ត្រីជនជាតិភាគតិចនៅកម្ពុជា អង្គការស្ត្រីដើម្បីសន្តិភាព ខែមករា ឆ្នាំ២០២៤
[224] ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ/ការពិភាក្សាក្រុមគោលដៅជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ក្រុមស្ត្រី និងក្រុមយុវជន ខែសីហា ឆ្នាំ២០២៤។
[225] សម្លេង និងភាពអាចមើលឃើញ៖ ការស្វែងយល់ដោយការចូលរួមអំពីសិទ្ធិមនុស្សរបស់ស្ត្រីជនជាតិភាគតិចនៅកម្ពុជា អង្គការស្ត្រីដើម្បីសន្តិភាព ខែមករា ឆ្នាំ២០២៤
[226] របាយការណ៍ជាតិកម្ពុជា, BPfA+30, ខែ មិថុនា ឆ្នាំ ២០២៤
[227] Laura van Wass et al., ទំនាក់ទំនងរវាងភាពគ្មានសញ្ជាតិនិងការជួញដូរមនុស្សនៅប្រទេសថៃ (Oisterwijk៖ សម្ព័ន្ធអ្នកបោះពុម្ពផ្សាយផ្នែកច្បាប់ Wolf ២០១៥; Laura van Wass et al., វិធីសាស្ត្រសម្រាប់ស្វែងយល់អំពីអន្តរកម្មរវាងភាពគ្មានសញ្ជាតិនិងការជួញដូរមនុស្ស (Oisterwijk៖ សម្ព័ន្ធអ្នកបោះពុម្ពផ្សាយផ្នែកច្បាប់ Wolf ២០១៥)។
[228] អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ របាយការណ៍តាមកាលកំណត់រួមគ្នាលើកទី១៨ ដល់ទី២០ ដែលបានដាក់ជូនដោយកម្ពុជាក្រោមប្រការទី៩ នៃអនុសញ្ញា ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣ (CERD/C/KHM/18-20)
[229] Ibid
[230] *Voice and Visibility: A participatory exploration of Minority Women's human rights in Cambodia*, Women Peace Makers, January 2024

ក្រសួងកិច្ចការនារីបានបង្កើតក្រុមការងារពិសេសស្តីពីបរិយាបន្នស្ត្រី និងក្មេងស្រីងាយរងគ្រោះ ក្រោមការដឹកនាំដោយថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រសួង ដើម្បីពង្រឹងការសម្របសម្រួលផ្ទៃក្នុង និងបង្កើនកិច្ចសហការជាមួយទីភ្នាក់ងារពាក់ព័ន្ធផ្សេងទៀត។ ក្រុមការងារនេះមានគោលដៅជានាថា យុទ្ធសាស្ត្រនារីរតនៈរួមបញ្ចូល បញ្ជ្រាប និងឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមស្ត្រី និងក្មេងស្រីងាយរងគ្រោះផ្សេងៗ រួមទាំងស្ត្រីមានពិការភាព ស្ត្រីខ្មែរអ៊ីស្លាម ស្ត្រីវ័យចំណាស់ ស្ត្រីស្រឡាញ់ភេទដូចគ្នា និងស្ត្រី និងក្មេងស្រីជនជាតិដើមភាគតិច[231]។ ក្រសួងអប់រំ យុវជន និងកីឡា គាំទ្រកម្មវិធីអប់រំតាមសាលាសម្រាប់សហគមន៍ចាម រួមទាំងតាមរយៈការរក្សាសិទ្ធិរបស់ស្ត្រីមូស្លីមក្នុងការពាក់ក្រមាគ្របក្បាលក្នុងសាលារដ្ឋ ទោះបីជាសមាជិកសហគមន៍ជាច្រើននៅតែបារម្ភពីការបាត់បង់អត្តសញ្ញាណវប្បធម៌របស់ខ្លួន រួមទាំងភាសាក៏ដោយ[232]។

ជាញឹកញាប់ ស្ត្រី និងក្មេងស្រីដែលមានពិការភាព ច្រើនតែជួបប្រទះទម្រង់ចម្រុះ និងប្រទាក់ក្រឡាគ្នានៃការរើសអើង ដែលធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះ និងប្រឈមនឹងគ្រោះថ្នាក់ និងរារាំងការសម្រេចបានពេញលេញនូវសិទ្ធិមនុស្សរបស់ពួកគេ។ ហានិភ័យទាំងនេះមានភាពស្រួចស្រាវបំផុត ក្នុងអំឡុងពេលមានជម្លោះ ឬគ្រោះមហន្តរាយ នៅពេលដែលស្ត្រី និងក្មេងស្រីដែលមានពិការភាព រងផលប៉ះពាល់យ៉ាងខ្លាំង និងក្នុងបរិបទក្រោយជម្លោះ ឬអន្តរកាល ដែលការចូលរួមរបស់ពួកគេក្នុងការដោះស្រាយជម្លោះ ការផ្តល់សេវា យន្តការយុត្តិធម៌ និងដំណើរការអភិវឌ្ឍន៍ ច្រើនតែត្រូវបានមើលរំលង ឬចាត់ទុកថាមិនសូវសំខាន់[233]។

កម្ពុជាបានបង្ហាញការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះសិទ្ធិជនមានពិការភាព ដែលឆ្លុះបញ្ចាំងដោយការផ្តល់សច្ចាប័នដល់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ និងពិធីសារបន្ថែមនៃអនុសញ្ញានេះ ការចុះហត្ថលេខាលើសន្ធិសញ្ញាម៉ារ៉ាកេស និងការអនុម័តច្បាប់ស្តីពីកិច្ចការពារ និងការលើកកម្ពស់សិទ្ធិជនពិការ (ឆ្នាំ ២០០៩)។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣ ផ្តល់ក្របខណ្ឌរឹងមាំសម្រាប់សកម្មភាពក្នុងគ្រប់ក្រសួង និងទីភ្នាក់ងារទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាមួយនឹងគោលបំណងយុទ្ធសាស្ត្រនៃការលើកកម្ពស់សមភាពយេនឌ័រ និងភាពជាអ្នកដឹកនាំរបស់ស្ត្រី ក៏ដូចជាបរិយាបន្នពិការភាព និងសេវាដែលមានគុណភាពសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ[234]។ ការរួមបញ្ចូលកញ្ចប់បណ្តុះបណ្តាលសមភាពយេនឌ័រ និងបរិយាបន្នពិការភាព (GEDI) សម្រាប់អ្នកផ្តល់សេវា ជាឧទាហរណ៍មួយនៃកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធភាព រវាងក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ដើម្បីដោះស្រាយភាពប្រទាក់ក្រឡាគ្នារវាងអំពើហិង្សាទាក់ទងនឹងលើយេនឌ័រ និងពិការភាព[235]។

ក្រោមផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) ក្រុមស្ត្រីស្រលាញ់ភេទដូចគ្នា ត្រូវបានកំណត់ថាជាក្រុមងាយរងគ្រោះអាទិភាព និងងាយប្រឈមនឹងអំពើហិង្សា។ កិច្ចពិភាក្សាជាមួយមនុស្សស្រឡាញ់ភេទដូចគ្នា (LGBTIQ+) ដែលបានធ្វើឡើងសម្រាប់ជាផ្នែកមួយនៃការសិក្សានេះ បានបង្ហាញពីកម្រិតនៃពាក្យសម្តី និងមតិស្អប់ខ្ពើមការរករឿងរំខាន និងការបៀតបៀនតាមអ៊ីនធឺណិត ក៏ដូចជាការរើសអើងជាបន្តបន្ទាប់ក្នុងការទទួលបានសេវាសាធារណៈ។ បទពិសោធន៍ទាំងនេះបានជះផលអវិជ្ជមានលើសន្តិសុខផ្ទាល់ខ្លួន និងសុខភាពផ្លូវចិត្តរបស់មនុស្សស្រឡាញ់ភេទដូចគ្នា (LGBTIQ+) ដែលនាំទៅរកការបាត់បង់ការគោរពខ្លួនឯង តម្លៃផ្ទាល់ខ្លួនទាប និងជំងឺធ្លាក់ទឹកចិត្ត ហើយក៏រួមចំណែកដល់ភាពតានតឹងក្នុងសង្គមផងដែរ។

អនុសាសន៍លេខ ៤៥, ៤៧, ៥១, ៥២, ៥៤ និង ៥៥ ពីការពិនិត្យជាសកលតាមកាលកំណត់ ឆ្នាំ ២០១៩ របស់កម្ពុជាអំពាវនាវឱ្យមានការបង្កើតច្បាប់ ឬគោលនយោបាយប្រឆាំងការរើសអើងប្រឆាំងមនុស្សស្រឡាញ់ភេទដូចគ្នា (LGBTIQ+) រួមទាំងការបង្កើត និងអនុវត្តច្បាប់ស្តីពីសមភាពអាពាហ៍ពិពាហ៍ (marriage equality law)។ វិធានការទាំងនេះ នឹងជំរុញសមភាពយេនឌ័រ និងរក្សាសិទ្ធិរបស់មនុស្សស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ហើយក្នុងពេលជាមួយគ្នានោះ មានគោលដៅកាត់បន្ថយពាក្យសម្តីស្អប់ខ្ពើម និងបទល្មើសស្អប់ខ្ពើម។

[231] MoWA Neary Rattanak VI, 2024-2028
[232] Ibid
[233] https://reliefweb.int/report/world/working-toward-disability-inclusion-women-peace-and-security-agenda-arab-region
[234] https://www.undp.org/cambodia/projects/programme-promote-disability-inclusion-ppdi
[235] របាយការណ៍ថ្នាក់ជាតិកម្ពុជា, BPfA+30 ខែ មិថុនា ឆ្នាំ ២០២៤



# ៤. ការវិភាគការគូសផែនទីអ្នកពាក់ព័ន្ធ

Photo: UN Women/Lim Sophorn

ផ្នែកមួយនៃការអនុវត្តលំហាត់វិភាគស្ថានភាព គឺដើម្បីកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធបច្ចុប្បន្ន និងអ្នកពាក់ព័ន្ធសក្តានុពលដែលចូលរួមក្នុងទិដ្ឋភាពផ្សេងៗទាក់ទងនឹងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា រួមទាំងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ស្ថាប័នសិក្សា និងស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍។ ខាងក្រោមនេះជាការពិពណ៌នាបឋមអំពីអ្នកពាក់ព័ន្ធដែលត្រូវពិពណ៌នាបន្ថែមក្នុងពេលរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា។

## ៤.១. ក្រសួង/ស្ថាប័ន និងយន្តការរដ្ឋាភិបាល

គ្រប់ក្រសួង និងស្ថាប័នរដ្ឋាភិបាលទាំងអស់នៅកម្ពុជា មានតួនាទី ក្នុងការជំរុញរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ នៅពេលចាប់ផ្តើម វាមានសារៈសំខាន់ក្នុងការកំណត់អត្តសញ្ញាណស្ថាប័នពាក់ព័ន្ធ និងបន្ទាប់មកផ្តល់អាទិភាពដល់ការចូលរួមរបស់ពួកគេក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងជាអតិបរមា និងកាត់បន្ថយការងារត្រួតគ្នា។ ក្រសួង និងស្ថាប័ននានាអាចរួមចំណែកនៅដំណាក់កាលរៀបចំផែនការ ដំណាក់កាលអនុវត្ត និងដំណាក់កាលតាមដាន។ ខាងក្រោមនេះជាបញ្ជីបណ្តោះអាសន្ននៃក្រសួង/ស្ថាប័នរដ្ឋាភិបាល។

*តារាងទី ២ ៖ ក្រសួង/ស្ថាប័នរបស់រដ្ឋាភិបាល*

| ក្រសួង/ស្ថាប័ន | តួនាទី និងការរួមចំណែកដែលមានសក្តានុពលចំពោះរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា |
|---|---|
| **រដ្ឋសភា** (គណៈកម្មការទី៨) (ក្រុមស្ត្រី) | ការពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ តាមរយៈផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ការលើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងការរក្សាសន្តិភាព និងការទប់ស្កាត់ជម្លោះ រួមទាំងភាពជាអ្នកដឹកនាំរបស់ស្ត្រី និងការស្វែងរកការគាំទ្រមតិសម្រាប់ការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា។ |

| | |
|---|---|
| **ទីស្ដីការគណៈរដ្ឋមន្ត្រី (CoM)** | ការផ្ដល់ទិសដៅ និងការណែនាំយុទ្ធសាស្ត្រជារួមសម្រាប់ការរៀបចំផែនការសកម្មភាពជាតិស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ស្របតាមផែនការសកម្មភាពតំបន់អាស៊ានស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ រួមទាំងការត្រួតពិនិត្យការតាមដានការអនុវត្ត។ |
| **ក្រសួងកិច្ចការនារី (MoWA)** | ការដឹកនាំ និងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងស្ដីពីសមភាពយេនឌ័រ និងការផ្ដល់ភាពអង់អាចដល់ស្ត្រី និងការបញ្ជ្រាបយេនឌ័រក្នុងវិស័យអាទិភាព ដើម្បីពន្លឿនរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា។ នេះរួមមានការលើកកម្ពស់សិទ្ធិស្ត្រី ការចូលរួម និងភាពជាអ្នកដឹកនាំ ការលើកកម្ពស់ផែនការសកម្មភាពតំបន់អាស៊ានស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្រិតតំបន់ និងតាមរយៈការធ្វើមូលដ្ឋានីយកម្ម និងការលើកកម្ពស់ការបង្កើតយន្តការសម្របសម្រួល ក្នុងចំណោមក្រសួង និងស្ថាប័នសាមី ដោយមានការគាំទ្រពីរដ្ឋសភា គណៈរដ្ឋមន្ត្រី និងភាគីពាក់ព័ន្ធផ្សេងទៀត។ |
| **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MoFAIC)** | ការលើកកម្ពស់របៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុង វិស័យសន្តិភាព និងសន្តិសុខកម្រិតតំបន់ និងកម្រិតអន្តរជាតិ ការដាក់បញ្ចូលទស្សនៈយេនឌ័រ និងចក្ខុវិស័យស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ២០២៤-២០២៨ ដើម្បីពង្រឹងសន្តិសុខសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការអន្តរជាតិ[236] និងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។ មានចំណាប់អារម្មណ៍យ៉ាងខ្លាំង លើការដឹកនាំការរៀបចំផែនការសកម្មភាពជាតិស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា រួមទាំងការបង្កើតយន្តការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ដែលផ្ដោតសំខាន់លើទំនាក់ទំនងខាងក្រៅ និងទំនាក់ទំនងការទូតខាងក្រៅ។ |
| **ក្រសួងការពារជាតិ (MoND)** | ការដាក់បញ្ចូលរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងយុទ្ធសាស្ត្រការពារជាតិ ក្នុងករណីមានភាពពាក់ព័ន្ធ ដោយផ្ដោតលើសន្តិភាព ស្ថិរភាព និងកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ នេះរួមបញ្ចូលវិស័យសន្តិសុខ ប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងការបង្កើនការចូលរួមពេញលេញ និងប្រកបដោយអត្ថន័យ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងប្រតិបត្តិការរក្សាសន្តិភាព និងវិស័យសន្តិសុខទាំងមូល។ មានចំណាប់អារម្មណ៍យ៉ាងខ្លាំងលើការដឹកនាំការរៀបចំផែនការសកម្មភាពជាតិស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា និងការបង្កើតយន្តការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព។ |

[236] MoFAIC, Economic Diplomacy Strategy 2021-2023; Available at: https://www.mfaic.gov.kh/files/uploads/S2QKPXXAOTPW/%5BEn%5D_Economic_Diplomacy_Strategy.pdf

| | |
|---|---|
| **ក្រសួងមហាផ្ទៃ (MoI)** | ការដាក់បញ្ចូលរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងក្របខណ្ឌសន្តិសុខជាតិ ក្នុងករណីមានភាពពាក់ព័ន្ធ រួមទាំងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងអន្តរជាតិ ដើម្បីដោះស្រាយបទល្មើសឆ្លងដែន ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត ការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន និងទម្រង់ផ្សេងទៀតនៃបទល្មើសចាត់តាំង តាមរយៈគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ធានាការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាពប្រកបដោយប្រសិទ្ធភាព (VCSP)។ មានចំណាប់អារម្មណ៍យ៉ាងខ្លាំង លើការដឹកនាំការរៀបចំផែនការសកម្មភាពជាតិស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ និងការបង្កើតយន្តការសម្របសម្រួល ដោយផ្ដោតលើវិស័យសន្តិសុខក្នុងស្រុក និងការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី។ |
| **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF)** | ការដោះស្រាយភាពប្រទាក់ក្រឡាគ្នានៃអាកាសធាតុ សន្តិភាព និងសន្តិសុខ រួមទាំងការស្វែងយល់ពីរបៀបដែលផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ/បរិស្ថាន បង្កផលជះផ្សេងគ្នាលើស្ត្រី និងបុរស។ ការធានាថា ស្ត្រី និងក្រុមជួបការលំបាកត្រូវបានរួមបញ្ចូលប្រកបដោយអត្ថន័យ ហើយការព្រួយបារម្ភរបស់ពួកគេត្រូវបានដោះស្រាយ។ តាមការរំពឹងទុក នឹងមានការចូលរួមរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងការរៀបចំផែនការសកម្មភាពជាតិស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ និងយន្តការសម្របសម្រួល ដោយផ្ដោតលើការបង្កើនការចូលរួម និងការរួមចំណែកពេញលេញរបស់ស្ត្រី ដល់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាពបរិស្ថាន។ |
| **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MoPTC)** | ការបញ្ចូលទស្សនៈយេនឌ័រ និងចក្ខុវិស័យស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត អក្ខរកម្មឌីជីថល រួមទាំងក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ឆ្នាំ២០២២-២០៣៥ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ ២០២០។ តាមការរំពឹងទុក នឹងមានការចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងសសរស្តម្ភទី ១ (ការបង្ការទប់ស្កាត់) និង សសរស្តម្ភទី ៣ (ការការពារ)។ |
| **ក្រសួងព័ត៌មាន (MoINF)** | ការបញ្ចូលទស្សនៈយេនឌ័រ និងចក្ខុវិស័យស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត បណ្ដាញសង្គម និងសុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត រួមទាំងការការពារប្រឆាំងនឹងព័ត៌មានមិនពិត ពាក្យសម្ដីស្អប់ខ្ពើម និងអំពើហិង្សាលើស្ត្រី ក្នុងវេទិកាឌីជីថល។ តាមការរំពឹងទុក នឹងមានការចូលរួមរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងសសរស្តម្ភទី ១ (ការបង្ការទប់ស្កាត់) និងសសរស្តម្ភទី ៣ (ការការពារ)។ |
| **ក្រសួងអប់រំ យុវជន និងកីឡា (MoEYS)** | ការលើកកម្ពស់ការចូលរួមរបស់យុវជន និងការពង្រឹងការតភ្ជាប់រវាងយុវជន សន្តិភាព និងសន្តិសុខ (YPS) និងរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ។ នេះរួមបញ្ចូលការបង្កើនការអប់រំស្ដីពីសន្តិភាព ដោយផ្អែកលើប្រវត្តិសាស្ត្រជម្លោះ សម្រាប់ការទប់ស្កាត់ និងការស្តារឡើងវិញពីជម្លោះ និងការលើកកម្ពស់អក្ខរកម្មឌីជីថលសម្រាប់ស្ត្រី និងក្មេងស្រី។ តាមការរំពឹងទុក នឹងមានការចូលរួមរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ ក្នុងសសរស្តម្ភទី ១ (ការបង្ការទប់ស្កាត់)។ |

| | |
|---|---|
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY)** | ការផ្តល់សេវាទប់ស្កាត់ និងសេវាគាំទ្រសម្រាប់ក្រុមងាយរងគ្រោះ រួមទាំងស្ត្រីជួបការលំបាក សហគមន៍ជនជាតិដើមភាគតិច ពលករទេសន្តរប្រវេសក៍ជាស្ត្រី ស្ត្រី និងក្មេងស្រីដែលត្រូវបានជួញដូរ និងអ្នកដែលរងផលប៉ះពាល់ដោយវិបត្តិមនុស្សធម៌ ។ តាមការរំពឹងទុក នឹងមានការចូលរួមរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ ក្នុងសសរស្តម្ភទី ២ (ការការពារ) និងសសរស្តម្ភទី ៤ (ការសង្គ្រោះ និងស្តារឡើងវិញ)។ |
| **ក្រសួងសុខាភិបាល (MoH)** | ការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី/អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងលើយេនឌ័រ និងហានិភ័យសុខភាពដែលពាក់ព័ន្ធ ជាពិសេសក្នុងពេលវិបត្តិ និងស្ថានភាពគ្រោះអាសន្ន។ តាមការរំពឹងទុក នឹងមានការចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងសសរស្តម្ភទី ២ (ការការពារ) និងសសរស្តម្ភទី ៤ (ការសង្គ្រោះ និងស្តារឡើងវិញ)។ |
| **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT)** | ទ្រទេសន្តរប្រវេសន៍ការងារ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រួមទាំងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការងារសមរម្យ ទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព និងអក្ខរកម្មឌីជីថលសម្រាប់ស្ត្រី និងក្មេងស្រី។ រំពឹងថានឹងមានការចូលរួមក្នុងសសរស្តម្ភទី ១ (ការបង្ការទប់ស្កាត់) សសរស្តម្ភទី ២ (ការចូលរួម) និង សសរស្តម្ភទី ៣ (ការការពារ) និងការតភ្ជាប់នឹងសសរស្តម្ភទី ៤ (ការសង្គ្រោះ និងស្តារឡើងវិញ)។ |
| **វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ (NIS, MoP)** | ការធ្វើការស្រាវជ្រាវ និងការស្ទង់មតិដែលពាក់ព័ន្ធនឹងរបៀបវារៈ WPS រួមទាំងការផលិតស្ថិតិយេនឌ័រ និងទិន្នន័យស្តីពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ការអនុវត្តគោលនយោបាយ និងកម្មវិធី។ |
| **គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)** | ការសម្របសម្រួលផែនការសកម្មភាពជាតិ ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដើម្បីធានាការចូលរួមពេញលេញ និងប្រកបដោយអត្ថន័យរបស់ស្ត្រី និងក្រុមជួបការលំបាកក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ រំពឹងថានឹងមានការចូលរួមក្នុងសសរស្តម្ភទី ២ (ការចូលរួម) និងសសរស្តម្ភទី ៤ (ការសង្គ្រោះ និងស្តារឡើងវិញ)។ |
| **មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម (NPMEC)** | ការរួមចំណែកដល់សន្តិភាព សន្តិសុខ និងស្ថិរភាពជាតិ តំបន់ និងអន្តរជាតិតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងការពារជាតិក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ រួមទាំងកិច្ចខិតខំប្រឹងប្រែងបង្កើនការចូលរួមពេញលេញ និងប្រកបដោយអត្ថន័យ និងភាពជាអ្នកដឹកនាំរបស់ស្ត្រី។ នេះក៏ពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្ហាញភាពជាគំរូសម្រាប់ស្ត្រីនៅក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងទូទាំងវិស័យការពារជាតិ និងវិស័យសន្តិសុខផងដែរ។ |

| | |
|---|---|
| **អាជ្ញាធរមីនកម្ពុជា/មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAA/CMAC)** | ការគាំទ្រសកម្មភាពមីនដែលឆ្លើយតបនឹងយេនឌ័រ និងការបោសសម្អាតមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមក្នុងប្រទេស និងការរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងក្នុងតំបន់ និងសកល។ សកម្មភាពទាំងនេះជួយបង្កើនសន្តិសុខរបស់ស្ត្រី គ្រួសារ និងសហគមន៍ និងគាំទ្រការអនុវត្តរបៀបវារៈ WPS ទូទាំងសសរស្តម្ភទាំង ៤។ |
| **ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (CNCW)** | ទទួលខុសត្រូវក្នុងការត្រួតពិនិត្យតាមដាន និងរាយការណ៍អំពីការអនុវត្តអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) តាមរយៈយន្តការសម្របសម្រួលជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាការស្វែងរកការគាំទ្រមតិនៅកម្រិតសភា និងកម្រិតនាយករដ្ឋមន្ត្រី។ ការត្រួតពិនិត្យផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គួរតែស្របតាមការប្តេជ្ញាចិត្តក្រោមអនុសញ្ញា CEDAW។ |
| **គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (CHRC)** | ទទួលខុសត្រូវក្នុងការតាមដាន និងរាយការណ៍ជូនអង្គការសហប្រជាជាតិអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា រួមទាំងកាតព្វកិច្ចក្រោមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (CERD) ដោយមានការសម្របសម្រួលនៅទូទាំងក្រសួង និងស្ថាប័នរបស់រដ្ឋាភិបាល រួមទាំងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (CNCW)។ |

## ៤.២. សង្គមស៊ីវិល

### ៤.២.១ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអង្គការសង្គមស៊ីវិល

សង្គមស៊ីវិលនៅកម្ពុជា មានភាពរឹងមាំ និងសកម្ម ដោយអង្គការសង្គមស៊ីវិល (CSOs) ភាគច្រើនផ្តោតលើការផ្តល់សេវា និងទម្រង់ផ្សេងៗនៃការអភិវឌ្ឍ។[237] គិតត្រឹមចុងឆ្នាំ ២០២២ សមាគមជាង ២.៦០០ និងអង្គការមិនមែនរដ្ឋាភិបាលជិត ៣.៥០០ ត្រូវបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ[238] ហើយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិចំនួន ៣០០ ផ្សេងទៀត ត្រូវបានចុះបញ្ជីជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ[239]។ ក្រៅពីនេះ ក៏មានការប៉ាន់ស្មានថា មានអង្គការសហគមន៍មូលដ្ឋានចំនួន ២៥.០០០ និងបណ្តាញយ៉ាងហោចណាស់ ១១០ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអង្គការសង្គមស៊ីវិល ចូលរួមស្ទើរតែគ្រប់ទិដ្ឋភាពទាំងអស់នៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា រួមទាំងការកសាងសន្តិភាព និងការផ្សះផ្សា។ អង្គការទាំងនេះគាំទ្រយ៉ាងសកម្មដល់គោលនយោបាយ ផែនការ និងយន្តការសម្របសម្រួលភាគច្រើនរបស់រដ្ឋាភិបាល។ក្រសួងមហាផ្ទៃ ទទួលស្គាល់ការរួមចំណែករបស់អង្គការសង្គមស៊ីវិលដល់ការអភិវឌ្ឍជាតិ ជាពិសេសក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ សិទ្ធិមនុស្ស ប្រព័ន្ធយុត្តិធម៌ ការអប់រំ សុខាភិបាល ធនធានធម្មជាតិ និងបរិស្ថាន[240]។ ឧទាហរណ៍ អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិលជាង ៣០ បានចូលរួមក្នុងផែនការសកម្មភាពជាតិស្តីពីអំពើហិង្សាលើស្ត្រី និងក្រុមការងារបច្ចេកទេសស្តីពីយេនឌ័រ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ អង្គការមិនមែនរដ្ឋាភិបាលជាង ២០ បានចូលរួមក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង គ.ជ.ប.ជ ហើយអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិលជាង ១០ ធ្វើការដោយផ្ទាល់ជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ អង្គការជាច្រើនផ្សេងទៀតបានសហការជាមួយក្រសួងសាមីស្តីពីផែនការសកម្មភាពថ្នាក់ជាតិ និងផែនការសកម្មភាពតាមវិស័យ ដែលទាក់ទងនឹងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដូចជា ក្នុងវិស័យកសិកម្ម ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រង

[237] មជ្ឈមណ្ឌលសិក្សាយុទ្ធសាស្ត្រនិងអន្តរជាតិ (CSIS) ដោយ Laura Mooney និង Lana Baydas "សង្គមស៊ីវិលកម្ពុជានៅចំណុចសំខាន់" ខែមិថុនា ឆ្នាំ២០១៨
[238] https://www.khmertimeskh.com/501218514/over-6100-associations-and-ngos-recorded-in-cambodia-as-of-december-2022/
[239] https://www.mfaic.gov.kh/Page/2021-02-10-List-of-Foreign-NGOs-Which-Signed-MoU-with-the-Ministry-of-Foreign-Affairs-and-International-Cooperation
[240] https://www.khmertimeskh.com/501218514/over-6100-associations-and-ngos-recorded-in-cambodia-as-of-december-2022/

ធនធានធម្មជាតិ សកម្មភាពមីន សុខាភិបាល សង្គមកិច្ច ការអភិវឌ្ឍជនបទ ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ស្ត្រី និងការអភិវឌ្ឍយុវជន។ កិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការពង្រឹកលំហពលរដ្ឋ នៅតែជាកត្តាសំខាន់ក្នុងការជំរុញឱ្យ អង្គការសង្គមស៊ីវិលរួមចំណែកប្រកបដោយអត្ថន័យដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា និងការពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

ក្រោមគោលដៅ ១៧.៧ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព រដ្ឋត្រូវបានលើកទឹកចិត្តឱ្យលើកកម្ពស់ភាពជាដៃគូក្នុងចំណោមវិស័យសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិលប្រកបដោយប្រសិទ្ធភាព។ ខាងក្រោមនេះជាបញ្ជីសង្ខេបឈ្មោះអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ដែលចូលរួម ឬបានបង្ហាញចំណាប់អារម្មណ៍ចង់រួមចំណែកដល់ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា។ អង្គការមួយចំនួនជាអង្គការដែលអាចជាអ្នករួមចំណែក ដែលគួរស្វែងយល់បន្ថែមអំពីចំណាប់អារម្មណ៍របស់ពួកគេ។ បញ្ជីនេះនឹងត្រូវបានកែសម្រួលទៅតាមការចាំបាច់។

*តារាងទី ៣ ៖ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល*

| អង្គការ | តួនាទី និងលទ្ធភាពនៃការរួមចំណែកដល់របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា |
|---|---|
| **អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ** (ឧទាហរណ៍ មូលនិធិអាស៊ី អង្គការអាក់សិនអេតកម្ពុជា អាចនឹងមានអង្គការឃែរអន្តរជាតិ អង្គការភ្លែនអន្តរជាតិ) | អាចផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងការកសាងសមត្ថភាពក្រោមភាពជាដៃគូជាមួយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដោយផ្តោតលើសិទ្ធិស្ត្រី ការចូលរួម ភាពជាអ្នកដឹកនាំ សមភាពយេនឌ័រ ការកសាងសន្តិភាព និងការដោះស្រាយជម្លោះក្នុងមូលដ្ឋាន។ ការចូលរួមប្រកបដោយអត្ថន័យក្នុងការរៀបចំផែនការ និងការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខប្រកបដោយបរិយាបន្ន រួមទាំងការកសាងសមត្ថភាព និងការអនុវត្ត។ |
| **អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិលក្នុងស្រុក រួមទាំងបណ្តាញស្ត្រី** (អង្គការនារីដើម្បីសន្តិភាព ក្រុមការងារដើម្បីដោះស្រាយទំនាស់ មជ្ឈមណ្ឌលសិក្សា បណ្តុះបណ្តាលកសាងសន្តិភាព និងដោះស្រាយទំនាស់ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា អង្គការសីលការអង្គការក្តីករុណា អង្គការតម្លាភាពអន្តរជាតិ សមាគមជនជាតិដើមភាគតិចកម្ពុជា អង្គការជនពិការកម្ពុជា អាចនឹងមាន អង្គការចិត្តសង្គមអន្តរវប្បធម៌) | ការចូលរួមក្នុងការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ រួមទាំងតួនាទីប្រឹក្សាដែលអាចមាន នៅក្នុងយន្តការសម្របសម្រួលការអនុវត្តសកម្មភាពអាទិភាព និងការធានាថា ស្ត្រី និងសហគមន៍ដែលទទួលបានឱកាសតិចតួច ត្រូវបានតំណាង។ អាចរួមចំណែកផងដែរដល់ការត្រួតពិនិត្យតាមដាន និងរាយការណ៍ ស្របតាមផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។<br><br>ផ្តោតលើសិទ្ធិស្ត្រី និងសមភាពយេនឌ័រ រួមទាំងការចូលរួម ភាពជាអ្នកដឹកនាំ ការកសាងសន្តិភាពសហគមន៍ ការដោះស្រាយជម្លោះ និងវិវាទក្នុងមូលដ្ឋាន សិទ្ធិសេដ្ឋកិច្ច បរិយាបន្នពិការភាព អំពើហិង្សាលើស្ត្រី និងក្មេងស្រី/អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ និងការអប់រំអំពីសន្តិភាព និងយុត្តិធម៌នៅកម្រិតមូលដ្ឋាន។ |
| **អង្គការ និងបណ្តាញយុវជន** (ឧទាហរណ៍ ក្រុមប្រឹក្សាយោបល់យុវជននៃអង្គការសហប្រជាជាតិ សមាគមយុវជនខ្មែរ អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន ជាដើម) | ការចូលរួមប្រកបដោយអត្ថន័យក្នុងការរៀបចំ និងការអនុវត្តគំនិតផ្តួចផ្តើមផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅថ្នាក់មូលដ្ឋាន ដោយផ្តោតសំខាន់លើការធានាការរួមបញ្ចូលសំឡេងយុវជនដែលទទួលបានឱកាសតិចតួច។ សង្កត់ធ្ងន់លើសមភាពយេនឌ័រ និងការអប់រំអំពីសន្តិភាពសម្រាប់យុវជន រួមទាំងការកសាងសន្តិភាពសហគមន៍។ |

*ចំណាំ ៖ បញ្ជីនេះមិនមែនជាបញ្ជីគ្រប់ជ្រុងជ្រោយទេ ហើយនឹងត្រូវការការអភិវឌ្ឍបន្ថែមក្នុងអំឡុងដំណើរការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ*

### ៤.២.២ ស្ថាប័នសិក្សា/ស្រាវជ្រាវ ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធផ្សេងទៀត

ក្នុងនាមជាផ្នែកមួយនៃសង្គមស៊ីវិល ស្ថាប័នសិក្សា ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកដឹកនាំសាសនា អាចដើរតួនាទីសំខាន់ក្នុងការផ្តល់ព័ត៌មាន អប់រំ និងជំរុញរបៀបវារៈស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា ដោយផ្តោតលើសមភាពយេនឌ័រ និងសិទ្ធិស្ត្រីសម្រាប់សន្តិភាព និងស្ថិរភាពជាមួយសាធារណជនទូទៅ និស្សិត និងសហគមន៍។

*តារាងទី ៤ ៖ គ្រឹះស្ថានសិក្សា ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកដឹកនាំសាសនា*

| ស្ថាប័នសិក្សាធិការ/ប្រព័ន្ធផ្សព្វផ្សាយ/អ្នកដឹកនាំសាសនា | តួនាទី និងការរួមចំណែកប្រកបដោយសក្តានុពលចំពោះរបៀបវារៈស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខ និងផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា |
|---|---|
| **មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវនីតិមនុស្សធម៌/សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យផ្សេងទៀត** | ចូលរួមជាមួយដំណើរការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីផ្តល់ព័ត៌មានអំពីសកម្មភាពអាទិភាពស្តីពីសិទ្ធិស្ត្រី និងសមភាពយេនឌ័រ និងលើកកម្ពស់ការអប់រំអំពីសន្តិភាព យុត្តិធម៌ និងការដោះស្រាយជម្លោះ រួមទាំងប្រវត្តិសាស្ត្រខ្មែរក្រហម/អំពើប្រល័យពូជសាសន៍។ នេះរួមបញ្ចូលការស្រាវជ្រាវ ការអប់រំ ឬសិក្ខាសាលា ដើម្បីកសាងការយល់ដឹងរបស់សាធារណជន និងសិស្សនិស្សិតអំពីរបៀបវារៈស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខ។ |
| **វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និងស្ថាប័នស្រាវជ្រាវផ្សេងទៀត** | ចូលរួមក្នុង ឬធ្វើការស្រាវជ្រាវ និងការសិក្សាស្តីពីបញ្ហាស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា ដើម្បីផ្តល់ព័ត៌មានដល់ការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ នេះរួមបញ្ចូលការស្រាវជ្រាវស្តីពីភាពជាអ្នកដឹកនាំ និងការចូលរួមរបស់ស្ត្រី ការផលិតទិន្នន័យយេនឌ័រ និងភស្តុតាងដើម្បីណែនាំដល់ការរៀបចំគោលនយោបាយ និងការអនុវត្ត និងការគាំទ្រសម្រាប់គំនិតផ្តួចផ្តើមកសាងការយល់ដឹងជាសាធារណៈ។ |
| **ប្រព័ន្ធផ្សព្វផ្សាយ** | ចូលរួមក្នុងការបង្កើនការយល់ដឹង និងការផ្សព្វផ្សាយរបៀបវារៈស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខ និងផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ រួមទាំងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមប្រកបដោយសុវត្ថិភាព និងការទទួលខុសត្រូវ អក្ខរកម្មឌីជីថល និងលទ្ធភាពទទួលបានព័ត៌មានដែលអាចជឿទុកចិត្តបាន និងសិទ្ធិស្ត្រី។ |
| **អ្នកដឹកនាំសាសនា** | ផ្សព្វផ្សាយព័ត៌មានអំពីរបៀបវារៈស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខតាមរយៈអាជ្ញាធរមូលដ្ឋាន និងសហគមន៍។ គាំទ្រការកសាងសន្តិភាពសហគមន៍ និងការចូលរួមរបស់សាធារណជនជាមួយផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា។ |

## ៤.៣. ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត

ទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍អាស៊ាន គឺជាតួអង្គសំខាន់ៗក្នុងការគាំទ្ររបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ខាងក្រោមនេះ គឺជាបញ្ជីបណ្ដោះអាសន្នមួយនៃភាគីពាក់ព័ន្ធទាំងនេះសម្រាប់ការជំរុញផែនការសកម្មភាពជាតិស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា។

*តារាងទី ៥ ៖ ដៃគូអភិវឌ្ឍន៍ និងទីភ្នាក់ងារអង្គការសហប្រជាជាតិ*

| **អង្គការ** | **តួនាទី និងលទ្ធភាពនៃការរួមចំណែកដល់របៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ និងផែនការសកម្មភាពជាតិស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ នៅកម្ពុជា** |
|---|---|
| **អង្គការ UN Women** | ដឹកនាំការគាំទ្របច្ចេកទេសសម្រាប់ការរៀបចំ និងការអនុវត្តក្របខណ្ឌគោលនយោបាយបែបនិយាម ដើម្បីពន្លឿនរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា រួមទាំងការតម្រឹមតម្រង់រវាងផែនការសកម្មភាពតំបន់អាស៊ានស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ និងផែនការសកម្មភាពជាតិស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ។ នេះរួមបញ្ចូលការជំរុញសិទ្ធិស្ត្រី និងសមភាពយេនឌ័រ (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៥) ការផ្ដល់ជំនួយបច្ចេកទេស ដើម្បីដាក់បញ្ចូលអំពើហិង្សាទាក់ទងនឹងយេនឌ័រទៅក្នុងស្ថានភាពក្រោយជម្លោះ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការឆ្លើយតបផ្នែកមនុស្សធម៌ ការកសាងការយល់ដឹងស្ដីពីភាពពាក់ព័ន្ធគ្នារវាងអាកាសធាតុ សន្តិភាព និងសន្តិសុខ និងរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ការលើកកម្ពស់ការបញ្ជ្រាបយេនឌ័រទៅក្នុងភាពធន់នឹងអាកាសធាតុ និងគ្រោះមហន្តរាយ និងការកៀរគរតួអង្គសង្គមស៊ីវិល រួមទាំងអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល។ |
| **ការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិ (UNRCO)** | ប្រើប្រាស់ការចូលរួមរបស់ទីភ្នាក់ងារអង្គការសហប្រជាជាតិ ជាមួយផែនការសកម្មភាពជាតិស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៥ និងទី ១៦ និងគោលការណ៍មិនទុកនរណាម្នាក់ចោល តាមរយៈការស្វែងរកមតិគាំទ្រនយោបាយកម្រិតខ្ពស់ ការគាំទ្រដល់ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល និងការសម្របសម្រួលជាមួយរដ្ឋាភិបាល និងទីភ្នាក់ងារទ្វេភាគី ដើម្បីពន្លឿនរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ។ |
| **មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA)** | អាចនឹងផ្ដល់ការគាំទ្របច្ចេកទេស ក្នុងនាមជាសហប្រធានក្រុមមូលបទយេនឌ័រនៃអង្គការសហប្រជាជាតិ ដោយផ្ដោតលើសមភាពយេនឌ័រ សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងសិទ្ធិរបស់ស្ត្រី អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ/អំពើហិង្សាលើស្ត្រីក្នុងស្ថានភាពក្រោយជម្លោះ និងមនុស្សធម៌ (GBViE) ការចូលរួមរបស់យុវជន និងការបង្កើនការប្រមូលទិន្នន័យបែងចែកជាប្រភេទ និងការវិភាគសម្រាប់ការអភិវឌ្ឍ។ |

| | |
|---|---|
| **កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)** | អាចនឹងផ្ដល់ការគាំទ្របច្ចេកទេស ក្នុងនាមជាសហប្រធានក្រុមមូលបទយេនឌ័ររបស់អង្គការសហប្រជាជាតិ តាមរយៈឯកទេសតាមមូលបទស្ដីពីសិទ្ធិស្ត្រី សេដ្ឋកិច្ចដែលគិតគូរពីសុខុមាលភាព សិទ្ធិសេដ្ឋកិច្ច ការប្រែប្រួលអាកាសធាតុ ឬការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ សកម្មភាពមីន និងសិទ្ធិជនមានពិការភាព។ |
| **ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UN OHCHR)** | អាចនឹងផ្ដល់ការគាំទ្របច្ចេកទេស ដល់ផែនការសកម្មភាពជាតិស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ដោយផ្ដោតលើវិស័យច្បាប់ និងយុត្តិធម៌ និងក្រុមស្ត្រីទទួលបានឱកាសតិចតួច រួមទាំងតួនាទីជំរុញគំនិតផ្ដួចផ្ដើមជាមួយអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិល។ |
| **ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC)** | អាចនឹងផ្ដល់ការគាំទ្រដល់សកម្មភាពរដ្ឋាភិបាលស្ដីពីស្ត្រី ក្នុងការអនុវត្តច្បាប់ បទល្មើសឆ្លងដែន និងបទល្មើសឆ្លងកាត់ព្រំដែន ការជួញដូរមនុស្ស និងការជួញដូរគ្រឿងញៀន។ |
| **ស្ថានទូតចក្រភពអង់គ្លេស (រួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមកាណាដា អូស្ត្រាលី សហរដ្ឋអាមេរិក សាធារណរដ្ឋកូរ៉េ ជប៉ុន ហ្វីលីពីន និងប្រទេសសមាជិកអាស៊ានផ្សេងទៀត)** | ស្ថានទូតរបស់បណ្ដាប្រទេសនានា មានគោលជំហរល្អប្រសើរក្នុងការផ្ដល់ការគាំទ្រដ៏មានតម្លៃក្នុងផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងនយោបាយសម្រាប់ការពន្លឿនរបៀបវារៈ WPS នៅកម្ពុជា រួមទាំងការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ និងផែនការសកម្មភាពជាតិស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខដែលនឹងរៀបចំឡើងនាពេលខាងមុខ។ លទ្ធភាពនៃការរួមចំណែក គ្របដណ្ដប់លើផ្នែកមូលបទផ្សេងៗជាច្រើន រួមទាំងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ច ការអប់រំ សកម្មភាពមីន យុត្តិធម៌ស្ដារឡើងវិញ ការចូលរួមរបស់សភា ការប្រែប្រួលអាកាសធាតុ ពិការភាព និងបរិយាបន្នសង្គម ការកសាងសន្តិភាពសហគមន៍ ការប្រឡូក និងការចូលរួមរបស់យុវជនក្នុងប្រតិបត្តិការរក្សាសន្តិភាព អ.ស.ប។ ស្ថានទូតជាច្រើនក៏គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់សង្គមស៊ីវិល ក្នុងមូលដ្ឋានផងដែរ ជាពិសេសអង្គការមិនមែនរដ្ឋាភិបាល និងគំនិតផ្ដួចផ្ដើមដឹកនាំដោយយុវជន។ ខណៈដែលចំណុចចាប់ផ្ដើមអាចខុសគ្នាទៅតាមស្ថានទូតនីមួយៗ ការរួមចំណែកទាំងអស់សុទ្ធតែបន្សុីគ្នានឹងក្របខណ្ឌជាតិ និងក្របខណ្ឌតំបន់ និងត្រូវបានសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ។ |

# ផ្នែកទី ៣

# ភាលានុវត្តភាព បញ្ហាប្រឈម និង មេរៀនដែលទទួលបាន



Photo: UN Women/Lim Sophorn



# ៥. ឧត្តមានុវត្តន៍ កាលានុវត្តភាព និងបញ្ហាប្រឈម

## ៥.១. កាលានុវត្តភាព

ការបង្កើតផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នឹងផ្អែកលើការតម្រឹមតម្រង់ជាមួយផែនការសកម្មភាពជាតិ និងយុទ្ធសាស្ត្រមានស្រាប់របស់រដ្ឋាភិបាល ដើម្បីធានាភាពស៊ីសង្វាក់គ្នានឹងអាទិភាពគោលនយោបាយជាតិ និងពង្រឹងកម្លាំងផ្គួបក្នុងចំណោមផែនការផ្សេងៗ។ ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នឹងបំពេញបន្ថែមលើក្របខណ្ឌដែលមានស្រាប់ទាំងនេះនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការដាក់ចេញសមាសភាគសន្តិភាព និងសន្តិសុខ និងការអនុវត្តចក្ខុវិស័យស្ត្រី សន្តិភាព និងសន្តិសុខ។ ផែនការសកម្មភាពនេះក៏នឹងជួយលើកកម្ពស់ និងចាប់ដំណើរការឡើងវិញនូវរបៀបវារៈសមភាពយេនឌ័រផងដែរ ដោយសង្កត់ធ្ងន់លើភាពពាក់ព័ន្ធដ៏សំខាន់របស់វាទៅនឹងអាទិភាពរបស់រដ្ឋាភិបាលស្តីពីសន្តិភាព និងសន្តិសុខ។

ឧទាហរណ៍ កម្ពុជាមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងផ្នែកនយោបាយ ដើម្បីបង្កើនការបញ្ជូនកងកម្លាំងរក្សាសន្តិភាពជាស្ត្រី ឱ្យបានយ៉ាងតិច ២០ ភាគរយ នៅឆ្នាំ ២០២៤ ដែលលើសគោលដៅកំណត់ ១៥ ភាគរយរបស់អង្គការសហប្រជាជាតិ។ កម្ពុជាសម្រេចបានគោលដៅនេះនៅខែ ឧសភា ឆ្នាំ ២០២៤ និងសម្រេចលើសគោលដៅនៅខែ ធ្នូ ឆ្នាំ ២០២៤ ដោយបានបញ្ជូនកងកម្លាំងរក្សាសន្តិភាពជាស្ត្រីចំនួន ២១,៤ ភាគរយ។ សមិទ្ធផលនេះឆ្លុះបញ្ចាំងពីការទទួលស្គាល់របស់រដ្ឋាភិបាលកម្ពុជាចំពោះតួនាទីដ៏សំខាន់របស់ស្ត្រីក្នុងការរក្សាសន្តិភាព និងការទប់ស្កាត់ជម្លោះ។ លើសពីនេះទៀត ក្រសួងកិច្ចការនារីមានតួនាទីសក្តិសមក្នុងការពន្លឿនរបៀបវារៈ WPS នៅកម្ពុជា ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដោយយោងទៅតាមការដឹកនាំយ៉ាងស្វិតស្វាញ ការប្តេជ្ញាចិត្តដ៏មុតមាំ និងតួនាទីរបស់ក្រសួងនេះ ក្នុងនាមជាប្រធានក្រុមប្រឹក្សាអាស៊ានស្តីពី WPS។

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុសម្រាប់យេនឌ័រ និងការប្រែប្រួលអាកាសធាតុ (២០១៣-២០២៣) និងផែនការសកម្មភាពស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (២០១៩-២០២៣) ដែលសុទ្ធតែគាំទ្រដោយយន្តការសម្របសម្រួលដែលបានបង្កើតឡើង ដូចជា ក្រុមការងារបច្ចេកទេសស្តីពីយេនឌ័រ-អំពើហិង្សាទាក់ទងនឹងលើយេនឌ័រ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានជួយពង្រឹងកិច្ចការរវាងភាគីពាក់ព័ន្ធ ពន្លឿនវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅដែលពាក់ព័ន្ធនឹងយេនឌ័រ និងបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការដោះស្រាយបញ្ហា

ទាំងនេះ ដើម្បីកែលម្អស្ថានភាពរបស់ស្ត្រី ក្មេងស្រី និងសង្គមទាំងមូល។ ផែនការសកម្មភាពជាតិទាំងនេះ គឺជាឧបករណ៍ដែលមានប្រសិទ្ធភាពសម្រាប់ពន្លឿនវឌ្ឍនភាពរបស់កម្ពុជាឆ្ពោះទៅសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ហើយផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នឹងរួមចំណែកដល់ការពន្លឿនអាទិភាពជាតិស្តីពីសន្តិភាព និងសន្តិសុខ។

ឧទាហរណ៍ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ដើរតួនាទីជាក្របខណ្ឌដែលមានប្រសិទ្ធភាពសម្រាប់ការសម្របសម្រួលពហុវិស័យរវាង និងជាមួយភាគីពាក់ព័ន្ធរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ក្រុមការងារបច្ចេកទេសស្តីពីយេនឌ័រ-អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងក្រុមការងារអំពើហិង្សាទាក់ទងនឹងយេនឌ័រ បានផ្តល់យន្តការសម្រាប់ការសម្របសម្រួល និងកិច្ចសហការលើការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ មេរៀនដែលទទួលបានពីការវាយតម្លៃចុងក្រោយលើផែនការសកម្មភាពជាតិទី៣ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៩-២០២៣) ដែលពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ រួមបញ្ចូលសារៈសំខាន់នៃការកំណត់លក្ខខណ្ឌយោងច្បាស់លាស់សម្រាប់ស្ថាប័នសម្របសម្រួល និងសមាជិក ដែលរៀបរាប់យ៉ាងច្បាស់នូវតួនាទី និងការទទួលខុសត្រូវលើការរៀបចំផែនការ ការអនុវត្ត និងការរាយការណ៍ ហើយទន្ទឹមនឹងនោះ ក៏គូសបញ្ជាក់ពីភាពចាំបាច់នៃការប្រមូលទិន្នន័យជាប្រព័ន្ធ ការវាស់វែងវឌ្ឍនភាព ការត្រួតពិនិត្យតាមដាន ការវិភាគ និងការរាយការណ៍ស្តីពីលទ្ធផល និងសមិទ្ធផល ក៏ដូចជាការពង្រឹងការរៀបចំផែនការថវិកាផងដែរ។[241]

ការជួញដូរមនុស្សត្រូវបានលើកឡើងក្រោមផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NSP-CTIP) ដែលដឹកនាំដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ វិស័យអាទិភាពរបស់ផែនការនេះបំពេញបន្ថែមលើវិស័យអាទិភាពនៃ NAPVAW។ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី គឺជាប្រធានក្រុមការងារអន្តរក្រសួងស្តីពីទំនាក់ទំនងអន្តរជាតិរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហើយនាយកដ្ឋានកិច្ចការពារផ្លូវច្បាប់នៃក្រសួងកិច្ចការនារីចូលរួមយ៉ាងសកម្មក្នុងក្រុមការងាររបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជានាបាននូវកម្លាំងផ្ទួនៃកិច្ចខិតខំប្រឹងប្រែងរវាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ក្រសួងកិច្ចការនារីដើរតួនាទីជាយុទ្ធសាស្ត្រក្នុងការលើកកម្ពស់ភាពពាក់ព័ន្ធគ្នារវាង NAP-WPS, NAPVAW, NSP-CTIP និង NAP-DRR។

ផែនការសកម្មភាពជាតិនៅកម្ពុជា បានបន្តពង្រឹងការសម្របសម្រួលពហុភាគីពាក់ព័ន្ធ និងការអនុវត្តសកម្មភាពនានា ដើម្បីជំរុញសមភាពយេនឌ័រ និងសិទ្ធិស្ត្រី។ ការអនុវត្តដែលមានសក្តានុពល រួមមានការជំរុញការចូលរួមរបស់ក្រសួង និងស្ថាប័នរដ្ឋាភិបាលផ្សេងៗ អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល វិស័យឯកជន ប្រព័ន្ធផ្សព្វផ្សាយ គ្រឹះស្ថានសិក្សា និងស្រាវជ្រាវ និងអ្នកដឹកនាំសាសនា នៅក្នុងការរៀបចំផែនការ និងការអនុវត្ត ដែលផ្តោតជុំវិញគោលដៅរួម ដូចជា ការបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ឬការទប់ស្កាត់ការជួញដូរមនុស្ស។

អង្គការ UN Women ដើរតួនាទីដ៏សំខាន់ក្នុងការជំរុញរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ នៅកម្រិត សកល កម្រិតតំបន់ និងកម្រិតជាតិ។ នៅកម្រិតសកល អង្គការ UN Women ជាទីភ្នាក់ងារឈានមុខលើរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ហើយផ្អែកលើការងារនៃស្ថាប័នមុនៗរបស់ខ្លួន អង្គការនេះបាន និងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប និងសេចក្តីសម្រេចជាបន្តបន្ទាប់ផ្សេងទៀត។ នេះរួមបញ្ចូលការធ្វើការងារយ៉ាងជិតស្និទ្ធជាមួយចលនាស្ត្រី និងការផ្អែកលើការជំរុញការចូលរួមក្នុងប្រព័ន្ធ អ.ស.ប ជាច្រើនទសវត្សរ៍កន្លងមកនៅក្នុងបរិបទចម្រុះ។ នៅកម្រិតតំបន់ អង្គការ UN Women គឺជាទីភ្នាក់ងារឈានមុខដែលជួយដល់អាស៊ានក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដោយបានផ្តល់ឱកាសដល់កម្ពុជាក្នុងការផ្លាស់ប្តូរការអនុវត្តល្អ និងមេរៀននៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ តាមរយៈការិយាល័យអង្គការ UN Women ប្រចាំតំបន់

[241] ក្រសួងកិច្ចការនារី ការវាយតម្លៃចុងក្រោយនៃផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី III ខែឧសភា ឆ្នាំ២០២៣

អាស៊ីប៉ាស៊ីហ្វិក។ នៅកម្រិតជាតិ អង្គការ UN Women គឺជាដៃគូសំខាន់ និងយូរអង្វែងរបស់រដ្ឋាភិបាលកម្ពុជាក្នុងការពន្លឿនសមភាពយេនឌ័រ រួមទាំងតាមរយៈការផ្តល់ការគាំទ្រដល់ក្រសួងកិច្ចការនារី ក្នុងការរៀបចំ និងអនុវត្តគោលនយោបាយសំខាន់ៗ ដូចជា ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងការតាមដានការអនុវត្តអនុសញ្ញា CEDAW។

អង្គការ UN Women ក៏រក្សាទំនាក់ទំនងរឹងមាំជាមួយសង្គមស៊ីវិល និងអង្គការស្ត្រីនៅកម្ពុជាផងដែរ តាមរយៈការធានាការរួមបញ្ចូលប្រកបដោយអត្ថន័យនូវក្រុមស្ត្រីជួបការលំបាកក្នុងដំណើរការអភិវឌ្ឍន៍ និងការស្តាបនាពីលើការផ្តល់សេវា និងការចូលរួមរបស់ខ្លួនក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្នុងនាមជាសមាជិកសំខាន់នៃក្រុមបច្ចេកទេសយេនឌ័រនៃអង្គការសហប្រជាជាតិនៅកម្ពុជា អង្គការ UN Women សហការជាមួយទីភ្នាក់ងារអង្គការសហប្រជាជាតិផ្សេងទៀត ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិស្ត្រីក្នុងបរិបទស្ត្រី សន្តិភាព និងសន្តិសុខ ស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០៣០។

អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលជាច្រើនបានបង្ហាញថាជា អ្នកអនុវត្តដ៏មានប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋាន ដោយចូលរួមជាមួយក្រុមស្ត្រី យុវជន និងក្មេងស្រីផ្សេងៗគ្នានៅកម្រិតសហគមន៍ រួមទាំងស្ត្រីមកពីក្រុមជួបការលំបាក និងធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីជំរុញសមភាពយេនឌ័រ ស្របតាមគោលនយោបាយ និងផែនការជាតិ។ អង្គការទាំងនេះបានផ្តល់សេវាសំខាន់ៗ គាំទ្រកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាព និងបានរួមចំណែកផ្តល់មតិយោបល់ដ៏មានតម្លៃ និងមេរៀន ដើម្បីកែលម្អគោលនយោបាយ គោលការណ៍ណែនាំ នីតិវិធីប្រតិបត្តិស្តង់ដារ និងយន្តការផ្សេងទៀត ដើម្បីលើកកម្ពស់សិទ្ធិស្ត្រីនៅកម្ពុជា។

## ៥.២. បញ្ហាប្រឈម

ការគំរាមកំហែងថ្មីៗដល់សន្តិភាព និងសន្តិសុខបង្កផលប៉ះពាល់កាន់តែខ្លាំងលើសន្តិសុខរបស់ស្ត្រី។ បញ្ហាទាំងនេះក៏អាចធ្វើឱ្យប៉ះពាល់ដល់សិនិទ្ធពលសង្គម និងសន្តិភាព និងសន្តិសុខជារួមនៅកម្ពុជាទៀតផង។ ឧទាហរណ៍ វិបត្តិកូវីដ-១៩ ដែលបច្ចុប្បន្ន ត្រូវបានទទួលស្គាល់ជាការគំរាមកំហែងសន្តិភាព និងសន្តិសុខថ្មីមួយ បានបង្កបញ្ហាប្រឈមដល់ស្ថិរភាពអន្តរជាតិ តំបន់ និងជាតិ។ នៅកម្ពុជា វិបត្តិនេះបានគំរាមកំហែងដល់សិនិទ្ធពលសង្គម និងសន្តិសុខនៅកម្រិតសហគមន៍ និងធ្វើឱ្យស្ត្រីកាន់តែងាយប្រឈមនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ មេរៀនសំខាន់មួយពីជំងឺរាតត្បាតសកល រួមទាំងនៅក្នុងតំបន់អាស៊ាន គឺគ្មានប្រទេស ឬសហគមន៍ណាអាចមានសុវត្ថិភាព ដោយគ្មានការចូលរួមពេញលេញ និងប្រកបដោយអត្ថន័យរបស់ស្ត្រីបានឡើយ។ ប្រសិនបើស្ត្រីត្រូវបានដាត់ចេញពីការធ្វើសេចក្តីសម្រេចចិត្ត និងការរៀបចំ និងអនុវត្តដំណោះស្រាយ ដូចជាការចាក់វ៉ាក់សាំង ការពាក់ម៉ាស់ និងការរក្សាគម្លាតសង្គម វីរុសនេះនឹងបន្តឆ្លងរាលដាល ដែលធ្វើឱ្យប្រជាជនគ្រប់រូបកាន់តែប្រឈមនឹងហានិភ័យ និងគួបផ្សំនឹងការគំរាមកំហែងសន្តិសុខដែលមានស្រាប់។

ការគំរាមកំហែងដល់សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត គឺជាឧទាហរណ៍មួយផ្សេងទៀត។ ពាក្យសម្តីស្អប់ខ្ពើមតាមអ៊ីនធឺណិត ការរករឿងរំខាន ការបៀតបៀន និងការរើសអើងដែលផ្តោតគោលដៅលើស្ត្រី ក្មេងស្រី និងក្រុមជួបការលំបាកផ្សេងទៀត អាចជំរុញឱ្យមានអំពើហិង្សាលើបុគ្គល ក៏ដូចជាសហគមន៍ទាំងមូល ដូច្នេះ វានឹងធ្វើឱ្យធ្លាក់ចុះទំនុកចិត្តក្នុងសង្គម និងបង្កការគំរាមកំហែងធ្ងន់ធ្ងរដល់សុវត្ថិភាព និងសន្តិសុខរបស់សហគមន៍ និងប្រទេសកម្ពុជាទាំងមូល។

ទោះបីជាភាគីពាក់ព័ន្ធបានទទួលស្គាល់ពីសារៈសំខាន់ និងការមានក្របខណ្ឌតាមដាន វាយតម្លៃ និងរៀនសូត្រនៅក្នុងផែនការសកម្មភាពជាតិ និងយុទ្ធសាស្ត្រនានា ដូចជា ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក៏ដោយ ក៏ការតាមដានការអនុវត្ត និងការវាស់វែងលទ្ធផល នៅតែជាបញ្ហាប្រឈម ដោយសារកង្វះខាតធនធាន កត្តារារាំងផ្នែកសមត្ថភាព និងសំណុំសកម្មភាពដែលមានមានមហិច្ឆតាខ្ពស់ពេក។ ជារឿយៗ មានកង្វះខាតយន្តការជាប្រព័ន្ធសម្រាប់ការប្រមូលទិន្នន័យ ការវិភាគ ការតាមដាន និងការរាយការណ៍ ដែលធ្វើឱ្យមានការលំបាកក្នុងការប៉ាន់ប្រមាណកម្រិតនៃការអនុវត្ត ឬការវាស់វែងវឌ្ឍនភាពធៀបនឹងគោលបំណងដែលបានកំណត់។[២៤២]

[242] ក្រសួងកិច្ចការនារី ការវាយតម្លៃចុងក្រោយនៃផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី III ខែឧសភា ឆ្នាំ២០២៣

រាជរដ្ឋាភិបាល ដែលមានក្រសួងកិច្ចការនារីជាតួអង្គដឹកនាំកិច្ចខិតខំប្រឹងប្រែង សម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការជំរុញសមភាពយេនឌ័រ តាមរយៈការបញ្ជ្រាបយេនឌ័រនៅក្នុងផែនការថ្នាក់ជាតិ និងផែនការតាមវិស័យ និងការអនុវត្តវិធីសាស្ត្រសម្របសម្រួលពហុភាគីពាក់ព័ន្ធ។ ទោះយ៉ាងណា មន្ត្រីរដ្ឋាភិបាលជាច្រើននៅតែយល់ថា សកម្មភាពទាក់ទងនឹងយេនឌ័រ និងសិទ្ធិស្ត្រី គឺជាការទទួលខុសត្រូវរបស់ក្រសួងកិច្ចការនារីតែមួយគត់។ ការយល់ឃើញបែបនេះអាចបន្ទុចបង្អាក់មិនឱ្យក្រសួង និងស្ថាប័នផ្សេងទៀតរួមចំណែកផ្តល់ធនធានដល់កិច្ចខិតខំប្រឹងប្រែងស្តីពីសមភាពយេនឌ័រ។[243] ការសិក្សាមួយស្តីពីស្ត្រីក្នុងការអនុវត្តច្បាប់នៅទូទាំងអាស៊ាន បានរកឃើញថា ការបណ្តុះបណ្តាលស្តីពីយេនឌ័រ និងសិទ្ធិមនុស្សកម្រត្រូវបានកំណត់ជាកាតព្វកិច្ចណាស់ ហើយនៅពេលដែលការបណ្តុះបណ្តាលបែបនេះមិនមែនជាកាតព្វកិច្ច បុរសកម្រនឹងចូលរួមណាស់ ដោយសារតែពួកគេមិនត្រូវបានអញ្ជើញ ឬដោយសារខ្វះចំណាប់អារម្មណ៍លើប្រធានបទនៃការបណ្តុះបណ្តាលនោះ។[244]

ទោះបីជាមានសមិទ្ធផលគួរឱ្យកត់សម្គាល់ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីក៏ដោយក៏ស្ត្រីកម្ពុជាបន្តប្រឈមនឹងការលំបាកនានា។ បទដ្ឋានសង្គម ជាពិសេសបទដ្ឋានជុំវិញការងារថែទាំដោយមិនទទួលបានប្រាក់កម្រៃ និងការទទួលខុសត្រូវក្នុងគ្រួសារ បន្តរឹតត្បិតការអភិវឌ្ឍសក្តានុពលពេញលេញរបស់ស្ត្រី និងកម្រិតការចូលរួមរបស់ស្ត្រីនៅក្នុងជីវិតសេដ្ឋកិច្ច សង្គម សាធារណៈ និងនយោបាយ។

[243] ដូចខាងលើ
[244] ស្ត្រីក្នុងការអនុវត្តច្បាប់នៅក្នុងតំបន់អាស៊ាន របាយការណ៍សង្ខេប អង្គការប៉ូលីសអន្តរជាតិ (INTERPOL) ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀននិងឧក្រិដ្ឋកម្ម (UNODC) និងអង្គការ UN Women ឆ្នាំ២០២០



# ៦. មេរៀនដែលបានទទួលពីបទពិសោធន៍របស់ប្រទេសផ្សេងទៀត លើផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS)

Photo: UN Women/Lim Sophorn

## ៦.១. បទពិសោធន៍សកលនៃការរៀបចំ និងការអនុវត្តផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS)

ចាប់តាំងពីឆ្នាំ ២០០៦ មក រដ្ឋសមាជិកអង្គការសហប្រជាជាតិចំនួន ១០៨ (៥៦ ភាគរយ) បានអនុម័តផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ហើយអង្គការអនុតំបន់ចំនួន ៨ រួមទាំងអាស៊ាន បានបង្កើតផែនការសកម្មភាពថ្នាក់តំបន់។ ទាំងនេះជាបង្គោលចរសំខាន់ៗ ក្នុងការពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ប្រទេសចំនួន ១៣ បានបង្កើតផែនការសកម្មភាពជាតិយ៉ាងតិចមួយស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ទោះយ៉ាងណា រដ្ឋជាច្រើនដែលមានការទទួលខុសត្រូវចម្បងលើការអនុវត្ត នៅតែប្រឈមនឹងបញ្ហាក្នុងការប្រែក្លាយការប្តេជ្ញាចិត្តទៅជាសកម្មភាពប្រកបដោយអត្ថន័យ។

ការសិក្សាជាសកល ឆ្នាំ ២០១៥ ស្តីពីការអនុវត្តសេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប (UNSCR 1325) បានទទួលស្គាល់ភស្តុតាងនៃវឌ្ឍនភាព ប៉ុន្តែបានរកឃើញថាផែនការសកម្មភាពជាតិជាច្រើន គឺជាញឹកញាប់មិនអាចសម្រេចបានជាក់ស្តែង ឬខ្វះឆន្ទៈនយោបាយ និងធនធានដែលត្រូវការចាំបាច់សម្រាប់ការអនុវត្តដោយប្រសិទ្ធភាព។ កម្សោយក្នុងការតាមដានគណនេយ្យភាពមានកម្រិត និងកង្វះការសម្របសម្រួល រវាងស្ថាប័នរដ្ឋាភិបាល និងកម្រិតអភិបាលកិច្ច ត្រូវបានចាត់ទុកជាបញ្ហាប្រឈមដដែលៗ។[246] ចំណុចខ្សោយរួមមួយនៃផែនការសកម្មភាពជាតិដំបូងៗ គឺថាផែនការនេះព្យាយាមលើកឡើងពីវិសាលភាពនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដោយមិនមានភាពស៊ីជម្រៅ។ ឧទាហរណ៍ ផែនការសកម្មភាពជាតិស្តីពីស្ត្រីសន្តិភាព និងសន្តិសុខលើកទី ៤ របស់ប្រទេសន័រវែស បានបង្រួមចំណុចផ្តោតសំខាន់ត្រឹមគោលបំណងរួមចំនួន ៤ ៖ ដំណើរការសន្តិភាព និងការផ្សះផ្សា ការអនុវត្តកិច្ចព្រមព្រៀងសន្តិភាព ប្រតិបត្តិការ និងបេសកកម្ម និងកិច្ចខិតខំប្រឹងប្រែងមនុស្សធម៌។[246]

ផ្អែកលើមេរៀនដែលទទួលបានវិធីសាស្ត្រមានផលជះខ្ពស់ត្រូវបានបង្កើតឡើងសម្រាប់ណែនាំដល់រដ្ឋាភិបាលក្នុងការរៀបចំក្របខណ្ឌផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលគាំទ្រការអនុវត្តដោយជោគជ័យ។ វិធីសាស្ត្រនេះបានកំណត់ធាតុផ្សំសំខាន់ៗ និងគោលការណ៍ណែនាំ ដែលគួរបញ្ចូលជាការអនុវត្តល្អក្នុងការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ។[247]

[245] https://wps.unwomen.org/about/
[246] ឆ្ពោះទៅរកការអនុវត្តរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខពេញលេញនៅវៀតណាម របាយការណ៍ដើម្បីរួមចំណែកដល់ការអភិវឌ្ឍផែនការសកម្មភាពជាតិលើកដំបូងរបស់វៀតណាមស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ Mirsad Miki Jacevic អង្គការ UN Women ការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ខែធ្នូ ឆ្នាំ២០២២
[247] Ibid

*រូបភាពទី ១ ៖ ទម្រង់ធម្មតានៃក្របខណ្ឌផលជះកម្រិតខ្ពស់នៃផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ*




*តារាងទី ៦ ៖ ការពណ៌នាអំពីក្របខណ្ឌផលជះខ្ពស់នៃផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ*

| ក្របខណ្ឌផលជះកម្រិតខ្ពស់ | |
|---|---|
| **១.ឆន្ទៈនយោបាយរឹងមាំ និងមាននិរន្តរភាព** | គោលបំណងនៃផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គឺការផ្តល់ក្របខណ្ឌមួយសម្រាប់ការសម្របសម្រួល ការបង្កើតសកម្មភាព និងគណនេយ្យភាព។ ក្រសួងពាក់ព័ន្ធទាំងអស់ត្រូវបញ្ចូលសកម្មភាព និងគោលបំណងនៃផែនការសកម្មភាពនេះទៅក្នុងផែនការការងាររបស់ខ្លួន។ ការកសាងសមត្ថភាព និងការគាំទ្របច្ចេកទេស ក្នុងចំណោមតួអង្គនានាជាកត្តាសំខាន់ក្នុងការពង្រឹងភាពម្ចាស់ការ និងឆន្ទៈនយោបាយ។ |

| | |
|---|---|
| **២.ការធ្វើមូលដ្ឋានីយកម្មផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ** | ផែនការសកម្មភាពថ្នាក់មូលដ្ឋាន (LAP) ដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងសមត្ថភាពរបស់តួអង្គនៅមូលដ្ឋាន ដើម្បីគាំទ្រដល់ការអនុវត្ត និងការពិនិត្យតាមដានផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ វាជាការសំខាន់ក្នុងការពង្រឹងសមត្ថភាពក្នុងការតាមដានវឌ្ឍនភាព និងធានាថា ផែនការសកម្មភាពថ្នាក់មូលដ្ឋានត្រូវបានបញ្ចូលទៅក្នុងផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| **៣.ដំណើរការរៀបចំផែនការបែបបរិយាបន្នដែលនាំទៅរកការរចនាដែលផ្តោតលើលទ្ធផល** | ដំណើរការរៀបចំផែនការគួរមានបរិយាបន្ន និងការចូលរួម។ ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គួរស្ថាបនាពីលើគោលនយោបាយជាតិដែលមានស្រាប់ និងក្របខណ្ឌបែបនិយាម ដែលផ្សារភ្ជាប់នឹងសមភាពយេនឌ័រ សន្តិភាព និងរបៀបវារៈអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ ការពិគ្រោះយោបល់គួរចូលរួមដោយអ្នកពាក់ព័ន្ធផ្សេងៗ រួមមានអង្គការសង្គមស៊ីវិល បណ្តាញស្ត្រី ដៃគូអន្តរជាតិ ស្ថាប័នសិក្សាស្រាវជ្រាវ និងវិស័យឯកជនជាដើម។ |
| **៤.ការពិចារណាពីអាទិភាព និងបរិបទស្ត្រី សន្តិភាព និងសន្តិសុខក្នុងមូលដ្ឋាន** | ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវតែបន្សីគ្នានឹងបរិបទជាតិធំទូលាយ និងផ្សារភ្ជាប់ជាមួយផែនការ និងដំណើរការថ្នាក់ជាតិផ្សេងទៀត និងគួរបញ្ចូលបទដ្ឋានអន្តរជាតិ ក៏ដូចជាឆ្លុះបញ្ចាំងពីលក្ខណៈពិសេសៗនៃបរិបទជាតិ និងមូលដ្ឋាន។ |
| **៥.ការបង្កើតប្រព័ន្ធសម្របសម្រួលសម្រាប់ការអនុវត្ត** | ការសម្របសម្រួល និងការដឹកនាំដ៏រឹងមាំ ជាកត្តាសំខាន់សម្រាប់ការរៀបចំ និងអនុវត្តផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខប្រកបដោយប្រសិទ្ធភាព។ ការសម្របសម្រួលឆ្លងរដ្ឋាភិបាល ជួយបង្កើតការគាំទ្រផ្នែកនយោបាយ និងកសាងការយល់ដឹងក្នុងក្រសួងនានា។ ការកំណត់ច្បាស់នូវការទទួលខុសត្រូវ ភារកិច្ចសម្រាប់តួអង្គពាក់ព័ន្ធនីមួយៗ និងការប្តេជ្ញាផ្នែកនយោបាយនៅកម្រិតខ្ពស់ នៅក្នុងរដ្ឋាភិបាល មានសារៈសំខាន់ណាស់។ |
| **៦.យន្តការគណនេយ្យភាព និងតម្លាភាពសាធារណៈ** | ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវរួមបញ្ចូលប្រព័ន្ធគណនេយ្យភាពដោយផ្អែកលើគោលដៅជាក់លាក់ និងអាចវាស់វែងបាន ការរាយការណ៍ជាសាធារណៈជាប្រចាំ ការវាយតម្លៃ ការត្រួតពិនិត្យដោយសភា និងការចូលរួមពីអង្គការសង្គមស៊ីវិល។ |

| | |
|---|---|
| **៧.ការកំណត់តួនាទីច្បាស់លាស់ និងបែបបរិយាបន្ន សម្រាប់សង្គមស៊ីវិល អង្គការ/ស្ថាប័នសង្គមនយោបាយ និងស្ថាប័នសិក្សាស្រាវជ្រាវ** | ការរៀបចំផែនការសកម្មភាពជាតិ គឺជាឱកាសមួយក្នុងការបង្កើតកិច្ចសន្ទនាជាប់លាប់រវាងរដ្ឋាភិបាល និងសង្គមស៊ីវិលដើម្បីពន្លឿនការអនុវត្តរបៀបវារៈស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខ។ វាជាការសំខាន់ក្នុងការរៀបចំយុទ្ធសាស្ត្រសម្រាប់ជំរុញការចូលរួមរបស់សង្គមស៊ីវិល ដែលមានបរិយាបន្នភាពបត់បែន និងផ្អែកតាមបរិបទ។ |
| **៨.ការកំណត់ និងបែងចែកធនធានសម្រាប់ការអនុវត្ត** | ផែនការសកម្មភាពជាតិនីមួយៗ គួររួមបញ្ចូលក្របខណ្ឌហិរញ្ញប្បទានច្បាស់លាស់មួយ។ ការប៉ាន់ស្មានចំណាយនៃផែនការសកម្មភាពដែលមានភាពជាក់ស្តែង គឺជាជំហានសំខាន់មួយក្នុងការរៀបចំថវិកា។ ការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ (GRB) មានសារៈសំខាន់សម្រាប់ការពន្លឿនរបៀបវារៈស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខ និងការទប់ស្កាត់មិនឱ្យមានភាពលំអៀងក្នុងការបែងចែកធនធាន។ |
| **៩.ការពិនិត្យតាមដាន និងវាយតម្លៃដោយមានធនធានសមស្រប និងប្រព័ន្ធរាយការណ៍ ដែលបន្សុីគ្នានឹងបរិបទជាតិ** | ប្រព័ន្ធពិនិត្យតាមដាន និងប្រព័ន្ធរាយការណ៍ ដែលបន្ស៊ីគ្នានឹងក្របខណ្ឌជាតិ និងធានាការផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់ដំណើរការពិនិត្យតាមដាន និងវាយតម្លៃមានសារៈសំខាន់។ ការរាយការណ៍តាមរយៈអនុសញ្ញា CEDAW ជួយពង្រឹងភាពពាក់ព័ន្ធគ្នារវាងរបៀបវារៈស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខ និងសមភាពយេនឌ័រ។ |
| **១០.ការឆ្លើយតបនឹងបញ្ហាប្រឈមដែលកំពុងលេចឡើង** | មេរៀនពីវិបត្តិកូវីដ-១៩ គូសបញ្ជាក់ពីភាពចាំបាច់ក្នុងការដាក់បញ្ចូល និងកែសម្រួលផែនការសកម្មភាពជាតិស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខឱ្យបន្ស៊ីគ្នានឹងការប្រែប្រួលបរិបទ រួមទាំងការគំរាមកំហែងដែលពាក់ព័ន្ធនឹងជំងឺរាតត្បាត និងការគំរាមកំហែងថ្មីៗផ្សេងទៀត។ |

ប្រភព ៖ *Towards Full Implementation of WPS Agenda in Vietnam, UN Women, December 2022*

## ៦.២. គំរូផែនការសកម្មភាពជាតិ

### ៦.២.១ ផែនការដាច់ដោយឡែក ឬផែនការរួមបញ្ចូលគ្នា

អាស្រ័យលើបរិបទជាតិ ប្រទេសនីមួយៗត្រូវកំណត់វិធីសាស្ត្រសមស្របបំផុត ដើម្បីអនុវត្តរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ប្រទេសខ្លះបានដាក់បញ្ចូលបញ្ហា/អាទិភាពនៃរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងច្បាប់ គោលនយោបាយ ផែនការជាតិដែលមានស្រាប់ និងយុទ្ធសាស្ត្រសន្តិសុខជាតិ ឬយុទ្ធសាស្ត្រការពារជាតិដែលពាក់ព័ន្ធ។ ប្រទេសផ្សេងទៀតបានបង្កើតផែនការសកម្មភាពជាតិដាច់ដោយឡែក តាមរយៈដំណើរការពិគ្រោះយោបល់។ វិធីសាស្ត្រទាំងពីរនេះមានទាំងគុណសម្បត្តិ និងគុណវិបត្តិ។

ការដាក់បញ្ចូលស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងផែនការដែលមានស្រាប់ អាចត្រូវការធនធានតិចជាង និងជួយបញ្ជ្រាបរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងក្របខណ្ឌជាតិ។ ទោះជាយ៉ាងណា មានហានិភ័យដែលបញ្ហាស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានចាត់ទុកជា "ការបន្ថែម" និងមិនបានទទួលការយកចិត្តទុកដាក់ ឬធនធានចាំបាច់សម្រាប់ការអនុវត្តពេញលេញឡើយ។

ផែនការដាច់ដោយឡែក ផ្តល់អត្ថប្រយោជន៍ដល់ការបង្កើនការយល់ដឹងថ្នាក់ជាតិ និងការប្តេជ្ញាចិត្តលើបញ្ហានៃរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ដោយផ្តោតសំខាន់លើការអនុវត្តនៅក្នុងគោលដៅជាតិ និងជារឿយៗជំរុញឱ្យមានភាពងាយស្រួលក្នុងការតាមដានវឌ្ឍនភាព។ ទោះជាយ៉ាងណា ផែនការទាំងនេះអាចត្រូវការធនធាន និងកិច្ចខិតខំប្រឹងប្រែងកាន់តែច្រើននៅពេលចាប់ផ្តើម អាចមានហានិភ័យនៃការធ្វើការងារត្រួតគ្នា និងប្រឈមនឹងបញ្ហាក្នុងការអនុវត្ត ប្រសិនបើមិនមានធនធានសមស្រប។[248]

បទពិសោធន៍កន្លងមករបស់កម្ពុជាក្នុងការដាក់បញ្ចូលធាតុផ្សំនៃរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (ឆ្នាំ ២០១៤-២០១៨) បានធ្វើឱ្យមានការកំណត់សកម្មភាពគោលដៅតែមួយចំនួនតូច ដែលភាគច្រើនជាការកសាងសមត្ថភាពស្ដីពីការទប់ស្កាត់ និងការឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រសម្រាប់វិស័យនគរបាល និងសន្តិសុខ។ បទពិសោធន៍នេះ បូករួមនឹងលក្ខណៈឆ្លងវិស័យនៃបញ្ហាស្ត្រី សន្តិភាព និងសន្តិសុខនៅក្នុងវិស័យ និងស្ថាប័ននានា គាំទ្រដល់ការរៀបចំ NAP-WPS ដាច់ដោយឡែក ដើម្បីធានាការរួមបញ្ចូលចំណុចអាទិភាពនៃរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ឱ្យកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាពជាងមុន ស្របតាមផែនការសកម្មភាពថ្នាក់តំបន់អាស៊ានស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ។

### ៦.២.២ អភិក្រមផ្តោតលើផ្ទៃក្នុង សម្លឹងឆ្ពោះទៅខាងក្រៅ ឬចម្រុះ

ការប្រែក្លាយរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខទៅជាគោលនយោបាយជាតិ អាស្រ័យលើបរិបទរបស់ប្រទេសនីមួយៗ។ ជាទូទៅ ផែនការសកម្មភាពជាតិ មានបីប្រភេទ ៖

១.ផែនការសម្លឹងឆ្ពោះទៅក្រៅ ដែលផ្តោតជាចម្បងលើគោលនយោបាយការបរទេស
២.ផែនការផ្តោតលើផ្ទៃក្នុង ដែលផ្តោតលើអាទិភាពជាតិ និង
៣.ផែនការអភិក្រមចម្រុះ ដែលរួមបញ្ចូលការផ្តោតសម្លឹងឆ្ពោះទៅក្រៅ តាមរយៈការផ្តោតលើគោលនយោបាយ ការបរទេស និងការផ្តោតលើផ្ទៃក្នុង តាមរយៈការផ្តោតលើបញ្ហាក្នុងស្រុក។

[248] ឧបករណ៍និងគោលការណ៍ណែនាំសម្រាប់ការធ្វើមូលដ្ឋានីយកម្មផែនការសកម្មភាពតំបន់អាស៊ានស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ទីក្រុងចាការតា លេខាធិការដ្ឋានអាស៊ាន ខែធ្នូ ឆ្នាំ២០២៣

ជារឿយៗ ប្រទេសផ្តល់ជំនួយបង្កើតផែនការសកម្មភាពជាតិដែលផ្តោតលើការសម្លឹងឆ្ពោះទៅខាងក្រៅ ដែលជំរុញដោយគោលនយោបាយការបរទេស និងដឹកនាំដោយក្រសួងការបរទេស។ ជាទូទៅ ផែនការដែលផ្តោតលើផ្ទៃក្នុង គ្រប់គ្រងដោយក្រសួងកិច្ចការនារី ឬកិច្ចការយេនឌ័រ ឬមហាផ្ទៃ។[249] មានការទទួលស្គាល់កាន់តែច្រើនលើភាពពាក់ព័ន្ធគ្នាទៅវិញទៅមករវាងអាទិភាពក្រៅប្រទេស និងអាទិភាពក្នុងប្រទេសស្តីពីសន្តិភាព និងសន្តិសុខ។ ឧ. NAP-WPS ទី ១ របស់កាណាដា (២០១១) ផ្តោតចម្បងលើការសម្លឹងឆ្ពោះទៅខាងក្រៅ ខណៈដែល NAP-WPS ទី ៣ (២០២៣-២០២៩) ផ្តោតកាន់តែខ្លាំងលើការអនុវត្តគោលការណ៍ WPS ទាំងក្នុង និងក្រៅប្រទេស[250]។

*តារាងទី ៧ ៖ ប្រភេទផ្សេងៗនៃផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ*

| **ផែនការផ្តោតលើផ្ទៃក្នុង** | **ផែនការសម្លឹងឆ្ពោះទៅខាងក្រៅ** | **ផែនការអភិក្រមចម្រុះ** |
|---|---|---|
| អ៊ូហ្គង់ដា | កាណាដា | ឥណ្ឌូណេស៊ី ហ្វីលីពីន ទីម័រខាងកើត |
| ស៊ូដង់ | ន័រវែស | ថៃឡង់ (វិធានការ និងគោលការណ៍ណែនាំជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ) |

*ប្រភព ៖ កញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំស្តីពីការធ្វើមូលដ្ឋានីយកម្មសម្រាប់ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ*

### ៦.២.៣ គំរូសម្របសម្រួល

ការបង្កើតយន្តការសម្របសម្រួលផ្ទៃក្នុងដែលមានប្រសិទ្ធភាព និងការជ្រើសរើសទីភ្នាក់ងាររដ្ឋាភិបាលដឹកនាំ ដើម្បីណែនាំដល់ការរៀបចំផែនការ ជាកត្តាសំខាន់សម្រាប់ធានាការគាំទ្រស្ថាប័នយ៉ាងទូលំទូលាយ។ កិច្ចសហការអន្តរវិស័យ គឺជាគន្លឹះនៃការសម្របសម្រួល និងការអនុវត្តដោយជោគជ័យ។ ឧទាហរណ៍នៃទីភ្នាក់ងារដឹកនាំដែលមានប្រសិទ្ធភាពនៅតំបន់អាស៊ានរួមមានក្រសួងបង្កើនភាពអង់អាចដល់ស្ត្រី និងការពារកុមារ (ឥណ្ឌូណេស៊ី) ការិយាល័យទីប្រឹក្សាប្រធានាធិបតីស្តីពីដំណើរការសន្តិភាព (ហ្វីលីពីន) និងក្រសួងសន្តិសុខផ្ទៃក្នុង (ទីម័រខាងកើត)។[251]

គំរូផ្សេងៗសម្រាប់ការសម្របសម្រួល រួមមានការចូលរួមពីស្ថាប័នមួយ ឬច្រើន។ ផែនការជាតិ ប្រហែលពីរភាគបី ត្រូវបានបង្កើតឡើងដោយការប្រចាប់បញ្ចូលក្រសួងពាក់ព័ន្ធ។ ការសម្របសម្រួលអាចត្រូវបានរៀបចំនៅពីរកម្រិត៖

- កម្រិតយុទ្ធសាស្ត្រ ៖ ស្ថាប័នកម្រិតខ្ពស់មួយ ដែលរួមមានអនុរដ្ឋមន្ត្រី/ឧបការីក្រសួង ឬប្រធាននាយកដ្ឋាន។ ក្រុមនេះកំណត់គោលបំណងយុទ្ធសាស្ត្រ ផ្តល់ការគាំទ្រផ្នែកនយោបាយ លើកកម្ពស់ការចូលរួមទូទាំងរដ្ឋាភិបាល និងដើរតួនាទីជាយន្តការគណនេយ្យភាពចម្បង
- កម្រិតប្រតិបត្តិការ ៖ រួមមានបុគ្គលិកបច្ចេកទេសដែលត្រូវបានចាត់តាំងជាមន្ត្រីបង្គោលរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ/មន្ត្រីបង្គោលយេនឌ័រ នៅក្នុងក្រសួង ឬនាយកដ្ឋានពាក់ព័ន្ធ។ ក្រុមនេះគ្រប់គ្រងការអនុវត្តកម្មវិធី ក្រោមការសម្របសម្រួលជាមួយតួអង្គពាក់ព័ន្ធផ្សេងទៀត។ [252]

[249] ឆ្ពោះទៅរកការអនុវត្តរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខពេញលេញនៅវៀតណាម របាយការណ៍ដើម្បីរួមចំណែកដល់ការអភិវឌ្ឍផែនការសកម្មភាពជាតិលើកដំបូងរបស់វៀតណាមស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ Mirsad Miki Jacevic អង្គការ UN Women ការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ខែធ្នូ ឆ្នាំ២០២២
[250] https://wpsfocalpointsnetwork.org/wp-content/uploads/2022/07/WPS-FPN-TLS_Internal-External-NAPs_July-2022.pdf
[251] ឧបករណ៍និងគោលការណ៍ណែនាំសម្រាប់ការធ្វើមូលដ្ឋានីយកម្មផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ទីក្រុងចាការតា លេខាធិការដ្ឋានអាស៊ាន ខែធ្នូ ឆ្នាំ២០២៣
[252] ដូចខាងលើ

គំរូមួយចំនួននៃការសម្របសម្រួល រួមមាន៖

- ការសម្របសម្រួលតាមខ្សែបណ្ដោយ (Vertical coordination) ៖ ទីភ្នាក់ងារតែមួយគ្រប់គ្រងទាំងការសម្របសម្រួល និងការអនុវត្ត (ឧ. នីហ្សេរីយ៉ា)។
- ការសម្របសម្រួលតាមខ្សែទទឹង (Horizontal coordination)៖ ក្រុមតូចមួយនៃក្រសួងពាក់ព័ន្ធ សំខាន់ៗ បែងចែកការទទួលខុសត្រូវលើការអនុវត្ត (ឧ. បូស្នៀ និងហឺហ្សេហ្គូវីណា)។
- ការសម្របសម្រួលបែបត្រួតពិនិត្យ៖ អង្គភាពប្រតិបត្តិមួយ ដូចជា ក្រុមប្រឹក្សាសន្តិសុខជាតិ ត្រួតពិនិត្យការអនុវត្ត (សហរដ្ឋអាមេរិក)។
- ការចូលរួមរបស់អង្គការសង្គមស៊ីវិល ៖ អង្គការសង្គមស៊ីវិលចូលរួមដោយផ្ទាល់នៅក្នុងគណៈកម្មាធិការដឹកនាំ ឬក្រុមការងារ (ឧ. បង់ក្លាដេស ឥណ្ឌូនេស៊ី នេប៉ាល់)។

### ៦.២.៤ ភាពអាចអនុវត្តបាននៅកម្ពុជា

ភស្តុតាងបង្ហាញ ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ជាឧបករណ៍ដែលមានប្រសិទ្ធភាពសម្រាប់ការកាត់បន្ថយគម្លាតយេនឌ័រ បង្កើនសន្តិសុខជាតិ និងលើកកម្ពស់សន្តិភាពរយៈពេលវែង។[253] របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ខិតខំការពារសិទ្ធិស្ត្រី និងធានាថា សិទ្ធិស្ត្រីត្រូវបានអនុវត្តយ៉ាងពេញលេញ។ ការសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធ ដែលចូលរួមក្នុងផែនការសកម្មភាពថ្នាក់តំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងមានចំណេះដឹងអំពីដំណើរការផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៃកម្ពុជា បានកំណត់ឱកាសសំខាន់ៗសម្រាប់កម្ពុជា ដូចខាងក្រោម ៖

- ការពង្រឹងភាពស៊ីសង្វាក់គ្នានៃគោលនយោបាយនៅក្នុងក្រសួង និងស្ថាប័ននានា ដើម្បីពន្លឿនសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ទន្ទឹមនឹងការបង្កើនការអនុវត្ត គណនេយ្យភាព និងតម្លាភាព

- លើកកម្ពស់តួនាទីប្រកបដោយអត្ថន័យរបស់ស្ត្រីដល់ការទប់ស្កាត់ជម្លោះ ដោះស្រាយ និងស្តារឡើងវិញ។ ផ្អែកតាមប្រវត្តិសាស្ត្រក្រោយជម្លោះ និងកិច្ចខិតខំប្រឹងប្រែងផ្សះផ្សារបស់កម្ពុជា របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គឺជាឱកាសក្នុងការបង្កើនការចូលរួមរបស់ស្ត្រីក្នុងបេសកកម្មរក្សាសន្តិភាព និងការដឹកនាំក្នុងវិស័យនានា ដូចជា ការទូត សន្តិសុខ ការពារជាតិ និងអភិបាលកិច្ចនៅគ្រប់កម្រិត។

- ការដាក់បញ្ចូលចក្ខុវិស័យស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីដោះស្រាយបញ្ហាប្រឈមថ្មីៗក្នុងវិស័យសន្តិភាព និងសន្តិសុខ។ របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ មិនកំណត់ត្រឹមបរិបទដែលរងផលប៉ះពាល់ដោយជម្លោះនោះទេ។ ភាគីពាក់ព័ន្ធក្នុងប្រទេសកម្ពុជាបានទទួលស្គាល់ការគំរាមកំហែងថ្មីៗ ដូចជា បទល្មើសឆ្លងដែន និងបទល្មើសបច្ចេកវិទ្យា ដែលផ្តោតគោលដៅលើស្ត្រី តាមរយៈការបោកប្រាស់ និងការបៀតបៀនតាមអនឡាញ អំពើហិង្សាទាក់ទងនឹងយេនឌ័រតាមរយៈបច្ចេកវិទ្យា និងការផ្សព្វផ្សាយព័ត៌មានខុស ព័ត៌មានមិនពិត ពាក្យសម្តីមាក់ងាយលើស្ត្រី ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិពលសង្គម សន្តិភាព និងសន្តិសុខ។ ហានិភ័យទាំងនេះបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ស្ត្រី ជាពិសេសស្ត្រីមកពីក្រុមជួបការលំបាក។

ផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ មន្ត្រីស្ថានទូតជាច្រើនដែលបានសម្ភាសន៍ បានកំណត់សមាសភាគនៃ NAP-WPS ដែលមានប្រសិទ្ធភាព ដូចតទៅ ៖ ១) ចក្ខុវិស័យ និងការប្តេជ្ញាចិត្តរួមចំពោះសមភាពយេនឌ័រ និងសិទ្ធិស្ត្រី សម្រាប់ជាគន្លឹះនៃវិបុលភាព និងសន្តិសុខ ២) យន្តការសម្របសម្រួលផ្ទៃក្នុងដ៏រឹងមាំ ជាមួយនឹងកម្រិតការងារចម្រុះ ៣) ការទទួលស្គាល់ទំនាក់ទំនងរវាងបញ្ហាក្នុងស្រុក និងអន្តរជាតិ ៤) ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិលនៅក្នុងយន្តការសម្របសម្រួល តាមរយៈបណ្តាញផ្លូវការដើម្បីអាចឱ្យទស្សនវិស័យ និងចម្រុះស្តែងឡើង និង ៥) ការបង្កើតក្របខណ្ឌត្រួតពិនិត្យតាមដាន និងវាយតម្លៃដ៏រឹងមាំ ដើម្បីវាស់វែងវឌ្ឍនភាព WPS ដោយមិនមានតម្រូវការរាយការណ៍ដាក់បន្ទុកហួសហេតុពេក។[254]

[253] ឆ្ពោះទៅរកការអនុវត្តរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខពេញលេញនៅវៀតណាម របាយការណ៍ដើម្បីរួមចំណែកដល់ការអភិវឌ្ឍផែនការសកម្មភាពជាតិលើកដំបូងរបស់វៀតណាមស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ Mirsad Miki Jacevic អង្គការ UN Women ការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ខែធ្នូ ឆ្នាំ២០២២
[254] ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗជាមួយមន្ត្រីស្ថានទូត រាជធានីភ្នំពេញ ខែសីហា ឆ្នាំ២០២៤

# ផ្នែកទី ៤

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍



Photo: UN Women/Lim Sophorn

# ៧. សេចក្តីសន្និដ្ឋាន



Photo: UN Women/Lim Sophorn

ក្នុងនាមជាប្រទេសដែលមានបទពិសោធន៍រាប់ទសវត្សរ៍មកហើយ កម្ពុជាបានប្តេជ្ញាក្នុងការសម្រេចឱ្យបាននូវការកសាងសន្តិភាព ការស្តារឡើងវិញ និងការផ្សះផ្សានៅថ្នាក់ជាតិប្រកបដោយជោគជ័យ រួមជាមួយនឹងការរួមចំណែកដែលទទួលស្គាល់លើឆាកអន្តរជាតិ ដល់ប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងការប្តេជ្ញាចិត្តចំពោះសន្តិភាព និងស្ថិរភាពក្នុងតំបន់ កម្ពុជាមានគោលជំហរសមស្របក្នុងការអនុវត្តអភិក្រមបែបចម្រុះសម្រាប់ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខរបស់ខ្លួន។ របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ពាក់ព័ន្ធទាំងអាទិភាពជាតិរបស់កម្ពុជាស្តីពីសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងមហិច្ឆិតារបស់ខ្លួនក្នុងការលើកកម្ពស់សន្តិភាព និងស្ថិរភាពនៅគ្រប់កម្រិត ៖ កម្រិតសហគមន៍/ថ្នាក់ក្រោមជាតិ កម្រិតជាតិ កម្រិតតំបន់ និងកម្រិតសកល។

ដោយទទួលស្គាល់ថា កម្ពុជាមានយន្តការសម្របសម្រួលដែលមានប្រសិទ្ធភាពជាច្រើន និងផែនការសកម្មភាពជាតិ ដែលលើកឡើងពីសមភាពយេនឌ័រ និងសិទ្ធិស្ត្រី រួមមានគណៈកម្មាធិការជាតិ ក្រុមប្រឹក្សាជាតិ ក្រុមការងារបច្ចេកទេស និងក្រុមការងារតាមវិស័យ គួរស្ថាបនាពីលើប្រព័ន្ធទាំងនេះសម្រាប់ការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ កម្ពុជាអាចរៀបចំ NAP-WPS ដើម្បីពង្រឹងក្របខណ្ឌដែលមានស្រាប់ និង ដោះស្រាយគម្លាត និងតម្រូវការថ្មីៗនៅក្នុងទិដ្ឋភាពគោលនយោបាយបច្ចុប្បន្នស្តីពីយេនឌ័រ និងសន្តិសុខ។ ឧ. NAP-WPS អាចដើរតួនាទីជាក្របខណ្ឌគោលនយោបាយ ដែលអនុវត្តចំពោះគំនិតផ្តួចផ្តើមថ្មីៗ នៅពេលវាលេចឡើងក្នុងដំណាក់កាលរៀបចំ ដូចជា គោលនយោបាយ ឬគណៈកម្មការ និងជួយធានាការសម្របសម្រួលរវាងក្របខណ្ឌផ្សេងៗ និងស្ថាប័នអនុវត្តក្របខណ្ឌទាំងនេះ រួមទាំងក្របខណ្ឌដែលផ្តោតលើការប្រែប្រួលអាកាសធាតុ ឬសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត។ នេះនឹងគាំទ្រដល់ភាពបន្សីគ្នា ការចែករំលែកការអនុវត្តល្អ និងការកំណត់រកតម្រូវការថ្មីៗ។ ទិដ្ឋភាពសំខាន់មួយក្នុងការរៀបចំ NAP-WPS នៅកម្ពុជា គឺតម្លៃបន្ថែមរបស់វាពាក់ព័ន្ធនឹងក្របខណ្ឌបញ្ជ្រាបយេនឌ័រដែលមានស្រាប់ និងផែនការសកម្មភាពជាតិដែលពាក់ព័ន្ធផ្សេងទៀតស្តីពីសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី។

ការរៀបចំ និងការអនុវត្តផែនការសកម្មភាពជាតិផ្សេងទៀតនៅកម្ពុជា បានជួយពង្រឹងកិច្ចសហការរវាងភាគីពាក់ព័ន្ធ និងជំរុញវឌ្ឍនភាពលើបញ្ហាសំខាន់ៗ ដូចជា អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ការជួញដូរមនុស្ស ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ លក្ខណៈរួមនៃផែនការសកម្មភាពដែលទទួលបានជោគជ័យនៅកម្ពុជា និងប្រទេសផ្សេងទៀត រួមមានការប្តេជ្ញាចិត្តផ្នែកនយោបាយនៅកម្រិតខ្ពស់ ការដឹកនាំ និងគណនេយ្យភាពរបស់រដ្ឋាភិបាលជាន់ខ្ពស់ ការចូលរួមពីពហុភាគីពាក់ព័ន្ធ (រួមទាំងការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល) និងតម្លាភាពសាធារណៈ។ ផ្នែកដែលបានកត់សម្គាល់សម្រាប់ការកែលម្អនៅក្នុងផែនការដែលមានស្រាប់ រួមមានការ

ពង្រឹងការសម្របសម្រួល និងការអនុវត្តសកម្មភាព ក៏ដូចជាការបង្កើតក្របខណ្ឌត្រួតពិនិត្យតាមដាន វាយតម្លៃ និងរាយការណ៍ ដែលអាចសម្រេចបានជាក់ស្តែង ដែលអាចបង្ហាញពីវិសាលភាពពេញលេញនៃវឌ្ឍនភាព និងកំណត់រកទាំងគម្លាត និងបញ្ហាប្រឈមក្នុងការអនុវត្ត។ ថវិកា និងធនធានមនុស្សមានកម្រិត ក៏ត្រូវបានគូសបញ្ជាក់ថាជាឧបសគ្គសំខាន់ៗសម្រាប់ការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពផងដែរ។

ការពិភាក្សាជាមួយមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ បានបង្ហាញពីកង្វល់ទូទៅដែលប៉ះពាល់ដល់សន្តិសុខរបស់ស្ត្រី រួមទាំងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងការរេចរិលបរិស្ថានលើសន្តិសុខសេដ្ឋកិច្ចគ្រួសារ អំពើហិង្សាលើស្ត្រី និងក្មេងស្រី (រួមទាំងស្ត្រីជួបការលំបាក) ភាពជាតំណាងមានកម្រិតរបស់ស្ត្រីក្នុងតួនាទីដឹកនាំ និងតួនាទីធ្វើសេចក្តីសម្រេចចិត្ត ឱកាសតិចតួចសម្រាប់ឱ្យស្ត្រីចូលរួម ឥរិយាបថអវិជ្ជមានចំពោះសារៈសំខាន់នៃសមភាពយេនឌ័រក្នុងកន្លែងការងារ និងការកើនឡើងនៃការគំរាមកំហែងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត (រួមទាំងរូបភាពអាសអាភាសតាមប្រព័ន្ធអនឡាញ ការកេងប្រវ័ញ្ច ការជួញដូរមនុស្ស និងការបោកប្រាស់ហិរញ្ញវត្ថុដែលផ្តោតគោលដៅមកលើស្ត្រី និងក្មេងស្រី)។ ការគំរាមកំហែងទាំងនេះរងផលអន្តរាយពីបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ ផ្នត់គំនិត និងឥរិយាបថរើសអើង ដែលបន្តរឹតត្បិតឱកាសរបស់ស្ត្រី និងក្មេងស្រី។ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត បានសម្តែងការព្រួយបារម្ភស្រដៀងគ្នា ដោយគូសបញ្ជាក់ទាំងការរើសអើង និងការផាត់ចេញដែលជាបញ្ហាប្រឈមរបស់ក្រុមស្ត្រីជួបការលំបាក នៅក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្ត និងសារៈសំខាន់នៃការបន្តដោះស្រាយអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងលើយេនឌ័រ ព្រមទាំងការប៉ះទង្គិចផ្លូវចិត្តអន្តរជំនាន់ដែលចាក់ឫសក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា។

នៅថ្នាក់ក្រោមជាតិ ភាគីពាក់ព័ន្ធបានលើកឡើងពីការព្រួយបារម្ភស្រដៀងគ្នា រួមមានផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើសន្តិសុខសេដ្ឋកិច្ចគ្រួសារ និងធនធានធម្មជាតិ ដែលអាចបង្កឱ្យមានភាពតានតឹងក្នុងមូលដ្ឋានពាក់ព័ន្ធនឹងដីធ្លី និងទឹក ការកើនឡើងនៃបន្ទុកបំណុល កង្វះឱកាសសេដ្ឋកិច្ចនៅជនបទ។ សម្ពាធទាំងនេះបានរួមចំណែកដល់អត្រាបោះបង់ការសិក្សា ការធ្វើទេសន្តរប្រវេសន៍ និងការកេងប្រវ័ញ្ចពលកម្ម ដែលសុទ្ធតែប៉ះពាល់ដល់សន្តិសុខសេដ្ឋកិច្ចរបស់ស្ត្រី និងគ្រួសារ។ ការព្រួយបារម្ភបន្ថែមទៀត រួមមានអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ ការកើនឡើងនៃការគំរាមកំហែងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត រួមទាំងការបៀតបៀន និងការរំលោភបំពានតាមអនឡាញ និងការឆបោកហិរញ្ញវត្ថុ និងការកើនឡើងនៃការប្រើប្រាស់គ្រឿងញៀន និងសកម្មភាពក្រុមក្មេងទំនើងក្នុងចំណោមយុវជន ដែលធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាព និងសន្តិសុខសហគមន៍។

តំណាងរបស់ស្ត្រីនៅមានកម្រិតក្នុងតំណែងដឹកនាំ និងធ្វើសេចក្តីសម្រេចចិត្ត ក៏ត្រូវបានកត់សម្គាល់ផងដែរ។ កង្វល់ជាក់លាក់សម្រាប់ស្ត្រីជនជាតិដើមភាគតិច (និងយុវជន) រួមមានការរើសអើង កង្វះភាពជាតំណាងនៅក្នុងជួររដ្ឋាភិបាល និងការបាត់បង់ដីធ្លី និងរបៀបរស់នៅតាមប្រពៃណី រួមទាំងការធ្វើកសិកម្ម។ សម្រាប់ស្ត្រីខ្មែរអ៊ីស្លាម កម្រិតទាបនៃការចូលរួម និងភាពជាតំណាងក្នុងសកម្មភាពសហគមន៍ បានរឹតត្បិតការទទួលបានព័ត៌មាន និងសេវា និងរួមចំណែកធ្វើឱ្យមានអារម្មណ៍ដាច់ឆ្ងាយពីសង្គមទាំងមូល។

ផ្អែកតាមបញ្ហាសន្តិភាព និងសន្តិសុខផ្សេងៗ ដែលបានស្វែងយល់ចេញពីទស្សនៈវិស័យ WPS ក្នុងបរិបទកម្ពុជា និងស្របតាមរបៀបវារៈ WPS និងផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ASEAN RPA-WPS) និងអាទិភាពរបស់រដ្ឋាភិបាល ចំណុចខាងក្រោមបានលេចឡើងជាផ្នែកមូលបទរឹងមាំសម្រាប់ដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពជាតិដំបូងបង្អស់របស់កម្ពុជាស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ៖

**១. ស្ត្រី ការជួញដូរ និងបទល្មើសឆ្លងដែន**
**២. ស្ត្រី សន្តិភាព និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត**
**៣. ស្ត្រីក្នុងវិស័យសន្តិសុខ ការទូតអន្តរជាតិ និងកងកម្លាំងរក្សាសន្តិភាព និង**
**៤. ស្ត្រី និងអាកាសធាតុ សន្តិភាព និងសន្តិសុខ។**

**សម្រាប់ប្រធានបទ "ស្ត្រី ការជួញដូរ និងបទល្មើសឆ្លងដែន"** គោលនយោបាយការពារជាតិឆ្នាំ ២០២២ កំណត់ការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន និងសកម្មភាពឆ្លងដែនខុសច្បាប់ផ្សេងទៀត ជាបញ្ហាកង្វល់ថ្នាក់ជាតិ ព្រោះវាធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាព និងសន្តិសុខសាធារណៈ បង្កភាពតានតឹងក្នុងសង្គមដែលអាចកើតមានឡើងនៅក្នុង និងឆ្លងកាត់ព្រំដែន និងបង្កើនហានិភ័យសម្រាប់សហគមន៍ងាយរងគ្រោះ។ ជំងឺរាតត្បាតកូវីដ-១៩ បានផ្លាស់ប្តូរទិដ្ឋភាពហានិភ័យសម្រាប់ការជួញដូរមនុស្ស ដោយការកេងប្រវ័ញ្ច និងការរំលោភបំពានតាមអ៊ីនធឺណិត កំពុងលេចឡើងជាបញ្ហាចម្បង ដែលបង្កផលប៉ះពាល់ខ្លាំងលើស្ត្រី។ ខណៈដែល NSP-CTIP ដោះស្រាយការជួញដូរមនុស្ស និងបទល្មើសឆ្លងដែន មានឱកាសបន្ថែមដើម្បីធានាថា NAP-WPS ដោះស្រាយបញ្ហាសន្តិសុខ និងការចូលរួមរបស់ស្ត្រី។

**សម្រាប់ប្រធានបទ "ស្ត្រី សន្តិភាព និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត"** បទល្មើសតាមអ៊ីនធឺណិតបង្កការគំរាមកំហែងយ៉ាងខ្លាំងដល់កម្ពុជា និងតំបន់។ បទល្មើសតាមអ៊ីនធឺណិតដែលផ្តោតគោលដៅលើស្ត្រី រួមមានការបោកបញ្ឆោតតាមអ៊ីនធឺណិត ការបៀតបៀន និងអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមរយៈបច្ចេកវិទ្យា អាចបង្កើនការផ្សព្វផ្សាយព័ត៌មានខុស ព័ត៌មានមិនពិត និងពាក្យសម្តីមាក់ងាយស្ត្រី ដែលសុទ្ធតែធ្វើឱ្យអន្តរាយដល់សិទ្ធិពលសង្គម និងសន្តិភាពសង្គម។ ស្ត្រីនៅតែមានតំណាងតិចតួចក្នុងតួនាទីដឹកនាំ និងតួនាទីជាអ្នកធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងសន្តិសុខតាមអ៊ីនធឺណិត ការអភិវឌ្ឍបច្ចេកវិទ្យា និងការកសាងសន្តិភាព ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងប្រកបដោយបរិយាបន្នក្នុងគោលនយោបាយ ដូចជា គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ឆ្នាំ ២០២០ ក៏ដោយ។

**សម្រាប់ប្រធានបទ "ស្ត្រីក្នុងវិស័យសន្តិសុខ ការទូតអន្តរជាតិ និងកងកម្លាំងរក្សាសន្តិភាព"** គោលនយោបាយការពារជាតិឆ្នាំ ២០២២ របស់កម្ពុជា រៀបរាប់ពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការការពារសន្តិភាព សន្តិសុខ និងស្ថិរភាពក្នុងតំបន់ រួមទាំងតាមរយៈការរួមចំណែកដល់ប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។ ក្រសួងការពារជាតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម (NPMEC) និងក្រសួងមហាផ្ទៃ សុទ្ធតែទទួលស្គាល់តួនាទីដ៏សំខាន់របស់ស្ត្រីក្នុងវិស័យសន្តិសុខ ជាពិសេសក្នុងការកាត់បន្ថយជម្លោះ ការកសាងទំនុកចិត្តជាមួយសហគមន៍ និងភាពជាអ្នកដឹកនាំ។ ប៉ុន្តែការចូលរួមរបស់ស្ត្រីនៅតែមានកម្រិតទាប ទោះបីជាមានគោលនយោបាយ ផែនការ និងវិធានការអំណោយផល ដែលមានគោលបំណងបង្កើនសមត្ថភាព និងការចូលរួមរបស់ស្ត្រីក៏ដោយ។

**សម្រាប់ប្រធានបទ "ស្ត្រី និងអាកាសធាតុ សន្តិភាព និងសន្តិសុខ"** ភាពងាយរងគ្រោះដោយការប្រែប្រួលអាកាសធាតុរបស់កម្ពុជា បានបង្កកង្វល់សន្តិសុខ រួមមានផលប៉ះពាល់លើការផ្គត់ផ្គង់ស្បៀងអាហារ ទឹក និងថាមពល ការប្រជែងដណ្តើមធនធានធម្មជាតិកាន់តែប្រឈមខ្លាំង ការបាត់បង់របរចិញ្ចឹមជីវិត គ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុ ការធ្វើចំណាកស្រុក និងការផ្លាស់ទីលំនៅដោយបង្ខំ។ ជាញឹកញាប់ ស្ត្រីស្ថិតក្នុងចំណោមក្រុមងាយរងគ្រោះបំផុតដោយផលប៉ះពាល់ទាំងនេះ ប៉ុន្តែស្ត្រីក៏ជាភ្នាក់ងារនៃការផ្លាស់ប្តូរដ៏មានឥទ្ធិពល និងអាចដើរតួនាទីសំខាន់ក្នុងសន្តិសុខអាកាសធាតុផងដែរ។ កម្ពុជាបានបង្កើតផែនការជាច្រើនដែលដោះស្រាយបញ្ហាយេនឌ័រ និងការប្រែប្រួលអាកាសធាតុ រួមទាំងផែនការយុទ្ធសាស្ត្រយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ២០១៣-២០២៣ ផែនការសកម្មភាពស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ២០១៩-២០២៣ និងផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (២០១៩-២០២៣/២០២៤-២០២៨) ក្រោមគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។ ទោះជាយ៉ាងណា នៅតែមានឱកាសក្នុងការដោះស្រាយកាន់តែពេញលេញលើការព្រួយបារម្ភចំពោះសន្តិសុខ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងសកម្មភាពអាកាសធាតុ តាមរយៈផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

ប្រធានបទសំខាន់ៗផ្សេងទៀតដែលបានស្វែងយល់ក្នុងការវិភាគស្ថានភាពនេះ រួមមាន ៖

**១. ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី**
**២. ស្ត្រី និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងជម្លោះ និងវិបត្តិមនុស្សធម៌**
**៣. របៀបវារៈ WPS និងសន្តិសុខសេដ្ឋកិច្ច ឱកាសប្រកបរបរចិញ្ចឹមជីវិត ធនធានធម្មជាតិ និងសន្តិសុខមនុស្ស និង**
**៤. ស្ត្រី និងសិទ្ធិពលសង្គម**

ក្នុងចំណោមនេះ ប្រធានបទមួយចំនួនអាចត្រូវបានលើកឡើង ឬដាក់បញ្ចូលតាមវិធីផ្សេងទៀត ដូចជា បញ្ចូលទៅក្នុងផែនការសកម្មភាពជាតិផ្សេងទៀត ឬបញ្ជ្រាបទៅក្នុងផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

ឧទាហរណ៍ ប្រធានបទ **"ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី"** បានក្លាយជាយុទ្ធសាស្ត្រគន្លឹះរួចទៅហើយ ក្រោមផែនការនារីរតនៈទី ៦ (យុទ្ធសាស្ត្រទី ៥ ៖ ស្ត្រីនៅក្នុងការដឹកនាំ និងអភិបាលកិច្ច) ត្រូវបានរួមបញ្ចូលក្នុង GMAPs តាមវិស័យស្ទើរតែទាំងអស់ ជាសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភទាំងបួននៃរបៀបវារៈ WPS និងត្រូវបានទទួលស្គាល់ថាជាបញ្ហាអន្តរវិស័យមួយនៅក្រោមផ្នែកតាមមូលបទផ្សេងទៀត។

សម្រាប់ប្រធានបទ **"ស្ត្រី និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងវិបត្តិជម្លោះ និងមនុស្សធម៌"** គេអាចគាំទ្រដល់កិច្ចអន្តរាគមន៍ពាក់ព័ន្ធ តាមរយៈផែនការសកម្មភាពជាតិ ដូចជា ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី ផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងក្របខណ្ឌកិច្ចគាំពារសង្គម។ វិបត្តិកូវីដ-១៩ ក៏បាននាំឱ្យមានការបង្កើនកិច្ចខិតខំប្រឹងប្រែងរួមបញ្ចូលអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រាអាសន្ន ទៅក្នុងផែនការសុខភាព និងការគ្រប់គ្រងគ្រោះមហន្តរាយផងដែរ។ កម្មវិធីកសាងសន្តិភាព ដោះស្រាយជម្លោះ និងផ្សះផ្សា ដូចជា កម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាល គួរតែត្រូវបានពិនិត្យឡើងវិញ និងពង្រឹងបន្ថែមទៀត។

សម្រាប់ប្រធានបទ **"របៀបវារៈ WPS និងសន្តិសុខសេដ្ឋកិច្ច ឱកាសប្រកបរបរចិញ្ចឹមជីវិត ធនធានធម្មជាតិ និងសន្តិសុខមនុស្ស"** គោលនយោបាយ និងក្របខណ្ឌជាតិជាច្រើន ដូចជា ផែនការនារីរតនៈទី ៦ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ GMPSFA ២០២២-២០២៦ ផែនការបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពកម្ចាត់មីន ២០២១-២០២៥ ក្របខណ្ឌកិច្ចគាំពារសង្គម និងប្រព័ន្ធដោះស្រាយជម្លោះ ដូចជា យន្តការដោះស្រាយជម្លោះដីធ្លីរបស់ MLMUPC និង អ.ជ.ក សុទ្ធតែផ្តល់ឱកាសដើម្បីដាក់បញ្ចូល និងការពារបន្ថែមទៀតនូវការចូលរួមផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ក្នុងកិច្ចខិតខំសង្គ្រោះ និងស្តារឡើងវិញ។

សម្រាប់ប្រធានបទ **"ស្ត្រី និងសនិទ្ធពលសង្គម"** រដ្ឋាភិបាលបានដាក់ចេញគោលនយោបាយ និងយន្តការនានា ដើម្បីគាំទ្រស្ត្រីក្នុងគ្រប់លក្ខណៈចម្រុះ រួមទាំងស្ត្រីជនជាតិភាគតិច ស្ត្រីជនជាតិដើមភាគតិច ស្ត្រីមានពិការភាព ស្ត្រីស្រឡាញ់ភេទដូចគ្នា (LBTIQ+) និងក្រុមស្ត្រីងាយរងគ្រោះផ្សេងទៀត។ ស្ត្រីទាំងនេះត្រូវបានដាក់បញ្ចូលទៅក្នុងក្របខណ្ឌ ដូចជា ផែនការនារីរតនៈ ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី និងផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក៏ដូចជាតាមរយៈ GMAPs តាមវិស័យ នៅក្នុងក្រសួង និងស្ថាប័នពាក់ព័ន្ធផងដែរ។ ទោះជាយ៉ាងណាប្រហែលជាចាំបាច់ត្រូវមានប្រព័ន្ធតាមដាន និងវាយតម្លៃរឹងមាំជាងនេះ ដើម្បីធានាថា កិច្ចខិតខំប្រឹងប្រែងទាំងនេះ ត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព និងរួមបញ្ចូលក្រុមងាយរងគ្រោះ និងក្រុមជួបការលំបាកទាំងអស់។

ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងកាន់តែច្រើនក្នុងការកសាងការយល់ដឹង និងពង្រឹងការយល់ដឹងកាន់តែច្រើនពាក់ព័ន្ធនឹងរបៀបវារៈ WPS និងតួនាទីដ៏សំខាន់ដែលស្ត្រីបានបំពេញនាពេលកន្លងមក និងអាចបន្តតួនាទីបែបនេះ ក្នុងការទប់ស្កាត់ជម្លោះ ដំណោះស្រាយ និងការស្តារឡើងវិញ ក៏ដូចជាក្នុងការដោះស្រាយការគំរាមកំហែងថ្មីៗ និងកំពុងលេចឡើងក្នុងវិស័យសន្តិភាព និងសន្តិសុខ។ ស្ត្រីមានតួនាទីសំខាន់ក្នុងការផ្សះផ្សា ការកសាងទំនុកចិត្ត និងទំនុកចិត្ត/ជំនឿចិត្តសហគមន៍ ហើយភាពជាអ្នកដឹកនាំរបស់ស្ត្រីជាកត្តាសំខាន់ក្នុងការធានាសន្តិភាព និងសិនិទ្ធពលសង្គម ដែលនឹងធានាថា សមិទ្ធផលដែលកម្ពុជាសម្រេចបានយ៉ាងលំបាកក្នុងការផ្សះផ្សាក្រោយជម្លោះ មិនត្រូវបានបង្វែរទិសដៅ និងធានាថា កិច្ចខិតខំប្រឹងប្រែងពន្លឿនសន្តិភាព បន្តទៅមុខជានិច្ច។

ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នៅខែ កក្កដា ឆ្នាំ ២០២៤ ភាគីពាក់ព័ន្ធដែលមានបទពិសោធន៍ និងចំណេះដឹងអំពីរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ បានបង្ហាញការគាំទ្រយ៉ាងខ្លាំងចំពោះការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខសម្រាប់កម្ពុជា។ ពួកគេក៏បាន ទទួលស្គាល់ផងដែរនូវបញ្ហាប្រឈមក្នុងការសម្របសម្រួល ការដឹកនាំ និងការអនុវត្តផែនការនេះ និងសង្កត់ធ្ងន់លើ សារៈសំខាន់នៃប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃដ៏រឹងមាំ ជាមួយនឹងសូចនាករដែលអាចវាស់វែងបានច្បាស់លាស់ និងយន្តការរាយការណ៍ដែលអាចសម្រេចបានជាក់ស្តែង។ កិច្ចប្រជុំតាមដាន ក្នុងខែ ធ្នូ ឆ្នាំ ២០២៤ ជាមួយភាគីពាក់ព័ន្ធ បានបញ្ជាក់ឡើងវិញពីសារៈសំខាន់នៃការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ តាមរយៈដំណើរការចូលរួមដោយភាគីពាក់ព័ន្ធចម្រុះ ដោយផ្សារភ្ជាប់ និងស្ថាបនាពីលើគោលនយោបាយ គំនិតផ្តួចផ្តើម និងផែនការសកម្មភាពជាតិដែលមានស្រាប់ និងផ្សារភ្ជាប់ជាមួយកិច្ចអន្តរាគមន៍ចំគោលដៅ ដើម្បីជំរុញរបៀបវារៈ WPS នៅកម្ពុជា។




# ៨. អនុសាសន៍ឆ្ពោះទៅរកការរៀបចំផែនការសកម្មភាពជាតិ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា

Photo: UN Women/Lim Sophorn

## ៨.១. អាទិភាពសំខាន់ៗនៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ សម្រាប់ការពិចារណាដែលស្របតាមផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ

ដើម្បីកាត់បន្ថយភាពត្រួតគ្នាឱ្យនៅតិចបំផុត នៅក្នុងផែនការសកម្មភាពជាតិ និងយុទ្ធសាស្ត្រតាមវិស័យនានា និងដើម្បីស្ថាបនាពីលើការប្តេជ្ញាចិត្ត សមិទ្ធផល និងល្បឿនក្នុងការជំរុញសមភាពយេនឌ័រ ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី គួរពិនិត្យឡើងវិញលម្អិតលើផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីកំណត់រកកម្លាំងផ្ទួបជាមួយផែនការ និងយុទ្ធសាស្ត្រដែលមានស្រាប់។ វិធីសាស្ត្រដែលមានចំណុចផ្តោតតាំងពីដំបូង អាចកាន់តែមានប្រសិទ្ធភាពដោយមានចំណុចអាទិភាព ដូចខាងក្រោម ៖

១.ការបង្កើនការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងរដ្ឋាភិបាល និងវិស័យសាធារណៈនៅគ្រប់កម្រិតទាំងអស់ ជាពិសេសក្នុងវិស័យសន្តិសុខ ដូចជា វិស័យអនុវត្តច្បាប់ កងកម្លាំងប្រដាប់អាវុធ ប្រតិបត្តិការរក្សាសន្តិភាព អ.ស.ប និងវិស័យយុត្តិធម៌

២.ការពង្រឹងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងការដោះស្រាយបទល្មើសបច្ចេកវិទ្យា ដែលកំណត់គោលដៅលើស្ត្រី និងក្មេងស្រី រួមទាំងតាមរយៈការបង្កើនអក្ខរកម្មឌីជីថល

៣. ការពង្រឹងភាពពាក់ព័ន្ធរវាងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងការចូលរួមរបស់ស្ត្រីក្នុងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការគ្រប់គ្រងធនធានធម្មជាតិ និង

៤.ការដោះស្រាយអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រក្នុងវិបត្តិ និងគ្រោះអាសន្ននានា និងដំណើរការផ្សះផ្សា។

### ៨.១.១ សសរស្តម្ភនៃការការពារ

**លទ្ធផលយុទ្ធសាស្ត្រទី ១ ៖** ការការពារសិទ្ធិស្ត្រី ស្ត្រីវ័យក្មេង និងក្មេងស្រី រួមទាំងអ្នកមកពីក្រុមអ្នកទទួលបានឱកាសតិចតួច តាមរយៈគោលនយោបាយ ការអនុវត្ត និងស្ថាប័នដែលទាក់ទងនឹងសន្តិភាព និងសន្តិសុខ រួមទាំងការការពារពីគ្រប់ទម្រង់នៃអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រនៅក្នុងស្ថានភាពជម្លោះ ក្រោយជម្លោះ ការកសាងសន្តិភាព និងមនុស្សធម៌។

**សកម្មភាពដែលស្នើឡើង ៖**

- ធានាថាជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងបរិកាលមានវិបត្តិ និងស្ថានភាពគ្រោះអាសន្ន រួមទាំងស្ថានភាពជម្លោះ និងគ្រោះមហន្តរាយពីអតីតកាល ឬក្នុងពេលបច្ចុប្បន្ន ឬនាពេលអនាគត អាចទទួលបានយន្តការច្បាប់ យន្តការយុត្តិធម៌ សន្តិសុខសង្គម ការការពារ និងយន្តការយុត្តិធម៌អន្តរកាល ដោយមានការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីក្នុងគ្រប់លក្ខណៈចម្រុះ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះអាចផ្អែកលើយុទ្ធសាស្ត្រ និងសកម្មភាពក្នុងផែនការសកម្មភាពស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក៏ដូចជាគំនិតផ្តួចផ្តើមជោគជ័យ ដូចជា អ.វ.ត.ក/អង្គភាពគាំពារជនរងគ្រោះ (ធាតុចេញ ១.១ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)
- ពង្រឹងសមត្ថភាពរបស់អ្នកឆ្លើយតបជួរមុខនៅក្នុងវិស័យសន្តិភាពនិងសន្តិសុខដើម្បីទប់ស្កាត់និងឆ្លើយតបនឹងអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ ស្របតាមអាទិភាពក្នុង NAPVAW និងយន្តការសម្របសម្រួលពហុវិស័យ (ធាតុចេញ ១.១ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)
- បង្កើនឱកាសសម្រាប់អង្គការសង្គមស៊ីវិលនិងអង្គការស្ត្រីក្នុងការសហការជាមួយអ្នកពាក់ព័ន្ធក្នុងរដ្ឋាភិបាលលើការគ្រប់គ្រង និងអនុវត្តបណ្តាញបញ្ជូន និងយន្តការគាំទ្រសម្រាប់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ ជាពិសេសក្នុងស្ថានភាពជម្លោះ និងគ្រោះអាសន្ន (ធាតុចេញ ១.១ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និង សន្តិសុខ)
- ពង្រឹងវិធានការសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីដោះស្រាយបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត និងការគំរាមកំហែងចំពោះសុវត្ថិភាព និងសន្តិសុខរបស់ស្ត្រី។ នេះរួមបញ្ចូលការដោះស្រាយការគំរាមកំហែងដែលធ្វើឱ្យមានអស្ថិរភាពក្នុងសហគមន៍។ ការគំរាមកំហែងទាំងនេះរួមមានការបៀតបៀនផ្លូវភេទ និងការកេងប្រវ័ញ្ច និងសារបោកប្រាស់តាមអនឡាញ ដែលផ្តោតគោលដៅលើស្ត្រីងាយរងគ្រោះ និងស្ត្រីជនបទ ពាក្យសម្តីស្អប់ខ្ពើម និងការរករឿងរំខាន ដែលផ្តោតគោលដៅលើក្រុមជួបការលំបាកផ្សេងៗ ដូចជា ជនជាតិភាគតិច ជនជាតិដើមភាគតិច ក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា (LGBTIQ+) ក៏បង្កហានិភ័យធ្ងន់ធ្ងរផងដែរ។ អ្នកការពារសិទ្ធិមនុស្សរបស់ស្ត្រី អ្នកសារព័ត៌មាន សកម្មជនបរិស្ថាន និងអ្នកផ្សេងទៀត រងផលប៉ះពាល់ខ្លាំងជាងគេ។ កិច្ចអន្តរាគមន៍ទប់ស្កាត់ គួរជួយទាំងអ្នកដែលងាយរងគ្រោះបំផុត និងអ្នកដែលកំពុងរងផលប៉ះពាល់ដោយបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត និងការគំរាមកំហែងតាមប្រព័ន្ធឌីជីថល (ធាតុចេញ ១.១ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)
- ធានាការការពារនិងការគាំទ្រដល់ជីវភាពរបស់ស្ត្រីជាពិសេសក្នុងបរិបទនៃវិបត្តិនិងគ្រោះមហន្តរាយ។នេះរួមបញ្ចូលការដោះស្រាយភារៈការងារថែទាំដែលមិនទទួលបានប្រាក់ឈ្នួល ដែលរឹតត្បិតការចូលរួមក្នុងសេដ្ឋកិច្ច និងសន្តិសុខរបស់ស្ត្រី។ ជារឿយៗ វិបត្តិបង្កើនភារៈថែទាំរបស់ស្ត្រី ដោយធ្វើឱ្យមិនសូវមានលទ្ធភាពចូលរួមក្នុងការសម្រេចចិត្ត (ធាតុចេញ ១.១ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)
- លើកកម្ពស់ការដាក់បញ្ចូលរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងកម្មវិធីសិក្សាសម្រាប់ការអប់រំ និងបណ្តុះបណ្តាល ដើម្បីកសាងការយល់ដឹងស្តីពីគោលបំណងនៃសន្តិភាព និងសន្តិសុខនៅក្នុងគ្រួសារ សហគមន៍ និងកម្មវិធីបណ្តុះបណ្តាលតាមស្ថាប័ន (ធាតុចេញ ១.២ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)
- ពង្រឹងការបញ្ជ្រាបយេនឌ័រ នៅក្នុងអភិបាលកិច្ច និងសន្តិសុខ និងស្ថាប័ន រួមទាំងនៅក្នុងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ/វិស័យការពារជាតិ កងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងប្រតិបត្តិការបោសសម្អាតមីន និងកសាងសមត្ថភាពរបស់ GMAG ក្នុងការអនុវត្ត GMAP (ធាតុចេញ ១.៣ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• កសាងសមត្ថភាពរបស់តួអង្គក្នុងវិស័យសន្តិសុខ រួមមាននគរបាលជាតិ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងរក្សាសន្តិភាពរបស់ អ.ស.ប ដើម្បីការពារសិទ្ធិស្ត្រីដែលមានហានិភ័យ ឬតម្រូវការពិសេស ដូចជា ស្ត្រីជនជាតិភាគតិច និងស្ត្រីជនជាតិដើមភាគតិច ស្ត្រីចំណាកស្រុក ស្ត្រីមានពិការភាព និងស្ត្រីចាស់ជរា ដើម្បីធានាសុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់ពួកគេ (ធាតុចេញ ១.៣ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)។

### ៨.១.២ សសរស្តម្ភនៃការចូលរួម

**លទ្ធផលយុទ្ធសាស្ត្រទី ២ ៖** ការចូលរួមពេញលេញ ប្រកបដោយអត្ថន័យ និងដោយស្មើភាពរបស់ស្ត្រី នៅក្នុងស្ថាប័ន អង្គការ និងដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលទាក់ទងនឹងសន្តិភាព និងសន្តិសុខ រួមទាំងនៅក្នុងតំណែងដឹកនាំ។

**សកម្មភាពដែលស្នើឡើង ៖**

• បង្កើតឱកាសសម្រាប់ការចូលរួម និងការរីកចម្រើនរបស់ស្ត្រីឆ្ពោះទៅរកតួនាទីដឹកនាំ ជាពិសេសក្នុងវិស័យសន្តិភាព និងសន្តិសុខ។ នេះរួមមានការបង្កើត និងរក្សាបរិយាកាសការងារដែលគាំទ្រ និងអំណោយផលសម្រាប់ស្ត្រី និងការកំណត់កូតាបណ្តោះអាសន្ន ដើម្បីជួយបំពេញចំណុចដៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៥ និងទី ១៦ ស្របតាមអនុសាសន៍ ៣១ក និង ៣១ខ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ឆ្នាំ២០១៩ ចំពោះកម្ពុជា។ ការដោះស្រាយឧបសគ្គផ្នែករចនាសម្ព័ន្ធ និងវប្បធម៌ គឺជាកត្តាសំខាន់ និងអាចសម្រេចបានតាមរយៈគោលនយោបាយស្តីពីសមភាពយេនឌ័រ ការបណ្តុះបណ្តាល និងការកសាងការយល់ដឹង ទន្ទឹមនឹងគណនេយ្យភាពសម្រាប់លទ្ធផល (ធាតុចេញ ២.១ និង ២.៤ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• បង្កើតវគ្គបណ្តុះបណ្តាលយេនឌ័រជាកាតព្វកិច្ចទាំងសម្រាប់បុរស និងស្ត្រី រួមទាំងថ្នាក់ដឹកនាំ ក្នុងគ្រប់ស្ថាប័នសន្តិភាព និងសន្តិសុខទាំងអស់។ សង្កត់ធ្ងន់លើសារៈសំខាន់នៃការគាំទ្ររបស់អ្នកដឹកនាំជាបុរស ចំពោះការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការកសាងសន្តិភាព និងការទប់ស្កាត់ជម្លោះ ការដោះស្រាយ និងការសម្រុះសម្រួល ជាពិសេសនៅកម្រិតជាតិ តំបន់ និងអន្តរជាតិ (ធាតុចេញ ២.១ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• ពង្រឹងការចូលរួមរបស់ស្ត្រី និងស្ត្រីវ័យក្មេងនៅកម្រិតថ្នាក់ក្រោមជាតិ កម្រិតសហគមន៍ និងកម្រិតមូលដ្ឋាន ក្នុងការលើកកម្ពស់សិនិទ្ធភាពសង្គម ការទប់ស្កាត់ជម្លោះ ដំណោះស្រាយ និងការកសាងសន្តិភាព។ នេះរាប់បញ្ចូលស្ត្រីក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ អ្នកដឹកនាំសហគមន៍ អង្គការសង្គមស៊ីវិល បណ្តាញស្ត្រី និងអ្នកដឹកនាំជាយុវជន ដើម្បីរួមចំណែកដល់ការកសាងសន្តិភាពក្នុងមូលដ្ឋាន (ធាតុចេញ ២.១ និង ២.២ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• គាំទ្រការចូលរួមរបស់អង្គការសង្គមស៊ីវិលស្ត្រី និងអង្គការយុវជន និងរួមបញ្ចូលបុរស និងស្ត្រីវ័យក្មេង ក្នុងដំណើរការពិគ្រោះយោបល់ រៀបចំផែនការ អនុវត្ត និងវាយតម្លៃ ក្នុងវិស័យសន្តិភាព សន្តិសុខ និងមនុស្សធម៌។ យន្តការស្ថាប័នគួរគាំទ្រការរួមចំណែកសង្គមស៊ីវិល និងយុវជន ជាពិសេសក្នុងការទប់ស្កាត់អំពើហិង្សាជ្រុលនិយម ការដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមរយៈបច្ចេកវិទ្យា និងការផ្សារភ្ជាប់ជាមួយអាកាសធាតុ សន្តិភាព និងសន្តិសុខ (ធាតុចេញ ២.២ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• ជំរុញការចូលរួមរបស់ប្រព័ន្ធផ្សព្វផ្សាយ ស្ថាប័នសិក្សាស្រាវជ្រាវ និងអង្គការជំនឿ ដើម្បីបង្កើនការដឹកនាំរបស់ស្ត្រីក្នុងគំនិតផ្តួចផ្តើមដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ។ នេះរួមមានការបង្កើនភាពលេចធ្លោរបស់ស្ត្រីគំរូនៅក្នុងការដោះស្រាយជម្លោះ និងការផ្សះផ្សា។ រិះរកវិធីជំរុញការចូលរួមរបស់វិស័យឯកជនក្នុងការពង្រឹងការចូលរួមរបស់ស្ត្រី (ធាតុចេញ ២.២ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• បង្កើតកម្មវិធី និងគំនិតផ្តួចផ្តើមនានា ដើម្បីបណ្តុះបណ្តាល និងកសាងសមត្ថភាពរបស់ស្ត្រីឱ្យក្លាយជាអ្នកផ្សះផ្សា និងអ្នកចរចាដែលមានគុណវុឌ្ឍិ ក្នុងផ្នែកមូលបទស្តីពីការកសាងសន្តិភាព និងការទប់ស្កាត់ជម្លោះទាំងនៅកម្រិតតំបន់ និងកម្រិតជាតិ។ នេះអាចរួមបញ្ចូលវគ្គបណ្តុះបណ្តាលស្តង់ដារ ដែលគ្របដណ្តប់លើជំនាញឌីជីថល និងការផ្សារភ្ជាប់ជាមួយ អ.ជ.ក NPMEC និង UN PKO (ធាតុចេញ ២.៣ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• បន្តពង្រីកលទ្ធភាពទទួលបានការបណ្តុះបណ្តាលស្តីពីអក្ខរកម្មឌីជីថល សន្តិសុខតាមប្រព័ន្ធបច្ចេកវិទ្យា និងបច្ចេកទេសសម្រាប់អ្នកដឹកនាំជាស្ត្រី និងមន្ត្រីអនុវត្តច្បាប់។ នេះនឹងពង្រឹងការចូលរួមរបស់ស្ត្រីក្នុងការទប់ស្កាត់ បទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត និងជួយឱ្យស្ត្រីអនុវត្តទស្សនៈវិស័យ និងជំនាញឯកទេសរបស់ពួកគេនៅក្នុងការកំណត់រកដំណោះស្រាយ (ធាតុចេញ ២.៤ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• ពង្រឹងការដឹកនាំរបស់ស្ត្រី និងការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីនៅក្នុងច្បាប់ និងការបង្កើតគោលនយោបាយដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យា ស្របតាមគោលការណ៍ WPS រួមទាំងក្នុងយន្តការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តច្បាប់ដែលដោះស្រាយការគំរាមកំហែងតាមប្រព័ន្ធអ៊ីនធឺណិត (ធាតុចេញ ២.៤ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• លើកកម្ពស់បរិយាបន្នពេញលេញសម្រាប់ស្ត្រីជួបការលំបាក និងក្រុមផ្សេងទៀតដែលមានតំណាងតិចតួចនៅក្នុងវិស័យសន្តិភាព និងសន្តិសុខ តាមរយៈការកំណត់រកឧបសគ្គ និងបទដ្ឋាន ដែលអាចផ្លាស់ប្តូរបាន និងការអនុវត្តវិធីសាស្ត្រថ្មីៗដើម្បីបង្កើនភាពជាតំណាង ជាពិសេសក្នុងតួនាទីដឹកនាំ និងបង្កើនតុល្យភាពយេនឌ័រ (ធាតុចេញ ២.១ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

### ៨.១.៣ សសរស្តម្ភនៃការទប់ស្កាត់

**លទ្ធផលយុទ្ធសាស្ត្រទី ៣ ៖** អង្គភាពតាមវិស័យ ស្ថាប័ន និងរដ្ឋជាសមាជិកអាស៊ាន ដើរតួនាទីយ៉ាងសកម្មក្នុងការរួមចំណែកដល់ការទប់ស្កាត់ជម្លោះជាសកល នៅថ្នាក់តំបន់ និងថ្នាក់ជាតិ និងការទប់ស្កាត់អំពើហិង្សា គ្រោះមហន្តរាយ និងការគំរាមកំហែងផ្សេងទៀតចំពោះសន្តិភាព និងសន្តិសុខ ដោយមានគោលការណ៍នៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ជាស្នូល។

សកម្មភាពដែលស្នើឡើង ៖

• លើកកម្ពស់កិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងតំបន់អាស៊ាន ដើម្បីផ្លោះប្តូរមេរៀន និងការអនុវត្តល្អស្តីពីការបញ្ជ្រាបយេនឌ័រ និងការចូលរួមរបស់ស្ត្រីក្នុងការទប់ស្កាត់ជម្លោះ រួមទាំងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការឆ្លើយតបគ្រោះអាសន្ន សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងការគំរាមកំហែងថ្មីៗផ្សេងទៀតចំពោះសន្តិភាព និងសន្តិសុខ (ធាតុចេញ ៣.១ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• ធ្វើការស្រាវជ្រាវផ្អែកលើភស្តុតាង ដើម្បីកំណត់រកវិធីធ្វើយ៉ាងណាឱ្យស្ត្រី បុរស និងយុវជន រួមទាំងអ្នកមកពីសហគមន៍ជួបការលំបាក បានចូលរួម ឬអាចទទួលបានការគាំទ្រកាន់តែប្រសើរក្នុងការកាត់បន្ថយហានិភ័យ និងការទប់ស្កាត់អំពើហិង្សាជម្លោះ អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ និងអសន្តិសុខបរិស្ថាន រួមទាំងក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព (ធាតុចេញ ៣.១ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• កសាងភាពជាដៃគូជាមួយស្ត្រីដែលជាអ្នកផ្សះផ្សា អង្គការសង្គមស៊ីវិលរបស់ស្ត្រី អង្គការយុវជន និងក្រុមជំនឿតាមរយៈយន្តការដែលមានការសម្របសម្រួល ដែលគាំទ្រការកសាងសន្តិភាពក្នុងមូលដ្ឋាន និងការទប់ស្កាត់ជម្លោះ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះគួរធានាថា តម្រូវការ និងទស្សនៈវិស័យរបស់ស្ត្រីត្រូវបានដាក់បញ្ចូលពេញលេញទៅក្នុងការបង្កើតគោលនយោបាយស្តីពីការទប់ស្កាត់ជម្លោះ (ធាតុចេញ ៣.១ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• កំណត់រក និងដោះស្រាយតម្រូវការកសាងសមត្ថភាពដើម្បីបំពាក់បំប៉នអ្នកឆ្លើយតបបឋម អ្នកបង្កើតគោលនយោបាយ និងអ្នកអនុវត្តន៍ ស្តីពីការទប់ស្កាត់ជម្លោះ និងការកាត់បន្ថយហានិភ័យ។ នេះរួមមានការបណ្តុះបណ្តាលស្តីពីការទប់ស្កាត់ការបៀតបៀនផ្លូវភេទ និងការអនុវត្តគោលនយោបាយការងារស្តីពីការបៀតបៀនផ្លូវភេទក្នុងកន្លែងធ្វើការ ក៏ដូចជាកិច្ចអន្តរាគមន៍ដែលត្រូវបានរៀបចំឡើងដើម្បីទប់ស្កាត់ការរីករាលដាល និងគ្រោះថ្នាក់បន្ថែមទេ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះគួររួមបញ្ចូលការវាស់វែងលទ្ធផលច្បាស់លាស់សម្រាប់ការដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រ/អំពើហិង្សាលើស្ត្រី និងក្មេងស្រី (ធាតុចេញ ៣.២ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• ស្របតាមអនុសញ្ញា CEDAW អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (CERD) និងសម្រាប់ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ពាក្យសម្តីស្អប់ខ្ពើម ដែលអាចបង្កឱ្យមានភាពតានតឹង បន្តការលើកកម្ពស់ការយល់ដឹង និងការផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ និងសាធារណជនស្តីពី ការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការរើសអើងពូជសាសន៍។ នេះរួមបញ្ចូលការដោះស្រាយការរើសអើងបែបនេះនៅក្នុងរដ្ឋបាល និងដំណើរការនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងការធានាលទ្ធភាពប្រើប្រាស់ នីតិវិធីបណ្តឹង (ធាតុចេញ ៣.២ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• បង្កើតកិច្ចអន្តរាគមន៍កម្មវិធី ដើម្បីកសាងការយល់ដឹង និងបង្កើនការការពារពីការគំរាមកំហែងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត ជាពិសេសសម្រាប់ស្ត្រី ក្មេងស្រី និងសហគមន៍ងាយរងគ្រោះ។ នេះរួមបញ្ចូលការបង្កើនអក្ខរកម្មឌីជីថល និងការយល់ដឹងអំពីហានិភ័យសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត (ធាតុចេញ ៣.២ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• ពង្រឹងសមត្ថភាពក្នុងការតាមដានរក និងទប់ស្កាត់ផលប៉ះពាល់ផ្អែកតាមយេនឌ័រដោយសារការគំរាមកំហែងក្នុងប្រព័ន្ធឌីជីថល គ្រោះថ្នាក់ និងបទល្មើសដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ធាតុចេញ ៣.២ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

**លទ្ធផលយុទ្ធសាស្ត្រទី ៤ ៖** ស្ថាប័ន យន្តការ និងដំណើរការសន្តិភាព និងសន្តិសុខ ទទួលបានជោគជ័យក្នុងការបង្ការទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ។

សកម្មភាពដែលស្នើឡើង ៖

• ទាញយកប្រយោជន៍ពីមេរៀនដែលទទួលបានពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីធានាថា ផែនការឆ្លើយតបក្នុងគ្រាអាសន្ន និងការត្រៀមបង្ការគ្រោះមហន្តរាយ រួមបញ្ចូលស្តង់ដារសម្រាប់អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រក្នុងពេលមានអាសន្ន។ នេះអាចរួមបញ្ចូលការស្រាវជ្រាវបន្ថែម ដើម្បីផ្តល់មូលដ្ឋានព័ត៌មានកាន់តែប្រសើរដល់អន្តរាគមន៍ឆ្លើយតបដែលផ្តោតគោលដៅលើយេនឌ័រ ដែលដោះស្រាយឫសគល់នៃអំពើហិង្សា រួមទាំងអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ (ធាតុចេញ ៤.១ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• ធានាថា យុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់វិស័យសុខាភិបាល ឆ្នាំ២០២០-២០២៤ គាំទ្រតម្រូវការរបស់ស្ត្រី និងក្មេងស្រី ដោយរួមបញ្ចូលយ៉ាងពេញលេញនូវក្រុមការងារអន្តរទីភ្នាក់ងារ ស្តីពីកញ្ចប់សេវាបឋមអប្បបរមា (MISP) សុខភាពបន្តពូជក្នុងគ្រាមានវិបត្តិ ដែលគ្របដណ្តប់លើការផ្តល់សេវាសុខភាពមាតា សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងការទប់ស្កាត់ និងគ្រប់គ្រងផលវិបាកនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រាអាសន្ន[255] (ធាតុចេញ ៤.១ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• ស្របតាមអនុសាសន៍ទូទៅលេខ៣៧ (២០១៨) នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ធ្វើស្ថាប័ននូបនីយកម្មភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅគ្រប់កម្រិតនៃការទប់ស្កាត់គ្រោះមហន្តរាយ ការត្រៀមបង្ការ រួមទាំងការអភិវឌ្ឍ និងការផ្សព្វផ្សាយជាប្រព័ន្ធជូនដំណឹងជាព័ត៌មានជាមុនការឆ្លើយតប និងការស្តារឡើងវិញ ព្រមទាំងការកាត់បន្ថយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ ធានាការផ្តល់ការប្រកាសជូនព័ត៌មានជាមុន ដោយប្រើប្រាស់បច្ចេកវិទ្យាដែលទំនើប មានលក្ខណៈសមស្របតាមវប្បធម៌ អាចមានលទ្ធភាពទទួលបាន និងប្រកបដោយបរិយាបន្ន ដោយពិចារណាលើតម្រូវការរបស់ក្រុមស្ត្រីដែលមានភាពចម្រុះ។ អ្នកឆ្លើយតបបឋមគួរតែមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានទិន្នន័យបែងចែកតាមភេទ និងការកសាងសមត្ថភាព ដើម្បីធានាថា វិស័យសន្តិភាព និងសន្តិសុខ អនុវត្តកិច្ចអន្តរាគមន៍ដែលមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រក្នុងពេលឆ្លើយតបនឹងគ្រោះអាសន្ន (ធាតុចេញ ៤.២ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

• ដាក់បញ្ចូលលទ្ធផលរកឃើញ និងអនុសាសន៍នៃការសិក្សាឆ្នាំ ២០២៣ របស់ RCAF ស្តីពី MOWIP ទៅក្នុងសកម្មភាពអាទិភាពនៃផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខសម្រាប់ UN PKO និងផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវលទ្ធផលរកឃើញដែលពាក់ព័ន្ធនឹងស្ត្រី នៅក្នុងការអនុវត្តច្បាប់ (ធាតុចេញ ៤.២ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)

[255] ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗជាមួយមន្ត្រីស្ថានទូត រាជធានីភ្នំពេញ ខែសីហា ឆ្នាំ២០២៤

### ៨.១.៤ សសរស្តម្ភនៃការសង្គ្រោះ និងស្តារឡើងវិញ

**លទ្ធផលយុទ្ធសាស្ត្រទី ៥ ៖** តម្រូវការរបស់ស្ត្រី និងក្មេងស្រី ត្រូវបានបំពេញនៅក្នុងដំណើរការសង្គ្រោះ និងស្តារឡើងវិញនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ហើយស្ត្រីមានការចូលរួមដោយស្មើភាព និងប្រកបដោយ អត្ថន័យនៅក្នុងដំណើរការទាំងនេះ រួមទាំងនៅក្នុងតំណែងធ្វើសេចក្តីសម្រេចចិត្ត និងភាពជាអ្នកដឹកនាំ។

**សកម្មភាពដែលស្នើឡើង ៖**

- ធានាថា គោលនយោបាយ និងការអនុវត្តមានលក្ខណៈឆ្លើយតបនឹងយេនឌ័រដោយផ្អែកតាមអាទិភាពរបស់ស្ត្រីនៅដំណាក់កាលសង្គ្រោះ និងស្តារឡើងវិញ រួមទាំងតាមរយៈការពិគ្រោះយោបល់ជាមួយស្ត្រីក្នុងសហគមន៍ដែលមានតម្រូវការ និងពិការភាពផ្សេងៗ។ ប្រមូល និងវិភាគទិន្នន័យបែងចែកតាមភេទដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់គោលនយោបាយ និងអន្តរាគមន៍ផ្អែកលើភស្តុតាង (ធាតុចេញ ៥.១ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)
- ពង្រឹងការចូលរួម និងការដឹកនាំរបស់ស្ត្រីក្នុងយន្តការសម្របសម្រួលពហុវិស័យ បណ្តាញ និងភាពជាដៃគូនៅកម្រិតអន្តរជាតិ និងកម្រិតតំបន់ ដើម្បីធានាថា របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានដាក់បញ្ចូលក្នុងដំណាក់កាលសង្គ្រោះ និងស្តារឡើងវិញ ដើម្បីលើកកម្ពស់សិទ្ធិពលសង្គម និងការរួមបញ្ចូលអ្នកពាក់ព័ន្ធ (ធាតុចេញ ៥.២ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)
- លើកកម្ពស់ និងអនុវត្តកម្មវិធី ដែលលើកឡើងពីសិទ្ធិសេដ្ឋកិច្ច និងតម្រូវការរបស់ស្ត្រី រួមទាំងស្ត្រីនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីបង្កើនសុវត្ថិភាព និងសន្តិសុខរបស់ស្ត្រី គ្រួសារ និងជីវភាពរបស់ពួកគាត់។ នេះរួមមានលទ្ធភាពទទួលបានរបរចិញ្ចឹមជីវិត និងឱកាសរកប្រាក់ចំណូលក្នុងពេលការសង្គ្រោះ និងស្តារឡើងវិញក្រោយពេលមានវិបត្តិ (ធាតុចេញ ៥.៣ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)
- ស្របតាមអនុសាសន៍ ១៣ក នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ឆ្នាំ២០១៩ ចំពោះកម្ពុជា បន្តស្ថាបនាពីលើភាពជោគជ័យរបស់កម្ពុជា តាមរយៈអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងការជំរុញដំណើរការយុត្តិធម៌ និងការផ្សះផ្សាក្រោយរបបប្រល័យពូជសាសន៍ និងជម្លោះនាពេលកន្លងមក រួមទាំងយន្តការគាំទ្រជនរងគ្រោះដែលដោះស្រាយផលប៉ះពាល់នៃអំពើប្រល័យពូជសាសន៍ អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ និងការប៉ះទង្គិចផ្លូវចិត្តអន្តរជំនាន់ លើស្ត្រី គ្រួសារ និងសហគមន៍ ជាពិសេសសហគមន៍ជនជាតិភាគតិច។ នេះរួមបញ្ចូលទាំងគំនិតផ្តួចផ្តើមក្នុងមូលដ្ឋាន ដូចជា កិច្ចសន្ទនាសហគមន៍ស្តីពីការកសាងសន្តិភាព និងការផ្លាស់ប្តូរជម្លោះ កិច្ចសន្ទនារវាងជំនាន់ រវាងអ្នករស់រានមានជីវិតពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ/អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ និងកម្មវិធីអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងកាន់តែស៊ីជម្រៅស្តីពីជម្លោះនាពេលកន្លងមក សម្រាប់ជាមូលដ្ឋាននៃការទប់ស្កាត់ជម្លោះនាពេលអនាគត (ធាតុចេញ ៥.៣ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)
- បង្កើតកម្មវិធីដែលឆ្លើយតបនឹងយេនឌ័រ ដើម្បីផ្តល់ការគាំទ្រសមស្របផ្នែកចិត្តសង្គមដល់ជនរងគ្រោះនៃជម្លោះ និងអំពើហិង្សា។ កម្មវិធីទាំងនេះគួរតែដោះស្រាយការប៉ះទង្គិចផ្លូវចិត្ត រួមទាំងផលប៉ះពាល់អន្តរជំនាន់នៃអំពើហិង្សាលើស្ត្រី និងគ្រួសារ តាមរយៈដំណោះស្រាយជម្លោះ និងការកសាងសន្តិភាព (ធាតុចេញ ៥.៣ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)។

## ៨.២. យន្តការសម្របសម្រួលដែលអាចមាន

- ស្របតាមឧត្តមានុវត្តន៍ យន្តការសម្របសម្រួលសម្រាប់ការអភិវឌ្ឍ និងការអនុវត្តផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា គួរធ្វើឡើងនៅក្នុងកម្រិតរដ្ឋាភិបាលចំនួន ០២ កម្រិត ៖ គឺកម្រិតនយោបាយ (ជាន់ខ្ពស់) និងកម្រិតបច្ចេកទេស ជាមួយនឹងការត្រួតពិនិត្យជាន់ខ្ពស់នៅកម្រិតនាយករដ្ឋមន្ត្រី ឬឧបនាយករដ្ឋមន្ត្រី ស្រដៀងគ្នានឹងរចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។ ក្រសួង និងស្ថាប័នពាក់ព័ន្ធសំខាន់ៗ ដែលពាក់ព័ន្ធក្នុងការដឹកនាំការសម្របសម្រួល អាចរួមមានទាំងក្រសួងកិច្ចការនារី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការចូលរួមពីមជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងបរិស្ថាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងព័ត៌មាន ក្រសួងយុត្តិធម៌ និងអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន/មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជានៅកម្រិតបច្ចេកទេស និងការអនុវត្ត។
- ជាយុទ្ធសាស្ត្រ ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងយន្តការសម្របសម្រួល គួរស្ថាបនាពីលើការគាំទ្រយ៉ាងខ្លាំងរបស់ថ្នាក់ដឹកនាំនៃគណៈកម្មការទី ៨ នៃរដ្ឋសភា និងក្រុមស្ត្រី ដើម្បីជំរុញការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នៅកម្រិតរដ្ឋាភិបាលជាន់ខ្ពស់។
- ប្រើប្រាស់ក្រុមការងារបញ្ជ្រាបយេនឌ័រតាមក្រសួងស្ថាប័ន (GMAGs) ដែលមានស្រាប់នៅក្នុងក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់តាំងបុគ្គលឆ្នើម ឬជនបង្គោល ដែលអាចជួយដល់ការរៀបចំផែនការ និងការអនុវត្ត។ ស្រដៀងគ្នានឹងគំរូរបស់ប្រទេសកាណាដា បុគ្គលឆ្នើមនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ អាចដឹកនាំការស្វែងរកការគាំទ្រមតិផ្ទៃក្នុង ធានាភាពស៊ីសង្វាក់គ្នាជាមួយយុទ្ធសាស្ត្រ និងផែនការតាមវិស័យ និងដើរតួនាទីជាជនបង្គោលស្តីពីរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។
- ប្រើប្រាស់ TWGG ដែលមានស្រាប់ ដើម្បីសម្របសម្រួលការងារពាក់ព័ន្ធនឹងរបៀបវារៈ WPS ក្នុងចំណោមអ្នកពាក់ព័ន្ធផ្សេងៗ រួមទាំងដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល និងវិស័យឯកជន។ នេះគួររួមបញ្ចូលការតាមដានវឌ្ឍនភាព ការកំណត់រកបញ្ហាប្រឈម ការចែករំលែកមេរៀនដែលទទួលបាន និងការកំណត់ទិសដៅសម្រាប់ការងារនាពេលអនាគត។
- បង្កើតបណ្តាញក្រៅផ្លូវការ ឬក្រុមប្រឹក្សាផ្លូវការមួយនៃអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ដែលមានចំណាប់អារម្មណ៍ចង់សហការលើផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខរបស់កម្ពុជា។ ក្រុមនេះគួរធានាការតំណាងពីក្រុមទទួលបានឱកាសតិចតួច រួមទាំងយុវជន។ ក្រុមប្រឹក្សានេះគួរតែមានលក្ខខណ្ឌយោងច្បាស់លាស់ ចូលរួមក្នុងការរៀបចំផែនការ ការត្រួតពិនិត្យតាមដាន និងការរាយការណ៍ ព្រមទាំងការជួបប្រជុំជាប្រចាំ។ អង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត ក៏អាចចូលរួមក្នុងការចែករំលែកព័ត៌មាន ការអនុវត្ត និងការពិនិត្យឡើងវិញបានផងដែរ។
- ការធ្វើឱ្យមានលក្ខណៈផ្លូវការនូវការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល នៅក្នុងដំណើរការផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ អាចធ្វើឱ្យប្រសើរឡើងដល់ការរៀបចំផែនការ ការអនុវត្ត និងដំណើរការរាយការណ៍ជាប្រព័ន្ធ ក៏ដូចជាពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសមត្ថភាព និងការលើកកម្ពស់ការយល់ដឹងដែលពាក់ព័ន្ធនឹងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។
- ធានាថាការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ បន្សីគ្នាយ៉ាងល្អនឹងគោលនយោបាយ ផែនការ និងក្របខណ្ឌតាមដានជាតិផ្សេងទៀត ដូចជា ផែនការយុទ្ធសាស្ត្រនារីរតនៈ យុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុ និងផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងរួមបញ្ចូលជាមួយក្របខណ្ឌរាយការណ៍ថ្នាក់ជាតិ និងអន្តរជាតិ (ឧ. គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ)។ នេះនឹងពន្លឿនវឌ្ឍនភាពនៃសមភាពយេនឌ័រ កាត់បន្ថយការងារត្រួតគ្នានៃកិច្ចខិតខំប្រឹងប្រែង និងសម្រួលតម្រូវការនៃរាយការណ៍។

## ៨.៣. ជំហានបន្ទាប់ដែលបានលើកឡើងពីការសិក្សានេះ

- ផ្អែកតាមការដឹកនាំដ៏គ្រប់ជ្រុងជ្រោយរបស់ក្រសួងកិច្ចការនារី (MoWA) ក្នុងការគាំទ្រការរៀបចំ ASEAN RPA-WPS បទពិសោធន៍ និងចំណេះដឹងរបស់ក្រសួង ក្នុងនាមជាប្រធានក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ(WPS) និងតួនាទីដឹកនាំរបស់ក្រសួងក្នុងការជំរុញសមភាពយេនឌ័រ និងសិទ្ធិស្ត្រី តាមរយៈផែនការសកម្មភាពជាតិ និងគោលនយោបាយផ្សេងទៀត ដូចជា NAPVAW, NSP-CTIP និងផែនការនារីរតនៈ ក្រសួងកិច្ចការនារីមានភាពសក្តិសមបំផុតក្នុងការដឹកនាំការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រីសន្តិភាព និងសន្តិសុខ (NAP-WPS) នៅកម្ពុជា ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងពាក់ព័ន្ធផ្សេងទៀត ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍។
- ប្រទេសកម្ពុជាមានលក្ខណៈសម្បត្តិក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS) ដោយឡែកមួយ ដោយយោងទៅលើសមត្ថភាពដឹកនាំរបស់ក្រសួងកិច្ចការនារីក្នុងការបញ្ជ្រាបយេនឌ័រទៅគ្រប់វិស័យទាំងអស់ និងការជំរុញសមភាពយេនឌ័រ និងសិទ្ធិស្ត្រីនៅក្នុងផែនការ គោលនយោបាយ និងយុទ្ធសាស្ត្រជាតិ។ អត្ថប្រយោជន៍នៃផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS) បែបនេះ គឺផែនការនេះនឹងទទួលស្គាល់ និងគូសបញ្ជាក់ពីលក្ខណៈស្មុគស្មាញ និងឆ្លងវិស័យនៃបញ្ហាស្ត្រី សន្តិភាព និងសន្តិសុខនៅតាមវិស័យ និងស្ថាប័នផ្សេងៗជាច្រើន។ ផែនការនេះក៏នឹងធានាឱ្យមានការដាក់បញ្ចូលអាទិភាព WPS កាន់តែច្រើន ស្របតាម ASEAN RPA-WPS ផងដែរ។ ផ្ទុយទៅវិញ ការដាក់បញ្ចូលបញ្ហា WPS ទៅក្នុងផែនការ ឬយុទ្ធសាស្ត្រជាតិផ្សេងទៀត អាចនាំមានការដោះស្រាយមិនបានគ្រប់គ្រាន់នូវបញ្ហាជាច្រើនដែលបានកត់សម្គាល់ ការពិបាកក្នុងការពិនិត្យតាមដាន និងវាស់វែងវឌ្ឍនភាព ហើយដូច្នេះ អាទិភាព WPS អាចនឹងត្រូវបានបាំងបិទដោយអាទិភាពផ្សេងទៀត។
- ស្របតាមការអនុវត្តល្អបំផុតនៃវិធីសាស្ត្រដែលមានផលជះខ្ពស់ចាំបាច់ត្រូវមានការដឹកនាំយ៉ាងមុះមុត ក្នុងផ្នែកនយោបាយ ដើម្បីកៀរគរការគាំទ្រប្រកបដោយប្រសិទ្ធភាពពីគ្រប់កម្រិតនៃរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍អន្តរជាតិ និងដើម្បីបង្ហាញពីសារៈសំខាន់នៃរបៀបវារៈ WPS សម្រាប់សន្តិភាព និងស្ថិរភាពនៅកម្រិតជាតិ តំបន់ និងអន្តរជាតិ។
- ដោយយកលំនាំតាមការអនុវត្តវិធីសាស្ត្រដែលមានផលជះខ្ពស់ផងដែរនោះ ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា នឹងត្រូវការវិភាគថវិកាគ្រប់គ្រាន់ពីថវិកាជាតិ ក៏ដូចជាការគាំទ្រពីដៃគូអភិវឌ្ឍន៍។ ក្រោមភាពជាដៃគូជាមួយក្រសួងផ្សេងទៀត ក្រសួងកិច្ចការនារីមានលក្ខណៈសម្បត្តិក្នុងការសហការ និងការស្វែងរកការគាំទ្រមតិជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យមានការបែងចែកថវិកាជាតិសម្រាប់ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាពនិងសន្តិសុខ (NAP-WPS)។
- បង្កើតយន្តការសម្របសម្រួលនៅពេលចាប់ផ្តើមដំណើរការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS) ដើម្បីធានាភាពម្ចាស់ការ និងការប្តេជ្ញាចិត្តផ្នែកនយោបាយក្នុងការអនុវត្ត។ លក្ខខណ្ឌការងារ (TOR) សម្រាប់យន្តការសម្របសម្រួល គួរកំណត់ច្បាស់ពីក្រសួង/ស្ថាប័នដឹកនាំ និងក្រសួង/ទីភ្នាក់ងារដែលចូលរួមនៅកម្ពុជា។
- អង្គការ UN Women បន្តផ្តល់ការគាំទ្របច្ចេកទេសដល់ក្រសួងកិច្ចការនារី និងយន្តការសម្របសម្រួលក្នុងការជំរុញរបៀបវារៈ WPS និងការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS) រួមទាំងតាមរយៈការទទួលបានការគាំទ្រ និងការកៀរគរធនធានពីទីភ្នាក់ងារអង្គការសហប្រជាជាតិផ្សេងទៀត និងដៃគូអភិវឌ្ឍន៍ ការចូលរួមជាមួយអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល និងការធានាឱ្យមានការដាក់បញ្ចូលក្រុមដែលជួបការលំបាកទៅក្នុងដំណើរការនេះ។
- ជាផ្នែកមួយនៃការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា បង្កើនការយល់ដឹងស្តីពីរបៀបវារៈ WPS រួមទាំង ASEAN RPA-WPS និងបរិបទកម្ពុជា ជាមួយតួអង្គរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល អង្គការយុវជន ស្ថាប័នសិក្សាស្រាវជ្រាវ ប្រព័ន្ធផ្សព្វផ្សាយ និងអាជ្ញាធរថ្នាក់ក្រោមជាតិ។ នេះរួមបញ្ចូលទាំងការសង្កត់ធ្ងន់លើបញ្ហាសន្តិសុខ លើសពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលនៃការវិភាគស្ថានភាព និងប្រើប្រាស់ភស្តុតាងទាំងនេះ ដើម្បីផ្តោតអាទិភាពលើបញ្ហាដែលពាក់ព័ន្ធ និងអាចសម្រេចបានបំផុត សម្រាប់បញ្ចូលទៅក្នុងផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខសម្រាប់កម្ពុជា។
- រៀបចំកាលវិភាគសម្រាប់ការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAP-WPS) រួមទាំងការបង្កើតយន្តការសម្របសម្រួល លក្ខខណ្ឌការងារ (TOR) ច្បាស់លាស់ និងដំណើរការសម្រាប់ការចូលរួមរបស់អ្នកពាក់ព័ន្ធដែលប្រកបដោយបរិយាបន្ន។



# ៩. ឧបសម្ព័ន្ធ

## ៩.១. តារាងសង្ខេបបញ្ហាស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គោលនយោបាយ វិធានការ និងគម្លាត

| បញ្ហាស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ | ដែលត្រូវបានដោះស្រាយដោយ គោលនយោបាយ/ផែនការសកម្មភាព បច្ចុប្បន្ន រួមទាំងផែនការនារីរតនៈទី ៦ | តើសកម្មភាព/វិធានការអ្វីខ្លះដែលមាន ឬ តើមានគម្លាតអ្វីខ្លះដែលត្រូវដោះស្រាយ? |
|---|---|---|
| **១. ស្ត្រី និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងវិបត្តិជម្លោះ និងមនុស្សធម៌** | ១.១. ផែនការនារីរតនៈទី៦ ២០២៤-២០២៨ រួមបញ្ចូលយុទ្ធសាស្ត្រទី ៥៖ ការការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី<br>១.២. NAPVAW ទី ៤ ២០២៤-២០៣០ រួមមាន៖<br>- TWGG-GBV ក្រុមការងារ GBV ថ្នាក់ខេត្ត/ស្រុក អង្គភាពច្រកចេញចូលតែមួយ សេវាគាំទ្រតាមទូរស័ព្ទ និងឌីជីថល (ខ្សែទូរស័ព្ទជំនួយ, GBV SafeApp, Chatbot)<br>១.៣ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ<br>- JPA/JPO កិច្ចអន្តរាគមន៍ សេចក្តីសម្រេចចិត្តផ្នែករដ្ឋបាល ដីកាការពារ<br>១.៤. ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាលើកុមារ (NAP VAC) ២០១៧-២០២១/២០២៣ | ១.១.១.ផែនការនារីរតនៈទី ៦ មិនផ្តោតលើអំពើហិង្សាលើស្ត្រីក្នុងបរិបទ WPS នោះទេ។<br>១.១.២. ផែនការនារីរតនៈទី ៦ មិនរួមបញ្ចូលការចូលរួមរបស់ស្ត្រីក្នុងការបោសសម្អាតមីន និងការរក្សាសន្តិភាព និងយុទ្ធសាស្ត្រ និងការវិវត្តក្នុងការដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រនិងផលប៉ះពាល់នៃជំងឺរាតត្បាតលើស្ត្រី និងសន្តិសុខ។<br>១.១.៣. NAPVAW - មិនគ្របដណ្តប់គ្រប់ជ្រុងជ្រោយលើរបៀបវារៈ WPS ជាពិសេសស្ត្រីក្នុងជម្លោះប្រដាប់អាវុធ។<br>១.១.៤. NAPVAW ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងគោលនយោបាយ និងយន្តការជាតិ អាចអនុវត្តបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។<br>១.១.៥. NAPVAW រួមបញ្ចូលក្រុមសីលធម៌ប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ពីអំពើហិង្សាលើស្ត្រី។ |

| | | |
|---|---|---|
| | ១.៥. គោលនយោបាយភូមិ ឃុំ ស្រុកមានសុវត្ថិភាព (VCSP) (២០១០/២០២១)<br>១.៦. យុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សម្រាប់សុខភាព)<br>១.៧ . គោលការណ៍ណែនាំសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយបរិយាបន្ន<br>១.៨. ផែនការសកម្មភាពជាតិ ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០២៤-២០២៨ (NAP-DRR)<br>១.៩. ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ | ១.១.៦. ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ៖ គ្មានបទប្បញ្ញត្តិស្តីពីអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិត។<br>១.១.៧. NAP VAC លើកឡើងពីអំពើហិង្សាលើកុមារ/ក្មេងស្រី រួមទាំងការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមអ៊ីនធឺណិត<br>១.១.៣. VCSP លើកឡើងពីបញ្ហាសន្តិសុខដែលពាក់ព័ន្ធនឹង WPS រួមមានការជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ ការជួញដូរគ្រឿងញៀន និងអំពើហិង្សាបង្កឡើងដោយក្មេងទំនើង ឆ្លើយតបទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ ជំងឺឆ្លង និងជំងឺរាតត្បាត និងដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការប្រកបដោយប្រសិទ្ធភាព។<br>១.១.៩. កញ្ចប់សេវាបឋមអប្បបរមា (MISP) សុខភាពបន្តពូជក្នុងគ្រាវិបត្តិ ដោះស្រាយសេវាសុខភាពផ្លូវភេទ និងបន្តពូជ ក្នុងសកម្មភាពមនុស្សធម៌។ ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមដើម្បីធានាប្រព័ន្ធទប់ស្កាត់/ឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រាអាសន្ន (GBViE)<br>១.១.១០. គោលការណ៍ណែនាំសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយបរិយាបន្ន (MoWA/NCDM)<br>១.១.១១. NAP-DRR រួមបញ្ចូលវិធានការដែលឆ្លើយតបនឹងយេនឌ័រ<br>១.១.១២. ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន (២០២៣) រួមបញ្ចូលអនុក្រឹត្យ ៣ (លេខ ១៥២, ១៥៣, ១៥៤)។ |

| | | |
|---|---|---|
| **២. ស្ត្រី ការជួញដូរ និងបទល្មើសឆ្លងដែន** | ២.១. ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ២០០៨<br>២.២. ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NSP-CTIP) ២០១៩-២០២៣ របស់ NCCT (MoWA ជាអនុប្រធាន)<br>២.៣. ផែនការយុទ្ធសាស្ត្រស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ២០១៨-២០២៣ ដោយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (NACD) (MoWA ជាសមាជិក)<br>២.៤. គោលនយោបាយភូមិ ឃុំ ស្រុក មានសុវត្ថិភាព (២០១០/២០២១)<br>២.៥. គោលនយោបាយការពារជាតិ ២០២២ | ២.១.១. វិធានការ ៖ NCCT NSP-CTIP ២០២៤-២០២៨ ត្រៀមដាក់ឱ្យដំណើរការ និងតម្រូវឱ្យពង្រឹងបន្ថែម ដើម្បីធានាថា វិធានការប្រឆាំងការជួញដូរ ត្រូវបានត្រៀមជាស្រេច ហើយយន្តការកំពុងដំណើរការ (MTR NSP-CTIP)។<br>២.១.២.MoWA ជាប្រធានក្រុមការងារអន្តរជាតិនៃ NCCT។<br>២.១.៣. វិធានការ៖ អនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារស្តីពីការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស (MoSVY)។<br>២.១.៤. វិធានការ ៖ ការចូលរួមរបស់រាជរដ្ឋាភិបាលកម្ពុជាជាមួយ COMMIT<br>២.១.៥. ផែនការយុទ្ធសាស្ត្រស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន ២០២៤-២០២៨ (NACD) ត្រៀមដាក់ឱ្យដំណើរការ។<br>២.១.៦.VCSP លើកឡើងពីបញ្ហាសន្តិសុខដែលពាក់ព័ន្ធនឹង WPS៖ គ្មានការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សា អំពើហិង្សាបង្កឡើងដោយក្មេងទំនើង។<br>២.១.៧. គោលនយោបាយការពារជាតិទទួលស្គាល់ការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន និងសកម្មភាពឆ្លងដែនខុសច្បាប់ផ្សេងទៀតថា ជាការគំរាមកំហែង។ |
| **៣. ស្ត្រី សន្តិភាព និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត*** | ៣.១. អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា នាយកដ្ឋានសន្តិសុខ ICT និង CamCERT (MoPTC)<br>៣.២. អង្គភាពប្រឆាំងបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត (MoI នគរបាលជាតិ)<br>៣.៣. គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ លើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងវិស័យឌីជីថល | ៣.១.១. MoPTC ផ្តល់ការបណ្តុះបណ្តាលមូលដ្ឋានស្តីពី ICT រួមទាំងសម្រាប់ស្ត្រី និងក្រុមងាយរងគ្រោះ។<br>៣.១.២. វិធានការ៖ យុទ្ធនាការសុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត បង្កើនការយល់ដឹងអំពីសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត។<br>៣.១.៣. គម្លាត/ឱកាស៖ បង្កើនអក្ខរកម្មឌីជីថលក្នុងចំណោមស្ត្រី និងនៅតំបន់ជនបទ<br>៣.១.៤. គម្លាត/ឱកាស៖ ពង្រឹងអក្ខរកម្មឌីជីថលសម្រាប់ស្ត្រីក្នុងកងកម្លាំងនគរបាល ដើម្បីប្រយុទ្ធប្រឆាំងបទល្មើស តាមប្រព័ន្ធអ៊ីនធឺណិត |

| | | |
|---|---|---|
| | ៣.៤. ផែនការសកម្មភាពបញ្ជ្រាបយេនឌ័ររបស់ MoPTC ២០១៩-២០២៣ យុទ្ធសាស្ត្រអភិវឌ្ឍន៍ ICT គោលការណ៍ណែនាំស្តីពីការលើកកម្ពស់យេនឌ័រនៅក្នុង CADT<br>៣.៥. ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ មាត្រា ៤៩៤ និង ៤៩៦ ហាមឃាត់ពាក្យសម្តីស្អប់ខ្ពើម<br>៣.៦. គោលនយោបាយការពារជាតិ ២០២២<br>៣.៧. សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងសេចក្តីព្រាងច្បាប់ស្តីពីការការពារទិន្នន័យផ្ទាល់ខ្លួន | ៣.១.៥ គោលនយោបាយការពារជាតិទទួលស្គាល់បទល្មើសតាមប្រព័ន្ធអ៊ីនធឺណិតថាជាការគំរាមកំហែងដល់កម្ពុជា និងតំបន់<br>៣.១.៦ គម្លាត/ឱកាស៖ សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងសេចក្តីព្រាងច្បាប់ស្តីពីការការពារទិន្នន័យផ្ទាល់ខ្លួន ដែលតម្រូវឱ្យមានទស្សនៈវិស័យយេនឌ័រ ដើម្បីធានា និងការពារសិទ្ធិរបស់ស្ត្រី។ |
| **៤. ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី** | ៤.១. រដ្ឋធម្មនុញ្ញកម្ពុជាធានាថា ស្ត្រីស្មើភាពគ្នានឹងបុរស (មាត្រា ៣១ និងមាត្រា ៤៥) ស្របតាម អនុសញ្ញា CEDAW, BPfA, SDG ៥ ស្តីពីសមភាពយេនឌ័រ<br>៤.២. យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១៖ ២០២៤-២០២៨ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩-២០២៣ និង ២០២៤-២០២៨ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ៥.១៖ សមភាពយេនឌ័រ<br>៤.៣. ផែនការនារីរតនៈទី ៦ យុទ្ធសាស្ត្រស្នូល៖ ការបញ្ជ្រាបយេនឌ័រ និងយុទ្ធសាស្ត្រទី ៥ ៖ ស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច<br>៤.៤. កម្មវិធីជាតិសម្រាប់រដ្ឋបាលសាធារណៈ ២០២១-២០៣០ និងគោលការណ៍ណែនាំរបស់ក្រសួងមុខងារសាធារណៈ (MoCS)<br>៤.៥. យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅ រដ្ឋបាលថ្នាក់ក្រោមជាតិ ២០២៤-២០២៨ និងគោលនយោបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១៩ (NCDD) | ៤.១.១. ឱកាស៖ ពង្រឹង និងបង្កើនការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី ស្របតាមកម្មវិធីជាតិសម្រាប់រដ្ឋបាលសាធារណៈ ២០២១-២០៣០ រួមទាំងក្នុងវិស័យ<br>សន្តិសុខ<br>៤.១.២. ឱកាស៖ ភ្ជាប់សកម្មភាព/លទ្ធផលនៃ NAP-WPS ជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSGDs) ជាពិសេសគោលដៅ ៥.១ ៖ សមភាពយេនឌ័រ និងអនុសាសន៍ CEDAW<br>៤.១.៣. ឱកាស ៖ ប្រមូលករណីសិក្សាស្តីពីបុរស និងស្ត្រីគំរូ ដែលគាំទ្រសមភាពយេនឌ័រ ក្នុងរបៀបវារៈ WPS<br>៤.១.៤. គម្លាត/ឱកាស៖ សេចក្តីព្រាងក្របខណ្ឌសេដ្ឋកិច្ចថែទាំ និងផែនការសកម្មភាពដែលផ្តោតលើចំណុចគន្លឹះបួន ៖ ១) ហេដ្ឋារចនាសម្ព័ន្ធថែទាំ ២) សេវាថែទាំ ៣) គោលនយោបាយថែទាំដែលពាក់ព័ន្ធនឹងការងារ និង ៤) កិច្ចគាំពារសង្គមដែលពាក់ព័ន្ធនឹងការថែទាំ។<br>៤.១.៥. ក្រុមសកម្មភាពបញ្ជ្រាបយេនឌ័រតាមវិស័យ (GMAGs) និងផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ (GMAPs) |

| | | |
|---|---|---|
| **៥. ស្ត្រីក្នុងវិស័យ សន្តិសុខ ការទូត អន្តរជាតិ និងកងកម្លាំងរក្សាសន្តិភាព*** | ៥.១. គោលនយោបាយការពារជាតិ ២០២២ (MoND/RCAF)<br>៥.២. គោលនយោបាយបញ្ជ្រាបយេនឌ័ររបស់ MoND ដឹកនាំដោយក្រុមបញ្ជ្រាបយេនឌ័រ<br>៥.៣. មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម (NPMEC)<br>៥.៤. ផែនការសកម្មភាពបញ្ជ្រាបយេនឌ័ររបស់ អគ្គស្នងការដ្ឋាននគរបាលជាតិ ២០១៩-២០២៣ និង ២០២៤-២០២៨<br>៥.៥. អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក) ២០២៣ រួមបញ្ចូលសមភាពយេនឌ័រ និងបញ្ហាស្ត្រីក្នុងគំនិតផ្តួចផ្តើម និងក្របខណ្ឌជាច្រើន<br>៥.៦. យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចរបស់កម្ពុជា ២០២១-២០២៣ (MoFAIC) | ៥.១.១. គោលនយោបាយការពារជាតិប្តេជ្ញាការពារសន្តិភាព សន្តិសុខ និងស្ថិរភាពក្នុងតំបន់ និងរួមចំណែកដល់ UN PKO នៅទូទាំងពិភពលោក។<br>៥.១.២. វិធានការ៖ ឱកាសក្នុងការប្រើប្រាស់ និងគាំទ្រអនុសាសន៍ពីរបាយការណ៍ឆ្នាំ ២០២៣ ស្តីពីលទ្ធផលនៃ MOWIP រួមទាំងការពង្រឹងការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី<br>៥.១.៣. គម្លាត៖ ពង្រឹងគោលនយោបាយស្តីពីការបៀតបៀនផ្លូវភេទ និងប្រព័ន្ធបណ្តឹងផ្ទៃក្នុង នៅក្នុងរដ្ឋាភិបាល<br>៥.១.៤. វិធានការ៖ ឱកាសពង្រឹងការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងកងកម្លាំងនគរបាល ស្របតាមរបៀបវារៈ WPS<br>៥.១.៥.វិធានការ៖ ឱកាសដោះស្រាយបញ្ហារបស់ស្ត្រី និងពង្រឹងការចូលរួមរបស់ស្ត្រីក្នុង អ.ដ.ក។<br>៥.១.៦.វិធានការ៖ ឱកាសបញ្ជ្រាបយេនឌ័រ និងទស្សនៈវិស័យ WPS បន្ថែមទៀតទៅក្នុងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចរបស់កម្ពុជា ២០២៤-២០២៨ (MoFAIC) |
| **៦. ស្ត្រី និងអាកាសធាតុ សន្តិភាព និង សន្តិសុខ*** | ៦.១. ផែនការនារីរតនៈទី ៦ ២០២៤-២០២៨ យុទ្ធសាស្ត្រទី ៦៖ ស្ត្រី និងការប្រែប្រួលអាកាសធាតុ<br>៦.២. ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ២០១៨-២០៣០ (MoWA និង MoEn)<br>៦.៣. បច្ចុប្បន្នភាពការចូលរួមចំណែករបស់ជាតិ (NDC) រួមបញ្ចូលវិធានការផ្តោតលើយេនឌ័រសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ<br>៦.៤. ផែនការយុទ្ធសាស្ត្រយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ២០១៣-២០២៣ ផែនការសកម្មភាពស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ២០១៩-២០២៣ | ៦.១.១. ការបញ្ជ្រាបយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ត្រូវបានរួមបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រ និងគោលនយោបាយរបស់ក្រសួងអាទិភាព ដូចជា ក្រសួងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម ក្រសួងសុខាភិបាល ក្រសួងធនធានទឹក និងក្រសួងសាធារណការ និងដឹកជញ្ជូន។<br>៦.១.២. បច្ចុប្បន្នភាពការចូលរួមចំណែករបស់ជាតិ រួមបញ្ចូលការវាយតម្លៃ និងការពិនិត្យផលប៉ះពាល់យេនឌ័រ។<br>៦.១.៣. វិធានការ៖ NAP-DRR ២០២៤-២០២៨ រួមបញ្ចូលយេនឌ័រ និងបរិយាបន្នមានគោលបំណងពង្រឹងតួនាទីរបស់ស្ត្រីក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ។ |

| | | |
|---|---|---|
| | ៦.៦. គោលការណ៍ណែនាំសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយបរិយាបន្ន ២០២១<br>៦.៧. យុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព ២០២០-២០២៤<br>៦.៨. ក្រុមបរិស្ថាន និងធនធានធម្មជាតិ ២០២៣<br>៦.៩. គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) រួមទាំងតួនាទីរបស់ RCAF ក្នុងជំនួយមនុស្សធម៌ និងការសង្គ្រោះក្នុងគ្រោះមហន្តរាយ។ | ៦.១.៤.វិធានការ៖ យុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព ២០២០-២០២៤ រួមបញ្ចូលកញ្ចប់សេវាបឋមអប្បបរមា (MISP) សុខភាពបន្តពូជក្នុងគ្រាវិបត្តិ និងតម្រូវឱ្យបន្តពង្រឹងការទប់ស្កាត់ និងការគ្រប់គ្រង GBViE។<br>៦.១.៥.គម្លាត៖ ក្រុមបរិស្ថាន និងធនធានធម្មជាតិ ឆ្នាំ ២០២៣ លើកឡើងពីសមភាពយេនឌ័រ និងការចូលរួមរបស់ស្ត្រី និងក្រុមងាយរងគ្រោះ ប៉ុន្តែមិនច្បាស់លាស់ពាក់ព័ន្ធរបៀបវារៈ WPS។ |
| **៧. របៀបវារៈ WPS និងការទទួលបានសន្តិសុខសេដ្ឋកិច្ច ឱកាសប្រកបរបរចិញ្ចឹមជីវិត ធនធានធម្មជាតិ និងសន្តិសុខមនុស្ស** | ៧.១. ផែនការនារីរតនៈទី ៦ ២០២៤-២០២៨៖ យុទ្ធសាស្ត្រទី ១៖ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងយុទ្ធសាស្ត្រទី ៦៖ ស្ត្រី និងការប្រែប្រួលអាកាសធាតុ<br>៧.២. គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ២០១៧-២០២៥ (MoLVT) យុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ២០២៣-២០២៨ (MISTI)<br>៧.៣. ច្បាប់ភូមិបាលឆ្នាំ ២០០១ និងសេចក្តីប្រកាសគោលនយោបាយដីធ្លីឆ្នាំ ២០០៨ រួមបញ្ចូលការផ្លាស់ប្តូរក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ដើម្បីពង្រឹងលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានសិទ្ធិកាន់កាប់ដីធ្លី<br>៧.៤. នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច (MRD) គណៈកម្មាធិការអន្តរក្រសួងសម្រាប់ការអភិវឌ្ឍជនជាតិភាគតិច និងគណៈកម្មាធិការអន្តរក្រសួងសម្រាប់ការអភិវឌ្ឍប្រជាជនតំបន់ខ្ពង់រាប។ | ៧.១.១. ផែនការនារីរតនៈទី ៦៖ យុទ្ធសាស្ត្រទី ១៖ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី លើកឡើងពីបរិស្ថានប្រកបដោយបរិយាបន្ន ការពង្រឹងសហគ្រាសធុនតូច និងមធ្យម និងសហគ្រិនភាព និងសេដ្ឋកិច្ចថែទាំ និងបច្ចេកវិទ្យាឌីជីថល។<br>៧.១.២. គម្លាត៖ គោលនយោបាយជាតិមានយុទ្ធសាស្ត្រយេនឌ័រច្បាស់លាស់ ប៉ុន្តែវិបត្តិកូវីដ-១៩ បានរំលេចភាពចាំបាច់ក្នុងការដោះស្រាយសេដ្ឋកិច្ចថែទាំ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីនៅមុន ក្នុងអំឡុង និងក្រោយវិបត្តិ និងគ្រោះអាសន្ន។<br>៧.១.៣. យន្តការដោះស្រាយវិវាទរបស់ MLMUPC៖ ១) អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី (ដីរដ្ឋ) ២) គណៈកម្មការសុរិយោដី (ដីគ្មានប័ណ្ណកម្មសិទ្ធិ) ៣) ក្រុមដោះស្រាយវិវាទដីធ្លីចល័ត ៤) ក្រុមដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ (២៥ ក្រុម) និង ៥) ក្រុមអធិការកិច្ចសំណង់ (យ៉ាងហោចណាស់មានស្ត្រីមួយភាគបី ចូលរួម)<br>៧.១.៤. GMPSFA ២០២២-២០២៦ ផ្តល់ការវិភាគលម្អិតអំពីយេនឌ័រ និងកសិកម្ម |

| | | |
|---|---|---|
| | ៧.៥. គោលនយោបាយបញ្ជ្រាបយេនឌ័រ និងក្របខណ្ឌយុទ្ធសាស្ត្រក្នុងវិស័យកសិកម្ម (GMPSFA) ២០២២-២០២៦ មានលក្ខណៈផ្លាស់ប្រែយេនឌ័រ (MAFF)<br>៧.៦. ក្រុមបរិស្ថាន និងធនធានធម្មជាតិ (២០២៣) និងយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ (២០១៦-២០២៣) (NESAP) (NCSD)<br>៧.៧. ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពកម្ចាត់មីនលើកទី ៣ ២០២១-២០២៥ ក្រុមបញ្ជ្រាបយេនឌ័រ និងសេចក្តីព្រាងបទដ្ឋានជាតិស្តីពីការបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពកម្ចាត់មីន (CMAA) | ៧.១.៥. NESAP ២០១៦-២០២៣ រួមបញ្ចូលក្រុមងាយរងគ្រោះ ជាពិសេសស្ត្រី កុមារ និងក្រុមជនជាតិភាគតិច ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយវិបត្តិអាកាសធាតុ និងវិបត្តិផ្សេងទៀត។<br>៧.១.៦. គម្លាត៖ សក្តានុពលសម្រាប់ស្ត្រីក្នុងការបង្កើនភាពជាអ្នកដឹកនាំរបស់ពួកគេក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព សហគមន៍ដែលធន់នឹងអាកាសធាតុ និងការពង្រឹងសន្តិភាពនិងស្ថិរភាព។ |
| **៨. ស្ត្រី និងសនិទ្ធពលសង្គម** | ៨.១. គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច (២០០៩)<br>៨.២. កម្មវិធីអប់រំពហុភាសាសម្រាប់សហគមន៍ ជនជាតិដើមភាគតិច (MoEYS)<br>៨.៣. MoEYS គាំទ្រកម្មវិធីអប់រំតាមសាលាសម្រាប់សហគមន៍ខ្មែរអ៊ីស្លាម<br>៨.៤. ផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម (២០១៧-២០២៦)<br>៨.៥. ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣ រួមបញ្ចូលគោលបំណងយុទ្ធសាស្ត្រ ដើម្បីធានាសមភាពយេនឌ័រ<br>៨.៦. NAPVAW រួមបញ្ចូលស្ត្រីស្រឡាញ់ភេទដូចគ្នា ជាក្រុមងាយរងគ្រោះអាទិភាព និងងាយប្រឈមនឹងអំពើហិង្សា<br>៨.៧. ផែនការសកម្មភាពដើម្បីទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះវ័យជំទង់ ក្នុងខេត្តរតនគិរី ២០១៧-២០២១/២០២៣ | ៨.១.១.ក្រុមការងារពិសេសស្តីពីបរិយាបន្នស្ត្រី និងក្មេងស្រីងាយរងគ្រោះ (MoWA)<br>៨.១.២. ក្រុមសកម្មភាពជនពិការ (MoWA) មានកម្មវិធីអភិវឌ្ឍន៍សមត្ថភាពដើម្បីជំរុញតួនាទី និងសិទ្ធិរបស់ស្ត្រី និងជនមានពិការភាព។<br>៨.១.៣. កញ្ចប់បណ្តុះបណ្តាល GEDI លើកឡើងពីភាពប្រទាក់ក្រឡាគ្នារវាងអំពើហិង្សាទាក់ទងនឹងយេនឌ័រនិងពិការភាព។<br>៨.១.៤. គម្លាត/ឱកាស- គ្មានច្បាប់ ឬគោលនយោបាយប្រឆាំងការរើសអើង ដើម្បីទប់ស្កាត់ការរើសអើង និងពាក្យសម្តីស្អប់ខ្ពើម ការរករឿងរំខាន និងការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណិតដែលផ្តោតគោលដៅ លើក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា (LGBTIQ+)។<br>៨.១.៥. គម្លាត/ឱកាស៖ បង្កើតផែនការសកម្មភាពជាតិ ដើម្បីទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះវ័យជំទង់ (២០២៤-២០៣០)។ |

## ៩.២. បញ្ជីឯកសារដែលបានពិនិត្យ

- របៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព / គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព អង្គការសហប្រជាជាតិ, នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គម, អាចស្វែងរកបាននៅ៖ https://sdgs.un.org/goals

- ការជំរុញរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក (ឆ្នាំ២០២២-២០២៧) (សង្ខេប) អង្គការ UN WOMEN។ អាចស្វែងរកបាននៅ៖ https://asiapacific.unwomen.org/en/digital-library/publications/2023/03/peace-and-security-agenda-in-asia-pacific

- សេចក្តីសង្ខេបនៃការស្វែងរកការគាំទ្រមតិ៖ សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិតក្នុងបរិបទនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ, ការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក (ROAP) អង្គការ UN WOMEN ឆ្នាំ២០២២។ អាចស្វែងរកបាននៅ៖ https://asiapacific.unwomen.org/sites/default/files/2022-09/ap-Advocacy-Brief-Peace-and-Cybersecurity-v03.pdf

- សៀវភៅណែនាំជាសកល៖ សភាជាដៃគូគាំទ្ររបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ, កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ, ឆ្នាំ២០១៩

- អាស៊ាន, ការសិក្សាថ្នាក់តំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខឆ្នាំ២០២១, អាស៊ាន, ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ, ភាពជាដៃគូសម្រាប់ការធ្វើឱ្យប្រសើរបំផុតថ្នាក់តំបន់ ជាមួយសហគមន៍នយោបាយ-សន្តិសុខ និងសង្គម-វប្បធម៌ (PROSPECT) និងអង្គការ UN WOMEN ខែមីនា ឆ្នាំ២០២០។ អាចស្វែងរកបាននៅ៖

- ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ, ហ្សាការតា, លេខាធិការដ្ឋានអាស៊ាន ខែធ្នូ ឆ្នាំ២០២២។ អាចស្វែងរកបាននៅ៖

- អាស៊ាន, កញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំស្តីពីការធ្វើមូលដ្ឋានីយកម្មសម្រាប់ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ, ហ្សាការតា, លេខាធិការដ្ឋានអាស៊ាន ខែធ្នូ ឆ្នាំ២០២៣។ អាចស្វែងរកបាននៅ៖

- ពិព័រណ៍រូបថតអាស៊ាន៖ សន្តិភាពរួមគ្នា។ អាចស្វែងរកបាននៅ៖ https://wps.asean.org/photo-exhibition-peace-together/#opening-gallery

- សេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងប៉េកាំង (ឆ្នាំ១៩៩៥) និងសេចក្តីប្រកាសនយោបាយ និងលទ្ធផលទីក្រុងប៉េកាំង+៥, អង្គការ UN Women, អង្គការសហប្រជាជាតិ ឆ្នាំ១៩៩៥ អាចស្វែងរកបាននៅ៖ https://www.unwomen.org/sites/default/files/Headquarters/Attachments/Sections/CSW/PFA_E_Final_WEB.pdf

- វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (ឆ្នាំ២០២០). អភិបាលកិច្ចតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា៖ អភិក្រមផ្តោតលើហានិភ័យចំពោះសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត របាយការណ៍ពិសេសលេខ១៨, វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា, ខែមករា ឆ្នាំ២០២០

- វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (ឆ្នាំ២០២៤). ស្ថានភាពរបស់ស្ត្រីនៅក្នុង រដ្ឋាភិបាលឃុំ/សង្កាត់។ សេចក្តីសង្ខេបលទ្ធផលពីការសិក្សារបស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាស្តីពីស្ថានភាពនៃអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា៖ គណនេយ្យភាព ភាពជាតំណាង និងការឆ្លើយតប, វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា, ខែមិថុនា ឆ្នាំ២០២៤

-   អនុសាសន៍ទូទៅលេខ៣០ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW), ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ឆ្នាំ២០១៣)។ អាចស្វែងរកបាននៅ៖ https://www.unwomen.org/en/digital-library/publications/2015/8/guidebook-cedawgeneralrecommendation30-women-peacesecurity

-   អនុសាសន៍ទូទៅលេខ៣៧ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) ស្តីពីវិមាត្រយេនឌ័រក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ (ឆ្នាំ២០១៨)។ អាចស្វែងរកបាននៅ៖ https://www.ohchr.org/en/documents/general-comments-and-recommendations/general-recommendation-no37-2018-gender-related

-   អនុសាសន៍ទូទៅលេខ៤០ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW), ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ឆ្នាំ២០២៤), (សេចក្តីព្រាង)។ អាចស្វែងរកបាននៅ៖ https://www.ohchr.org/en/documents/general-comments-and-recommendations/draft-general-recommendation-no-40-equal-and

-   ការគំរាមកំហែងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត ភាពងាយរងគ្រោះ និងភាពធន់ក្នុងចំណោមអ្នកការពារសិទ្ធិមនុស្សរបស់ស្ត្រី និងសង្គមស៊ីវិលនៅអាស៊ីអាគ្នេយ៍ សេចក្តីសង្ខេបការស្រាវជ្រាវ, UNU Macao និងអង្គការ UN Women ខែ ឧសភា ឆ្នាំ ២០២៤

-   ច្បាប់ការពារទិន្នន័យនៃពិភពលោក, កម្ពុជា DLA Piper, ១៨ មករា ២០២៤។

-   របាយការណ៍អង្កេតចុងក្រោយ ការវាយតម្លៃរហ័សលើផលប៉ះពាល់សង្គម និងសុខភាពដោយសារជំងឺកូវីដ-១៩ ក្នុងចំណោមពលករចំណាកស្រុកនៅកម្ពុជាដែលវិលត្រឡប់មកវិញ ខែ វិច្ឆិកា ឆ្នាំ ២០២០, NCCT និងមូលនិធិអង្គការសហប្រជាជាតិសម្រាប់ការឆ្លើយតប និងស្តារឡើងវិញពីវិបត្តិកូវីដ-១៩

-   (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០២២) គោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្រ ស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ឆ្នាំ២០២២-២០២៦, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០២២។

-   យេនឌ័រ សន្តិភាព និងសន្តិសុខក្នុងការគ្រប់គ្រងធនធានធម្មជាតិ៖ ការគ្រប់គ្រងដី ព្រៃឈើ និងទឹកនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក (សេចក្តីសង្ខេបការស្រាវជ្រាវ), អង្គការ UN WOMEN, ខែធ្នូ ឆ្នាំ២០២២។ អាចស្វែងរកបាននៅ៖ https://asiapacific.unwomen.org/sites/default/files/2022-12/ap-Gender-Peace-NRM-Research-Brief-s.pdf

-   សៀវភៅណែនាំ ស្តីពី អនុសាសន៍ទូទៅលេខ៣០ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ, អង្គការ UN WOMEN, ឆ្នាំ២០១៥

-   (Hennings, A. and Pen R., ២៨ មករា ២០២១)។ កម្ពុជា-បរិបទ និងអភិបាលកិច្ចដីធ្លី។ អាចស្វែងរកបាននៅ៖ https://landportal.org/book/narratives/2021/cambodia#:

-   (Jacevic ២០២២) ឆ្ពោះទៅកាន់ការអនុវត្តពេញលេញនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS) នៅវៀតណាម, របាយការណ៍ដើម្បីរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយសក្តានុពលនៃផែនការសកម្មភាពជាតិលើកដំបូងរបស់វៀតណាម ស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ។ Mirsad Miki Jacevic, ការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក (ROAP) អង្គការ UN WOMEN, ខែធ្នូ ឆ្នាំ២០២២

- ការវិភាគផ្លូវច្បាប់៖ សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត, Access Now និងតុលាការអន្តរជាតិនៃយុត្តិវិទូ, ២៩ កញ្ញា ២០២៣។ អាចរកបាននៅ https://www.accessnow.org/wp-content/uploads/2023/10/Legal-Analysis-Cambodia-Cybersecurity-Draft-Law-Final-29-Sept.pdf

- របាយការណ៍ឆ្នាំ២០២៣ ស្តីពី លទ្ធផលនៃការវាស់ស្ទង់ឱកាសសម្រាប់ស្ត្រីនៅក្នុងប្រតិបត្តិការរក្សាសន្តិភាព (MOWIP) កងយោធពលខេមរភូមិន្ទ មជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម, មជ្ឈមណ្ឌលសិក្សាបណ្តុះបណ្តាលកសាងសន្តិភាព និងដោះស្រាយទំនាស់, ជាមួយមន្ទីរពិសោធន៍GSS, មជ្ឈមណ្ឌលសម្រាប់អភិបាលកិច្ចវិស័យសន្តិសុខនៅទីក្រុងហ្សឺណែវ (DCAF), ផ្តល់មូលនិធិដោយមូលនិធិគំនិតផ្តួចផ្តើម Elsie។ អាចស្វែងរកបាននៅ៖

- Ngin,C. & Neef, A. (ឆ្នាំ២០២១)។ ដំណើរការបដិទានដីធ្លីដែលមានជម្លោះនៅកម្ពុជា។ អាចស្វែងរកបាននៅ៖ https://www.mdpi.com/2073-445X/10/5/482#:

- FAO ២០២៤ សាវតារយេនឌ័រថ្នាក់ជាតិនៃវិស័យកសិកម្ម និងរបរចិញ្ចឹមជីវិតជនបទនៅកម្ពុជា។ កម្រងឯកសារវាយតម្លៃយេនឌ័រថ្នាក់ប្រទេសទីក្រុងភ្នំពេញអាចរកបានតាម៖ https://openknowledge.fao.org/items/fc50b8f7-94b7-4fda-a768-7be21025e513

- ទិដ្ឋភាពទូទៅនៃក្របខណ្ឌតំបន់ឆ្ពោះទៅរកសង្គមប្រកបដោយសន្តិភាព និងបរិយាបន្ន៖ ការជំរុញរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក (សង្ខេប), អង្គការ UN WOMEN។ អាចរកបានតាម https://asiapacific.unwomen.org/en/digital-library/publications/2023/05/advancing-the-women-peace-and-security-agenda-and-inclusive-governance

- ការទប់ស្កាត់ជម្លោះ, បរិវត្តកម្មយុត្តិធម៌, ការធានាសន្តិភាព៖ ការសិក្សាជាសកលស្តីពីការអនុវត្តសេចក្តីសម្រេចលេខ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ, អង្គការ UN WOMEN ឆ្នាំ២០១៥ https://wps.unwomen.org/about/

- បច្ចុប្បន្នភាពស្ថានភាព ៖ ការបៀតបៀនក្នុងបណ្តាញសង្គមនៅកម្ពុជា, LICADHO ខែ វិច្ឆិកា ឆ្នាំ ២០២១

- ការបង្កើតផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ៖ ទស្សនវិស័យ និងមេរៀនដែលទទួលបាន, អង្គការ UN WOMEN, ខែមិថុនា ឆ្នាំ២០២៣។ ប្រភព៖ https://asiapacific.unwomen.org/en/digital-library/publications/2023/07/the-making-of-the-asean-regional-plan-of-action-on-women-peace-and-security-insights-and-lessons-learned

- តាមរយៈកែវឆ្លុះ៖ សុវត្ថិភាពឌីជីថល និងសេរីភាពអ៊ីនធឺណិតនៅតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍, EngageMedia និងមូលនិធិបច្ចេកវិទ្យាឯកជនភាព Oxen, ខែមិថុនា ឆ្នាំ២០២២។ អាចស្វែងរកបាននៅ៖ https://engagemedia.org/wp-content/uploads/2023/06/EngageMedia_Report-GIF-Report_06062023.pdf

- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ៖ សេចក្តីសម្រេចលេខ១៣២៥ (ឆ្នាំ២០០០) សេចក្តីសម្រេចលេខ១៨២០ (ឆ្នាំ២០០៨) សេចក្តីសម្រេចលេខ១៨៨៨ និង១៨៨៩ (ឆ្នាំ២០០៩) សេចក្តីសម្រេចលេខ១៩៦០ (ឆ្នាំ២០១០) សេចក្តីសម្រេចលេខ២១០៦ និង២១២២ (ឆ្នាំ២០១៣) សេចក្តីសម្រេចលេខ២២៤២ (ឆ្នាំ២០១៥) សេចក្តីសម្រេចលេខ២៤៦៧ និង២៤៩៣ (ឆ្នាំ២០១៩) សេចក្តីសម្រេចលេខ២៥៣៨ (ឆ្នាំ២០២០)

- ក្របខណ្ឌសហប្រតិបត្តិការអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០២៤-២០២៨ របស់អង្គការសហប្រជាជាតិសម្រាប់កម្ពុជា, ខែមីនា ឆ្នាំ២០២៤។ អាចស្វែងរកបាននៅ៖ https://cambodia.un.org/en/252482-united-nations-sustainable-development-cooperation-framework-2024-2028

- វីដេអូស្តីពីផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ https://wps.asean.org/video/aseans-regional-plan-of-action-on-women-peace-and-security/

- សំឡេង និងការមើលឃើញ៖ ការស្វែងរកដែលមានការចូលរួមនៃសិទ្ធិមនុស្សរបស់ស្ត្រីជនជាតិភាគតិចនៅកម្ពុជា, អង្គការនារីដើម្បីសន្តិភាព, ខែមករា ឆ្នាំ២០២៤

- ស្ត្រីក្នុងការអនុវត្តច្បាប់នៅតំបន់អាស៊ាន, របាយការណ៍សង្ខេប, អង្គការអាំងទែប៉ូល, ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) និងអង្គការ UN WOMEN ឆ្នាំ២០២០

- ស្ត្រី សន្តិភាព និងសន្តិសុខនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ២០ឆ្នាំក្រោយ៖ ការរីកចម្រើន និងមេរៀនដែលទទួលបាន, អង្គការ UN WOMEN ឆ្នាំ២០២០

- ស្ត្រី សន្តិភាព និងសន្តិសុខ និងជំងឺកូវីដ១៩នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក, សេចក្តីសង្ខេបសកម្មភាព, អង្គការ UN WOMEN

- ស្ត្រី សន្តិភាព និងសន្តិសុខអាកាសធាតុក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក សេចក្តីសង្ខេប អង្គការ UN Women ឆ្នាំ ២០២៤

- អង្គការ UN WOMEN និងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (ឆ្នាំ២០២១)។ ស្ថានភាពនៃសមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុនៅកម្ពុជា អង្គការ UN WOMEN និងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០២១

- ឯកសារទស្សនទាន៖ កិច្ចសន្ទនាអន្តរកម្មជាមួយអង្គការសង្គមស៊ីវិលស្តីពីការជំរុញរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ និងកំណត់ត្រាសិក្ខាសាលា។ អង្គការ UN WOMEN កម្ពុជា,  អង្គការនារីដើម្បីសន្តិភាព, និងសម្ព័ន្ធដើម្បីការផ្លាស់ប្តូរជម្លោះ។

- ឯកសារទស្សនទាន៖ ការដាក់ឱ្យដំណើរការកញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំស្តីពីការធ្វើមូលដ្ឋានីយកម្មសម្រាប់ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងសិក្ខាសាលាលើកកម្ពស់ការយល់ដឹងស្តីពីការធ្វើមូលដ្ឋានីយកម្មនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា ថ្ងៃទី១៤-១៥ ខែធ្នូ ឆ្នាំ២០២៣ រាជធានីភ្នំពេញ និងកំណត់ត្រាសិក្ខាសាលា។ ក្រសួងកិច្ចការនារី អង្គការ UN WOMEN និងគណៈកម្មាធិការអាស៊ានទទួលបន្ទុកកិច្ចការស្ត្រី ឆ្នាំ២០២៣

- សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារបច្ចេកទេសនៃក្រសួងកិច្ចការនារីសម្រាប់ការរៀបចំផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ, រដ្ឋមន្ត្រីក្រសួងកិច្ចការនារី, ខែមេសា ឆ្នាំ២០២៤

**គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការជាតិរបស់កម្ពុជាដែលទាក់ទងនឹងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ៖**

- របាយការណ៍តាមកាលកំណត់លើកទី៦ ដែលដាក់ជូនដោយកម្ពុជាក្រោមមាត្រា១៨នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(CEDAW) ដែលត្រូវដាក់ជូននៅឆ្នាំ២០១៧ (កាលបរិច្ឆេទទទួល៖ ១២ មិថុនា ២០១៨) (CEDAW/C/KHM/CO/6; ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៨)

- សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) លើរបាយការណ៍តាមកាលកំណត់លើកទី៦របស់កម្ពុជា ១៤ វិច្ឆិកា ២០១៩ (CEDAW/C/KHM/CO/6)

- ក្រសួងកិច្ចការនារី ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ឆ្នាំ២០១៩-២០២៣ ស្តីពីការពង្រឹងការបញ្ជ្រាបយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី

- ក្រសួងកិច្ចការនារី, ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ឆ្នាំ២០២៤-២០២៨, ស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី និងក្មេងស្រី

- ក្រសួងកិច្ចការនារីរបាយការណ៍វាយតម្លៃចុងក្រោយនៃផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣ (NAPVAW III), ភ្នំពេញ, ខែឧសភា ឆ្នាំ២០២៣

- ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ (NAPVAW III) រៀបចំដោយ ក្រសួងកិច្ចការនារី រាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស, ផែនការសកម្មភាពជាតិស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨, ភ្នំពេញ, ខែមិថុនា ឆ្នាំ២០២៤។ អាចស្វែងរកបាននៅ៖ https://download.ncct.gov.kh/plans/ncct-action-plan-2024-2028-en.pdf

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស, ផែនការយុទ្ធសាស្ត្រជាតិប្រាំឆ្នាំស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០១៩-២០២៣, ការពិនិត្យពាក់កណ្តាលអាណត្តិ, ភ្នំពេញ, ខែមីនា ឆ្នាំ២០២២។ អាចស្វែងរកបាននៅ៖ https://winrock.org/wp-content/uploads/2022/05/2022_NSPTIP-MID-TERM-REVIEW_FINAL-REPORT_EN.pdf

- កងយោធពលខេមរភូមិន្ទ, គោលនយោបាយការពារជាតិឆ្នាំ២០២២, ក្រសួងការពារជាតិ

- រាជរដ្ឋាភិបាលកម្ពុជា, យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ (ឆ្នាំ២០១៩-២០២៣), ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព៖ កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០, ភ្នំពេញ, ខែកញ្ញា ឆ្នាំ២០១៨

- រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ (ឆ្នាំ២០២៤-២០២៨) ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព៖ កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០, ភ្នំពេញ, ខែសីហា ឆ្នាំ២០២៣

- រាជរដ្ឋាភិបាលកម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣, ក្រសួងផែនការ, ភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩

- រាជរដ្ឋាភិបាលកម្ពុជា, ការពិនិត្យពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣, ភ្នំពេញ, ខែតុលា ឆ្នាំ២០២២

- (របាយការណ៍ជាតិកម្ពុជា, BPfA+30). រាជរដ្ឋាភិបាលកម្ពុជា, របាយការណ៍ជាតិកម្ពុជា ក្នុងឱកាសខួបលើកទី៣០ នៃសន្និសីទពិភពលោកលើកទី៤ស្តីពីស្ត្រី និងការអនុម័តសេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងប៉េកាំង (ឆ្នាំ១៩៩៥), ក្រសួងកិច្ចការនារី ភ្នំពេញ ខែមិថុនា ឆ្នាំ២០២៤

- (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០). គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព កម្ពុជា ឆ្នាំ២០១៦-២០៣០, បញ្ជីគោលដៅ និងសូចនាករដែលបានកែសម្រួលតាមគោលដៅនីមួយៗ, ក្រសួងផែនការ រាជរដ្ឋាភិបាលកម្ពុជា, ខែកក្កដា ឆ្នាំ២០២២

- (ការពិនិត្យជាសកលតាមកាលកំណត់របស់កម្ពុជាឆ្នាំ២០២៤). របាយការណ៍ជាតិដាក់ជូនដោយអនុលោមតាមសេចក្តីសម្រេចលេខ ៥/១ និង១៦/២១ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស, កម្ពុជា, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤។ ក្រុមការងារក្រុមប្រឹក្សាសិទ្ធិមនុស្សស្តីពីការពិនិត្យជាសកលតាមកាលកំណត់, សម័យប្រជុំលើកទី៤៦, ថ្ងៃទី២៩ ខែមេសា ដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ (A/HRC/WG.6/46/KHM/1)

- (របាយការណ៍ពិនិត្យតាមដានថ្នាក់ជាតិដោយស្ម័គ្រចិត្តរបស់កម្ពុជាឆ្នាំ២០២៣), រាជរដ្ឋាភិបាលកម្ពុជា របាយការណ៍ពិនិត្យតាមដានថ្នាក់ជាតិដោយស្ម័គ្រចិត្តរបស់កម្ពុជាឆ្នាំ២០២៣, ស្តីពីការបង្កើនល្បឿនការស្តារឡើងវិញពីជំងឺកូវីដ១៩ និងការអនុវត្តពេញលេញនូវរបៀបវារៈឆ្នាំ២០៣០, ខែមិថុនា ឆ្នាំ២០២៣

## ៩.៣ បញ្ជីអ្នកពាក់ព័ន្ធដែលបានពិគ្រោះយោបល់

| ១. សិក្ខាសាលាពិគ្រោះយោបល់ ៖ ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០២៤ | សរុប | ស្ត្រី | បុរស | កំណត់សម្គាល់ |
|---|---|---|---|---|
| **ក្រុមអ្នកពាក់ព័ន្ធ** | **៥០** | **៣៩** | **១១** | |
| ក្រសួង និងស្ថាប័នរដ្ឋាភិបាល | ១៧ | ១១ | ៦ | ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងយុត្តិធម៌ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មជ្ឈមណ្ឌលកម្ពុជាសកម្មភាពកំចាត់មីន មជ្ឈមណ្ឌលជាតិ គ្រប់គ្រងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| ក្រសួងកិច្ចការនារី | ១៨ | ១៤ | ៤ | អ្នកចូលរួម និងឡជីស្ទិក |
| អង្គការមិនមែនរដ្ឋាភិបាល/ អង្គការសង្គមស៊ីវិល | ៦ | ៥ | ១ | អង្គការក្រុមការងារដោះស្រាយទំនាស់ វិទ្យាស្ថាន Raoul Wallenberg អង្គការសីលការ មូលនិធិអាស៊ី អង្គការតម្លាភាពអន្តរជាតិ អង្គការនារីដើម្បីសន្តិភាព |
| ទីភ្នាក់ងារអង្គការសហប្រជាជាតិ | ៥ | ៥ | ០ | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិ អង្គភាពអង្គការសហប្រជាជាតិសម្រាប់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី |
| ក្រុមទីប្រឹក្សា/អង្គការ UN Women | ៤ | ៤ | ០ | អ្នកសម្របសម្រួល/ឡជីស្ទិក |

| ២.សិក្ខាសាលា ៖ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០២៤ | សរុប | ស្រ្តី | បុរស | កំណត់សម្គាល់ |
|---|---|---|---|---|
| **ក្រុមអ្នកពាក់ព័ន្ធ** | **៧១** | **៦៣** | **៨** | |
| ក្រសួង និងស្ថាប័នរដ្ឋាភិបាល | ៣៣ | ២៩ | ៤ | ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងយុត្តិធម៌ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មជ្ឈមណ្ឌលកម្ពុជាសកម្មភាពកំចាត់មីន មជ្ឈមណ្ឌលជាតិ គ្រប់គ្រងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងពាណិជ្ជកម្ម មន្ទីរកិច្ចការនារីខេត្តស្វាយរៀង |
| ក្រសួងកិច្ចការនារី | ១៥ | ១៤ | ៤ | អ្នកចូលរួម និងឡជីស្ទិក |
| អង្គការមិនមែនរដ្ឋាភិបាល/ អង្គការសង្គមស៊ីវិល | ៩ | ៨ | ១ | សម្ព័ន្ធដើម្បីការផ្លាស់ប្តូរជម្លោះ Breakthrough GAD/C អង្គការក្តីករុណា អង្គការសីលការ មូលនិធិអាស៊ី អង្គការនារីដើម្បីសន្តិភាព |
| ទីភ្នាក់ងារអង្គការសហប្រជាជាតិ | ៨ | ៧ | ១ | UNFPA UNOHCHR UN Women ស្ថានទូតអាមេរិក ស្ថានទូតអង់គ្លេស |
| ក្រុមទីប្រឹក្សា/អង្គការ UN Women | ៦ | ៦ | ០ | អ្នកសម្របសម្រួល/ឡជីស្ទិក |

| ៣. ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់/ការពិភាក្សាក្រុមគោលដៅនៅថ្នាក់ជាតិ | សរុប | ស្ត្រី | បុរស | កំណត់សម្គាល់ |
|---|---|---|---|---|
| **ក្រុមអ្នកពាក់ព័ន្ធ** | **៩១** | **៦៩** | **២២** | |
| ក្រសួង/ស្ថាប័នរដ្ឋាភិបាល | ៣៧ | ៣១ | ៦ | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| រដ្ឋសភា/ឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ | ២ | ២ | ០ | ថ្នាក់ដឹកនាំជាន់ខ្ពស់ជាស្ត្រី |
| ស្ថានទូត/ដៃគូអភិវឌ្ឍន៍ | ៩ | ៥ | ៤ | កាណាដា ចក្រភពអង់គ្លេស អូស្ត្រាលី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល | ៤ | ៣ | ១ | អង្គការនារីដើម្បីសន្តិភាព មូលនិធិអាស៊ី អង្គការអាក់សិនអេតកម្ពុជា អង្គការក្តីករុណា |
| ស្ថាប័នសិក្សា/ស្រាវជ្រាវ | ២ | ១ | ០ | មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវនីតិមនុស្សធម៌ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| ការពិភាក្សាក្រុមគោលដៅជាមួយនគរបាលជាតិ / ក្រសួងមហាផ្ទៃ | ៨ | ៨ | ០ | នគរបាលជាស្ត្រី |
| ការពិភាក្សាក្រុមគោលដៅជាមួយក្រុមយុវជន | ៨ | ៥ | ៣ | ការពិភាក្សាក្រុមគោលដៅដាច់ដោយឡែកសម្រាប់ស្ត្រី/បុរស |
| ការពិភាក្សាក្រុមគោលដៅជាមួយក្រុម LGBTQI+ | ៦ | ៥ | ១ | |
| ការពិភាក្សាក្រុមគោលដៅជាមួយកងកម្លាំងរក្សាសន្តិភាព | ១២ | ៦ | ៦ | ការពិភាក្សាក្រុមគោលដៅដាច់ដោយឡែកសម្រាប់ស្ត្រី/បុរស |
| ការពិភាក្សាក្រុមគោលដៅជាមួយពលករទេសន្តរប្រវេសន៍ជាស្ត្រី | ៣ | ៣ | ០ | ខេត្តសៀមរាប និងរាជធានីភ្នំពេញ |

| ៤. ការសម្ភាសន៍អ្នកផ្ដល់ព័ត៌មានសំខាន់/ការពិភាក្សាក្រុមគោលដៅនៅថ្នាក់ក្រោមជាតិ | សរុប | ស្ត្រី | បុរស | កំណត់សម្គាល់ |
|---|---|---|---|---|
| **ក្រុមអ្នកពាក់ព័ន្ធ** | **១០៧** | **៩៧** | **១០** | |
| គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត | ១៦ | ១៥ | ១ | ខេត្តមណ្ឌលគិរី ស្វាយរៀង កំពង់ឆ្នាំង |
| គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារថ្នាក់ស្រុកនិងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ | ២២ | ២០ | ២ | ១ ស្រុក/ខេត្ត ៣-៤ គណៈកម្មការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ |
| អាជ្ញាធរភូមិ | ១៣ | ១៣ | ០ | ស្ត្រីទាំងអស់ |
| ការពិភាក្សាក្រុមគោលដៅជាមួយស្ត្រីជនជាតិដើមភាគតិច | ១៦ | ១៦ | ០ | ខេត្តមណ្ឌលគិរី (២ ក្រុម) |
| ការពិភាក្សាក្រុមគោលដៅជាមួយស្ត្រីជនបទ | ១៤ | ១៤ | ០ | ខេត្តស្វាយរៀង និងកំពង់ឆ្នាំង |
| ការពិភាក្សាក្រុមគោលដៅជាមួយក្រុមយុវជន | ១៨ | ១១ | ៧ | ការពិភាក្សាក្រុមគោលដៅដាច់ដោយឡែកសម្រាប់ស្ត្រី និងបុរស |
| ការពិភាក្សាក្រុមគោលដៅជាមួយស្ត្រីខ្មែរអ៊ីស្លាម | ៨ | ៨ | ០ | ខេត្តកំពង់ឆ្នាំង |

## ៩.៤. សេចក្ដីសង្ខេបនៃសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ស្ដីពី ស្ត្រី សន្តិភាព និងសន្តិសុខ អនុសាសន៍ទូទៅលេខ ៣០ និង ៣៧ នៃអនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងផែនការសកម្មភាពទីក្រុងប៉េកាំង

| សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ | ការពិពណ៌នា |
|---|---|
| ១៣២៥ (២០០០) | លើកកម្ពស់ស្ត្រីជាអ្នកចូលរួមដោយស្មើភាពក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃសន្តិភាព និងសន្តិសុខអន្តរជាតិ និងបង្ហាញពីការកំណត់គោលដៅលើស្ត្រីដែលនៅតែបន្តសម្រាប់ការរំលោភបំពាននៅក្នុងស្ថានភាពជម្លោះ |
| ១៨២០ (២០០៨) | ទទួលស្គាល់អំពើហិង្សាផ្លូវភេទទាក់ទងនឹងជម្លោះ ថាជាយុទ្ធសាស្ត្រនៃសង្គ្រាម អំពាវនាវឱ្យមានការបណ្ដុះបណ្ដាលកងពលអំពីអំពើហិង្សាទាក់ទងនឹងលើយេនឌ័រ និងរួមបញ្ចូលស្ត្រីកាន់តែច្រើនទៅក្នុងប្រតិបត្តិការសន្តិភាព |
| ១៨៨៨ (២០០៩) | អំពាវនាវឱ្យមានការដាក់ពង្រាយអ្នកជំនាញយោធា និងយេនឌ័រទៅតំបន់ជម្លោះ និងឱ្យមានការកែលម្អឱ្យកាន់តែប្រសើរឡើងនូវការតាមដាន និងការរាយការណ៍ |
| ១៨៨៩ (២០០៩) | អំពាវនាវឱ្យមានសូចនាករសកលលើសេចក្ដីសម្រេចលេខ ១៣២៥ និងកែលម្អការឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រីនៅក្នុងបរិបទនៃជម្លោះ និងក្រោយជម្លោះ |
| ១៩៦០ (២០១០) | អំពាវនាវឱ្យបញ្ចប់អំពើហិង្សាផ្លូវភេទនៅក្នុងជម្លោះប្រដាប់អាវុធ និងផ្ដល់វិធានការដើម្បីបញ្ចប់និទណ្ឌភាពសម្រាប់ជនប្រព្រឹត្តអំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| ២១០៦ (២០១៣) | ផ្ដល់ការណែនាំប្រតិបត្តិការ ស្ដីពីការដោះស្រាយអំពើហិង្សាទាក់ទងនឹងលើយេនឌ័រនិងអំពាវនាវឱ្យមានទីប្រឹក្សានៃកិច្ចការពារស្ត្រី |
| ២១២២ (២០១៣) | អំពាវនាវឱ្យមានការចូលរួមរបស់ស្ត្រីនៅក្នុងការចរចាសន្តិភាព បង្កើនធនធានសម្រាប់ស្ត្រីនៅក្នុងតំបន់ជម្លោះ និងទទួលស្គាល់សង្គមស៊ីវិល |
| ២២៤២ (២០១៥) | គូសបញ្ជាក់ពីតួនាទីរបស់ស្ត្រីនៅក្នុងការប្រឆាំងនឹងលទ្ធិជ្រុលនិយមហិង្សា និងតួនាទីរបស់ស្ត្រីនៅក្នុងវិស័យថ្មីៗផ្សេងទៀត |
| ២៤៦៧ (២០១៩) | ទទួលស្គាល់អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងជម្លោះ និងតម្រូវការអភិក្រមដែលផ្ដោតការយកចិត្តទុកដាក់ចំពោះជនរងគ្រោះ និងការផ្ដល់អាទិភាពដល់ក្រុមងាយរងគ្រោះ |
| ២៤៩៣ (២០១៩) | ជំរុញឱ្យសមាជិកប្ដេជ្ញាឡើងវិញចំពោះរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ និងអំពាវនាវឱ្យមានការចូលរួមស្មើភាពរបស់ស្ត្រី ក្នុងការដោះស្រាយអំពើហិង្សាទាក់ទងនឹងលើយេនឌ័រ និងនៅក្នុងការរក្សាសន្តិភាព |
| ២៥៣៨ (២០២០) | អំពាវនាវឱ្យមានការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីពាក់ឯកសណ្ឋាន និងស្ត្រីស៊ីវិល នៅក្នុងប្រតិបត្តិការកងកម្លាំងរក្សាសន្តិភាព |

*ប្រភព ៖ ដកស្រង់ចេញពីកញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំស្ដីពីការធ្វើមូលដ្ឋានីយកម្មផែនការសកម្មភាពតំបន់អាស៊ាន ស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ*

| អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ | ការពិពណ៌នា |
|---|---|
| អនុសាសន៍ទូទៅលេខ ៣០ (២០១៣) | ស្តីពីស្ត្រីក្នុងការទប់ស្កាត់ជម្លោះ ស្ថានភាពជម្លោះ និងក្រោយជម្លោះ ចង្អុលបង្ហាញពីកាតព្វកិច្ចជាក់លាក់របស់រដ្ឋជាសមាជិកក្នុងការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី នៅក្នុងស្ថានភាពទាក់ទងនឹងជម្លោះ |
| អនុសាសន៍ទូទៅលេខ ៣៧ (២០១៨) | ស្តីពីវិមាត្រទាក់ទងនឹងយេនឌ័រនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ អំពាវនាវឱ្យមានវិធានការប្រកបដោយប្រសិទ្ធភាពដើម្បីបង្ការទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ និងធានាថាសិទ្ធិមនុស្សរបស់ស្ត្រីត្រូវបានការពារ គោរព និងអនុវត្ត |
| សេចក្តីព្រាងអនុសាសន៍ទូទៅលេខ ៤០ (២០២៤) | ស្តីពីភាពជាតំណាងដោយស្មើភាព និងបរិយាបន្នរបស់ស្ត្រីនៅក្នុងប្រព័ន្ធធ្វើសេចក្តីសម្រេចចិត្ត អំពាវនាវឱ្យមានសមភាពនៅក្នុងទិដ្ឋភាពនៃការធ្វើសេចក្តីសម្រេចចិត្ត រួមទាំងក្នុងការបង្ការទប់ស្កាត់ជម្លោះ ការកសាងសង្គមដែលមានភាពធន់ និងកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងឡើងវិញក្រោយជម្លោះ ដែលជាផ្នែកមួយនៃនិម្មាបនកម្មសន្តិភាពថ្មី |

*ប្រភព ៖ អនុសាសន៍ទូទៅលេខ ៣០ ៣៧ និង ៤០ របស់គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ*

| ផែនការសកម្មភាពទីក្រុងប៉េកាំង | ស្ត្រី និងជម្លោះប្រដាប់អាវុធ ៖ គោលបំណងយុទ្ធសាស្ត្រ (SO) |
|---|---|
| SO ១ | បង្កើនការចូលរួមរបស់ស្ត្រីក្នុងការដោះស្រាយជម្លោះនៅកម្រិតធ្វើសេចក្តីសម្រេចចិត្ត និងការពារស្ត្រីដែលរស់នៅក្នុងស្ថានភាពជម្លោះប្រដាប់អាវុធ និងជម្លោះផ្សេងទៀត ឬក្រោមការកាន់កាប់របស់បរទេស |
| SO ២ | កាត់បន្ថយការចំណាយផ្នែកយោធាហួសហេតុ និងគ្រប់គ្រងវត្តមានអាវុធយុទ្ធភណ្ឌ |
| SO ៣ | លើកកម្ពស់ទម្រង់នៃការដោះស្រាយជម្លោះដោយមិនប្រើអំពើហិង្សា |
| SO ៤ | លើកកម្ពស់ការរួមចំណែករបស់ស្ត្រីក្នុងការលើកកម្ពស់វប្បធម៌សន្តិភាព |
| SO ៥ | ផ្តល់ការការពារ ជំនួយ និងការបណ្តុះបណ្តាលដល់ជនភៀសខ្លួនជាស្ត្រី ស្ត្រីដែលត្រូវផ្លាស់ទីលំនៅផ្សេងទៀតដែលត្រូវការ ការការពារជាអន្តរជាតិ និងស្ត្រីផ្លាស់ទីលំនៅក្នុងប្រទេស |
| SO ៦ | ផ្តល់ជំនួយដល់ស្ត្រីនៅក្នុងដែនដីអាណានិគម និងដែនដីដែលមិនមានរដ្ឋាភិបាលគ្រប់គ្រងដោយខ្លួនឯង |

*ប្រភព ៖ ផែនការសកម្មភាពទីក្រុងប៉េកាំង (១៩៩៥)*

## ៩.៥. សេចក្តីសង្ខេបនៃតារាងម៉ាទ្រិកផែនការសកម្មភាពតំបន់អាស៊ាន ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ

| |
|---|
| **ការការពារ** |
| **លទ្ធផលយុទ្ធសាស្ត្រទី ១៖** ការការពារសិទ្ធិរបស់ស្ត្រី ស្ត្រីវ័យក្មេង និងក្មេងស្រី រួមទាំងអ្នកមកពីក្រុមដែលទទួលបានឱកាសតិចតួច នៅក្នុងគោលនយោបាយ ការអនុវត្ត និងស្ថាប័នពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ រួមទាំងការការពារស្ត្រី និងក្មេងស្រីពីគ្រប់ទម្រង់នៃអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ (SGBV) នៅក្នុងបរិបទជម្លោះ ក្រោយជម្លោះ ការកសាងសន្តិភាព និងមនុស្សធម៌។ |
| **ធាតុចេញ ១.១.** រដ្ឋជាសមាជិកអាស៊ានមានសមត្ថភាពកើនឡើងក្នុងការបង្កើត និងអនុវត្តច្បាប់ គោលនយោបាយ និងវិធានការដើម្បីទប់ស្កាត់ និងលុបបំបាត់អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ និងដោះស្រាយតម្រូវការរបស់ជនរងគ្រោះ/អ្នករស់រានមានជីវិត ពីអំពើហិង្សាផ្លូវភេទនិងផ្អែកលើយេនឌ័រ រួមទាំងនៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយជម្លោះ គ្រាអាសន្ន និងបរិបទមនុស្សធម៌។ |
| **ធាតុចេញ ១.២.** សមត្ថភាពដែលត្រូវបានពង្រឹងរបស់អាស៊ាន និងរដ្ឋជាសមាជិកអាស៊ានក្នុងការលើកកម្ពស់កិច្ចការពារ និងការគាំពារសិទ្ធិស្ត្រី និងក្មេងស្រី និងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី នៅក្នុងបរិបទដែលរងផលប៉ះពាល់ដោយជម្លោះ ក៏ដូចជាក្នុងអំឡុងពេលមានគ្រាអាសន្ន ការឆ្លើយតបផ្នែកមនុស្សធម៌ និងភាពអសន្តិសុខ។ |
| **ធាតុចេញ ១.៣.** វិស័យសន្តិសុខ (រួមទាំងកងកម្លាំងយោធា និងនគរបាល) បានកំណត់វិធីក្នុងការកែលម្អកាន់តែប្រសើរឡើងនូវការបញ្ជ្រាបយេនឌ័រ និងកិច្ចការពារសិទ្ធិស្ត្រី នៅក្នុងការឆ្លើយតបរបស់ខ្លួន ចំពោះបញ្ហាប្រឈមផ្នែកសន្តិសុខបែបប្រពៃណី និងមិនមែនប្រពៃណី |
| **ការចូលរួម** |
| **លទ្ធផលយុទ្ធសាស្ត្រទី ២ ៖** ការចូលរួមពេញលេញ ប្រកបដោយអត្ថន័យ និងដោយស្មើភាពរបស់ស្ត្រីនៅក្នុងស្ថាប័នអង្គការ និងដំណើរការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងសន្តិភាព និងសន្តិសុខ រួមទាំងនៅក្នុងតួនាទីដឹកនាំ។ |
| **ធាតុចេញ ២.១.** សមត្ថភាពដែលត្រូវបានពង្រឹង ក្នុងការធានាភាពជាតំណាងរបស់ស្ត្រី និងការចូលរួមពេញលេញនិងស្មើភាពនៅថ្នាក់តំបន់ និងថ្នាក់ជាតិ និងនៅក្នុងតួនាទីដឹកនាំសំខាន់ៗក្នុងសសរស្តម្ភសហគមន៍អាស៊ាន ស្ថាប័នតាមវិស័យ និងអង្គភាពពាក់ព័ន្ធ។ |
| **ធាតុចេញ ២.២.** អង្គការស្ត្រី អង្គការយុវជន និងក្រុមសង្គមស៊ីវិលផ្សេងទៀត អាចចូលរួមប្រកបដោយអត្ថន័យនៅក្នុងដំណើរការពិគ្រោះយោបល់ ការរៀបចំផែនការ ការអនុវត្ត និងការវាយតម្លៃរបស់អាស៊ាន ដើម្បីឆ្លុះបញ្ចាំងឱ្យកាន់តែប្រសើរនូវទស្សនៈ និងតម្រូវការរបស់ស្ត្រី និងក្មេងស្រីនៅក្នុងតំបន់ និងធានាការចូលរួម និងបរិយាបន្នស្ត្រីប្រកបដោយសមធម៌។ |
| **ធាតុចេញ ២.៣.** អ្នកកសាងសន្តិភាពជាស្ត្រី ទាំងក្នុងនាមជាអ្នកសម្របសម្រួល អ្នកចរចា និង/ឬអ្នកឆ្លើយតបដំបូងមានឱកាស និងសមត្ថភាពដែលត្រូវបានពង្រឹង ក្នុងការចូលរួមនៅថ្នាក់អន្តរជាតិ ថ្នាក់តំបន់ ថ្នាក់ជាតិ និងមូលដ្ឋាន។ |
| **ធាតុចេញ ២.៤.** ស្ត្រីអាចចូលរួមប្រកបដោយអត្ថន័យ និងពេញលេញនៅក្នុងស្ថាប័នវិស័យសន្តិសុខនៃរដ្ឋជាសមាជិកអាស៊ាន ដូចជាកងកម្លាំងប្រដាប់អាវុធ និងនគរបាល រួមទាំងនៅក្នុងតួនាទីដឹកនាំ និងមានសមត្ថភាពដែលត្រូវបានពង្រឹងក្នុងការដាក់ពង្រាយអ្នករក្សាសន្តិភាពជាស្ត្រី នៅគ្រប់ឋានន្តរសក្តិ និងជាពិសេសក្នុងតួនាទីជាអ្នកដឹកនាំ។ |
| **ការបង្ការទប់ស្កាត់** |
| **លទ្ធផលយុទ្ធសាស្ត្រទី ៣ ៖** ស្ថាប័នតាមវិស័យ ស្ថាប័ន និងរដ្ឋជាសមាជិកអាស៊ានមានតួនាទីសកម្មក្នុងការរួមចំណែកដល់ការទប់ស្កាត់ជម្លោះ និងការទប់ស្កាត់អំពើហិង្សា គ្រោះមហន្តរាយ និងការគំរាមកំហែងផ្សេងទៀតដល់សន្តិភាព និងសន្តិសុខនៅថ្នាក់សកល តំបន់ និងជាតិ ដោយគោលការណ៍នៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ជាស្នូលនៃសកម្មភាពទាំងនេះ។ |

**ធាតុចេញ ៣.១.** យន្តការ និងសកម្មភាពប្រកាសព័ត៌មានឱ្យដឹងមុន ដើម្បីទប់ស្កាត់ជម្លោះ និងហានិភ័យផ្សេងទៀត ចំពោះសន្តិភាព និងសន្តិសុខ (ដូចជាការកាត់បន្ថយគ្រោះមហន្តរាយ/ការផ្លាស់ទីលំនៅ ការជួញដូរមនុស្ស ជំងឺរាតត្បាត ការគំរាមកំហែងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត ការប្រែប្រួលអាកាសធាតុ និងលទ្ធិជ្រុលនិយមហិង្សា) ត្រូវបានពង្រឹងសមត្ថភាព ក្នុងការវិភាគនិងយល់ដឹងពីតួនាទី បទពិសោធន៍ តម្រូវការ និងផលប៉ះពាល់ផ្សេងៗគ្នាសម្រាប់ស្ត្រី និងបុរស ជាពិសេសអ្នកដែលមកពីក្រុមដែលទទួលបានឱកាសតិចតួច។

**ធាតុចេញ ៣.២.** គោលនយោបាយ វិធានការ និងកម្មវិធីបង្ការទប់ស្កាត់ជម្លោះ និងកាត់បន្ថយហានិភ័យ ផ្អែកលើភស្តុតាង ដែលយកចិត្តទុកដាក់លើបរិបទ និងឆ្លើយតបទៅនឹងយេនឌ័រ។

**លទ្ធផលយុទ្ធសាស្ត្រទី ៤ ៖** ស្ថាប័ន យន្តការ និងដំណើរការសន្តិភាព និងសន្តិសុខទទួលបានជោគជ័យក្នុងការបង្ការទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ។

**ធាតុចេញ ៤.១.** វិធីសាស្ត្រ និងយន្តការត្រូវបានកំណត់ និងការស្រាវជ្រាវត្រូវបានធ្វើឡើង (និងប្រព័ន្ធសម្រាប់ធ្វើបច្ចុប្បន្នភាពទិន្នន័យ) ដើម្បីយល់ដឹង និងកំណត់សញ្ញាការប្រកាសជូនព័ត៌មានជាមុន ក៏ដូចជាមូលហេតុចម្បងនៃអំពើហិង្សា ជាពិសេសអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ នៅក្នុងសហគមន៍ និងបរិបទផ្សេងៗគ្នា ក្នុងគោលបំណងផ្តល់ព័ត៌មានអំពីអន្តរាគមន៍គោលដៅដែលឆ្លើយតបទៅនឹងយេនឌ័រ សម្រាប់ការដោះស្រាយឫសគល់នៃបញ្ហាទាំងនេះ និងការបង្ការទប់ស្កាត់អំពើហិង្សា រួមទាំងអំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ។

**ធាតុចេញ ៤.២.** អ្នកឆ្លើយតបជួរមុខ ក៏ដូចជាអ្នកបង្កើតគោលនយោបាយ និងអ្នកអនុវត្ត មានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានទិន្នន័យ និងការបណ្តុះបណ្តាលដែលពួកគេត្រូវការ ដើម្បីធានាថា ស្ថាប័នសន្តិភាព និងសន្តិសុខ បង្ការទប់ស្កាត់អំពើហិង្សាផ្លូវភេទនិងផ្អែកលើយេនឌ័រ ដោយមានការគាំទ្រពីការអនុវត្តស្ថាប័នពហុវិស័យ គោលនយោបាយ និងបរិយាកាសច្បាប់ ដែលទទួលបានព័ត៌មានពីគោលការណ៍ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

**ការសង្គ្រោះ និងស្តារឡើងវិញ**

**លទ្ធផលយុទ្ធសាស្ត្រទី ៥ ៖** តម្រូវការរបស់ស្ត្រី និងក្មេងស្រីត្រូវបានបំពេញ នៅក្នុងដំណើរការនៃការសង្គ្រោះ និងស្តារឡើងវិញនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងមូលដ្ឋាន ហើយស្ត្រីមានការចូលរួមដោយស្មើភាព និងប្រកបដោយអត្ថន័យនៅក្នុងដំណើរការទាំងនេះ រួមទាំងនៅក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្ត និងភាពជាអ្នកដឹកនាំ។

**ធាតុចេញ ៥.១.** ការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយរបស់អាស៊ាន ត្រូវបានផ្តល់ព័ត៌មានពីបទពិសោធន៍ និងអាទិភាពរបស់ស្ត្រីក្នុងអំឡុងពេលដំណាក់កាលការសង្គ្រោះ និងស្តារឡើងវិញ រួមទាំងនៅកម្រិតសហគមន៍។

**ធាតុចេញ ៥.២.** គោលនយោបាយ និងដំណើរការនៃការសង្គ្រោះ និងស្តារឡើងវិញនៅថ្នាក់តំបន់ និងជាតិត្រូវបានរៀបចំ និង អនុវត្តតាមរយៈដំណើរការពហុវិស័យ ពហុភាគីពាក់ព័ន្ធ និងពហុវិមាត្រ ដោយផ្អែកលើបណ្តាញនិងភាពជាដៃគូ ដើម្បីសិទ្ធិពលសង្គម បរិយាបន្ន និងការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ៗ។

**ធាតុចេញ ៥.៣.** គោលនយោបាយ និងគំនិតផ្តួចផ្តើមការសង្គ្រោះ និងស្តារឡើងវិញ ឆ្លើយតបទៅនឹងយេនឌ័រ និងយកចិត្តទុកដាក់លើបរិបទយេនឌ័រ ដោយដោះស្រាយតម្រូវការ និងអាទិភាពទាំងរបស់ស្ត្រី និងបុរស និងការពារសិទ្ធិរបស់ពួកគេ រួមទាំងសម្រាប់អ្នកដែលមកពីក្រុមដែលទទួលបានឱកាសតិចតួច។

**UN Women Regional Office for Asia and the Pacific**
United Nations Building, 12th floor.
Rajdamnern Nok Avenue, Bangkok, 10200, Thailand

https://asiapacific.unwomen.org

www.instagram.com/unwomenasia

www.linkedin.com/showcase/un-women-asia-and-the-pacific/

www.facebook.com/unwomenasia

www.twitter.com/unwomenasia

www.youtube.com/c/unwomenasiapacific


Australian Aid

In partnership with Canada

Ministry of Gender Equality and Family

UK International Development
Partnership | Progress | Prosperity

UN WOMEN